# សៀវភៅណែនាំស្តីពីវារីវប្បកម្ម បែបពាណិជ្ជកម្ម





សហការរៀបចំដោយ

**សាកលវិទ្យាល័យអ័រប៊ុន**

**សមាគមសណ្តែកសៀងអាមេរិក**



បោះពុម្ពលើកដំបូង

ភ្នំពេញ ខែ តុលា ឆ្នាំ ២០២២

# អារម្ភកថា

សៀវភៅណែនាំស្ដីអំពីវារីវប្បកម្មបែបពាណិជ្ជកម្មនេះត្រូវបានបង្កើតឡើងជាពិសេសដើម្បីបង្រៀនដល់អ្នកចិញ្ចឹមត្រី (វារីវប្បករ) នៅកម្ពុជាឱ្យមានការអនុវត្តការគ្រប់គ្រងល្អ ស្របតាមគោលការណ៍ណែនាំអាស៊ានស្ដីពីការអនុវត្តន៍វារីវប្បកម្មល្អសម្រាប់ម្ហូបអាហារត្រី (ASEAN GaqP for Food Fish)។ ព័ត៌មាននេះត្រូវបានប្រមូលផ្ដុំដោយសាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យអ័រប៊ុន (Auburn University) និងបុគ្គលិកនៃមហាវិទ្យាល័យផលផល វារីវប្បកម្ម និងវិទ្យាសាស្ត្រវារីសត្វ (SFAAS) ដោយសហការជាមួយបុគ្គលិកគម្រោងខាស់ (CAST) ដោយផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំស្ដីពីការងារវារីវប្បកម្មជាសកល រួមទាំងការងារនៅកម្ពុជាជាមួយវារីវប្បករក្នុងស្រុក។ មហាវិទ្យាល័យផលផល វារីវប្បកម្ម និងវិទ្យាសាស្ត្រវារីសត្វ នៃសាកលវិទ្យាល័យអ័រប៊ុន (SFAAS) បានចូលរួមយ៉ាងច្រើនក្នុងការអភិវឌ្ឍវារីវប្បកម្មអន្តរជាតិអស់រយៈពេលជាងហុកសិបឆ្នាំ ហើយត្រូវបានគេទទួលស្គាល់ជាសកលសម្រាប់ការងាររបស់ខ្លួន។ ការចងក្រងឯកសារនេះត្រូវបានដឹកនាំដោយលោកបណ្ឌិត វីល្លៀម (ប៊ីល) ដានែល (Dr. William (Bill) Daniels) សាស្ត្រាចារ្យរង និងលោកស្រី ការ៉ែន វើវីរីកា (Karen Veverica) បុគ្គលិកនៃសាកសវិទ្យាអ័រប៊ុន។ អ្នកទាំងពីរនាក់បានធ្វើការនៅក្នុងវិស័យវារីវប្បកម្មពិភពលោក តាំងពីចុងទសវត្សឆ្នាំ ១៩៧០ ជាមួយនឹងបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងទ្វីបអាហ្វ្រិក និងអាស៊ី។ អ្នកទាំងពីរធ្លាប់ធ្វើការនៅប្រទេសកម្ពុជាកាលពីមុនជាមួយគម្រោងហាវ៉េស (HARVEST) គាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ។

បណ្ឌិតដានែល បានធ្វើការក្នុងវិស័យវារីវប្បកម្មនៅតំបន់អាស៊ីអាគ្នេយ៍តាំងពីឆ្នាំ ២០០៨ នៅប្រទេសកម្ពុជា វៀតណាម និងមីយ៉ាន់ម៉ាជាមួយនឹងប្រភេទសត្វដែលចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា។ សៀវភៅណែនាំនេះបានទាញយកបទពិសោធន៍ដ៏ធំធេងរបស់សាកលវិទ្យាល័យអ័រប៊ុន និងដៃគូសកលរបស់ខ្លួនជាមួយនឹងព័ត៌មានអំពីប្រភេទសត្វជាក់លាក់ដោយផ្អែកលើការអនុវត្តវារីវប្បកម្មនាពេលបច្ចុប្បន្ននៅតំបន់អាស៊ីអាគ្នេយ៍។

យើងសូមថ្លែងអំណរគុណចំពោះដៃគូកម្ពុជាទាំងអស់រួមទាំងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជរដ្ឋាភិបាលកម្ពុជា និងមជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្ម កសិកម្ម និរន្តភាព និងអាហារូបត្ថម្ភ (ស៊ីសេន/CE SAIN) នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងការចូលរួមចំណែករបស់ពួកគេចំពោះព័ត៌មាននៅក្នុងសៀវភៅណែនាំនេះ។

នៅមជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្ម កសិកម្ម និរន្តភាព និងអាហារូបត្ថម្ភ (ស៊ីសេន/CE SAIN) មានស្រះបង្ហាញវារីវប្បកម្មនៅឧទ្យានបច្ចេកវិទ្យាកសិកម្មរបស់ពួកគេនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យបាត់ដំបង និងវិទ្យាល័យរស្មីសោភ័ណ ខេត្តកំពង់ធំ។ នៅចុងបញ្ចប់យើងខ្ញុំសូមថ្លែងអំណរគុណដល់សមាគមវារីវប្បករនៅកម្ពុជា និងកសិករកម្ពុជាដែលជាសមាជិកសមាគមក៏ដូចជាសមាជិកនៃគម្រោងខាស់ (CAST)ដែលបានអនុញ្ញាតឱ្យយើងចូលទៅទស្សនៈកិច្ចកសិដ្ឋានដើម្បីឱ្យយល់កាន់តែច្បាស់អំពីការអនុវត្តនិងតម្រូវការបច្ចុប្បន្នរបស់ពួកគេ។

យើងក៏សូមថ្លែងអំណរគុណចំពោះ សមាគមសណ្តែកសៀងអាមេរិក (ASA) និងក្រុមការងារបច្ចេកទេសនៅកម្ពុជានៃគម្រោងខាស់ (CAST) ដែលបានជួយធ្វើឱ្យសៀវភៅណែនាំសម្រាប់វារីវប្បកម្មកម្ពុជាមានឡើង រួមមាន លោក ប៊ុន ចន្ទ្រា លោក ឃ្លាំង សុខុម លោក សំវាសនា ដាវីដ លោក ប្រាក់ វុធ លោក សរ សាន្តភិរម្យ លោក សំរិទ្ធិករុណា និងលោកបណ្ឌិត ឡេអូណាត រូជឺ (Dr. Leonard Rodgers) ទីប្រឹក្សាបច្ចេកទេសវារីវប្បកម្ម។

**គម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាព ពាណិជ្ជកម្មនៅកម្ពុជា(ខាស់)**

**គម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាព ពាណិជ្ជកម្មនៅកម្ពុជា (ខាស់)** គឺជាគម្រោងដែលទទួលបានការឧបត្ថម្ភថវិកាពីក្រសួងកសិកម្មសហរដ្ឋអាមេរិក ដើម្បីជំរុញផលិតកម្មត្រីទឹកសាប និងអភិវឌ្ឍវិស័យវារីវប្បកម្មសម្រាប់តម្រូវការទីផ្សារ និងប្រកបដោយនិរន្តរភាព។ គម្រោងនេះជួយពង្រឹងវិស័យវារីវប្បកម្មនៅកម្ពុជាតាមរយៈការពង្រឹងគុណភាពចំណី ពូជត្រី និងបង្កើនប្រសិទ្ធភាពទីផ្សារសំរាប់ផលិតផលវារីវប្បកម្ម។ តាមរយៈគម្រោង វិស័យឯកជននិងសាកលវិទ្យាល័យបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកផលិតសណ្តែកសៀងនៅសហរដ្ឋអាមេរិក អាជីវករ ក៏ដូចជាស្ថាប័នសិក្សា និងអង្គការមិនមែនរដ្ឋាភិបាល។

ដៃគូអនុវត្តគម្រោងខាស់

# មាតិកាអត្ថបទ៖ សៀវភៅណែនាំស្តីពីការអនុវត្តវារីវប្បកម្មល្អបែបពាណិជ្ជកម្ម

**អារម្ភកថា**


**១.ផែនការផលិតកម្ម**......................................................................................................១-៣

សេចក្តីផ្តើម

តារាងប៉ារ៉ាម៉ែត្រនៃការគណនាក្នុងផែនការផលិតកម្ម

**២.សមត្ថភាពផ្ទុករបស់ស្រះសម្រាប់ការចិញ្ចឹមត្រី**..........................................................៤-៧

និយមន័យ

តើធ្វើយ៉ាងណាទើបវារីវប្បករដឹងថាស្រះរបស់ខ្លួនជិតឈានដល់សមត្ថភាពផ្ទុក?

តើវារីវប្បករអាចបង្កើនសមត្ថភាពផ្ទុករបស់ស្រះបានដែរឬទេ?

**៣.ការគ្រប់គ្រងកសិដ្ឋាន**..........................................................................................៨-១៤

ការធ្វើផែនការ

ការវាស់វែង និងការរក្សាកំណត់ត្រា

ការបណ្តុះបណ្តាលបុគ្គលិក និងពិធីសារប្រតិបត្តិតាមស្តង់ដា

បន្តការកែលំអ

**៤.ការសាងសង់ស្រះចិញ្ចឹមត្រីសម្រាប់វារីវប្បកម្មលក្ខណៈពាណិជ្ជកម្ម**.......................១៥-១៨

និយមន័យ និងបទដ្ឋាន

**៥.ការសាងសង់ស្រះ** ....................................................................................................១៩-២៣

ដំណាក់កាលក្នុងការសាងសង់ស្រះ

ការបង្ហាញ

**៦.ការរៀបចំស្រះ**.........................................................................................................២៤-២៩

ការរៀបចំបាតស្រះនិងភ្លឺស្រះ

សកម្មភាពមុនពេលបញ្ចូលទឹកក្នុងស្រះ

សកម្មភាពក្រោយការបញ្ចូលទឹកក្នុងស្រះ

ការរៀបចំស្រះដែលមិនអាចបូមទឹកចេញអស់

**៧.ការគ្រប់គ្រងទឹក**.......................................................................................................៣០-៣៦

ប្រភពទឹក

ការបាត់បង់ទឹក

តើស្រះខ្ញុំត្រូវការទឹកប៉ុន្មានដើម្បីចិញ្ចឹមត្រីក្នុងមួយវគ្គ?

**៨.ការគ្រប់គ្រងគុណភាពទឹកស្រះ និងឥទ្ធិពលរបស់វាលើការចិញ្ចឹមត្រី**...................៣៧-៤៣
ស្វែងយល់ពីប៉ារ៉ាម៉ែត្រទឹកសំខាន់ៗ
សីតុណ្ហភាព និងកម្រិតរលាយអុកស៊ីសែនក្នុងទឹក
អាម៉ូញាក់ និងនីទ្រីត
កម្រិតថ្លានៃទឹក
អ៊ីដ្រូសែនស៊ុលផួរ
កត្តាព្រួយបារម្ភផ្សេងទៀត
**៩.កូនត្រីមានគុណភាពខ្ពស់សម្រាប់ទីផ្សារ**.......................................................................៤៤-៤៧
លក្ខណៈវិនិច្ឆ័យលើគុណភាពកូនត្រី
ហេតុអ្វីត្រូវយកកូនត្រីធំមកចិញ្ចឹម?
**១០.ការរៀបចំដឹកជញ្ជូនកូនត្រី**.......................................................................................៤៨-៥២
ការគ្រប់គ្រងមុនពេលដឹកជញ្ជូន
ជម្រើសដឹកជញ្ជូន
ការប្រើប្រាស់ថង់ដោយមានដាក់អុកស៊ីសែន
ការប្រើប្រាស់ធុងដែលមានដាក់អុកស៊ីសែន ឬធ្វើឲ្យទឹកមានចរន្ត
លក្ខខណ្ឌសម្រាប់លែងត្រីទៅក្នុងមជ្ឈដ្ឋានទឹកថ្មី
**១១.ការគ្រប់គ្រងសុខភាពត្រី និងជីវសុវត្ថិភាព**...............................................................៥៣-៥៧
ប្រភពនៃជំងឺ
ការគ្រប់គ្រងសុខភាពត្រី
បញ្ជូនសំណាកត្រីដើម្បីធ្វើរោគវិនិច្ឆ័យ
ការព្យាបាលត្រី
**១២.របៀបរក្សាទុកចំណីត្រី និងចំណីសត្វផ្សេងៗឲ្យបានត្រឹមត្រូវ**.................................៥៨-៦០
ការណែនាំផ្សេងៗ
សេចក្តីសង្ខេប
**១៣.ការត្រួតពិនិត្យលក្ខណៈរូបនៃចំណីត្រី**.....................................................................៦១-៦៤
ការវេចខ្ចប់
លក្ខណៈខាងក្រៅរបស់ចំណីត្រី
សេចក្តីសង្ខេប
**១៤.មេគុណចំណី**..........................................................................................................៦៥-៦៨
ឧទាហរណ៍នៃការគណនាមេគុណចំណី

គន្លឹះសំខាន់ៗនៃមេគុណចំណី
អនុសាសន៍សម្រាប់ការផ្តល់ចំណីត្រី
**១៥.ការប្រើប្រាស់តារាងចំណី: តើខ្ញុំគួរឲ្យចំណីត្រីប៉ុន្មាន?**.....................................៦៩-៧១
កែតម្រូវការដាក់ចំណីមួយចម្អែត
ការប្រើប្រាស់តារាងផ្តល់ចំណី
គន្លឹះខ្លះៗត្រូវចងចាំពីតារាងផ្តល់ចំណី
**១៦.ប្រព័ន្ធបញ្ចូលខ្យល់**.....................................................................................................៧២-៨០
ផ្នែកទីមួយ៖ ម៉ាស៊ីនផ្លុំខ្យល់ ម៉ាស៊ីនសម្ពាធខ្យល់ និងម៉ាស៊ីនបូមខ្យល់
ផ្នែកទីពីរ៖ ការរៀបចំប្រព័ន្ធបញ្ចូលខ្យល់ក្នុងស្រះ
**១៧.ការចិញ្ចឹមត្រីក្នុងបែ**.......................................................................................................៨១-៨៥
គោលការណ៍ណែនាំមួយចំនួនទាក់ទងនឹងការចិញ្ចឹមក្នុងបែ
ការឲ្យចំណីត្រីក្នុងបែ
គម្របបែ
ចំណុចដែលមានបញ្ហា
ការអនុវត្តការគ្រប់គ្រងវារីវប្បកម្មល្អសម្រាប់ការចិញ្ចឹមក្នុងបែ
**១៨.ប្រព័ន្ធវារីវប្បកម្មទឹកហូរជាបន្តក្នុងស្រះ**..........................................................៨៦-៩០
**សន្ទានុក្រម និងបច្ចេកសព្ទវារីវប្បកម្ម**
**ឧបសម្ព័ន្ធ**

# មេរៀន ៖

# ផែនការផលិតកម្ម

# ផែនការផលិតកម្ម

## សេចក្តីផ្តើម

ការធ្វើផែនការផលិតកម្មអាជីវកម្មចិញ្ចឹមត្រីគឺជាសកម្មភាពសំខាន់មួយ។ ការធ្វើផែនការត្រូវបានធ្វើឡើងមុនពេលសកម្មភាពផលិតកម្មផ្សេងទៀតត្រូវបានចាប់ផ្តើម។ ការសម្រេចចិត្តចុងក្រោយលើប្រពន្ធ័ ឬប្រភេទណាមួយដែលត្រូវចិញ្ចឹម និងរបៀបចិញ្ចឹមគឺត្រូវរង់ចាំរហូតដល់ការរៀបចំផែនការសកម្មភាពត្រូវបានបញ្ចប់ ហើយគួរតែយកផែនការមកពិចារណា។ គោលបំណងនៃផែនការគឺដើម្បីកំណត់ថា៖

- ប្រសិនបើការចិញ្ចឹមទំនងជាទទួលបានជោគជ័យ នោះយើងត្រូវមានធនធានសម្រាប់អនុវត្ត
- តើត្រូវការធនធានអ្វីខ្លះដើម្បីអនុវត្តការចិញ្ចឹម
- ការរំពឹងទុកនៃប្រាក់ចំណេញក្នុងផលិតកម្មនៃវគ្គនេះ
- ប្រភពធនធានដែលត្រូវប្រើប្រាស់ និងទីផ្សារ
- ថាតើមានជម្រើសអ្វីខ្លះឬទេ ឬមានវិធីសាស្ត្រគ្រប់គ្រងណាខ្លះ
- ត្រូវមើលឃើញអំពីសក្តានុពលនៃការទទួលបានទុនពីស្ថាប័នហិរញ្ញវត្ថុ សម្រាប់អភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួន។




រូបភាព៖ ការធ្វើផែនការផលិតកម្ម អ្នកគួរដឹង និងស្គាល់អ្នកពាក់ព័ន្ធក្នុងខ្សែច្រវាក់តម្លៃវារីវប្បកម្ម




រូបភាព៖ ប្រភេទត្រីសម្រាប់ការពិចារណាក្នុងផែនការផលិតកម្ម

តារាងនៅទំព័រចុងក្រោយនៃមេរៀននេះ អាចប្រើដើម្បីស្វែងយល់ និងគណនាប៉ារ៉ាម៉ែត្រផ្សេងៗដែលត្រូវការដើម្បីធ្វើផែនការផលិតកម្មរបស់ខ្លួន។ តារាង និងឧទាហរណ៍ទាំងនេះមិនមានន័យថាដើម្បីវាយប៉ារ៉ាម៉ែត្រផលិតកម្មដែលអាចធ្វើបានទាំងអស់នោះទេ ផ្ទុយទៅវិញវាជាការណែនាំមួយដែលអាចប្រើដើម្បីធ្វើផែនការផលិតកម្មផ្ទាល់ខ្លួន។

ដៃគូអនុវត្តគម្រោង៖

ជំហានដំបូងនៃផែនការផលិតកម្ម គឺដើម្បីពិពណ៌នាអំពីស្ថានភាពទូទៅរបស់ស្រះដែលនឹងត្រូវប្រើសម្រាប់ផលិតកម្ម ។ ទាំងនេះរួមមានទំហំស្រះ ផ្ទៃស្រះ និងបរិមាណរបស់វា (តារាងទី ១, A-E)។

ជំហានបន្ទាប់គឺត្រូវសម្រេចចិត្តថាតើប្រភេទ និងវិធីសាស្រ្តគ្រប់គ្រងណាមួយដែលត្រូវស្វែងរក ឬដាក់ចិញ្ចឹមអោយបានហ្មត់ចត់ (តារាងទី ១, F-J)។ នៅក្នុងឧទាហរណ៍នៃផែនការផលិតកម្ម ការចិញ្ចឹមត្រីទីឡាព្យាដោយប្រើចំណីគ្រាប់ចំនួន ៣០ ភាគរយ និងការចិញ្ចឹមត្រីដល់ទំហំទីផ្សារដែលជាមធ្យមទម្ងន់ 0,៤ គីឡូក្រាមក្នុងមួយក្បាលត្រី។ ប៉ារ៉ាម៉ែត្រផលិតកម្មជាច្រើនទាក់ទងដោយផ្ទាល់ទៅនឹងប្រភេទសត្វត្រូវដាក់ចិញ្ចឹម ការលូតលាស់ និងប្រព័ន្ធនៃការគ្រប់គ្រងដែលនឹងត្រូវអនុវត្ត ដូច្នេះពេលនេះត្រូវតែធ្វើការសម្រេចចិត្តជាចាំបាច់ ។

នៅពេលដែលការសម្រេចចិត្តអំពីប្រភេទសត្វទឹកត្រូវដាក់ចិញ្ចឹម និងវិធីសាស្រ្តគ្រប់គ្រងរួចហើយ នោះវាមានសារៈសំខាន់ណាស់ក្នុងការកំណត់ធាតុចូលទាំងអស់ដែលនឹងត្រូវការសម្រាប់ការផលិតនោះ។ ឧទាហរណ៍ខាងក្រោម បានលើកយកតែកូនត្រីពូជ និងចំណីប៉ុណ្ណោះមកបកស្រាយលម្អិត ។ ទោះជាយ៉ាងណាក៏ដោយ ធាតុចូលសំខាន់ៗផ្សេងទៀតអាចត្រូវបានរួមបញ្ចូល។ ជាឧទាហរណ៍ ប្រសិនបើការប្រើកំបោរ ឬជួលស្រះគឺជាធាតុចូលដ៏សំខាន់ដើម្បីពិចារណា ពួកគេគួរតែបញ្ចូលទៅក្នុងផែនការផលិតកម្មផងដែរ។ នៅពេលដែលធាតុចូលទាំងអស់ត្រូវបានដាក់បញ្ចូលគ្នា វាពិតជាសំខាន់ណាស់ដើម្បីកំណត់ថាតើធាតុចូលទាំងនោះអាចទទួល ឬរកបាននៅពេលត្រូវការ រួមជាមួយនឹងតម្លៃផងដែរ (តារាងទី ១, K-L)។ ឧទាហរណ៍ ប្រសិនបើកូនត្រីទីឡាព្យាមិនអាចរកបានពេលត្រូវដាក់ចិញ្ចឹមទេនោះ ផែនការនេះមិនអាចធ្វើទៅបានទេ ហើយមិនចាំបាច់ធ្វើផែនការផលិតកម្មបន្ថែមទៀតនោះទេ។

នៅពេលធាតុចូល និងតម្លៃរបស់វាត្រូវបានកំណត់ ទីផ្សារ និងតម្លៃលក់ដុំនៅកសិដ្ឋានសម្រាប់ផលិតកម្មគួរតែត្រូវបានពិចារណាផងដែរ(តារាងទី១, M) ។ គោលបំណងនៃការចិញ្ចឹម ឬផលិតលក្ខណៈពាណិជ្ជកម្មគឺដើម្បីលក់ផលិតផល។ វាមិនមានបញ្ហាថាតើត្រូវផលិតបានល្អប៉ុណ្ណានោះទេ។ ប្រសិនបើគ្មាននរណាម្នាក់ចង់ទិញទេនោះ ផែនការបានឈានដល់ទីបញ្ចប់ ហើយគួរតែត្រូវគិតគូរផែនការផលិតកម្មសារជាថ្មី។

នៅពេលដែលធាតុចូល និងទីផ្សារសម្រាប់ផលិតផលត្រូវបានកំណត់ គេអាចប្រើសមីការក្នុងឧទាហរណ៍ដើម្បីគណនាប៉ារ៉ាម៉ែត្រផលិតកម្មផ្សេងៗទៀតដែលនៅសល់ (តារាងទី ១, N-T)។ ទាំងនេះគួរតែរួមបញ្ចូលការគណនាសំខាន់ៗមួយចំនួនដោយប្រើព័ត៌មានដែលបានប្រមូលរួចហើយ។ ព័ត៌មានទាំងនោះរួមមានដូចជា៖

- ទម្ងន់ប៉ាន់ស្មាននៃផលិតកម្មនៅពេលប្រមូលផល
- តើត្រូវការកូនត្រីពូជប៉ុន្មានដើម្បីផលិតផលតាមតម្រូវការ
- ការប៉ាន់ប្រមាណអំពីបរិមាណចំណីដែលនឹងត្រូវការសម្រាប់ផលិតកម្ម។

ផ្នែកចុងក្រោយនៃផែនការផលិតកម្មគឺដើម្បីបង្កើតផែនការថវិកាដោយប្រើព័ត៌មានទាំងអស់ដែលបានប្រមូលបាន ឬមានស្រាប់ពីមុន។ ថវិកានឹងកំណត់តម្លៃប៉ាន់ស្មាននៃការផលិត ប្រាក់ចំណូលប៉ាន់ស្មានពីការលក់ផលិតផល និងផលចំណេញរំពឹងទុក (តារាងទី ១, U-Z) ។ ថវិកានេះនឹងប្រាប់អ្នកផលិតថាតើពួកគេអាចមានលទ្ធភាពវិនិយោគលើផលិតកម្មនោះដែរឬទេ។ វាក៏អនុញ្ញាតឱ្យកសិដ្ឋានកំណត់ថាតើនឹងទទួលបានប្រាក់ចំណេញគ្រប់គ្រាន់ចំពោះការវិនិយោគដែរឬទេ ដើម្បីធ្វើឱ្យផែនការផលិតកម្មនោះនឹងអនុវត្តជាក់ស្តែងបាន ។

តារាងទី ១៖ ប៉ារ៉ាម៉ែត្រនៃការគណនាក្នុងផែនការផលិតកម្ម និងឧទាហរណ៍

| កូដ | ប៉ារ៉ាម៉ែត្រ | សមីការ | ឧទាហរណ៍ |
|---|---|---|---|
| | **ស្រះ** | | |
| A | បណ្តោយ ស្រះ | | ៥០ |
| B | ទទឹងស្រះ (ម៉ែត្រ): | | ៣០ |
| C | ជម្រៅស្រះ (ម៉ែត្រ): | | ២ |
| D | ក្រឡាផ្ទៃស្រះ (ម៉ែត្រការ៉េ): | AxB= | ១ ៥០០ |
| E | មាឌ (ម៉ែត្រគុប): | CxD= | ៣ ០០០ |
| | **ផលិតកម្មត្រីទីឡាព្យា** | | |
| F | សមត្ថភាពផ្ទុក (គីឡូក្រាម/ម៉ែត្រការ៉េ) | | ១ |
| G | អត្រាបាត់បង់ (ភាគរយ): | | ១០ ភាគរយ |
| H | មេគុណចំណី (FCR): | | ១,៤ |
| I | ទម្ងន់មធ្យមពេលប្រមូលផល (គីឡូក្រាម/ត្រី): | | ០,៤ |
| J | ទម្ងន់មធ្យមកូនត្រី១ក្បាល (គីឡូក្រាម/ត្រី): | | ០,០០៥ |
| K | តម្លៃកូនត្រី (ដុល្លារអាមេរិក/ត្រី): | | ០,០៤ ដុល្លារអាមេរិក |
| L | តម្លៃចំណី (ដុល្លារអាមេរិក/គីឡូក្រាម): | | ០,៧៥ ដុល្លាអាមេរិក |
| M | តម្លៃលក់នៅកសិដ្ឋាន (ដុល្លារអាមេរិក/គីឡូក្រាម):: | | ១,៧៥ ដុល្លារអាមេរិក |
| N | ទំងន់ពេលប្រមូលផល (គីឡូក្រាម): | FxD= | ១ ៥០០ |
| O | ចំនួនកូនត្រីត្រូវការ (បរិមាណ): | N÷I= | ៣ ៧៥០ |
| P | អត្រាបាត់បង់កូនត្រី (បរិមាណ): | OxG= | ៣៧៥ |
| Q | ចំនួនកូនត្រីដាក់ចិញ្ចឹម (បរិមាណ): | O+P= | ៤ ១២៥ |
| R | ទំងន់កូនត្រីសរុប (គីឡូក្រាម): | QxJ= | ២១ |
| S | កំណើនទំងន់ត្រី (គីឡូក្រាម): | N-R= | ១ ៤៧៩ |
| T | តម្រូវការចំណី (គីឡូក្រាម): | SxH= | ២ ០៧១ |
| | **ថវិកា** | | |
| U | ថ្លៃកូនត្រី (ដុល្លារអាមេរិក): | QxK= | ១៦៥ ដុល្លារអាមេរិក |
| V | ថ្លៃចំណី (ដុល្លារអាមេរិក): | TxL= | ១ ៥៥៣ ដុល្លារអាមេរិក |
| W | សរុបថ្លៃអថេរ (ដុល្លារអាមេរិក): | U+V= | ១ ៧១៨ ដុល្លារអាមេរិក |
| X | ប៉ាន់ប្រមាណចំណូល (ដុល្លារអាមេរិក): | NxM= | ២ ៦២៥ ដុល្លារអាមេរិក |
| Y | ប្រាក់ចំណេញ (ដុល្លារអាមេរិក): | X-W= | ៩០៧ ដុល្លារអាមេរិក |
| Z | អត្រាប្រាក់ចំណេញ (ភាគរយ): | (Y/W)x១០០= | ៥៣ ភាគរយ |

ដៃគូអនុវត្តគម្រោង៖ World Vision · Kansas State University · Auburn University

# មេរៀន ៖

# សមត្ថភាពផ្ទុករបស់ស្រះ
# សម្រាប់ការចិញ្ចឹមត្រី

# សមត្ថភាពផ្ទុករបស់ស្រះសម្រាប់ការចិញ្ចឹមត្រី

**សមត្ថភាពផ្ទុក** គឺជាទស្សនៈទានគន្លឹះមួយយ៉ាងសំខាន់សម្រាប់វារីវប្បករ។ វារីវប្បករដែលយល់ពី ទស្សនៈទានសមត្ថភាពផ្ទុកអាចធ្វើការសម្រេចចិត្តក្នុងការប្រកបមុខរបរអាជីវកម្មចិញ្ចឹមត្រីបានត្រឹមត្រូវ។ ជារួមសមត្ថភាពផ្ទុកគឺជាចំណុចដែលត្រីលែងធំធាត់ ដោយសារមានកាកសំណល់ច្រើនក្នុងស្រះ ឬក៏ចំណីដែលកំពុងប្រើប្រាស់មិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់។

**ឧទាហរណ៍៖** ស្រះតូចមួយបានដាក់កូនត្រីចិញ្ចឹមចំនួន ១០ ០០០ក្បាល (មួយម៉ឺនក្បាល) ដែលមានទម្ងន់មធ្យម ៥ក្រាមក្នុងមួយក្បាល។ តារាងនិងក្រាហ្វិកខាងក្រោមបង្ហាញពីទម្ងន់មធ្យមបន្ទាប់ពីធ្វើសំណាកប្រចាំខែ និងប៉ាន់ស្មានទម្ងន់ត្រីសរុបក្នុងស្រះ ដោយយកលទ្ធផលពីការធ្វើសំណាកប្រចាំខែជាគោល ព្រមជាមួយនឹងការប៉ាន់ស្មានចំនួនក្បាលត្រីនៅក្នុងស្រះ។




រូបភាព៖ ទស្សនៈទានសមត្ថភាពផ្ទុក




តើពេលណាដែលអ្នកចិញ្ចឹមត្រីគួរតែប្រមូលផល ឬលក់ត្រី? សាកល្បងគិតមើលថាតើមានរឿងអ្វីកើតឡើង ប្រសិនបើអ្នកចិញ្ចឹមត្រីចង់ចិញ្ចឹមបន្តដើម្បីអោយត្រីមានទម្ងន់ ៧០០ក្រាម (០,៧ គីឡូក្រាម) ក្នុងមួយក្បាល?

### តើមានបញ្ហាអ្វីកើតឡើងពេលអ្នកចិញ្ចឹមត្រីរង់ចាំដល់ខែទី៨ទើបប្រមូលផល?

ផ្អែកតាមក្រាហ្វិកខាងលើ អ្នកចិញ្ចឹមត្រីបន្តឱ្យចំណីក្នុងរយៈពេល០៣ខែ (ខែទី៦ ទី៧ និងទី៨) ប៉ុន្តែមិនមានកំណើនទម្ងន់ត្រីក្នុងស្រះទេ។ ក្នុងករណីនេះកសិករគួរប្រមូលផល ឬលក់ក្នុងរវាងខែទី៥ និងទី៦។ ផ្អែកតាមឧទាហរណ៍ខាងលើ តើស្រះមានសមត្ថភាពផ្ទុកប៉ុន្មានគីឡូ? (ប្រហែល ៣ ៧០០ គីឡូក្រាម)

### តើធ្វើយ៉ាងណាទើបអ្នកចិញ្ចឹមដឹងពីសមត្ថភាពផ្ទុកនៃស្រះរបស់ខ្លួន?

សមត្ថភាពផ្ទុកអាស្រ័យលើរបៀបនៃការគ្រប់គ្រងដូចជា៖

១. **គុណភាពចំណី៖** ចំណីមានគុណភាពខ្ពស់ធ្វើឱ្យត្រីងាយរំលាយ ហើយបន្សល់កាកសំណល់តិចតួច

២. **គុណភាពទឹក៖** កាកសំណល់នានាបន្សល់ទុកក្នុងស្រះ ហើយធ្វើឱ្យខូចគុណភាពទឹកដែលប៉ះពាល់យ៉ាងខ្លាំងដល់ត្រីក្នុងស្រះ។ អ្នកចិញ្ចឹមត្រីអាចប្តូរទឹកដើម្បីធ្វើឱ្យគុណភាពទឹកប្រែមកកម្រិតល្អវិញ ប៉ុន្តែត្រូវចងចាំថាទឹកដែលបញ្ចូលក្នុងស្រះត្រូវតែជាទឹកដែលមានគុណភាព(ទឹកល្អ) ។

៣. **ពូជត្រី៖** មានប្រភេទត្រីខ្លះធន់ជាមួយនឹងទឹកគុណភាពអន់បានល្អជាងប្រភេទត្រីមួយចំនួនទៀត។

### តើធ្វើយ៉ាងណាទើបវារីវប្បករដឹងថាស្រះរបស់ខ្លួនជិតឈានដល់សមត្ថភាពផ្ទុក?

១. ការធ្វើសំណាកគឺជាវិធីសាស្ត្រល្អជាងគេ។ វារីវប្បករអាចប្រមូលកំណត់ត្រាដែលបានពីការចិញ្ចឹមលើក មុនៗ ហើយផ្ទៀងផ្ទាត់ជាមួយលទ្ធផលសំណាកប្រចាំខែ នោះអ្នកចិញ្ចឹមនឹងដឹងបានថា ស្រះរបស់ខ្លួនជិតឈានកម្រិតអតិបរមា ឬយ៉ាងណានោះហើយ។

២. នៅពេលដែលស្រះឈានដល់សមត្ថភាពផ្ទុក ចរិកស៊ីចំណីរបស់ត្រីមានការផ្លាស់ប្តូរ។ នៅដំណាក់កាលនេះ គេអាចអង្កេតឃើញថា ត្រីអត់សូវស៊ីចំណីច្រើនថ្ងៃ។

៣. វារីវប្បករអាចអង្កេតមើលសុខភាពត្រី។ ត្រីក្នុងស្រះខ្លះមានលក្ខណៈមិនស្រស់ និងមានស្លាកស្នាមផ្សេងៗ។

៤. ទឹកស្រះមានក្លិនមិនល្អ។ ករណីនេះកើតឡើងដោយសារតែមានកាកសំណល់នានានៅកកកុញពេញក្នុងស្រះ។

### តើវារីវប្បករអាចបង្កើនសមត្ថភាពផ្ទុករបស់ស្រះបានដែរឬទេ?

វារីវប្បករអាចគិតឡើងវិញពីកត្តាកំណត់សមត្ថភាពផ្ទុកស្រះរបស់ខ្លួន ហើយផ្លាស់ប្តូរវិធានការឬរបៀបគ្រប់គ្រង។ វារីវប្បករអាច៖

- បង្កើនគុណភាព និងបរិមាណចំណី
- ធ្វើឱ្យគុណភាពទឹកល្អឡើងវិញតាមរយៈការផ្លាស់ប្តូរទឹក ឬការបញ្ចូលខ្យល់ក្នុងទឹក
- ផ្លាស់ប្តូរប្រភេទត្រីដែលមានភាពធន់នឹងជំងឺ និងគុណភាពទឹកកខ្វក់ ។

ប្រសិនវារីវប្បករដឹងពីសមត្ថភាពផ្ទុករបស់ស្រះ គាត់អាចគណនាចំនួនកូនត្រីសម្រាប់ដាក់ចិញ្ចឹម ដោយផ្អែកលើទម្ងន់មធ្យមត្រីមួយក្បាលដែលវារីវប្បករចង់បានពេលប្រមូលផល។ ឧទាហរណ៍ខាងលើបង្ហាញថាស្រះមានសមត្ថភាពផ្ទុក ៣ ៧០០គីឡូក្រាម អ្នកចិញ្ចឹមចង់បានទម្ងន់មធ្យមត្រីមួយក្បាល ០,៧គីឡូក្រាម (៧០០ ក្រាម) នៅពេលប្រមូលផល ហើយគាត់ចង់ប្រមូលផលមុនពេលដែលស្រះឈានដល់សមត្ថភាពផ្ទុក (មុនឈានដល់ ៣ ៧០០គីឡូក្រាម) ដែលជាគំនិតដ៏ឆ្លាតវៃ។ ដូច្នេះហើយគាត់ប្រមូលផលនៅក្នុងរវាងទិន្នផល ៣ ២០០គីឡូក្រាម ឬច្រើនបំផុត ៣ ៥០០គីឡូក្រាម វារីវប្បករអាចយក ៣ ៥០០ ចែកនិង០,៧ នោះឃើញថា វារីវប្បករអាចចាប់បានត្រី ៥ ០០០ក្បាល ពេលប្រមូលផលឬលក់។ ប៉ុន្តែវារីវប្បករត្រីគួរដាក់កូនត្រីចំនួន ៥ ៥០០ក្បាល។ ៥០០ក្បាល គឺសម្រាប់ប៉ះប៉ូវលើចំនួនកូនត្រីដែលអាចនឹងបាត់បង់ក្នុងរយៈពេលចិញ្ចឹម (ក្នុងអត្រា ១០ភាគរយ) ជាពិសេសក្នុងពេលដឹកជញ្ជូនពីកសិដ្ឋានមកកាន់ស្រះចិញ្ចឹម។

ប្រសិនបើវារីវប្បករចង់ចៀសវាងកំហុសឆ្គង ប៉ុន្តែមិនមានកំណត់ត្រាការចិញ្ចឹមពីកសិដ្ឋានខ្លួនឯង គាត់អាចសាកសួរទៅអ្នកចិញ្ចឹមត្រីជិតខាងដែលប្រើប្រាស់ប្រភេទចំណីស្រដៀងគ្នា។ តែសូមចងចាំថា អ្នកចិញ្ចឹមត្រីភាគច្រើនចាំតែលទ្ធផលជោគជ័យ (ប្រមូលបានផលច្រើន) និងមិនចង់និយាយប្រាប់ពីបរាជ័យ (ប្រមូលបានផលតិច) នោះទេ។

**ខាងក្រោមជាឧទាហរណ៍ សម្រាប់ការគណនាចំនួនកូនត្រីដាក់ចិញ្ចឹម៖**

**ប្រភេទត្រី៖ ប្រា**

**សមត្ថភាពផ្ទុករបស់ស្រះ៖ ៣ ៥០០គីឡូក្រាម = ២,៥គីឡូក្រាមក្នុង១ម៉ែត្រគូប**

**ទំហំស្រះ៖ ក្រឡាផ្ទៃស្រះ ៧ ០០ ម៉ែត្រការ៉េ x ជម្រៅស្រះ ២ ម៉ែត្រ = ១ ៤០០ម៉ែត្រគូប**

**ឧទាហរណ៍ទី១**

ទម្ងន់ត្រីជាមធ្យមដែលចង់បានពេលប្រមូលផល៖ ០,៧ គីឡូក្រាម ក្នុងមួយក្បាល

ចំនួនត្រីពេលប្រមូលផល = ៣ ៥០០ ចែកនឹង ០,៧ = ៥ ០០០ ក្បាល

ចំនួនកូនត្រីដាក់ចិញ្ចឹម = ៥ ០០០ ក្បាល ចែកនឹង ០,៩ (អត្រារស់ ៩០ ភាគរយ) = ៥ ៥០០ ក្បាល

**ឧទាហរណ៍ទី២**

ទម្ងន់ត្រីជាមធ្យមដែលចង់បានពេលប្រមូលផល៖ ០,៥ គីឡូក្រាម ក្នុងមួយក្បាល

ចំនួនត្រីពេលប្រមូលផល = ៣ ៥០០ ចែកនឹង ០,៥ = ៧ ០០០ ក្បាល

ចំនួនកូនត្រីដាក់ចិញ្ចឹម = ៧ ០០០ ក្បាល ចែកនឹង ០,៩ = ៧ ៧៧៨ ក្បាល

**ឧទាហរណ៍ទី៣**

ប្រសិនបើអ្នកដាក់ត្រី៖ ១០ ក្បាលក្នុង ១ ម៉ែត្រគូប

ចំនួនត្រីពេលប្រមូលផល = ១០ គុណនឹង ១ ៤០០ = ១៤ ០០០ ក្បាល

ចំនួនកូនត្រីដាក់ចិញ្ចឹម = ១៤ ០០០ក្បាល ចែកនឹង ០,៩ = ១៥ ៥៥៦ ក្បាល

ទម្ងន់ត្រីជាមធ្យមពេលប្រមូលផល = ៣ ៥០០ គីឡូ ចែកនឹង ១៥ ៥៥៦ = ០,២២៥ គីឡូក្រាម ក្នុងមួយក្បាល (២២៥ ក្រាម ឬជាង២ខាំ)។

# មេរៀន ៖

# ការគ្រប់គ្រងកសិដ្ឋាន

# ការគ្រប់គ្រងកសិដ្ឋាន

**ការគ្រប់គ្រងកសិដ្ឋានរួមមាន៖**

១. ការធ្វើផែនការ
២. ការវាស់វែង និងការកត់ត្រា
៣. ការបណ្តុះបណ្តាលបុគ្គលិក កម្មករក្នុងកសិដ្ឋាន រួមទាំងរៀបចំពិធីសារអនុវត្តតាមស្តង់ដា
៤. បន្តការកែលំអ




## ១. ការធ្វើផែនការ

"រៀបចំផែនការសម្រាប់រឿងអាក្រក់ រំពឹងលទ្ធផលល្អ"
"គិតឱ្យធំ ចាប់ផ្តើមពីតូច"
"គិតរួច សឹមគូរ"



ការធ្វើផែនការគឺជាសកម្មភាពសំខាន់មួយ ដែលអនុញ្ញាតឱ្យវារីវប្បករម្នាក់ធ្វើការកំណត់នូវលទ្ធផលជាផ្លែផ្ការបស់សកម្មភាពកសិដ្ឋានថ្មីមួយ (សហគ្រាស) មុនពេលដាក់ទុនក្នុងសកម្មភាពនោះ។ សកម្មភាពនានាក្នុងកសិដ្ឋានដែលគេបានកំណត់ជាផែនការ មានឱកាសតិចតួច នៃការផ្តល់ចំណូលគឺត្រូវចៀសវាង ដោយមិនត្រូវអនុវត្តទេ។ ការធ្វើផែនការអនុញ្ញាតដល់វារីវប្បករដើម្បីពិចារណានូវប្រសិទ្ធភាពនៃជម្រើសក្នុងសកម្មភាពរបស់កសិដ្ឋាន។ ជាឧទាហរណ៍ តើខ្ញុំនឹងរកលុយបានច្រើនពីការចិញ្ចឹមត្រីទីឡាព្យា ឬត្រីអណ្តែងមែនទេ? ផែនការល្អមួយគឺសំខាន់ផងដែរនៅពេលធ្វើការវិភាគលើប្រាក់កម្ចី។ អ្នកផ្តល់លុយឱ្យខ្ចីចង់ដឹង ថាតើទឹកលុយប៉ុន្មានដែលជាតម្រូវការ ហើយអ្វីដែលអាចធ្វើបានជាមួយនឹងលុយកាក់នោះ តើតម្រូវការលុយកាក់រយៈពេលយូរប៉ុន្មាន ដែលកម្ចីនេះត្រូវបានបង្វិលសងមកវិញ ជាដើម។ ទីភ្នាក់ងារផ្តល់កម្ចីនានា គឺមិនទំនងជាផ្តល់កម្ចីដល់នរណា ដែលគ្មានផែនការអាជីវកម្មបានទេ។

ផែនការរយៈពេលវែងអាចរួមបញ្ចូលវិធីសាស្រ្តពិនិត្យអង្កេត ដើម្បីសម្រេចបានប្រតិលាភប្រចាំឆ្នាំ ឬក៏គោលដៅផលិតកម្ម។ កសិដ្ឋានចិញ្ចឹមត្រីជាច្រើន ត្រូវសាងសង់តាមដំណាក់ៗ ពីព្រោះម្ចាស់កសិដ្ឋាននានា ទាញយកប្រាក់ចំណេញមួយចំនួនមកប្រើប្រាស់ដើម្បីពង្រីកកសិដ្ឋាន។ វាជាការងាយស្រួលដើម្បីរៀបចំកសិកដ្ឋានឱ្យមានលក្ខណៈប្លែកខុសៗគ្នាដោយបានចាប់ផ្តើមជាមួយផែនការ ដែលត្រូវបានសាងសង់ជាដំណាក់កាលៗ បើប្រៀបធៀបនឹងកសិដ្ឋានដែលពង្រីកដោយគ្មានផែនការអ្វីទាំងអស់។

ផែនការជោគជ័យចាប់ផ្តើមជាមួយនឹងការបញ្ជាប់គោលដៅដែលបានគិត។ នៅពេលដែលគោលដៅនៃសកម្មភាពត្រូវបានសម្រេចចិត្តចេញពីសកម្មភាពផែនការ នឹងជួយវារីវប្បករដើម្បីសម្រេចចិត្ត ប្រសិនបើគោលដៅនោះអាចត្រូវសម្រេចបាន។ ប្រសិនបើ គោលដៅមិនត្រូវបានសម្រេចទេ ដូច្នេះផែនការនោះនឹងត្រូវប្តូរចេញឬទម្លាក់ចោល។ ប្រសិនបើ វារីវប្បករសម្រេចចិត្តថា គោលដៅអាចសម្រេចបាន ដូច្នេះផែនការហ្នឹង ត្រូវបង្ហាញចេញមកនូវអ្វីដែលវារីវប្បករនឹងត្រូវការធ្វើឱ្យបានសម្រេចគោលដៅ។

នៅពេលគោលដៅនៃផែនការកសិដ្ឋានត្រូវបានរៀបចំរួចហើយ វារីវប្បករអាចចាប់ផ្តើមប៉ាន់ប្រមាណប៉ារ៉ាម៉ែត្រផលិតកម្មសម្រាប់សកម្មភាពនានា ។ ប៉ារ៉ាម៉ែត្រផលិតកម្មទាំងនោះរួមមាន អត្រាស្លាប់បានប្រមាណទុកជាមុន មេគុណចំណី (FCR) ទិន្នផលរំពឹងទុក ចំនួនកូនត្រីពូជសម្រាប់ដាក់ចិញ្ចឹម បរិមាណចំណីត្រូវការ ។ល។ (សូមមើលផែនការផលិតកម្មកសិដ្ឋាន)។ ការសន្មតទាំងឡាយណា ប្រើសម្រាប់ធ្វើផែនការនេះគួរផ្អែកលើកំណត់ត្រាពីការប្រមូលផលកន្លងមកក្នុងកសិដ្ឋាន (សូមមើលការរក្សាកំណត់ត្រារបស់កសិដ្ឋាន)។ ផែនការនានាគួរតែច្បាស់លាស់ ក្នុងការសន្មតរបស់វា ដូច្នេះប្រសិនបើការសន្មតខ្លះបញ្ជាក់ការពិតថា យកជាការមិនបានទេ វារីវប្បករអាចធ្វើការកែតម្រូវផែនការនោះភ្លាម។

## ២. ការវាស់វែង និងការរក្សាកំណត់ត្រា

**“បើអ្នកមិនវាស់វែង អ្នកមិនអាចគ្រប់គ្រងបានទេ”**

វារីវប្បកម្មគឺជាអាជីវកម្ម។ ផ្នែកមួយដែលសំខាន់នៃអាជីវកម្មនេះគឺរក្សាកំណត់ត្រា និងវារីវប្បកម្មគឺមិនខុសគ្នាទេ។ វារីវប្បករខ្លះ មានការចងចាំបានល្អប្រសើរនិងអាចរក្សាបានព័ត៌មានជាច្រើននៅក្នុងខ្លួនពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការចងចាំរបស់វារីវប្បករម្នាក់មិនអាចធ្វើឱ្យទីភ្នាក់ងារផ្តល់ប្រាក់កម្ចីជឿ ក្នុងការទទួលបាននូវកម្ចី ឬទាំងការធានា ឬលទ្ធភាពបញ្ជាក់អះអាងបានទេ។

ការអនុវត្តវារីវប្បកម្មល្អជាច្រើន គឺអាស្រ័យលើការរក្សាកំណត់ត្រា។ លទ្ធភាពអង្កេតដានគឺជាគន្លឹះមួយនៃការបញ្ជាក់វិញ្ញាបនបត្រ។ ទីភ្នាក់ងារផ្តល់ប្រាក់កម្ចីនានា នឹងចង់មើលពីកំណត់ត្រារបស់អ្នក។ កម្មវិធីធានាផលិតកម្មពីទិន្នផល អាស្រ័យលើការកត់ត្រារបស់វារីវប្បករ។ កំណត់ត្រាមិនគួរត្រូវបានរក្សាទុក គ្រាន់តែសម្រាប់បង្ហាញគេទេ។ កំណត់ត្រាគឺជារឿងរ៉ាវដែលមានតម្លៃមួយនៃការគ្រប់គ្រង កសិដ្ឋានល្អ និងគួរតែពិនិត្យមើលសារឡើងវិញ និងប្រើដើម្បីសម្រេចចិត្តការងារកសិដ្ឋាន។

ការវាស់វែងអ្វីមួយដូចជា បរិមាណចំណីដែលបានផ្តល់ប្រចាំថ្ងៃ មិនទាមទារឱ្យមានលក្ខណៈជាក់លាក់ហួសប្រមាណពេកទេ។ ប្រសិនបើការវាស់វែងក្លាយជាការស៊ីពេលច្រើនពេក អ្នកធ្វើការប្រហែលរំលងវាចោល ហើយគ្រាន់តែសរសេរជាលេខក៏បាន។ នៅក្នុងកសិដ្ឋានដែលមានស្រះធំៗ គួរធ្វើការកត់ត្រាចំនួនបាវចំណីដែលបានផ្តល់ចំណីឱ្យត្រីស៊ីប្រចាំថ្ងៃ។ សម្រាប់ចំនួនបរិមាណតិចតួច កែវក្រិតមួយ ឬក៏ធុងអាចប្រើដើម្បីវាស់ចំណីឱ្យត្រីស៊ី (សូមមើលមេរៀនចំណីនិងការផ្តល់ចំណី)។

ការធ្វើសំណាកត្រីគឺជាកត្តាសំខាន់មួយ នៃការគ្រប់គ្រងកសិដ្ឋាន ក៏ប៉ុន្តែប្រសិនធ្វើមិនបានល្អអាចបណ្តាលឱ្យមានបញ្ហាស្ត្រេសលើសលប់ និងអាចឱ្យត្រីងាប់បាន។ ពេលដំណើរការងារនានាក្នុងកសិដ្ឋានមានលំនឹង ការប្រមូលសំណាកត្រីអាចមិនសូវចាំបាច់ទេ។ ទោះជាយ៉ាងណាក៏ដោយ បើសិនជាការគ្រប់គ្រងមានការផ្លាស់ប្តូរ ដូច្នេះចំណីថ្មី ឬ ដាក់ប្រភេទត្រីថ្មី ឬក៏ការកែលំអគុណភាពទឹក នឹងត្រូវធ្វើឡើង ដូច្នេះវាជាការប្រសើរដើម្បីចាប់ផ្តើមធ្វើសំណាកជាថ្មីរៀងរាល់២អាទិត្យសម្រាប់ត្រីតូចៗ និងប្រចាំខែនៅពេលត្រីធំ(ធំជាង៥០ក្រាម) (សូមមើលការកំណត់ត្រាប្រមូលផល)។

វាជាការល្អដើម្បីប្រមូលទិន្នន័យនៅតាមស្រះ ហើយចម្លងទៅជាកំណត់ត្រាសម្រាប់កសិដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យពីស្រះមិនគួរគ្រាន់តែសរសេរលើក្រដាសព្រាងតូចៗ ដែលងាយស្រួលបាត់ណាស់។ អ្នកគ្រប់គ្រងកសិដ្ឋានគួររក្សាឱ្យមានសៀវភៅកត់ត្រាទិន្នន័យពីស្រះ។ បន្ទាប់មកបញ្ចូលទិន្នន័យពីស្រះចូលក្នុងកំណត់ត្រា ហើយពួកគេអាចពិនិត្យមើលតាមទំព័រនីមួយៗ។ គ្រប់ពេលកត់ត្រា អាចនឹងចម្លងឡើងវិញ ប៉ុន្តែចៀសវាងការចម្លងច្រើនដង ដែលអាចឱ្យមានការភាន់ច្រឡំ ។



Fish Sales Record

Hapa Number : #2.

| Date | Customer Name | Quantity (Kg) | Price per Unit (Riel) | Amount (Riel) | Remark |
|---|---|---|---|---|---|
| 15-12.20 | [illegible] | 50 | 5000 | 250,000 | Paid |
| 16.12.20 | [illegible] | 20 | 5,000 | 100,000 | Paid |
| 16.12-20 | [illegible] | 20 | 5000 | 100,000 | Paid |
| 17-12.20 | [illegible] | 20 | 5,000 | 100,000 | Paid |
| 18-12.20 | [illegible] | 20 | 5000 | 100,000 | |
| 18-12.20 | [illegible] | 20 | 5000 | 100,000 | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| TOTAL | | | | | |

រូបភាព៖ កំណត់ត្រាលក់ត្រី




រូបភាព៖ ផែនការផលិតកម្ម

## ៣. ការបណ្តុះបណ្តាលបុគ្គលិក និងពិធីសារអនុវត្តតាមស្តង់ដា

ការបណ្តុះបណ្តាលបុគ្គលិករួមមាន៖

- បង្រៀនពួកគេពីរបៀបឱ្យចំណីត្រីដែលល្អបំផុត
- របៀបលែងត្រីក្នុងស្រះដោយកាត់បន្ថយស្ត្រេស (សូមមើលពីការដាក់ត្រីនិងដឹកជញ្ជូន)
- របៀបប្រតិបត្តិឧបករណ៍ប្រើប្រាស់ដោយសុវត្ថិភាព
- របៀបថែទាំសម្ភារៈ និងឧបករណ៍
- របៀបប្រតិបត្តិតាមជាលក្ខណៈជាក់លាក់នៃការអនុវត្តវារីវប្បកម្មល្អ
    - តួនាទីអ្វីខ្លះរបស់ពួកគេដើម្បីធានាការអនុវត្តប្រកបដោយ អនាម័យនៅកន្លែងកសិដ្ឋាន រួមទាំងទប់ស្កាត់សារធាតុពុលនៃផលិតផលវារីវប្បកម្មនិងការធ្វើឱ្យត្រីចុះខ្សោយអំឡុងពេលចិញ្ចឹមនិងបន្ទាប់ពីប្រមូលផល។
    - ធានាសុខភាព និងសុខុមាលភាពត្រី
    - ការទទួលខុសត្រូវរបស់ពួកគេក្នុងការការពារបរិស្ថាន



រូបភាព៖ ការអនុវត្តវារីវប្បកម្មល្អ

ការបណ្តុះបណ្តាលបុគ្គលិកគឺងាយស្រួលទេ ប្រសិនបើកសិដ្ឋានបានសរសេររួចរាល់ពី**ពិធីសារអនុវត្តតាមស្តង់ដា**។ ជាការពិត នៅពេលកសិដ្ឋានខ្លះពង្រីក និងជួលអ្នកគ្រប់គ្រងថ្មី ជារឿយៗ ពួកគេស្នើឱ្យអ្នកគ្រប់គ្រងថ្មីនោះសរសេរជាថ្មីពី**ពិធីសារអនុវត្តតាមស្តង់ដា**សម្រាប់កសិដ្ឋាន បើសិនជាមិនទាន់មានវាស្រាប់ហើយនោះ។ ការបង្កើត **ពិធីសារអនុវត្តតាមស្តង់ដា**មួយ កំឡុងពេលវគ្គបណ្តុះបណ្តាលបុគ្គលិកកសិដ្ឋានអាចជាប្រយោជន៍ច្រើនណាស់ (សូមមើលឧទាហរណ៍ពីដំណើរការប្រតិបត្តិតាមស្តង់ដា)។

ទិដ្ឋភាពដ៏ទៃទៀតនៃពិធីសារអនុវត្តតាមស្តង់ដា៖

- ការធ្វើតារាងការងារនៃកិច្ចការកសិដ្ឋាន ដូចជា សំណាក់ត្រី និងការផ្លាស់ទីត្រី ការពិនិត្យគុណភាពទឹក ការសំអាត ការកាត់ស្មៅ ព្រមទាំងនរណាជាអ្នកទទួលខុសត្រូវក្នុងកិច្ចការនីមួយៗ។
- ការពិនិត្យតាមដានជាតម្រូវការនៃការអនុវត្តវារីវប្បកម្មល្អ។

## សុវត្ថិភាពបុគ្គលិក

ថៅកែឬអ្នកចាត់ចែងគឺទទួលធ្វើការណែនាំដល់បុគ្គលិករបស់គេពីរបៀបធ្វើការដោយសុវត្ថិភាពនិង បង្កើតជាបទបញ្ជាខ្លះៗតម្រូវឱ្យពួកគេមានសុវត្ថិភាព។ ជាឧទាហរណ៍ កសិដ្ឋានបែត្រីនៅក្នុងបឹង ក្រុមហ៊ុនធំៗតម្រូវឱ្យបុគ្គលិកពាក់អាវពោង/អាវសុវត្ថិភាពនៅគ្រប់ពេលវេលា ការពារក្នុងករណីពួកគេធ្លាក់ពីបែត្រី។ បុគ្គលិកក៏ត្រូវបានគេណែនាំផងដែរពីរបៀបត្រូវធ្វើយ៉ាងម៉េចប្រសិនបើមាននរណាម្នាក់មានរបួស។

មានបទបញ្ញត្តិគ្រប់គ្រាន់ហើយឱ្យបុគ្គលិកប្រតិបត្តិតាមដែលអាចជាប្រយោជន៍ ក្នុងព្រឹត្តិការណ៍ដែលបុគ្គលិកម្នាក់ធ្វេសប្រហែស ហើយបន្ទោសម្ចាស់កសិដ្ឋានសម្រាប់ឧប្បត្តិហេតុរបស់ពួកគេ។

ឧបករណ៍៖ ប្រភេទឧបករណ៍ជាច្រើនប្រើក្នុងកសិដ្ឋានចិញ្ចឹមត្រីដែលតម្រូវឱ្យមានការបណ្ដុះបណ្ដាលដើម្បីសុវត្ថិភាពគឺ៖

- គ្រឿងម៉ាស៊ីន ឧបករណ៍អគ្គិសនី ជាពិសេសនៅពេលប្រតិបត្តិការក្បែរទឹក។ ការតម្លើងគ្រឿងអគ្គិសនីគួរតែរៀបចំឱ្យរួចស្រេចតាមក្រុមការងារ។ ជាធម្មតា តម្រូវឱ្យដាក់ទីតាំងប្រអប់អគ្គិសនីនិងកុងតាក់ យ៉ាងហោចណាស់១ម៉ែត្រពីលើនៃកម្ពស់ទឹកអតិបរមា
- ឧបករណ៍អគ្គិសនីដែលប្រើក្នុងទឹកដោយចេតនាឬឧប្បទ្វហេតុ ដូចជាម៉ាស៊ីនបូមដាក់ពន្លិចទឹកគួរផ្ដាច់តំណចរន្តមុនពេលអ្នកណាម្នាក់ចុះទៅក្នុងទឹកដើម្បីចៀសវាងគ្រោះថ្នាក់ឆក់អគ្គិសនី
- ឧបករណ៍ដែលបំលែងភ្លើងចេញពីត្រាក់ទ័រ
    - គ្រឿងបង្កំកម្លាំងរុញវិល គឺវិលលឿនណាស់ ហើយបុគ្គលិកធ្វើការគួរស្ថិតនៅឱ្យឆ្ងាយពីវានៅពេលវាកំពុងដំណើរការ។ មានករណីជាច្រើនដែល សំលៀកបំពាក់និងសក់មនុស្សត្រូវគ្រឿងបង្កំកម្លាំងរុញវិលនេះចាប់ទាញចូល។
    - ឧបករណ៍ប្រើខ្សែពានក៏បង្កឱ្យមានគ្រោះថ្នាក់ របួសស្នាមបានដែរ។ វាបណ្ដាលពីការដាច់ខ្សែពានវាយចំបុគ្គលិកធ្វើការនិងមនុស្សត្រូវខ្សែពានទាញចូល។ បើសិនខ្សែពានមិនមានប្រអប់គ្របការពារ យើងគួរតែចៀសវាង។
    - ប្រេងខ្លាញ់នៅក្នុងទុយោកាប៉ែនគឺវាមានសំពាធខ្ពស់ណាស់។ បើសិនជាទុយោកាប៉ែនលេចជ្រាប បាញ់ប្រេងខ្លាញ់ដោយសំពាធខ្ពស់អាចកាត់ខ្លួនមនុស្សបាន ឬអាចកាត់ដាច់ម្រាមដៃ។
- កសិដ្ឋានខ្លះប្រើហាត់ភ្ជាប់ម៉ូទ័រក្បែរច្រាំង និងគ្រឿងបង្កំផែងបំពាក់ស្លាបចក្រច្រើនសម្រាប់បញ្ចូលខ្យល់ទៅក្នុងទឹក។ គ្រឿងបង្កំដែលបត់បាននេះអាចទាក់សំលៀកបំពាក់និងសក់បង្ករបួសស្នាមឬស្លាប់បាន។ បិទរាល់ឧបករណ៍គ្រឿងបង្កំវិល ឬដុំភ្លៅគ្រឿងបង្កំ មុនពេលសម្អាតកំទេចកំទី ឬក៏ធ្វើការថែទាំផ្សេងៗ។
- ធុងអុកស៊ីសែន៖គួធ្វើការសម្អាតនិងពិនិត្យវ៉ាល់។ ប្រេងខ្លាញ់មិនគួរប្រើនៅលើកុងទ័រអុកស៊ីសែនឡើយ ពីព្រោះវាអាចបង្កការផ្ទុះដោយឯងៗ។ អុកស៊ីសែនអាចត្រូវបានស្រូបចូលក្នុងខោអាវផងដែរ ហើយបង្កការឆេះភ្លាមៗដល់សំលៀកបំពាក់អ្នកធ្វើការ។ ហាមដាច់ខាតមានអណ្ដាតភ្លើងឬផ្កាភ្លើងនៅក្បែរនៅពេលធ្វើការជាមួយអុកស៊ីសែន។

**ការថែទាំឧបករណ៍**

បើសិនមានការថែទាំឧបករណ៍ប្រើបានយូរនិងប្រតិបត្តិដោយសុវត្ថិភាព។ ម៉ាស៊ីនភាគច្រើនមានតារាងថែទាំជាមួយការណែនាំសាមញ្ញៗពីអ្វីត្រូវថែទាំ។ អ្នកគ្រប់គ្រងកសិដ្ឋានល្អម្នាក់នឹងបង្កើតតារាងបញ្ជីកិច្ចការលើការថែទាំឧបករណ៍ ដែលអនុវត្តដោយមនុស្សធ្វើកិច្ចនោះនៅកសិដ្ឋាន។ ឧទាហរណ៍ខ្លះៗគឺ៖

- ម៉ាស៊ីនភ្លើងអន្តរាគមន៍បន្ទាន់ គឺត្រូវធ្វើតេស្តសាកល្បងប្រចាំខែ មិនត្រឹមតែបើកបញ្ឆេះសាកចោល ក៏ប៉ុន្តែ សាកប្រើក្នុងកម្រិតពេញបន្ទុក គឺមានន័យថា បិទចរន្តភ្លើង ហើយយកម៉ាស៊ីនមកដំណើរការជំនួសវិញ
- ម៉ាស៊ីនផ្លុំខ្យល់ គួរពិនិត្យមើលការលេចជ្រាប ហើយតម្រងចម្រោះខ្យល់គួរធ្វើការសម្អាត។ ការសម្អាតជាញឹកញាប់អាស្រ័យលើប្រភេទតម្រងចម្រោះនិងបរិស្ថាន ក៏ប៉ុន្តែជាធម្មតាត្រូវសម្អាតរៀងរាល់ ២ទៅ៦ខែ
- ម៉ាស៊ីនប្រើសាំងនិងប្រេងម៉ាស៊ូត ត្រូវការប្ដូរប្រេងរំអិលនិងការសម្អាតតម្រងខ្យល់ ព្រមទាំងប្ដូរតម្រងផងដែរ

- មងសំណាញ់សម្រាប់ប្រមូលផលគួរពិនិត្យមើលនិងជួសជុលជាប្រចាំ។ នេះធ្វើឱ្យសំណាញ់មានប្រសិទ្ធភាពក្នុងការចាប់ ហើយជំនួសដោយការអូសសំណាញ់រហែក១០លើក ដើម្បីប្រមូលផលក្នុងស្រះមួយ ហើយប្រហែលអាចចាប់ត្រីអស់ប្រើពេលតែ៣លើកប៉ុណ្ណោះ បើសិនជាសំណាញ់ល្អ។

**ការជ្រើសរើសបុគ្គលិក**

**"ជ្រើសរើសមនុស្សមើលឥរិយាបទ បណ្តុះមនុស្សមើលជំនាញ"**

នេះមានន័យថាជាការប្រសើរដើម្បីជួលនរណាដែលមានអាកប្បកិរិយាល្អនិងមានឆន្ទៈចង់រៀន ជាជាងជួលនរណាដែលគិតថាពួកគេចេះគ្រប់រឿងអស់ហើយ។

ការអនុវត្តវារីវប្បកម្មល្អចែងថា៖

- បុគ្គលិកត្រូវបានផ្តល់ជូនជាមួយលក្ខខណ្ឌការងារសមរម្យសម្រាប់ទាំងពីរភេទ
- ពលកម្មកុមារមិនគួរបានប្រើក្នុងរបៀបមិនស៊ីចង្វាក់គ្នាជាមួយអនុសញ្ញា អង្គការពលកម្មអន្តរជាតិទេ
- លក្ខខណ្ឌការងារកសិដ្ឋានដែលមានសុវត្ថិភាពត្រូវតែធ្វើឱ្យប្រាកដនូវគ្រប់ពេលដោយស្របជាមួយនឹងសុវត្ថិភាពនិងសុខុមាលភាពការងាររបស់អង្គការពលកម្មអន្តរជាតិ។

## ៤. បន្តការកែលំអ

**"កំហុសគឺត្រូវបានអភ័យទោសជានិច្ចកាល ប្រសិនបើនរណាម្នាក់មានចិត្តសារភាពពីកំហុស"** សំដី ព្រូសលី។

ក្នុងការបណ្តុះបណ្តាលសិស្ស ពួកយើងតែងប្រាប់ពួកគេថា ពួកគេនឹងមិនត្រូវបានដេញចេញទេ សម្រាប់ការធ្វើឱ្យមានកំហុស ក៏ប៉ុន្តែពួកគេនឹងត្រូវបណ្តេញចេញក្នុងបទក្លែងបន្លំទិន្នន័យ និងលាក់បាំងកំហុសនានា។

វារីវប្បករជារឿយៗរក្សាធ្វើកិច្ចការដដែលៗហើយមិនមើលលទ្ធផលរបស់ពួកគេជាលក្ខណៈគិតពិចារណាជិតដល់ ពីវិធីប្រសើរនៃកិច្ចការសាមញ្ញៗរបស់កសិដ្ឋានឡើយ។ វារីវប្បករខ្លះនៅតែមើលតម្លៃចំណីជំនួសតម្លៃនៃការផ្តល់ចំណី។ វារីវប្បករខ្លះទៀតលោតចេញពីគំនិតថ្មីមួយទៅរកគំនិតផ្សេងដោយគ្មានធ្វើការវាយតម្លៃពិតប្រាកដ នូវលទ្ធផលនៃការយល់ព្រមអនុវត្តនីមួយៗនៃគំនិតថ្មីទាំងនោះឡើយ។

នៅពេលយើងក្រឡេកមើលកសិដ្ឋានដែលទំនងជាទទួលជោគជ័យភាគច្រើន យើងមើលឃើញគុណភាពកិច្ចការសាមញ្ញទាំងនោះ៖

- បុគ្គលិកទទួលបានការបណ្តុះបណ្តាលបានល្អនិងឯករាជ្យម្ចាស់ការក្នុងការងារ
- មានការចាកចេញរបស់បុគ្គលិកតិចតួច
- បច្ចេកវិទ្យាថ្មីត្រូវបានសាកល្បងក្នុងទ្រង់ទ្រាយតូចសិន(តែ២-៣ស្រះឬអាងតែប៉ុណ្ណោះ) ហើយចាំយល់ព្រមអនុវត្តតាម បន្ទាប់ពីបានវាយតម្លៃបច្ចេកទេសថ្មីរួមទាំងតម្លៃចំណាយនិងផលចំណេញ
- ចំណូលគឺសំខាន់ ក៏ប៉ុន្តែនិរន្តភាពនៃអាជីវកម្មក៏ត្រូវពិចារណាផងដែរ និងត្រូវផ្តល់ជាអាទិភាពលើផលចំណេញរយៈពេលខ្លី
- កសិដ្ឋានមានផែនការផលិតកម្ម និងដឹងពីព័ត៌មានទីផ្សារជាមុន ។

# មេរៀន ៖

# ការសាងសង់ស្រះចិញ្ចឹមត្រីសម្រាប់វារីវប្បកម្មលក្ខណៈពាណិជ្ជកម្ម

# ការសាងសង់ស្រះចិញ្ចឹមត្រីសម្រាប់វារីវប្បកម្មលក្ខណៈពាណិជ្ជកម្ម
# និយមន័យ និងបទដ្ឋាន

**Dam:** ទំនប់ទប់ទឹក
**Levee:** ទំនប់ស្រះ
**Dike or dyke:** ទំនប់ ឬភ្លឺ
(ទាំងអស់នេះសំដៅទៅលើន័យតែមួយ)
**Freeboard:** កម្ពស់ខ្ពង់ទំនប់ធៀបនឹងកម្រិតកម្ពស់ទឹក




| | |
|---|---|
| កម្ពស់ | កម្ពស់ទំនប់គឺជាចំងាយពីបាតស្រះទៅមាត់លើ។ |
| ទទឹងភ្លឺ | ទទឹងភ្លឺពីស្រះមួយទៅស្រះមួយ គួរមានប្រវែងតូចបំផុត១ម៉ែត្រ។ ទទឹងភ្លឺ អតិបរិមាអាស្រ័យលើបរិមាណដីដែលអាចធ្វើបាន ហើយវាក៏អាស្រ័យលើយើងចង់បើកបរយានយន្តនៅលើភ្លឺដែរឬទេ។ ជាធម្មតាភ្លឺមេមានទទឹងធំជាងភ្លឺចែកស្រះព្រោះវាជាកន្លែងដែលអាចធ្វើសកម្មភាពប្រមូលផល។ |
| បាតទំនប់ | ប្រវែងបាតទំនប់អាស្រ័យលើជម្រាល។ |
| ជម្រាល | និយមន័យពិតប្រាកដនៃជម្រាលគឺកម្ពស់បញ្ឈរ (h) ចែកដោយចម្ងាយផ្តេក (បញ្ឈរផ្តេក)។ វារីវប្បករនិងអ្នកសាងសង់ស្រះ ជាធម្មតាបញ្ច្រាសរឿងនេះដូច្នេះពួកគេមិនចាំបាច់ធ្វើវិភាគទេ។ ជម្រាលសមាមាត្រ ២:១សម្រាប់វារីវប្បករ មានន័យថាចម្ងាយផ្តេក២ និងកម្ពស់បញ្ឈរ១។ |

## តើទំនប់គួរមានជម្រាលប៉ុន្មានទើបល្អ?

- ទីតាំងចិញ្ចឹមត្រីក្នុងស្រះជាលក្ខណៈពាណិជ្ជកម្ម ស្រះអាចមានទំហំធំចាប់ពី ៥ ទៅ ២០ហិកតា ក្នុងស្រះនីមួយៗ។ ជម្រាលទំនប់អប្បបរមាសមាមាត្រ ៤:១ និងអាចសមាមាត្រដល់ ៧:១។ ស្រះធំៗអាចមានសំណឹកខ្លាំងដោយសាររលក ដូច្នេះជម្រាលមិនសូវចោតអាចជួយបន្ថយការសំណឹក។ គួរបញ្ជាក់ផងដែរថា បរិមាណដីដែលត្រូវបានជីកចេញពីស្រះធំៗ អាចយកទៅទប់ធ្វើជម្រាលបានល្អប្រសើរ ពីព្រោះបរិវេណសមាមាត្រផ្ទៃលើគឺតិចជាងជើងជម្រាល។

- ចំពោះស្រះតូចៗ គួរមានជម្រាលសមាមាត្រ ២:១ ឬ៣:១។ វាជាការល្អបំផុត ប្រសិនបើមានដីបន្ថែមនៅទីកន្លែងនោះ ដែលអាចប្រើវាដើម្បីធ្វើឱ្យស្រះរឹងមាំដោយបង្កើនជម្រាល ឬពង្រីកទទឹងខ្នងភ្លឺ។
- ចំពោះស្រះតូចៗ (ត្រឹម ១៥០ម៉ែត្រការេ ឬតិចជាងនេះ) ជម្រាលសមាមាត្រ ១,៥:១ ឬ ១:១ មិនជាបញ្ហាទេ។
- ស្រះដែលក្រាលសំពត់តង់ មិនតម្រូវឱ្យមានជម្រាលទេ ប៉ុន្តែបើមានជម្រាលវាមានប្រយោជន៍ ហើយធ្វើឱ្យការងារកាន់តែងាយស្រួល។

## តើកម្ពស់ខ្នងទំនប់ធៀបនិងកម្រិតកម្ពស់ទឹកបែបណាដែលល្អជាងគេ?

- ចំពោះស្រះធំ (ធំជាង១ហិកតា) គួរមានប្រវែង៥០សង់ទីម៉ែត្រ ដើម្បីការពាររលកប៉ះពាល់ស្រះ។
- សម្រាប់ស្រះល្មម កម្ពស់ខ្នងទំនប់ គឺមានកម្ពស់ពី២០ទៅ៣០សង់ទីម៉ែត្រ គឺល្មមគ្រប់គ្រាន់។
- ប្រសិនបើទំនប់មិនបានបង្ហាប់ដីឱ្យណែនទេ ក្នុងរយៈពេលពីរបីឆ្នាំ កម្ពស់ខ្នងទំនប់ កម្រាស់៥០សង់ទីម៉ែត្រ អាចនឹងនៅសល់ត្រឹម២០សង់ទីម៉ែត្រ ដោយសារការបាក់ដី។

**កម្ពស់ខ្នងទំនប់ខ្ពស់ពេក៖**

- គឺមានតំលៃថ្លៃក្នុងការធ្វើវាឡើង
- ទាក់ទាញពពួកសត្វមាំសាសី និងសត្វដែលរស់នៅក្នុងរូងដូចជា ពពួកសត្វកកេរស្រដៀងសត្វកណ្ដុរតែវារស់នៅក្នុងទឹកដូចសត្វភេនិងពួកសត្វចចាត ដែលចូលចិត្តជញ្ជាំងខ្នងទំនប់ខ្ពស់សម្រាប់ធ្វើ សំបុករបស់ពួកវា
- ជាកន្លែងដែលស្រមោចមានស្លាប(ដូចជាមេភ្លៀង) និងកណ្ដៀរចូលចិត្តរស់នៅ ដែលនាំឱ្យមានការលេចធ្លុះធ្លាយ
- ធ្វើឱ្យមានការលំបាក ក្នុងការងារចេញចូល និងការងារស្រះ
- ទប់ចរន្តខ្យល់មិនឱ្យប៉ះដល់ផ្ទៃទឹកខាងលើ ព្រមទាំងទប់ការលាយអុកស៊ីសែនក្នុងខ្យល់ និងកាត់បន្ថយការផ្លាស់ប្តូរអុកស៊ីសែន
- មើលទៅមិនសម។

## តើស្រះគួរមានជម្រៅប៉ុន្មាន?

**ជម្រៅស្រះអតិបរិមា** ត្រូវបានកំណត់ដោយចម្ងាយដែលពន្លឺព្រះអាទិត្យអាចចាំងចូលក្នុងស្រះ ដើម្បីរាំងខ្ទប់ការធ្លាក់ចុះនៃអុកស៊ីសែនក្នុងទឹក។ គួរមានជម្រៅអតិបរមាចាប់ពី ១,៣ ទៅ ២ម៉ែត្រ។ ប្រសិនបើមានជម្រៅជ្រៅជាង ២ម៉ែត្រ ស្រទាប់ទឹកនឹងខ្វះអុកស៊ីសែន។ ប្រសិនបើអុកស៊ីសែនទាប ទឹកនៅស្រទាប់បាតលាយជាមួយកាកសំណល់នៃទឹកស្រះ (ឧទាហរណ៍នៅក្នុងលក្ខខណ្ឌខ្យល់ខ្លាំងឬមានភ្លៀងធ្លាក់នៅពេលល្ងាច) នោះបរិមាណអុកស៊ីសែនដែលមានក្នុងទឹកស្រះធ្លាក់ចុះទាបអាចបណ្ដាលឱ្យត្រីងាប់បាន។

**ជម្រៅស្រះអប្បបរមា** គួរមានជម្រៅ៦០សង់ទីម៉ែត្រ ពីព្រោះនៅជំរៅស្រះរាក់ជាងនេះ រុក្ខជាតិទឹកងាយនឹងកកើត។ ដូចគ្នានេះផងដែរ ធ្វើឱ្យបក្សីអាចចាប់ត្រីបានងាយស្រួល។ សមត្ថភាពផលិតកម្មរបស់ស្រះមិនត្រូវបានប្រើក្នុងកម្រិតពេញលេញបានទេ នៅពេលដែលជម្រៅទឹកស្រះរាក់ជាងការចាំងពន្លឺព្រះអាទិត្យចូលក្នុងជម្រៅទឹកស្រះ។

**ការក្រើនរំលឹក៖** ការចាំងចូលរបស់ពន្លឺព្រះអាទិត្យមិនមែនជាចម្ងាយនៃភាពថ្លានៃទឹកដែលយើងមើលឃើញដោយឧបករណ៍ស៊ិកជីឌីសឡើយ វាគឺមានចម្ងាយ២ដងរបស់ស៊ិកជីឌីស។ ដូច្នេះប្រសិនបើមើលឃើញស៊ិកជីឌីសក្នុងទឹកមានប្រវែង ៣៥ សង់ទីម៉ែត្រ នោះមានន័យថាពន្លឺព្រះអាទិត្យអាចចាំងចូលដល់ជម្រៅ ៧០សង់ទីម៉ែត្រ ហើយស្មៅអាចដុះឡើងបាន។

**ទំហំរបស់ស្រះអាស្រ័យលើ៖**

១. ទីតាំងភូមិសាស្ត្រ ជាពិសេសជម្រាល និងគុណភាពដី

២. ការប៉ាន់ប្រមាណការប្រើប្រាស់ស្រះ ជាពិសេសទម្ងន់សរុបដែលចង់បាននៅពេលប្រមូលផល (វាជាជំនួយប្រសិនបើអ្នកមានគំពោងអាជីវកម្មទីផ្សារជាមុន) និងវិធីសាស្ត្រប្រមូលផលដែលនឹងត្រូវប្រើ។

ជាធម្មតាស្រះមានរាងជាចតុកោណ។ ទំហំល្អមកំណត់ពីទំហំនៃអួនដែលនឹងត្រូវការប្រើ។ គួរធ្វើការពិចារណាលើទិសដៅខ្យល់ និងសំណឹកមុនពេលសម្រេចចិត្តជីករាងស្រះ ហើយក៏គួរពិចារណាផងដែរលើ៖

១. ស្រះដែលមានទំហំធំចំណាយប្រាក់សាងសង់ផ្ទៃខាងលើអស់តិច

២. ទោះជាយ៉ាងណាក៏ដោយ ស្រះធំមិនគួរសាងសង់នៅលើជម្រាលដែលចោទទេ

៣. ស្រះកាន់តែធំ កាន់តែពិបាកក្នុងការប្រមូលផល

៤. ការគ្រប់គ្រងស្រះតូចៗជាច្រើនមានតម្លៃថ្លៃជាងការគ្រប់គ្រងស្រះធំតែមួយ ប៉ុន្តែអាចបម្រើដល់ទីផ្សារតូចដែលធ្វើឱ្យតម្លៃកាន់តែមានប្រសិទ្ធភាព

៥. កសិដ្ឋានលក្ខណៈពាណិជ្ជកម្មភាគច្រើនមានស្រះទំហំខុសគ្នា ២ឬ៣ប្រភេទ ស្រះតូចបំផុតសម្រាប់ត្រីតូច/ ឬសម្រាប់ដាក់បណ្តោះអាសន្ន។



រូបភាព៖ ការជីកស្រះដោយប្រើប្រាស់គ្រឿងចក្រ

ដៃគូអនុវត្តគម្រោង៖ World Vision, Kansas State University, Auburn University

## តើការសាងសង់ស្រះត្រូវប្រើប្រាស់គ្រឿងចក្រ ឬកម្លាំងពលកម្ម?

នៅតំបន់ភាគច្រើននៃទ្វីបអាហ្វ្រិក វាមានតម្លៃថ្លៃក្នុងការប្រើកម្លាំងពលកម្មដើម្បីសាងសង់ស្រះដែលមានទំហំ ១០០០ម៉ែត្រការ៉េ ឬតិចជាងនេះ។ ការប្រើគ្រឿងចក្រ អាចមានប្រសិទ្ធភាពតម្លៃជាង ប្រសិនបើប្រើប្រាស់គ្រឿងចក្រសម្រាប់ជីក។ ជារឿយៗ គ្រឿងចក្រសម្រាប់ជីកដីគ្មានពេលសម្រាប់ជញ្ជូនដីចេញទេ ហើយការប្រើប្រាស់រួមគ្នារវាងកម្លាំងពលកម្មនិងគ្រឿងចក្រគឺជាវិធីល្អបំផុតដើម្បីដំណើរការសាងសង់ស្រះ។

## គុណសម្បត្តិនៃការជួលកម្លាំងពលកម្ម

១. មនុស្សច្រើនទទួលបានការងារធ្វើ

២. ប្រសិនបើមានការត្រួតពិនិត្យត្រឹមត្រូវ អាចទទួលបានទំហំដែលពិតប្រាកដ

៣. អាចធ្វើបាននៅតំបន់ដាច់ស្រយាល កន្លែងដែលគ្រឿងចក្រមិនអាចផ្លាស់ទីបាន

## គុណវិបត្តិនៃការជួលកម្លាំងពលកម្ម

១. បញ្ហាក្នុងការគ្រប់គ្រងពលកម្ម

២. ការជញ្ជូនដីចម្ងាយឆ្ងាយមានតម្លៃថ្លៃ

៣. ការសាងសង់អាចចំណាយពេលយូរ



រូបភាព៖ ស្រះចិញ្ចឹមត្រីទើបសាងសង់ថ្មី

# មេរៀន ៖

# ការសាចសង់ស្រះ

# ការសាងសង់ស្រះ

១. ស្រះត្រូវជីកឱ្យមានលក្ខណៈជារាងផត ឬរណ្តៅជម្រៅដោយប្រើប្រាស់អេស្កាវ៉ាទ័រជីកប៉ាន់ស្មានកំណត់ជម្រៅ ប៉ុន្តែបើគ្មាន ជើងទេរនោះទេ អាចបណ្តាលឱ្យមានដីល្បប់ច្រើន។ ប្រសិនបើមានការប្រើប្រាស់ហាត់ទឹកជាមួយស្រះដែលមានជើងទេរខ្លី នោះអត្រានៃការបាក់ក្លីស្រះនឹងអាចកើតមានយ៉ាងឆាប់រហ័ស (ភាពមិនរឹងមាំនិងការរលំ)។

២. ជាទូទៅខ្លះការរៀបចំផែនការទៅលើការលើកដាក់ត្រីពីស្រះទៅរថយន្ត ដោយសាររថយន្តមិនអាចបើកទៅដល់ស្រះ។

៣. ត្រូវប្រៀបធៀបតម្លៃរវាងការសាងសង់ស្រះដែលស្របទៅតាមស្តង់ដាបច្ចេកទេសនិងការជីករណ្តៅដីធម្មតានាពេលសព្វថ្ងៃ។ រួមបញ្ចូលទាំងតម្លៃនៃការកែសម្រួល ជាពិសេសការបូមភក់ចេញក្រៅដែលវាសុទ្ធតែជាកត្តាដែលអាចប៉ះពាល់ទៅលើគុណភាពទឹក សុវត្ថិភាពរបស់អ្នកធ្វើការនៅទីនោះ និងក្មេងៗ។

ស្រះត្រីមិនមែនគ្រាន់តែជារណ្តៅមួយនោះទេ។ នេះមានន័យថាស្រះត្រីគួរតែត្រូវបានសាងសង់ឡើងដោយមានការគិតទុកជាមុនដើម្បីជាប្រយោជន៍នៃការចិញ្ចឹម និងការប្រមូលផលត្រី។ តើយើងអាចចិញ្ចឹមត្រីនៅក្នុងរណ្តៅធម្មតាដែលមានទឹកនៅក្នុងនោះដែរឬទេ? វាពិតជាអាច តែវានឹងមានភាពងាយស្រួលសម្រាប់វារីវប្បករ ប្រសិនបើស្រះបានជីកដោយត្រឹមត្រូវដែលមានជើងទេរនិងរបងការពារ នោះវានឹងធ្វើឱ្យមានសុវត្ថិភាព ហើយអាចការពារបានក្នុងករណីដែលមានកូនក្មេងឬមនុស្សធំដែលមិនចេះហែលទឹកធ្លាក់ទៅក្នុងស្រះ។

## ដំណាក់កាលក្នុងការសាងសង់ស្រះ

១. ការរៀបចំផែនការ

- តើអ្នកសាងសង់ស្រះក្នុងគោលបំណងអ្វី? តើអ្នកនឹងប្រើប្រាស់ស្រះនោះដើម្បីផលិតកូនត្រី ឬត្រីចិញ្ចឹមយកសាច់?
- តើអ្នកបូមទឹកញឹកញាប់ប៉ុនណា? តើស្រះគួរតែត្រូវការជម្រៅប៉ុន្មាន?
- តើទីតាំងរបស់អ្នកមានទំហំប៉ុនណា? តើអ្នកមានគម្រោងនឹងពង្រីកបន្ថែមនៅពេលក្រោយឬទេ ហើយអ្នកគួរគិតនៅពេលនេះដែរឬទេ?
- តើសណ្ឋានដីនៅទីតាំងរបស់អ្នកមានលក្ខណៈបែបណា? មិនមែនតែមួយកន្លែងទេ។
- តើទឹកដែលប្រើសម្រាប់បូមបញ្ចូលស្រះមានប្រភពមកពីណា?
- តើទឹកនឹងហូរទៅទីណានៅពេលមានទឹកជំនន់ ឬក៏នៅពេលបង្ហូរទឹកចេញពីស្រះ? ទឹកដែលយកមកប្រើនោះមកពីណា ហូរមក ឬបង្ហូរចូលស្រះ?
- តើអ្នកនឹងប្រមូលផលត្រីដោយរបៀបណា? តើអ្នកនឹងប្រមូលផលដោយដឹកជញ្ជូនវាតាមរថយន្ត ឬប្រមូលផលក្នុងបរិមាណតិចតួចដោយប្រើដៃ? ប្រសិនបើអ្នកមានគម្រោងដឹកវាដោយប្រើប្រាស់រថយន្ត គួរតែរៀបចំកន្លែងឬផ្លូវដែលអាចឱ្យរថយន្តចូលទៅដល់។
- តើអ្នកនឹងលក់អាចម៍ដីនោះឬទុកវានៅទីនោះ?
- តើទីតាំងរបស់អ្នកអាចនឹងលិចទឹកដែរឬទេ? នៅពេលដែលមានទឹកជំនន់តើទឹកមានកម្ពស់ប៉ុន្មាន?
- តើអ្នកមានបានសិក្សាសណ្ឋានជម្រាលដីដើម្បីដឹងពីកម្ពស់ដីដែរឬទេ? ជាពិសេស ប្រសិនបើទីតាំងនោះមានស្រះច្រើន តើអ្នកបានរៀបចំផែនការសិក្សាអំពីប្រព័ន្ធលំហូរទឹកដោយទំនាញឬទេ?

២. អ្នកត្រូវដឹងអំពីគុណភាពទឹកដែលនឹងយកមកប្រើ ឬក៏យកទឹកនោះមកធ្វើតេស្តពិនិត្យគុណភាពដោយផ្ទាល់។ តើអ្វីដែលយើងត្រូវធ្វើតេស្តពិនិត្យអំពីគុណភាពទឹកនោះ? (ប្រហែលជានៅក្នុងផ្នែកនៃការគ្រប់គ្រងទឹក)។

សារធាតុទាំងនេះនឹងជះឥទ្ធិពលដល់ផលិតកម្មត្រីដូចជា៖ ភាពរឹងនៃទឹកសរុប អាល់កាឡាំងសរុប ប៉េហាស់(pH) និងកម្រិតអុកស៊ីសែនរលាយក្នុងទឹក។ សារធាតុផ្សេងទៀតមានដូចជា៖ អាសូត និងផូស្វ័រ គឺត្រូវប្រែប្រួលខ្លាំងនៅអំឡុងពេលចិញ្ចឹម ដូច្នេះល្អិកណាសារធាតុទាំងនោះមិនមានកំហាប់ខ្ពស់នៅពេលចាប់ផ្តើមនៃវគ្គផលិតកម្មថ្មី នោះអ្នកក៏មិនត្រូវការធ្វើតេស្តនោះដែរ (គួរតែធ្វើការសម្រេចចិត្ត ប្រសិនបើយើងត្រូវការការណែនាំពីការតេស្តគុណភាពទឹក)

ចំណុចដែលអាចប៉ះពាល់ដល់សុវត្ថិភាពចំណីអាហារមានដូចជា៖
លោហៈធ្ងន់មានដូចជា បារត សំណ កាត់ម្ញូម អាសេនិច។ អាសេនិចត្រូវបានគេចាប់អារម្មណ៍ និងកត់សម្គាល់ ហើយវាអាចមានកម្រិតខ្ពស់នៅក្នុងតំបន់ដីសណ្តរទន្លេមេគង្គ។

៣. ពិនិត្យមើលគុណភាពដី ប្រសិនបើមានខ្សាច់ច្រើន យើងប្រហែលជាត្រូវការទ្រនាប់ទ្រាប់ស្រះ។ ដីដែលមានលាយដីឥដ្ឋប្រហែល១៥ភាគរយ ល្អសម្រាប់ស្រះដែលអាចផ្ទុកទឹកបានល្អ តែដីត្រូវបង្ហាប់វាឱ្យបានណែនល្អ។ ប្រសិនបើមានល្បាយដីឥដ្ឋច្រើន អាចជាបញ្ហា។ ដីឥដ្ឋច្រើនមានន័យថាដីអាចនឹងសឹកហូរច្រោះនៅពេលមានទឹកហូរឬធ្វើឱ្យក្រហូង។ ដីឥដ្ឋនេះវាក៏អាចនឹងធ្វើឱ្យមានកករច្រើន (មានដីនៅក្នុងទឹក) នៅពេលខ្លះ។ ប្រភេទដីឥដ្ឋខ្លះនឹងប្រេះបែកជាងប្រភេទដីឥដ្ឋផ្សេងទៀត ហើយវាអាចបណ្តាលឱ្យមានការលេចជ្រាបច្រើន ហើយបាក់ទំនប់។ ការលាយច្របល់ល្បាយដីចូលគ្នាគឺជាការប្រសើរ។ ដីគួរមានល្បាយដីឥដ្ឋចន្លោះពី១៥ទៅ៥០ភាគរយ។

ការតេស្តដីមួយចំនួនដែលជាទូទៅត្រូវការឱ្យយកបរិមាណល្បាយដីឥដ្ឋច្រើន។ របៀបធ្វើតេស្តដីដែលល្អ មុនពេលសាងសង់ស្រះ គឺយកដីពូតជាដុំរាងមូលហើយបន្ទាប់មករក្សាឱ្យវាស្ងួត។ ប៉ុន្មានថ្ងៃក្រោយមក ប្រសិនបើវានៅរក្សាទម្រង់វាដដែល ដោយមិនប្រេះ នោះបង្ហាញថាវាល្អសម្រាប់ការជីកស្រះ។

## ការបង្ហាញ

### ជំហានក្នុងការសាងសង់ស្រះ

បោះបង្គោលស្ទឹងជ្រើសរើសទីតាំង

១. សម្អាតកំទេចកំទីរុក្ខជាតិនិងដីស្រទាប់លើ ដែលជាផ្ទៃត្រូវជីកស្រះ។ ដីស្រទាប់លើគួរទុកដើម្បីទប់ភ្លឺស្រះនៅពេលដែលរួចរាល់ ដូច្នេះស្មៅអាចលូតលាស់លឿន។
២. បន្ទាប់ពីសម្អាតរួច បោះបង្គោលស្ទឹងកំណត់ទីតាំងស្រះ។
៣. ហើយក៏គួរតែបោះបង្គោលស្ទឹងកន្លែងណា ដើម្បីចាប់ផ្តើមជីកស្រះ។ ទីតាំងបោះបង្គោលស្ទឹង ជាទូទៅគឺតូចជាងទំហំកំណត់របស់ស្រះ ហើយត្រូវនឹងទំហំពិតប្រាកដនៃបាតស្រះ។ ជៀសវាងការជីកដីហើយបន្ទាប់មកត្រូវចាក់ដីវិញនៅកន្លែងដដែលដោយការយកដីពីកន្លែងផ្សេងមកចាក់បំពេញ (អស់ដីច្រើន)។



រូបភាព៖ ការវាស់វែង និងបោះបង្គោលស្នឹង

**ចំណាំ៖** បោះបង្គោលស្នឹងនៅទីតាំងស្រះ ជារឿយៗត្រូវគ្រឿងចក្រកិនពន្លិចបាត់ ដូចនេះការដាក់សញ្ញាសំគាល់គួរប្រើជាគោលដើម្បីផ្ទៀតផ្ទាត់ទីតាំងបង្គោលស្នឹងដែលជាកន្លែងត្រូវជីកស្រះ។ វិធីមួយគឺបោះបង្គោលស្នឹងឱ្យបានល្អនៅខាងក្រៅទីតាំងជីកដែលងាយឱ្យអ្នកជីកមើលឃើញព្រំក្នុងទីតាំងជីក។

**ឧទាហរណ៍**

មនុស្សមួយចំនួនបានប្រើពណ៌ខុសៗគ្នាបាញ់លើដីដើម្បីធ្វើជាខ្សែកំណត់ទីតាំងចាប់ផ្តើមសាងសង់ស្រះ។ នៅពេលដែលស្រះបានគូសវាសកំណត់ត្រឹមត្រូវរួចរាល់ហើយ ការជីកត្រូវបានចាប់ផ្តើម ។

***ទីតាំងគួរតែត្រូវបានបោះស្នឹងកំណត់ ហើយរៀបចំពិភាក្សាអំពីផែនការឱ្យបានយល់ច្បាស់លាស់ជាមុនសិនរវាងអ្នកប្រើគ្រឿងចក្រជីកនិងម្ចាស់ស្រះ។ ដូច្នេះហើយ ដីមិនត្រូវបានជីកកកាយច្រើនដងនៅទីតាំងដដែលទេ។ ការជីកដីច្រើនដងមានតម្លៃថ្លៃ ហើយប្រសិនបើវាត្រូវបានផ្លាស់ប្តូរពីចំណុច A ដល់ចំណុច B ហើយបន្ទាប់មកចំណុច B ដល់ចំណុច C ហើយបន្ទាប់មកពីចំណុច C ដល់ចំណុច D អ្នកនឹងឃើញថាវានឹងកើនតម្លៃដើមប៉ុនណាហើយ។

៤. អំឡុងពេលការជីកស្រះ អ្នកគួរធ្វើការពិចារណាលើរដូវកាល អាកាសធាតុ និងចំណុចមួយចំនួនដែលចាំបាច់ត្រូវធ្វើឧទាហរណ៍ភ្លៀងឬទឹកជំនន់។ ជារៀងរាល់ថ្ងៃ ប្រតិបត្តិករគួរប្រមើលមើលអំពីភ្លៀងដែលអាចកើតឡើងក្នុងពេលយប់។ ប្រសិនបើពួកគេទុកគ្រឿងចក្រចោលនៅក្នុងបាតស្រះ តើវានឹងជន់លិចដែរឬទេ? តើពួកគេប្រាកដដែរទេ? អ្នកព្យាករណ៍អាកាសធាតុមិនមែនព្យាករណ៍ត្រូវគ្រប់ពេលទេ។

៥. ការចាក់ដីបំពេញណាដែលបានគ្រោងគឺត្រូវធ្វើការបង្ហាប់ដីឱ្យបានល្អ។ ប្រសិនបើដីស្ងួតឬសើមពេកវាពិបាកក្នុងការបង្ហាប់ឱ្យបានណែនល្អ (ដីត្រូវមានសំណើមចន្លោះពី១៤-១៧ភាគរយ។ សូមតេស្តមើលសំណើមដី)។ ការបង្ហាប់ដីគួរតែត្រូវបង្ហាប់ជាស្រទាប់ដែលកម្រាស់ប្រហែល១៥សង់ទីម៉ែត្រ ហើយបង្ហាប់ឱ្យនៅត្រឹម១០សង់ទីម៉ែត្រ ឬតិចជាងនេះ។

## លក្ខខណ្ឌសម្រាប់ស្រះត្រីឆ្ពិននិងស្រះត្រីទីឡាព្យា និងត្រីសផ្សេងទៀត

ពន្លឺថ្ងៃមានតួនាទីយ៉ាងសំខាន់សម្រាប់គុណភាពទឹកនិងផលិតភាពរបស់ស្រះ។ ដូច្នេះស្រះជ្រៅដែលបង្កើតឡើងសម្រាប់ត្រីខ្មៅមិនដំណើរការល្អសម្រាប់ត្រីសទេ។

ស្រះមានទឹកជ្រៅភាគច្រើននឹងធីតផ្នែកក្រោមចាប់ពីជម្រៅមួយម៉ែត្រដំបូងចុះក្រោម។ ដូច្នេះការផលិតអុកស៊ីសែនបានតិចតួចណាស់ គឺមានតែការស្រូបយកអុកស៊ីសែន។ ដូច្នេះប្រសិនបើស្រទាប់ទឹកត្រូវបានលាយគ្នារវាងផ្នែកលើនិងផ្នែកក្រោម វាទំនងជាបណ្តាលឱ្យកម្រិតអុកស៊ីសែនចុះទាបនៅក្នុងស្រះទាំងមូល ហើយត្រីអាចងាប់បាន។

## អាងប្រមូលផល (ហៅផងដែរថា "អាងចាប់")

អាងប្រមូលផលមានអត្ថប្រយោជន៍ណាស់សំរាប់ស្រះកូនត្រីម្យៅ និងស្រះថែបំប៉នកូនត្រីដែលមានការបង្ហូរទឹកញឹកញាប់។ ស្រះដែលមានការសាងសង់បានល្អហើយមានអាងប្រមូលផល អាចប្រមូលផលបានដោយគ្រាន់តែបង្ហូរស្រះនោះត្រីនឹងចូលទៅក្នុងអាងនោះ ហើយបន្ទាប់មកយើងអាចប្រមូលផលដោយកន្ត្រងដៃបាន។ នៅពេលប្រើអាងប្រមូលផលជាធម្មតាគ្មាននរណាម្នាក់ចូលក្នុងស្រះទេរហូតទាល់តែទឹកក្នុងស្រះហូរចេញអស់ហើយសល់តែទឹកក្នុងអាងប្រមូលផល។ មុនពេលបង្ហូរទឹកចេញពីស្រះ ស្រះអាចនឹងត្រូវគេអូសអួនម្តងដើម្បីប្រមូលយកត្រីមួយចំនួនធំមុន។

ក្រៅពីនេះទៀត ត្រូវប្រាកដថាអាងប្រមូលផលគ្មានភក់។ ប្រសិនបើអាងប្រមូលផលមានភក់ច្រើនពេក គឺត្រូវកើបប្រមូលយកភក់ចេញមុនពេលទឹកស្រករាក់ពេកដែលអាចធ្វើឱ្យត្រីស្រ្តេសបាន។

## លក្ខណៈមួយចំនួននៃការសាងសង់អាងប្រមូលផលដែលល្អ៖

- អាងប្រមូលផលត្រូវនៅឆ្ងាយពីជើងទេរស្រះ ដូច្នេះដីដែលសឹកហូរច្រោះពីជើងទេរមិនធ្លាក់ចូលអាងភ្លាមៗនោះទេ។
- បាតស្រះត្រូវមានជម្រាលទេរឆ្ពោះទៅអាងប្រមូលផលប្រហែល២ភាគរយ (ធ្លាក់ចុះ២ម៉ែត្ររៀងរាល់១០០ម៉ែត្រ)។
- ផ្នែកខាងនៃអាងប្រមូលផលគឺរាបស្មើជាមួយបាតស្រះ។
- ការបញ្ចូលទឹកចូលទៅក្នុងស្រះនៅត្រង់ចំណុចអាងប្រមូលផលដោយផ្ទាល់គឺមានលក្ខណៈអំណោយផលល្អ។ ខ្សែទឹកនេះអាចត្រូវប្រើសម្រាប់បង្ហូរទឹកបំពេញស្រះផងដែរ ដែលនឹងកាត់បន្ថយការច្រោះនៅបាតស្រះ ប្រសិនបើបញ្ចូលទឹកពីទុយោខាងលើភ្លឺស្រះ។ សូមកុំគិតថាយើងធ្វើបែបនេះអាចបណ្តាលឱ្យត្រីធ្លាក់ចូលអាង។ ត្រីមានទំនោរហែលបញ្រ្ចាស់ចរន្តទឹក ហើយមានតែត្រីដែលខ្សោយទេដែលអាចនឹងត្រូវបានធ្លាក់ចូលអាង។ អាងប្រមូលផលគឺជាប្រភពទឹកដែលនឹងទាក់ទាញត្រីផងដែរ។
- អាងប្រមូលផលគួរតែជ្រៅល្មម ដើម្បីអាចងាយប្រមូលផលត្រីដោយប្រើកន្ត្រងដួស។ វារីវប្បករភាគច្រើនដឹកទំហំអាងប្រមូលផលរបស់ពួកគេដោយផ្អែកលើខ្នាតនៃកន្ត្រងដួសដែលពួកគេនឹងប្រើ។

- អាងប្រមូលផលក៏អាចដើរតួជាកន្លែងសម្រាប់ដំឡើងម៉ាស៊ីនបូមទឹកចេញពីស្រះផងដែរ ទោះជាយ៉ាងណាក៏ដោយ ត្រូវពិនិត្យម៉ាស៊ីនបូមទឹកឱ្យបានល្អ ដើម្បីចៀសវាងបូមទឹកដោយត្រីចេញពីស្រះ។
- អាងប្រមូលផលភាគច្រើនចាក់បាតបេតុងនិងបន្ទះបេតុងឬឈើនៅជញ្ជាំងខាង ហើយគួរតែមានជម្រៅពី ៣០ ទៅ ៥០ សង់ទីម៉ែត្រ ហើយគ្របដណ្តប់លើផ្ទៃស្រះពី ១ ទៅ ៣ភាគរយ ប្រសិនបើមិនមានប្រភពទឹកសាបចូលអាង។ អាងអាចតូចជាងនេះ ប្រសិនបើមានប្រភពទឹក ដែលបង្ហូរតាមអាងប្រមូលផល ដើម្បីឱ្យត្រីមានជីវិតនិងមានលក្ខខណ្ឌល្អ។

**ឧទាហរណ៍នៃការសាងសង់អាងប្រមូលផល**

អាងប្រមូលផលនេះមានចំងាយ១ម៉ែត្រពីជើងទេរ និងស្ថិតនៅចំណុចដែលជ្រៅបំផុត។ បាតស្រះត្រូវទេរទៅរកអាងប្រមូលផលគ្រប់ជ្រុងទាំងអស់។ បរិវេណអាងប្រមូលផលត្រូវបានជីកមុនហើយចាក់បេតុង។ បន្ទាប់មកអាងទឹកត្រូវបានដំឡើងនៅលើផ្ទាំងបេតុង។ សូមចំណាំ ប្រព័ន្ធទឹកចូលស្រះគួរតែនៅទិសទល់មុខគ្នានឹងទុយោបញ្ឈរដែលជាចំនុចបង្ហូរទឹកចេញ។ នេះគឺល្អ ប៉ុន្តែទឹកគួរតែចូលតាមបាតក្រោម ហើយមិនមែនតាមចំហៀងទេ។ វាងាយស្រួលក្នុងការគ្រប់គ្រងប្រព័ន្ធនៅបាតក្រោម ប្រសិនបើទុយោមានសំណាញ់ឬតម្រងការពារ។

អាងប្រមូលផលនេះគួរមានទ្រនាប់ស៊ីម៉ងត៍ការពារនៅជុំវិញតែមខាងក្រៅដែលជាគំនិតល្អ ព្រោះវាការពារការច្រោះដីបាតស្រះ នៅក្បែរអាងប្រមូលផលដែលអាចបណ្តាលឱ្យត្រីតូចៗជាប់នឹងរន្ធឬប្រហោងជញ្ជាំងអាងនិងមិនអាចចូលទៅក្នុងអាងប្រមូលផល។ អាងប្រមូលផលនេះមានទំហំដែលអាចប្រើកន្ត្រងដួសពីរ ក្នុងពេលតែមួយ ដើម្បីយកត្រីដែលនៅសេសសល់ទាំងអស់ក្នុងការប្រមូលផលចុងក្រោយ។ ប្រសិនបើយើងមានប្រព័ន្ធទឹកចូលទៅក្នុងអាងប្រមូលផលនោះ យើងក៏អាចប្រើអាងនោះជាកន្លែងស្តុកត្រីបណ្តោះអាសន្នបាន តែត្រូវការពារពីបក្សីនិងរក្សាកម្រិតអុកស៊ីសែនឱ្យបានល្អ។

អាងប្រមូលផលតូចនៅក្នុងស្រះបំប៉នកូនត្រីសាងសង់នៅជិតជើងប្រឡាយ ប៉ុន្តែដីត្រូវបង្ហាប់ឱ្យបានល្អ ដូច្នេះមិនមានដីច្រោះ ចូលក្នុងអាងច្រើនទេ។



រូបភាព៖ ការសាងសង់អាងប្រមូលផល



រូបភាព៖ ការរៀបចំប្រព័ន្ធបង្ហូររបស់អាងប្រមូលផល

# មេរៀន ៖

# ការរៀបចំស្រះចិញ្ចឹមត្រី

# ការរៀបចំស្រះចិញ្ចឹមត្រី

ការរៀបចំស្រះមួយបានល្អសម្រាប់វារីវប្បកម្មវានឹងជួយជីវភាពកាន់តែប្រសើរ និងផលិតកម្មទទួលជោគជ័យ។ ការរៀបចំស្រះបានល្អនឹងជួយកាត់បន្ថយអត្រាងាប់របស់ត្រី ជួយកែលម្អការគ្រប់គ្រងស្រះនិងសុខភាពត្រី ជួយកែលម្អគុណភាពទឹក ជួយកាត់បន្ថយការបាត់បង់ទឹកដោយសាររំហួត និងជួយបង្កើនប្រសិទ្ធភាពប្រមូលផល ព្រមទាំងជួយបង្កើនទិន្នផលរបស់ស្រះផងដែរ។

## ការរៀបចំបាតស្រះ និងភ្លឺស្រះ

ត្រូវធ្វើឱ្យប្រាកដថា បាតស្រះមិនមានភក់ច្រើន (មិនលើស១០សង់ទីម៉ែត្រ) និងការសំណល់ ស្អុយរលួយ ហើយរាបស្មើ និងមានរាងទេរទៅជ្រុងណាមួយនៃស្រះ។ បាតស្រះគួរតែរៀបចំឱ្យរាបស្មើ ដើម្បីងាយស្រួលអូសអួន ហើយរាងទេររបស់ស្រះ ងាយស្រួលបូមទឹកចេញ។ ចុងក្រោយនៅសល់ទឹកមួយផ្នែកនៅបាតស្រះ ដែលសម្រួលដល់ការបូមឬបង្ហូរទឹកឱ្យអស់ពីបាតស្រះ។

បាតស្រះដែលមិនរាបស្មើគឺមានកន្លែងដក់ទឹកជាច្រើន គួរតែរៀបចំឱ្យបានរាបស្មើដើម្បីងាយស្រួលប្រមូលផលដោយប្រសិទ្ធភាព។ ដូច្នេះវានឹងជួយកាត់បន្ថយពេលវេលាក្នុងការអូសអួន ឬបង់សំណាញ់ចាប់ត្រីក្នុងស្រះ។ នេះក៏ជាពេលល្អដើម្បីស្តាររៀបចំភ្លឺស្រះក្បែរមាត់ស្រះផងដែរ។ រៀបចំជួសជុលកំហូង រន្ធ និងប្រហោងនានានៅតាមគែមស្រះ និងកន្លែងណាដែលមានទឹកដក់។ ធ្វើការជួសជុលរៀបចំស្រះនៅក្នុងពេលដែលស្រះរីងស្ងួត គឺងាយជួសជុលរៀបចំស្រះបានមាំមួន។

ជានិច្ចកាលត្រូវតែថៃទាំគិតគូរបញ្ហានានានៅបាតស្រះ មុនពេលបូមទឹកចូលស្រះ។ បញ្ហាទាំងនោះរួមមានឧបករណ៍សម្ភារៈដែលទុកចោលក្នុងស្រះ និងសម្ភារៈសំណង់ផ្សេងៗ ពិសេសគ្រឿងដែកមុតស្រួច ដូចជាសសៃដែកស្រួចជាដើម។ របស់របរផ្សេងទៀតក៏គួរតែយកចេញនៅពេលនោះ ដូចជាគល់ឈើ ដុំថ្ម និងកំទេចអំបែងកែវ។

## សកម្មភាពមុនពេលបញ្ចូលទឹកក្នុងស្រះ

### ១. ការប្រមូលរុក្ខជាតិចេញពីស្រះ

មុនពេលបញ្ចូលទឹកទៅក្នុងស្រះ វារីវប្បករគួរតែប្រមូលរុក្ខជាតិដុះនៅបាតស្រះចេញពីបាតស្រះឱ្យអស់។ ចំពោះស្រះរាក់ៗ បើសិនជាមិនយករុក្ខជាតិចេញទេ រុក្ខជាតិទាំងនោះនឹងបន្តដុះឡើងវិញ នៅពេលយើងបញ្ចូលទឹករួច រុក្ខជាតិដែលដុះចាក់ឫសនៅក្នុងស្រះ នឹងរារាំងការរីកដុះដាលរបស់ពពួករុក្ខជាតិតូចៗដែលដុះអណ្តែតក្នុងទឹក (ហ្វីតូប្លង់តុង) ដែលមានតួនាទីផលិតអុកស៊ីសែនសម្រាប់ត្រីចិញ្ចឹម។ ចំពោះស្រះជ្រៅ (ជ្រៅជាង២ម៉ែត្រ) រុក្ខជាតិនៅបាតស្រះនឹងងាប់បន្ទាប់ពីបញ្ចូលទឹកចូលក្នុងស្រះ ហើយរុក្ខជាតិងាប់នេះនឹងធ្វើឱ្យបរិមាណអុកស៊ីសែននៅក្នុងស្រះធ្លាក់ចុះ។

## ២. ការហាលបាតស្រះ

ហាលស្រះទាំងមូលរហូតដល់បាតស្រះក្លាយជាដីបែកក្រហែង និងជាន់លើមិនស្រុត។ នៅពេលដីប្រេះបែកក្រហែង ពពួកបាត់តេរីនឹងបំបែកជាតុចញ្ចឹមចូលក្នុងដីដែលបានមកពីកាកសំណល់ចំណីនិងលាមកត្រី។




រូបភាព៖ បាតស្រះដែលប្រេះ

ការហាលស្រះនឹងជួយកាត់បន្ថយភ្នាក់ងារបង្កជំងឺត្រី និងលុបបំបាត់ពូកត្រីកាចនិងពួកសត្វល្អិតផងដែរ។ បើសិនជាមានកន្លែងទឹកដក់ ឬផ្នែកខ្លះនៃស្រះមិនបានហាលឱ្យស្ងួត ជាការណែនាំត្រូវប្រើប្រាស់កំបោរដើម្បីសម្លាប់ត្រី និងសត្វល្អិតដែលនៅសល់ក្នុងស្រះ។ ដើម្បីសម្លាប់មេរោគដោយប្រសិទ្ធភាពដែលស្ថិតនៅផ្នែកខ្លះនៃបាតស្រះ ដោយសារមិនបានហាលថ្ងៃឱ្យស្ងួត យើងត្រូវប្រើប្រាស់កំបោរងាប់ឬកំបោររស់ ក្នុងកម្រិតពី២០០ក្រាមទៅ៣០០ក្រាមក្នុង១ម៉ែត្រការ៉េ នៃផ្ទៃសើម។ ដើម្បីរក្សាសុវត្ថិភាព ត្រូវពាក់វ៉ែនតាការពារភ្នែក ពាក់ម៉ាស់ និងពាក់ស្រោមដៃក្នុងពេលអនុវត្តការងារ។ បន្ទាប់ពីបាចកំបោរពេញស្រះរួចហើយ ត្រូវទុកស្រះចោលរយៈពេល១០ថ្ងៃឬយូរជាងនេះ ដើម្បីឱ្យកម្រិត ប៉េហាស់(pH) ធ្លាក់ចុះមកវិញ ហើយត្រូវពិនិត្យកម្រិតប៉េហាស់ (pH) មុនពេលលែងកូនត្រីចូលស្រះ។

## ៣. ការវាស់ប៉េហាស់ (pH) ដី

វារីវប្បករគួរតែធ្វើតេស្តវាស់ប៉េហាស់ដីនៅខណៈពេលហាលស្រះ។ បើសិនជាកម្រិតប៉េហាស់ដីទាបជាង៧ ដូចនេះស្រះគួរតែប្រើកំបោរ គឺកំបោរកសិកម្ម។ បើសិនជាមិនមានកំបោរកសិកម្មទេ អាចប្រើកំបោរងាប់ឬកំបោររស់ក៏បានដែរ ប៉ុន្តែវាមានហានិភ័យដោយសារកម្រិតប៉េហាស់ទឹកអាចនឹងកើនឡើងខ្ពស់ផងដែរ ហើយអាចសម្លាប់ត្រីបាន ប្រសិនបើលែងត្រីចូលស្រះរួចហើយនោះ។ ដូច្នេះត្រូវតែប្រុងប្រយ័ត្នខ្ពស់ក្នុងការត្រួតពិនិត្យប៉េហាស់ទឹកមុនពេលលែងត្រីចូលក្នុងស្រះ។



រូបភាព៖ ឧបករណ៍វាស់ប៉េហាស

## ៤. ការបាចកំបោរ

មានហេតុផល២ចំពោះការបាចកំបោរក្នុងស្រះ៖

ហេតុផលទី១៖ ដើម្បីបង្កើនកម្រិតប៉េហាស់ដីនិងដើម្បីកែតម្រូវសារជាតុគីមីរបស់ទឹកដែលធ្វើឱ្យដីអាចបំបែកខ្លួនបានល្អ ហើយកម្រិតប៉េហាស់ទឹកមិនមានការប្រែប្រួលច្រើនពេកទេ។ នៅក្នុងគោលបំណងនេះ កំបោរកសិកម្មអាចត្រូវបានគេយកមកប្រើប្រាស់ជាញឹកញាប់។

ហេតុផលទី២៖ ដើម្បីសម្លាប់មេរោគក្នុងស្រះ (រាប់ទាំងការសម្លាប់ត្រី និងប្រភេទសត្វស៊ីសាច់និងស៊ីត្រីជាអាហារ)។



រូបភាព៖ កំបោរកសិកម្ម

### ៥. ជីសរីរាង្គ

ជីសរីរាង្គមានសារសំខាន់ណាស់សម្រាប់ស្រះថ្មីព្រោះវាជួយឱ្យមានការលូតលាស់បាត់តេរីល្អៗនិងជួយដោះស្រាយបញ្ហាភក់នៅក្នុងទឹកនៅពេលស្រះទើបបញ្ចូលទឹកដំបូង។ ចំពោះស្រះចាស់មិនត្រូវការជីសរីរាង្គទេ ដោយសារមានសារធាតុសរីរាង្គគ្រប់គ្រាន់នៅសេសសល់ក្នុងបាតស្រះពីការចិញ្ចឹមក្នុងវគ្គមុនៗ។ សម្រាប់ស្រះថ្មី ត្រូវប្រើពី ១០០ ទៅ ២០០ក្រាមក្នុង១ម៉ែត្រការ៉េ សម្រាប់ជីលាមកសត្វ ឬក៏សារធាតុសរីរាង្គដទៃទៀតដែលមានប្រយោជន៍ ជាពិសេសសម្រាប់ស្រះចិញ្ចឹមត្រីឆ្អិនដែលត្រូវជួយឱ្យទឹកក្នុងស្រះប្រែពណ៌ជាបៃតងខ្ចីសម្រាប់បង្កើនចំណីធម្មជាតិមួយចំនួន ។

### ៦. ការរៀបចំរបងព័ទ្ធជុំវិញ

នៅពេលលែងប្រភេទត្រីដែលអាចដកដង្ហើមក្នុងបរិយាកាសបាន ដូចជាត្រីអណ្ដែងនិងត្រីក្រាញ់ វាអាចនឹងមានហានិភ័យមួយចំនួនដោយ ពពួកត្រីទាំងនោះនឹងផ្លាស់ទីចេញពីស្រះនៅពេលមានភ្លៀងខ្លាំង។

ប្រសិនបើជាស្រះចិញ្ចឹមនៅក្បែរតំបន់ដីសើម ឬវាលស្រែ ពពួកត្រីកាចដែលអាចដកដង្ហើមក្នុងបរិយាកាស (ត្រីរ៉ស់ ឬត្រីឆ្ដោ) ទាំងនោះអាចនឹងផ្លាស់ទីចូលទៅក្នុងស្រះចិញ្ចឹមត្រីបាន។ វិធីមួយដើម្បីត្រួតពិនិត្យការផ្លាស់ទីរបស់ត្រីទាំងនោះ យើងត្រូវធ្វើរបងទាបៗព័ទ្ធជុំវិញស្រះ។ របងធ្វើពីប្រភេទសំណាញ់ញឹកមានកំពស់ប្រហែល១ម៉ែត្រ ដែលមានជើងសំណាញ់កប់ចូលក្នុងដីប្រមាណ១តឹក (១០សង់ទីម៉ែត្រ) ។

### ៧. ការបញ្ចូលទឹកក្នុងស្រះទឹក

ប្រសិនបើយើងចាប់ផ្ដើមបញ្ចូលទឹកដែលមានគុណភាពមិនល្អ ដូចនេះយើងមិនអាចទទួលបានផលល្អឡើយ។ តើទឹកដែលមានគុណភាពមិនល្អជាទឹកដូចម្ដេច?

- ទឹកមានភក់៖ ភក់នេះយើងអាចកែលម្អឱ្យប្រសើរបាន បន្ទាប់ពីបញ្ចូលទឹករួចហើយ តែត្រូវរង់ចាំពេលមួយរយៈសិន។ ការដាក់ជីក្នុងស្រះក៏អាចជាជំនួយសម្អាតភក់នៅក្នុងទឹកផងដែរ ដោយសាររុក្ខជាតិប្លង់តុង (ហ្វីតូប្លង់តុង) និងបាក់តេរី ជារឿយៗអាចជួយសម្អាតកករដីដែលនៅអណ្ដែតក្នុងទឹកបាន។
- ទឹកមានកម្រិតអុកស៊ីសែនទាប៖ បើសិនជាបញ្ហានេះតែមួយមុខ វារីវប្បករអាចដោះស្រាយបានដោយខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទទឹកនេះមិនគួរត្រូវបានយកមកប្រើប្រាស់ ជាពិសេសសម្រាប់ករណីសង្គ្រោះបន្ទាន់នៅពេលទឹក្នុងស្រះមានកម្រិតអុកស៊ីសែនទាប ក្នុងអំឡុងពេលចិញ្ចឹមត្រីនោះឡើយ។
- ទឹកមានសារធាតុគីមី និងថ្នាំសម្លាប់សត្វល្អិតផ្សេងៗ៖ បញ្ហានេះមិនអាចកែលម្អដោយងាយៗនោះឡើយ។ ប្រភេទទឹកដែលគុណភាពបែបនោះគួរតែជៀសវាង ។
- ទឹកកខ្វក់៖ ប្រភេទទឹកនេះសំដៅលើទឹកស្អុយដែលមានភ្នាក់ងារបង្កជំងឺ ហើយវាមានតម្លៃខ្ពស់ក្នុងការកែលម្អគុណភាពទឹក និងតម្រូវឱ្យមានការសម្លាប់មេរោគមុនបញ្ចូលទៅក្នុងស្រះ។

### ៨. ការលែងត្រី

បន្ទាប់ពីបញ្ចូលទឹកឬក៏ក្នុងករណីមានទឹកក្នុងស្រះជិតពេញនោះ យើងអាចលែងកូនត្រីបាន។ បើសិនជាវារីវប្បកររង់ចាំយូរពេក កូនក្អុកឬក៏ពពួកវារីសត្វស៊ីសាច់ជាអាហារផ្សេងទៀតនឹងមានវត្តមានក្នុងស្រះ។ វារីវប្បករខ្លះមិនអាចលែងត្រីបានភ្លាមៗឡើយ។

វារីវប្បករទាំងនោះគួរពិចារណាការលែងកូនត្រីធំៗជាងនេះ ឬក៏បំប៉នកូនត្រីតូចៗទាំងនោះមួយរយៈសិនមុនពេលលែងកូនត្រីទាំងនោះចូលក្នុងស្រះធំ ដែលមានពពួកសត្វចង្រៃនិងពួកវារីសត្វដែលស៊ីសាច់ជាអាហារនៅក្នុងស្រះរួចទៅហើយ។

## សកម្មភាពក្រោយការបញ្ចូលទឹកក្នុងស្រះ

ជាទូទៅ មិនឱ្យមានពពួកវារីរុក្ខជាតិនៅក្នុងស្រះចិញ្ចឹមត្រីឡើយ។ អ្នកបច្ចេកទេសវារីវប្បកម្មខ្លះផ្តល់យោបល់ឱ្យដាក់កំប្លោកមួយចំនួនទៅក្នុងស្រះ។ ខាងក្រោមជាហេតុផលមួយចំនួនចំពោះការរក្សាទុកវារីរុក្ខជាតិក្នុងស្រះដែលជាមូលហេតុមិនល្អ៖

- ពពួកវារីរុក្ខជាតិដែលដុះអណ្តែតលើផ្ទៃទឹកក្នុងស្រះនឹងមិនបង្កើតអុកស៊ីសែនចូលក្នុងទឹកបានទេ។ ពួកវានឹងបង្កឱ្យកម្រិតអុកស៊ីសែននៅក្នុងទឹកធ្លាក់ចុះទាប។ នៅពេលឫស ឬរុក្ខជាតិទាំងនោះងាប់ ពួកវានឹងធ្លាក់ទៅបាតស្រះ និងរលួយ ហើយត្រូវការអុកស៊ីសែនដើម្បីបំបែកធាតុ។ រុក្ខជាតិទាំងនោះនឹងរាំងខ្ទប់ពន្លឺថ្ងៃសម្រាប់ការលូតលាស់របស់រុក្ខជាតិប្លង់តុងដែលមានតួនាទីផលិតអុកស៊ីសែននៅក្នុងទឹកស្រះ ។
- កំប្លោកនិងវារីរុក្ខជាតិដទៃទៀតដែលមានស្លឹកដុះផុតពីទឹកនឹងបង្កឱ្យមានការរំហួតទឹកពីក្នុងស្រះច្រើនជាងស្រះដែលគ្មានវារីរុក្ខជាតិនៅក្នុងស្រះ ពីព្រោះស្លឹកទាំងនោះបឺតទឹកបំលែងជាកំណាកញើសចូលទៅក្នុងបរិយាកាស។ ការបាត់បង់ទឹកតាមរយៈកំណាកញើសចូលក្នុងបរិយាកាសតាមរយៈស្លឹកកំប្លោក និងស្លឹករុក្ខជាតិផ្សេងៗដែលគ្របដណ្តប់ដោយស្លឹកលើផ្ទៃទឹកដ៏ធំដែលអាចបាត់បង់ទឹកជិតពីរដងដោយសារតែការរំហួតទឹកចេញពីផ្ទៃទឹកក្នុងស្រះ។
- អ្នកខ្លះយល់ថា រុក្ខជាតិនឹងជួយស្រូបយកសារធាតុចិញ្ចឹមដែលលើស។ នេះគឺជាការពិត ក៏ប៉ុន្តែបើសិនជារុក្ខជាតិទាំងនោះត្រូវបានប្រមូលចេញពីស្រះជាប្រចាំ ដូចជាប្រមូលយកចេញរៀងរាល់ពីរថ្ងៃម្តង។ រុក្ខជាតិដែលបានប្រមូលយកចេញ បើសិនជាមិនអាចយកមកហូបបាន គួរតែយកមកធ្វើជាជីសរីរាង្គក្នុងសួនដំណាំ។
- អ្នកខ្លះទៀតគិតថា រុក្ខជាតិនឹងអាចជាម្លប់សម្រាប់ត្រីនិងរក្សាទឹកមិនឱ្យក្តៅពេក។ នេះប្រហែលជាការពិត ចំពោះហេតុផលខ្លះ ក៏ប៉ុន្តែគុណវិបត្តិនៃការបាត់បង់ទឹកតាមរយៈស្លឹករុក្ខជាតិទៅក្នុងបរិយាយកាស ទំនងជាធ្វើឱ្យកម្រិតអុកស៊ីសែនធ្លាក់ចុះ។ ដូច្នេះហើយ ការគ្របដណ្តប់ផ្ទៃទឹកត្រឹមតែ១០ទៅ១៥ភាគរយ មិនអាចជួយសីតុណ្ហភាពទឹកបានទេ។
- បើសិនជាវារីវប្បករចង់រក្សាទុករុក្ខជាតិមួយចំណែកនៃផ្ទៃស្រះ សម្រាប់ការប្រើប្រាស់ផ្ទាល់ ដូចនេះពួកគេគួរតែកម្រិតបរិមាណរុក្ខជាតិ និងយករុក្ខជាតិចេញជាប្រចាំ។ បើសិនជាទឹកស្រះចាប់ផ្តើមរាក់ ពួកគេគួរតែប្រមូលរុក្ខជាតិទាំងនោះចេញឱ្យអស់។



រូបភាព៖ រុក្ខជាតិទឹក (កំប្លោក) មួយចំនួនក្នុងស្រះ

## ការរៀបចំស្រះដែលមិនអាចបូមទឹកចេញអស់

ចំពោះស្រះដែលធ្លាប់ចិញ្ចឹមពីមុនម្តងរួចហើយ កត្តាដែលសំខាន់បំផុតគឺត្រូវធ្វើឱ្យប្រាកដថាមិនមានត្រីស្រែធម្មជាតិ ឬក៏ត្រីនៅសេសសល់ក្រោយការចិញ្ចឹម។ ត្រីជាច្រើនប្រភេទអាចនៅសល់ក្នុងរន្ធនៅបាតស្រះដែលវារីវប្បករគិតថាមិនមានត្រីនៅសេសសល់ បន្ទាប់មកពេលស្រះបញ្ចូលទឹករួចហើយ ត្រីទាំងនោះនឹងចេញមកដោយត្រៀមស៊ីកូនត្រីដែលវារីវប្បករទើបតែទិញនិងលែងក្នុងស្រះ។ តើត្រូវធ្វើដូចម្តេចដើម្បីធានាថាមិនមានត្រីសល់ក្នុងស្រះ? នៅពេលទឹកដក់នៅបាតស្រះតិចតួច ត្រូវប្រើកំបោរងាប់ឬកំបោររស់សម្អាតទឹកដែលនៅសេសសល់ដើម្បីឱ្យកម្រិតប៉េហាស់ឡើងដល់១២។ ចាប់ផ្តើមបញ្ចូលទឹកនៅថ្ងៃបន្ទាប់ ហើយត្រូវប្រាកដថា ប៉េហាស់ត្រូវបានត្រួតពិនិត្យមើលជាក់លាក់ មុនដាក់លែងកូនត្រីចូលស្រះ។ ការងារនេះត្រូវចំណាយពេល១០ថ្ងៃឬយូរជាងនេះ ដើម្បីឱ្យកម្រិតប៉េហាស់វិលត្រឡប់ធ្លាក់ចុះមកធម្មតាវិញ។



រូបភាព៖ ស្រះចិញ្ចឹមត្រីដែលមិនអាចបូមពង្រីងបាន

ទឹកដក់នៅសេសសល់តិចតួចនៅបាតស្រះ ត្រូវប្រើសារធាតុអ៊ីប៉ូក្លរីត (អាចរកបានពីឃ្លាំងផ្គត់ផ្គង់សម្ភារៈអាងហែលទឹក) ក្នុងអត្រាពី ២០ក្រាម ទៅ ៥០ក្រាមក្នុង១ម៉ែត្រការ៉េ។ ការងារនេះត្រូវប្រើពេលច្រើនជាង១ថ្ងៃដើម្បីបន្សាប អាស្រ័យលើកំហាប់សារធាតុអ៊ីប៉ូក្លរីតនោះ។ បន្ទាប់ពីការបញ្ចូលទឹកជាថ្មី សារធាតុក្លរីនក្នុងស្រះនឹងរលាយបាត់អស់ក្នុងរយៈពេល ២-៣ថ្ងៃ ក៏ប៉ុន្តែជានិច្ចកាលនិងជាការល្អត្រូវធ្វើតេស្តសាកល្បងដោយដាក់ត្រី ២-៣ក្បាលក្នុងធុងជាមួយនឹងទឹកស្រះ ដើម្បីប្រាកដថាទឹកស្រះមិនមានបញ្ហាអ្វីទេ។

ត្រូវរក្សាកម្រិតប៉េហាស់ទឹកស្រះឱ្យនៅត្រឹមប្រមាណ១២ឬលើសនេះ យ៉ាងហោចណាស់រយៈពេលពី ២-៣ម៉ោង។ ធ្វើដូច្នេះ វានឹងចំណាយទិញកំបោរអស់តិចជាង ខណៈដែលជម្រៅទឹកក្នុងស្រះនៅមានកម្រិតទាបមុនពេលបញ្ចូលទឹកជាថ្មី។ បន្ទាប់ពីការបញ្ចូលទឹកជាថ្មី កម្រិតប៉េហាស់ទឹកអាចឡើងខ្ពស់ណាស់ ហើយមិនគួរលែងត្រីចូលស្រះឡើយ។ វារីវប្បករត្រូវរង់ចាំកម្រិតប៉េហាស់ធ្លាក់ចុះមកត្រឹម៨,៥ ដែលជាធម្មតាត្រូវប្រើពេល ១០ថ្ងៃ។ ចំពោះកម្រិតប៉េហាស់ក្នុងស្រះ គួរត្រូវបានត្រួតពិនិត្យឱ្យជាក់លាក់មុនពេលលែងត្រី។

ជម្រើសជទៃទៀតសម្រាប់ការសម្លាប់មេរោគតំបន់ដីនៅសើម គឺត្រូវប្រើកាល់ស្យូមអ៊ីប៉ូក្លរីត ហើយដែលគេស្គាល់ថាជាតេស្តសាកល្បងកម្រិតខ្ពស់នៃអ៊ីប៉ូក្លរីត។ ជាធម្មតាកម្រិតប្រព្រឹត្តកម្មគឺចាប់ពី ២៥-៥០ក្រាម ក្នុង១ម៉ែត្រការ៉េត្រូវបានប្រើ។ សារធាតុនេះនឹងសម្លាប់ត្រីនិងពួកសត្វមំសាសីដែលនៅសេសសល់ក្នុងស្រះ ក៏ប៉ុន្តែវានឹងមិនអាចសម្លាប់អស់នៅក្នុងស្រះទាំងស្រុងបានទេ ជាពិសេសបើសិនជាដីនៅសើម។ សារធាតុនេះអាចប្រើបានចំនួន ៣-៤ដង ។

# មេរៀន ៖

# ការគ្រប់គ្រងទឹក

## ការគ្រប់គ្រងទឹក

### ប្រភពទឹក

១. **ទឹកភ្លៀងធ្លាក់ចូលស្រះដោយផ្ទាល់៖** នេះគឺជារឿង **"ដ៏ល្អ"** ដែលទឹកភ្លៀងមានលាយឡំជាមួយសារធាតុរ៉ែមួយចំនួននិងសារធាតុពុលតិចតួច ។

- ប៉េហាស់ទឹកភ្លៀងមានកម្រិតទាប (ទាបជាង៧)។
- ទឹកភ្លៀងមិនអាចបំពេញស្រះបានគ្រប់គ្រាន់នោះទេ។ វាអាស្រ័យលើបម្រែបម្រួលអាកាសធាតុ ជួនកាលមានទឹកច្រើនពេក ហើយពេលខ្លះទឹកតិចពេក ដែលពិបាកទាយត្រូវណាស់ ។
- ជាទឹកដែល "មិនគិតថ្លៃ" ។

២. **ការហូរច្រោះដោយទឹកភ្លៀង៖** វាកើតឡើងពេលភ្លៀងធ្លាក់នៅកន្លែងផ្សេងខាងក្រៅស្រះ (ហៅថាទីជម្រាល)។ ព្រោះទីតាំងស្រះស្ថិតនៅទាបជាងបរិវេណជុំវិញស្រះ ដូច្នេះវាបាននាំទឹកភ្លៀងខ្លះហូរចូលក្នុងស្រះ។ វារីវប្បករភាគច្រើនជីកស្រះជ្រៅៗ ជាវិធីសាស្ត្រដែលពួកគេអាចប្រមូលទឹកភ្លៀងហូរចូលស្រះនិងរក្សាទុកប្រើប្រាស់ក្នុងរដូវប្រាំង។



រូបភាព៖ ស្រះចិញ្ចឹមត្រីដែលប្រមូលទឹកភ្លៀងពីទីជម្រាល

- គុណភាពទឹកភ្លៀងដែលហូរចូលស្រះមានល្បាយកករដីដោយសារសកម្មភាពនានានៅលើផ្ទៃដី។ ការហូរច្រោះអាចមានលាយឡំលាមកសត្វឬកាកសំណល់របស់មនុស្ស ពិសេសក្នុងពេលមានទឹកជំនន់។

បើសិនជាទឹកភ្លៀងប្រមូលចូលស្រះជាប្រភេទទឹកលូតាមផ្ទៃដីវាអាចមានលាយឡំជាតិប្រេងនិងផលិតផលឥន្ធនៈដទៃទៀត រួមទាំងរបស់របរផ្សេងទៀតដែលកំពប់ធ្លាយតាមផ្លូវ។ ហើយបើទឹកមកពីតំបន់កសិកម្ម អាចនាំមកជាមួយល្បប់ដីនិង សំណល់សារធាតុគីមី ជាដើម។

- បរិមាណទឹកភ្លៀងប្រមូលផ្តុំ វាអាស្រ័យលើដង់ស៊ីតេទឹកភ្លៀង ភាពជោកជាំទឹកនៃដីពីមុន(ទឹកភ្លៀងពីមុន) លក្ខណៈសណ្ឋានជម្រាលដី និងប្រភេទរុក្ខជាតិ។
- ទឹកភ្លៀងជាធម្មតាតែងត្រូវគិតថា"មិនគិតថ្លៃឬមិនអស់ថ្លៃ" ក៏ប៉ុន្តែវារីវប្បករត្រូវថែទាំប្រឡាយតូចៗ សម្រាប់បង្វែរមុខទឹកហូរមួយចំនួនហូរចូលស្រះឱ្យបានល្អ។
- ការថែទាំត្រូវតែចាត់វិធានការឱ្យប្រាកដថា ក្នុងអំឡុងភ្លៀងខ្លាំង គឺមានទឹកច្រើនលើសលប់ ដើម្បីបង្វែរនាំទឹកចេញពីស្រះ ឬក៏បើកបង្ហៀរទឹកចេញពីប្រឡាយនៃប្រព័ន្ធស្រះដោយចៀសវាងការខូចខាតនិងបាត់បង់ត្រី។

**៣. ការបញ្ចូលទឹកផ្ទាល់ពីប្រឡាយ ឬអូរ ឬពីស្រះផ្សេង ឬដោយការបូម ឬដោយបង្ហូរចូលផ្ទាល់៖**

- ជាធម្មតាមានភាពងាយស្រួលត្រួតពិនិត្យដោយមានវ៉ាល់មួលបិទ បើក ឬទ្វារទឹក ឬបញ្ឈប់ការបូម។
- បើទោះជាការបង្ហូរទឹកចូលដោយ "មិនគិតថ្លៃ" ប៉ុន្តែក៏ត្រូវការថែទាំចង្អូរ ប្រឡាយ និងទ្វារទឹកដែរ។
- បើសិនជាប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រប្រហែលត្រូវការបង់ថ្លៃទឹក ដូច្នេះក៏ប្រើក្នុងកម្រិតបរិមាណកំណត់។
- គុណភាពទឹកអាស្រ័យលើប្រភពទឹក គេអាចគិតថាជាទឹកភ្លៀងដែលទាញយកទឹកពីទីជម្រាល។

**៤. ការបូមទឹកអណ្តូងផ្ទាល់ (ត្រូវការបូម)៖** ទឹកអណ្តូងមានកម្រិតជាតិរ៉ែខ្ពស់ និងលោហៈធ្ងន់ច្រើន ដូចជាអាសេនិច ដែលអាចបង្កអន្តរាយបាន។ អណ្តូងជ្រៅៗអាចមានកម្រិតឧស្ម័នកាបូនិចរលាយក្នុងទឹកខ្ពស់អាចសម្លាប់ត្រីបាន ឬក៏ធ្វើឱ្យត្រីស្ថិតក្នុងសភាពងងុយដេក ឬមិនសកម្មបាន។ ឧស្ម័នកាបូនិចនឹងត្រូវបំភាយចេញពីទឹកដោយប្រើរហាត់ទឹក ឬធ្វើទឹកឱ្យបាចសាចក្នុងខ្យល់ ជាពិសេសបើសិនប្រើទឹកអណ្តូងដោយផ្ទាល់ក្នុងកសិដ្ឋានភ្ញាស់បង្កាត់។ អណ្តូងនីមួយៗមានលក្ខណៈផ្ទាល់របស់វានៃ **"បរិមាណទឹកចេញ"** ដែលនឹងកំណត់បរិមាណទឹកអាចបូមបានក្នុងចន្លោះពេលណាមួយពិតប្រាកដ ។ ជាឧទាហរណ៍បើសិនអណ្តូងចេញបាន ១០ម៉ែត្រគូប (១០ ០០០លីត្រ) ក្នុងរយៈពេល១ម៉ោង ដូចនេះយើងត្រូវបូម ៥០០លីត្រ (០,៥ម៉ែត្រគូប) ក្នុងរយៈពេល១ម៉ោង ដែលនឹងអាចធ្វើទៅបាន។ ក៏ប៉ុន្តែបើសិនជាយើងចង់បូម៥០០លីត្រក្នុង១នាទី ដូច្នេះយើងត្រូវបូមរយៈពេល២០នាទីតែប៉ុណ្ណោះ មុនពេលអណ្តូងទឹករីងស្ងួតអស់។ (ជាការពិត បូមលើស២០នាទី ចំណុះទឹក៣,៣ម៉ែត្រគូបចេញបន្ថែមនឹងត្រូវបូមដោយមិនធ្វើឱ្យអណ្តូងរីងទេ)។

**ការដាស់តឿនរំលឹក៖** កម្រិតទឹកចេញរបស់អណ្តូងអាចផ្សេងៗគ្នាដោយសារ៖

- តាមរដូវកាល (អណ្តូងនានា ពិសេសអណ្តូងរាក់ៗ នឹងមានកម្រិតចេញទឹកច្រើននៅចុងរដូវវស្សា បើប្រៀបធៀបនឹងចុងរដូវប្រាំង
- អណ្តូងដទៃទៀតដែលត្រូវបានជីកក្នុងជម្រៅដូចគ្នា
- ការបុកគ្រឹះនៃគម្រោងសាងសង់អាចធ្វើឱ្យប្រែប្រួលទម្រង់ដីស្រទាប់ក្រោម ហើយអាចមានឥទ្ធិពលទាំងកំណើន ឬកាត់បន្ថយបរិមាណទឹកចេញ។

**៥. ធារទឹកក្រោមដី៖**

ជាប្រភេទទឹកចេញពីក្នុងដីនៅពេលយើងជីកស្រះក្នុងកម្រិតជម្រៅសមស្របដែលអាចមានទឹកចេញ។ ថ្វីត្បិតតែទឹកក្រោមដី "មិនអស់លុយឬមិនគិតថ្លៃ" ក៏ប៉ុន្តែទឹកនោះតែងតែមានវត្តមានក្នុងស្រះ ខណៈយើងមិនត្រូវការវា។ ឧទាហរណ៍ នៅពេលយើងព្យាយាមបូមបង្ហូរទឹកចេញពីស្រះ ការជ្រាបចេញនៃទឹកក្រោមដីមានច្រើនលើសលប់ នឹងធ្វើឱ្យការបូមមិនអាចបង្ខះទឹកក្នុងស្រះបាន និងធ្វើឱ្យត្រីដែលយើងមិនចង់ចិញ្ចឹមបន្តរស់នៅក្នុងស្រះដដែល។ ទឹកក្រោមដីមួយចំនួនមានកំហាប់លោហៈខ្ពស់ ដូចជាអាសេនិច និងកាតមីញ៉ូមជាដើម ។

## ការបាត់បង់ទឹក

**១. ការជន់លិច៖** ទឹកហូរចេញពីស្រះ ដោយសារទឹកពេញហៀរនៅក្នុងស្រះ

**២. ការរំហួត ដែលបង្កដោយ៖**

- សីតុណ្ហភាព៖ ការរំហួតកាន់តែច្រើននៅពេលសីតុណ្ហភាពកើនឡើងខ្ពស់
- ខ្យល់៖ ការរំហួតកាន់តែច្រើន ក្នុងលក្ខខណ្ឌមានខ្យល់ច្រើន
- ពាក់ព័ន្ធនឹងសំណើមខ្យល់៖ ការរំហួតទឹកមានតិចនៅពេលមានសំណើម ហើយការរំហួតច្រើននៅពេលអាកាសធាតុក្តៅ
- ភាពល្អក់នៃទឹក៖ ភាពល្អក់នៃទឹកបង្កដោយរុក្ខជាតិប្លង់តុងមានន័យថាទឹកនឹងប្រែពណ៌បៃតងចាស់ជាធម្មតា និងឡើងកម្តៅ ដូច្នេះក៏បង្កើនរំហួតដែរ។ ភាពល្អក់បង្កដោយកករដីឥដ្ឋ (អាចរកមើលនៅក្នុងអត្ថបទរបស់ Hisham)
- ឧបករណ៍បញ្ចូលខ្យល់៖ ជាពិសេសរហាត់ទឹក និងប្រភេទឧបករណ៍បាញ់ទឹកផុសឡើង។ (ព័ត៌មានបន្ថែមសូមអានការស្រាវជ្រាវរបស់ Hisham)




រូបភាព៖ ដំណើរការរំហួត

ដៃគូអនុវត្តគម្រោង៖

ដោយសារការរំហួតកើតចេញពីផ្ទៃខាងលើនៃទឹកស្រះ ដូច្នេះចំពោះស្រះជ្រៅៗបាត់បង់ទឹកតិច បើធៀបនឹងស្រះរាក់ៗ។ ភាគរយនៃការបាត់បង់ទឹកដោយសារការរំហួត ខណៈពេលអត្រារំហួតប្រចាំឆ្នាំសរុប ១២០សង់ទីម៉ែត្រក្នុង១ឆ្នាំ

| ជម្រៅស្រះ | ភាគរយចំណុះទឹកស្រះដែលបាត់បង់ទឹកក្នុង១ឆ្នាំ |
|---|---|
| ១ម៉ែត្រ | ១២០ភាគរយ |
| ២ម៉ែត្រ | ៦០ភាគរយ |
| ៣ម៉ែត្រ | ៤០ភាគរយ |
| ៤ម៉ែត្រ | ៣០ភាគរយ |

**៣. ដំណើរការរំហួតដោយដើមឈើ និងរុក្ខជាតិដែលដុះនៅក្បែរខាង និងពួកវារីរុក្ខជាតិ។** ដំណើរការរំហួតជាការបាត់បង់ទឹកចូលទៅក្នុងបរិយាយកាសតាមរយៈស្លឹករុក្ខជាតិ។

រុក្ខជាតិនានាដែលដុះក្បែរស្រះឬភ្លឺស្រះនឹងស្រូបបឺតទឹកស្រះចេញពីដីដែលនៅជាប់នឹងស្រះ ដើម្បីដុះលូតលាស់ ហើយពួកវានឹងបង្កើតដំណើរការរំហួតទឹកតាមរយៈស្លឹករបស់រុក្ខជាតិទាំងនោះ។ រុក្ខជាតិដែលមានស្លឹកខ្ចីធំៗទំនងជាបឺតទឹកបានឆាប់រហ័សជាងរុក្ខជាតិដែលមានស្លឹកតូចៗ ស្លឹកក្រាស់ និងស្លឹករលោង។

នៅពេលមានការរំហួត កម្រិតនៃដំណើរការរំហួតកើនឡើងនៅពេលអាកាសធាតុក្តៅ អាកាសធាតុស្ងួតឬថ្ងៃដែលមានខ្យល់។ អ្នកខ្លះគិតថា បើសិនស្រះរបស់ពួកគេមានរុក្ខជាតិដុះគ្របលើស្រះ នឹងធ្វើឱ្យបាត់បង់ទឹកតិចក្នុងអំឡុងពេលរដូវប្រាំង។ ករណីនេះអាចជាការពិតតែម្យ៉ាងគត់ សម្រាប់ប្រភេទរុក្ខជាតិណាដែលមានស្លឹករលោង លាតនៅលើផ្ទៃទឹក។ ទោះជាយ៉ាងណាក៏ដោយ រុក្ខជាតិទាំងនោះនឹងរាំងពន្លឺថ្ងៃចាំងចូលទៅក្នុងទឹកផងដែរ ដូច្នេះធ្វើឱ្យកាត់បន្ថយការផលិតអុកស៊ីសែនដោយសារពពួករុក្ខជាតិប្លង់តុង(ហ្វីតូប្លង់តុង)។

រុក្ខជាតិទាំងឡាយដែលមានស្លឹកដុះផុតពីលើផ្ទៃទឹក អាចបណ្តាលឱ្យមានការបាត់បង់ទឹក២ដងឬច្រើនជាងនេះ ធៀបនឹងការរំហួតដោយរុក្ខជាតិដែលមានស្លឹកក្រាបផ្ទាល់នឹងផ្ទៃទឹក។ ពពួកកំប្លោក ត្រកួន ឬក៏ពពួករុក្ខជាតិដុះខ្ពស់ផុតពីទឹក ដូចជា កក់ ស្រងែ ឈូក ស្រូវ ក៏បង្កឱ្យមានការបាត់បង់ទឹកខ្ពស់ដែរ។ ឧទាហរណ៍ខ្លះមាននៅខាងក្រោម៖



រូបភាព៖ វារីរុក្ខជាតិប្រភេទផ្សេងៗ

**៤. ការលេចជ្រាបៈ** ល្បឿននៃការលេចជ្រាបទឹកចេញពីស្រះ បណ្តាលមកពីកត្តាមួយចំនួនៈ

- ប្រភេទដីស្រះៈ ដីខ្សាច់ឬដីល្បាយគ្រួស នឹងជ្រាបទឹកច្រើនជាងប្រភេទដីឥដ្ឋ។ ដីគួរតែជាដីដែលមានកម្រិតភាគល្អិតម៉ត់ ៥០ ភាគរយ ទំហំតិចជាង ០,០០៨ មីលីម៉ែត្រ និង១៥ភាគរយ ទំហំតិចជាង ០,០០០៣ មីលីម៉ែត្រ។
- វិធីដែលគេជីកស្រះៈ រួមមានការលេចជ្រាបតាមបណ្តោយទុយោដែលបានបំពាក់មិនបានត្រឹមត្រូវ។ ដីតែមស្រះជាដីល្បាយខ្សាច់ច្រើនឬល្បាយគ្រួសច្រើនក៏អាចមានការលេចជ្រាបតិចតួច បើទោះបីមានការបង្ហាប់ដីបានល្អតាមស្រទាប់ដីរួចរាល់ក៏ដោយ។ ជាមួយនេះដែរ ដីកស្នាមភ្លោះនៅចំកណ្តាលនៃទំនប់ ឬស្រទាប់ដីឥដ្ឋដែលល្អណាមួយអាចយកដីមកចាក់ជាដីស្រទាប់ក្រៅដើម្បីជួយកាត់បន្ថយការលេចជ្រាប។
- ជម្រៅទឹកៈ ជម្រៅទឹកកាន់តែជ្រៅកាន់តែមានសម្ពាធនិងបង្កើនការលេចជ្រាប។
- សីតុណ្ហភាពទឹកៈ សីតុណ្ហភាពខ្ពស់ធ្វើឱ្យកម្រិតការលេចជ្រាបកាន់តែខ្ពស់ដែរ ពីព្រោះទឹកមានភាពរាវខ្លាំងនៅពេលទឹកមានកម្តៅ។

ការលេចជ្រាបត្រូវបានវាស់ដោយការកំណត់របៀបដែលទឹកបាត់បង់សរុប និងដកទឹកចេញពីការបាត់ទឹកដោយការរំហួត។ ខាងក្រោមនេះ គឺជាតួលេខនៃការបាត់បង់ទឹកៈ

| ចំណាត់ថ្នាក់នៃជម្រាប | បាត់ទឹកដោយជម្រាប (សង់ទីម៉ែត្រ/ខែ) |
|---|---|
| ទាប | តិចជាង ១០ |
| ធម្មតា | ១០-២០ |
| ខ្ពស់ | ២០-៤០ |
| ខ្ពស់បំផុត | លើសពី៤០ |

**៥. ការប្រើប្រាស់ផ្សេងៗៈ** ស្រោចស្រព ការចិញ្ចឹមសត្វ និងការប្រើប្រាស់ក្នុងគ្រួសារ

បើសិនយើងប្រើប្រាស់ទឹកស្រះដើម្បីស្រោចស្រពសួនបន្លែ ឬប្រើទឹកសម្រាប់សត្វ នោះនឹងធ្វើឱ្យបាត់ទឹកក្នុងស្រះ។ ដោយសារតែការប្រើប្រាស់ទឹកមានភាពទូលំទូលាយ ដូច្នេះវាអាស្រ័យការសម្រេចចិត្តរបស់វារីវប្បករ ថាតើបរិមាណទឹកប៉ុន្មានដែលត្រូវទាញចេញពីស្រះយកមកប្រើ ហើយដាក់បញ្ចូលក្នុងផែនការប្រើប្រាស់ទឹក។



រូបភាពៈ កសិដ្ឋានចម្រុះដែលមានស្រះចិញ្ចឹមត្រីនិងចំការដំណាំ

## ៦.ការបង្ហូរទឹកៈ

ការគណនាបរិមាណទឹកបាត់ពីការបង្ហូរទឹកចេញពីស្រះមិនពិបាកឡើយ បើសិនយើងដឹងចំណុះទឹកក្នុងស្រះរបស់យើង។ បើសិនយើងបង្ហូរទឹកចេញពីស្រះចូលទៅក្នុងប្រឡាយសម្រាប់ការស្រោចស្រព ទឹកនេះមិនបានបាត់ទេ គឺវាគ្រាន់តែជាការផ្ទេរ ជាមួយអ្វីទាំងអស់រួមទាំងជីជាតិនិងភក់ល្បប់។ ជាធម្មតា បរិមាណទឹកដែលមាននៅសល់ចុងក្រោយប្រមាណ ២៥ភាគរយ ដែលត្រូវបង្ហូរចេញពីស្រះ មានសារធាតុចិញ្ចឹមច្រើន ពីព្រោះថាសារធាតុចិញ្ចឹមទាំងនោះត្រូវបានច្របល់ដោយការអូសអួនសំណាញ់ និងអ្នកចាប់ត្រី (កករសំណល់ល្បប់ភក់)។

## តើត្រូវការបរិមាណទឹកប៉ុន្មានដើម្បីចិញ្ចឹមត្រីក្នុង១វគ្គ?

ជាបឋម យើងនឹងត្រូវដឹងចំណុះស្រះ ដូច្នេះយើងនឹងដឹងបរិមាណទឹកដើម្បីបំពេញស្រះនោះ។ នៅរដូវវស្សា បើសិនជាយើងបូមទឹកចូលស្រះ ដូច្នេះយើងមិនគួរ បូមបំពេញឱ្យពេញតាមសមត្ថភាពស្រះនោះទេ។ ត្រូវទុកកម្រិតទឹកឱ្យទាបជាងកម្រិតទឹកពេញហៀរ ដូច្នេះស្រះអាចទទួលបានទឹកភ្លៀងបន្ថែមខ្លះទៀតបាន។

សូមមើលលេខ ៥ ខាងលើ ហើយបូកបន្ថែមការប្រើប្រាស់ទឹកផ្សេងៗទៀតដែលយើងត្រូវបូមទឹកស្រះយកទៅប្រើ។

ចុងក្រោយ ត្រូវពិនិត្យរំហួត និងប្រហែលជាត្រូវមើលផងដែរអំពីជម្រាបរបស់ស្រះ។ កម្រិតរំហួតដែលខ្ពស់បំផុត នៅកម្ពុជា កើតមាននៅអំឡុងខែមីនា និងខែមេសា ចាប់ពី ២០០ ទៅ ២៤០ មីលីម៉ែត្រក្នុង ១ខែ និងកម្រិតរំហួតទាបបំផុត នៅខែកញ្ញា ចាប់ពី ១២០ ទៅ ១៥០ មីលីម៉ែត្រក្នុង ១ខែ។ មធ្យមភាគរំហួតប្រចាំឆ្នាំគឺ ១ ០០០ ទៅ ២ ៣០០ មីលីម៉ែត្រ។

វារីវប្បករអាចប្រមូលទិន្នន័យរំហួតប្រចាំខែពីនាយកដ្ឋានឧតុនិយមកម្ពុជា បើទិន្នន័យរំហួត០,៨១ នោះជារំហួតទឹកស្រះ។ នៅកម្ពុជាទិន្នន័យរំហួតពិបាកស្វែងរកណាស់។ ក៏ប៉ុន្តែអាចរកបានរបាយការណ៍ពីស្ថានីយ៍ឧតុនិយមជាច្រើនកន្លែង ខណៈដែលទិន្នន័យឧតុនិយមដ៏ទៃទៀតត្រូវបានគេផ្តល់ជាទៀងរាល់ខែ។

បើសិនជាបង្ហូរទឹកកខ្វក់ចេញ(ផ្លាស់ប្តូរទឹក) វាស្ថិតក្នុងផែនការគ្រប់គ្រងរបស់យើង ដូចនេះតម្រូវការទឹកត្រូវតែគណនា ឬរាប់បញ្ចូល ។

ក្រៅអំពីការគណនាតម្រូវការប្រើប្រាស់ទឹកសរុប វារីវប្បករគួរគណនាតម្រូវការប្រចាំខែឬប្រចាំសប្តាហ៍ បើសិនពួកគេបាត់បង់ទឹកដោយការប្រើប្រាស់ច្រើន។

## ឧទាហរណ៍

ស្រះមានក្រឡាផ្ទៃ ៥០០ ម៉ែត្រការ៉េ និងជម្រៅ ៣ ម៉ែត្រ ។ ស្រះមានចំណុះប្រហែល ១ ៥០០ ម៉ែត្រគូប។

ដើម្បីបញ្ចូលទឹកចូលស្រះ យើងត្រូវការបរិមាណទឹកសរុបប្រមាណច្រើនជាង ១ ៥០០ម៉ែត្រគូប។ យើងនិយាយថាច្រើនជាងបន្តិច ពីព្រោះវាអាស្រ័យលើសំណើមដីនិងសភាពដីហាប់ណែន។ នៅពេលបូមទឹកបញ្ចូលស្រះ បរិមាណទឹកមួយចំនួននឹងជ្រាបចូលក្នុងដី។

បើសិនបញ្ចូលទឹកចូលស្រះដោយទឹកភ្លៀងផ្ទាល់ នោះមានន័យថាបរិមាណទឹកភ្លៀងសរុបកម្ពស់ ៣ម៉ែត្រ (៣ ០០០ មីលីម៉ែត្រ) ដែលលើសកម្រិតមធ្យមភាគទឹកភ្លៀងប្រចាំឆ្នាំនៅកម្ពុជា បើមិនដូច្នេះត្រូវប្រើពេលពេញមួយឆ្នាំ ដើម្បីបំពេញស្រះ។ ដូចនេះយើងត្រូវការយកទឹកបន្ថែមពីទីជម្រាលនៃផ្ទៃរងទឹកភ្លៀង ឬក៏បូមពីទឹកប្រឡាយ ឬអាងស្តុកទឹក។

បន្ទាប់ពីបញ្ចូលទឹកស្ទើរជិតពេញស្រះហើយ ទឹកភ្លៀងប្រចាំខែដកកម្រិតរំហួត វានឹងប្រាប់យើង បើសិនកម្រិតទឹកនឹងស្រកឬកើនឡើង។ សម្រាប់អំឡុងពេលមួយខែមានភ្លៀងតិចឬមិនមានភ្លៀង គឺវាទំនងជាមកពីសីតុណ្ហភាពក្តៅ។ តាមព័ត៌មានខាងលើ ស្រះនឹងបាត់ទឹករហូតដល់២៥សង់ទីម៉ែត្រ ដោយរំហួតក្នុងបរិយាកាស និងរហូតដល់ ២៥សង់ទីម៉ែត្រពីដំណើរការរំហួតដោយស្លឹករុក្ខជាតិមានដុះជុំវិញស្រះ ហើយក៏អាចបាត់បង់ទឹកថែមដល់ទៅ ៤០សង់ទីម៉ែត្រតាមរយៈការលេចជ្រាប។ **ករណីនេះបូកបន្ថែមរហូតដល់ ៩០ សង់ទីម៉ែត្រក្នុងមួយខែពីការបាត់ទឹក។**

បើសិនស្រះមានទឹក ៣ ម៉ែត្រ បន្ទាប់មកកម្រិតទឹកធ្លាក់មកក្រោម ១ម៉ែត្រ ក្នុងអំឡុងពេល២ខែនៃរដូវប្រាំង។ សមត្ថភាពផ្ទុក (គីឡូក្រាម/ហិចតា) របស់ស្រះគួរតែផ្អែកលើបរិមាណទឹកនៅសល់ក្នុងអំឡុងពេលជិតចុងបញ្ចប់នៃការចិញ្ចឹម (ការប្រមូលផល)។

របៀបបង្កើនការប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាព?

- ត្រួតពិនិត្យមើលពពួករុក្ខជាតិដែលលេចចេញពីទឹកដើម្បីកាត់បន្ថយដំណើរការរំហួតទឹក។
- ហាមដាំដើមឈើក្បែរភ្លឺស្រះ។
- រក្សាផ្ទៃទីជម្រាល (តំបន់ដែលទទួលទឹកបង្ហូរចូលស្រះ) ជាដីស្មៅដុះខ្ពីៗ ដូច្នេះមានទឹកហូរបន្ថែមចូលក្នុងស្រះនៅពេលមានភ្លៀង ហើយមានកករល្អក់ និងសារធាតុខនិចតិចតួចអាចហូរចូលស្រះ។
- បើសិនបញ្ចូលទឹកចូលស្រះពីខាងលើស្រះសូមកុំបញ្ចូលក្នុងកម្រិតអតិបរមា ដូច្នេះហើយបើសិនមានភ្លៀង គឺមានលំហផ្ទៃស្រះស្តុកទឹកភ្លៀងបន្ថែមទៀត។ យកល្អរក្សាទុក១០សង់ទីម៉ែត្រពីកម្រិតអតិបរមា ។
- គេអាចដាក់ត្រីចិញ្ចឹមឱ្យច្រើនក្នុងមួយឯកតា និងប្រើចំណីមានគុណភាពល្អ។ ត្រូវចាំនិងមានការប្រុងប្រយ័ត្នប្រសិនបើប្រើប្រព័ន្ធបញ្ចូលខ្យល់វាអាចបង្កើនការបាត់បង់ទឹកពីដោយសាររំហួត។



រូបភាព៖ ស្រះចិញ្ចឹមត្រីដែលមានដំណាំដូងនៅតាមភ្លឺស្រះ

# មេរៀន ៖

# ការគ្រប់គ្រងគុណភាពទឹកស្រះ និងឥទ្ធិពលរបស់វាលើការចិញ្ចឹមត្រី

# ការគ្រប់គ្រងគុណភាពទឹកស្រះ និងឥទ្ធិពលរបស់វាលើការចិញ្ចឹមត្រី

វារីវប្បករដែលកំពុងចិញ្ចឹមត្រីក្នុងស្រះ អាង ឬបែត្រូវយល់ឱ្យបានច្បាស់លាស់អំពីសារៈសំខាន់នៃគុណភាពទឹកស្រះរបស់ខ្លួន ដូចជារបៀបនៃការវាស់ ការគ្រប់គ្រងកសិដ្ឋានលើផ្នែកដែលមានឥទ្ធិពលលើគុណភាពទឹក និងថាតើវារីវប្បករត្រូវត្រួតពិនិត្យអ្វីខ្លះ ។ ចំពោះវារីវប្បកម្មទឹកសាប ប្រភេទដី និងប្រភពទឹកជាកត្តាកំណត់កម្រិតអាល់កាឡាំង (Alkalinity) ភាពរឹង (Hardness) និងប៉េហាស(pH)របស់ទឹក ខណៈដែលសីតុណ្ហភាពវាអាស្រ័យលើអាកាសធាតុនៃទីតាំងនីមួយៗ។ ការអនុវត្តការគ្រប់គ្រងកសិដ្ឋានវាពិតជាមានឥទ្ធិពលលើកម្រិតរលាយអុកស៊ីសែនក្នុងទឹកសម្រាប់ត្រីដកដង្ហើម សារធាតុពុលអាម៉ូញ៉ាក់ នីទ្រីត ភាពល្អក់នៃទឹក និងអ៊ីដ្រូសែនស៊ុលភីត (ដីខ្មៅបាតស្រះ) ដូច្នេះវារីវប្បករត្រូវតែយកចិត្តទុកដាក់លើកត្តាទាំងនេះ ព្រោះវាធ្វើឱ្យត្រីមានការលូតលាស់ល្អ និងទទួលផលត្រីបានច្រើន។ **ការតាមដាន និងគ្រប់គ្រងគុណភាពទឹកជាប្រចាំ និងកត់ត្រាទិន្នន័យទាំងអស់នោះ វាពិតជាមានសារៈសំខាន់ណាស់និងជួយវារីវប្បករ ឬអ្នកចិញ្ចឹមឱ្យបានដឹងច្បាស់ថាតើគួរកែលម្អគុណភាពទឹកនៅពេលណាពិតប្រាកដ។**



ក្រាហ្វ ការលូតលាស់របស់ត្រី

គុណភាពទឹក និងការគ្រប់គ្រងចំណីគឺជាកត្តា២ដ៏សំខាន់បំផុត ដើម្បីកំណត់ការលូតលាស់របស់ត្រី និងសមត្ថភាពផ្ទុករបស់ស្រះ (គីឡូក្រាម/ហិចតា) ហើយកត្តាទាំងពីរនេះពិតជាមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ។

ពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រះ ការផ្តល់ចំណីក៏នៅតិចតួច ពេលនោះគុណភាពទឹកស្រះនៅល្អ ហើយត្រីមានការលូតលាស់លឿន(ពិនិត្យរូបខាងក្រោម)។ ខណៈត្រីកំពុងលូតលាស់ ការផ្តល់ចំណីប្រចាំថ្ងៃមានការកើនឡើង គេសង្កេតឃើញថាគុណភាពទឹកក្នុងស្រះចាប់ផ្តើមថយគុណភាព ហើយត្រីក៏ចាប់ផ្តើមលូតលាស់យឺត។ ប្រសិនបើ នៅតែផ្តល់ចំណីក្នុងបរិមាណដ៏ច្រើនដដែលដោយសារតែមានត្រីក្នុងស្រះច្រើន ពេលនោះគុណភាពទឹកកាន់តែអន់ទៅៗ ហើយត្រីក៏ឈប់លូតលាស់ (ដល់កម្រិតផ្ទុករបស់ស្រះ)។ វារីវប្បករ ឬអ្នកចិញ្ចឹមត្រីនៅមានជម្រើសក្នុងការកែប្រែគុណភាពទឹកស្រះរបស់ខ្លួន ប៉ុន្តែពួកគាត់ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់ថាតើគុណភាពទឹកមានប៉ារ៉ាម៉ែត្រគុណភាពទឹកសំខាន់ៗដែលត្រូវយល់ដឹង ។


រូបភាព៖ ការប្រៀបធៀបល្បឿននៃការលូតលាស់របស់ត្រី

ដៃគូអនុវត្តគម្រោង៖

## ស្វែងយល់ពីប៉ារ៉ាម៉ែត្រគុណភាពទឹកសំខាន់ៗ

កម្រិតអាល់កាឡាំង (Alkalinity) ភាពរឹងនៃទឹក(Hardness) និងប៉េហាស- pH) មានទំនាក់ទំនងនឹងគ្នា មិនអាចផ្តាច់ពីគ្នាបានទេ ហើយវាអាស្រ័យតាមប្រភេទដី និងប្រភពទឹក។ កម្រិតនៃសារធាតុទាំងនោះ អាស្រ័យលើទឹក និងដីដែលលាយចូលគ្នា។ ភាពរឹងនៃទឹក ( Hardness ) គឺជាបរិមាណនៃអ៊ីយ៉ុងវ៉ែជាច្រើនដែលមានក្នុងល្បាយទឹក ដូចជា កាល់ស្យូម ម៉ាញ៉េស្យូម ហើយវាមានសារៈសំខាន់ និងល្អសម្រាប់ការលូតលាស់ឆ្អឹង ធ្មេញ និងស្រកាត្រី ក៏ដូចជាធ្វើឱ្យត្រីមានសុខភាពល្អ។ ការលូតលាស់ និងមុខងារនៃរាងកាយ ឬខ្លួនរបស់ត្រីទាំងមូលអាស្រ័យលើភាពគ្រប់គ្រាន់នៃកាល់ស្យូម និងម៉ាញ៉េស្យូម។ កម្រិតអាល់កាឡាំង (Alkalinity) គឺជាសមត្ថភាពរបស់ទឹកក្នុងការរក្សាលំនឹងជាតិអាស៊ីតក្នុងស្រះ វាអាស្រ័យលើសមាសធាតុកាបូន និងកាបូណាត ($CaCO_3$)។ វារីវប្បករអាចវាស់កម្រិតអាល់កាឡាំង (Alkalinity) ភាពរឹងនៃទឹក (Hardness) និងប៉េហាស (pH) ដោយប្រើក្រដាសចង្អុលពណ៌ ឬសមាសធាតុគីមី ដែលអាចប្តូរពណ៌បាន ដោយប្រៀបធៀបជាមួយតារាងដែលមានភ្ជាប់ជាមួយស្រាប់។ ដោយសារតែវិធីសាស្ត្រនេះមានភាពសាមញ្ញ ដូចនេះវាមិនត្រឹមត្រូវជានិច្ចកាលនោះឡើយ ប៉ុន្តែវាបង្ហាញឱ្យយើងដឹងយ៉ាងឆាប់រហ័សអំពីគុណភាពនៃទឹកស្រះថាតើនឹងត្រូវបាចកំបោរឬយ៉ាងណា។ មានតែមន្ទីរពិសោធន៍ដែលនឹងផ្តល់ព័ត៌មានជាក់លាក់ និងពិតប្រាកដរបស់វារីវប្បករអំពីសមាសភាពក្នុងទឹក និងដី។ មន្ទីរពិសោធន៍ក៏អាចពិនិត្យផងដែរអំពីវត្តមាននៃលោហៈធ្ងន់ និងមានភាពលំអិតនៃសារធាតុវ៉ែក្នុងទឹកដែលវាមាលក្ខណៈពិសេសសម្រាប់ស្ថានីយ៍ផលិតកូនត្រីពូជ។

កំហាប់អាល់កាឡាំង (Alkalinity) និងភាពរឹងនៃទឹក (Hardness) នៃផ្ទៃទឹកខាងលើមានលក្ខណៈខុសគ្នាទៅតាមសំណើមនៃតំបន់នីមួយៗ ដូចជានៅកម្ពុជាមានពីទាប (១៥-២០ មីលីក្រាមក្នុងទឹក១លីត្រ) ទៅមធ្យម (២០-៥០ មីលីក្រាមក្នុងទឹក១លីត្រ) ចំពោះដីមិនមានវត្តមានសមាសធាតុកាបូណាត។ ចំពោះតំបន់មានវត្តមានកាបូណាត វាអាចមានបរិមាណលើសពី ១០០ មីលីក្រាមក្នុងទឹក១លីត្រ ។ ចំពោះតំបន់ស្ងួតវិញវាអាចមានកម្រិតខ្ពស់ជាងនេះ។ ទឹកក្រោមដីពីអណ្តូង ឬទឹកចេញក៏មានកម្រិតជាតិកំបោរខ្ពស់ដែររហូតដល់ ៥០០ មីលីក្រាមក្នុងទឹក១លីត្រ ។ ម្យ៉ាងទៀតទឹកអណ្តូងក៏មានកម្រិតឧស្ម័នកាបូនិចខ្ពស់ដែរ ដែលបណ្តាលឱ្យប៉េហាស (pH) ចុះទាប។

សម្រាប់វារីវប្បកម្ម ភាពរឹងនៃទឹក (Hardness) វាស្មើរតែស្មើ ឬធំជាងកម្រិតអាល់កាឡាំង (Alkalinity) ខណៈដែលប៉េហាស (pH) កម្រនឹងលើសពី ៩,៥ ណាស់។ ក្នុងករណីនេះ អាល់កាឡាំងត្រូវបានប្រមូលផ្តុំដោយអីយ៉ុងកាបូណាត និងប៊ីការបូណាត ដែលជួយបង្កើនកម្រិតប៉េហាស់របស់ទឹក។ ទឹកដែលមានកម្រិតទឹករឹងនិងអាល់កាឡាំងយ៉ាងតិច ៨០ មីលីក្រាមក្នុងទឹក ១លីត្រ គឺល្អគ្រប់គ្រាន់សម្រាប់រារាំងការឡើងកម្រិតប៉េហាសប្រចាំថ្ងៃ។ ប៉ុន្តែកម្រិតអាល់កាឡាំងនិងភាពរឹងនៃទឹកលើសពី ២០មីលីក្រាមក្នុងទឹក១លីត្រ មិនអាចសមល្មមក្នុងការបំបែកពពួកជីផូស្វាត នៅពេលដែលកម្រិត កាល់ស្យូមខ្ពស់បានចាប់យកអីយ៉ុងស៊ុលផួរ។ ខណៈនេះគេអាចប្រើកំបោរកសិកម្ម (ថ្មកំបោរដែលមានសារធាតុម៉ាញេ ស្យូមកាបូណាត $CaMg(CO_3)$ ឬ ថ្មកំបោរមានសារធាតុកាលស្យូមកាបូណាត ($CaCO_3$) ក្នុងបរិមាណ ៥០មីលីក្រាមក្នុង១លីត្រទឹកដើម្បីបង្កើនភាពរឹងនៃទឹក និងកម្រិតអាល់កាឡាំង ។ តាមបទពិសោធន៍បង្ហាញថា ប៉េហាសខ្ពស់ (លើសពី៩,៥) បង្កបញ្ហាធំក្នុងស្រះដែលមានទឹកបៃតងចាស់ ដែលមានប្លង់តុងរុក្ខជាតិលូតលាស់ខ្លាំងបណ្តាលឱ្យមានបញ្ហាពីរកើតឡើងគឺ ត្រីស្ត្រេស (កាត់បន្ថយការលូតលាស់) និងស្លាប់។

អត្រានៃការប្រើកំបោរអាស្រ័យនឹងការប្រែប្រួលតាមកម្រិតប៉េហាសរបស់ដីដូចខាងក្រោម៖

- ប៉េហាស (pH) ពី ៥,៥-៦,០ ប្រើកំបោរ ២ ០០០គីឡូក្រាមក្នុង១ហិចតា ឬ ២០គីឡូក្រាមក្នុង១០០ ម៉ែត្រការ៉េ
- ប៉េហាស (pH) ពី ៦,១-៦,៥ ប្រើកំបោរ ១ ០០០ គីឡូក្រាមក្នុង១ហិចតា ឬ ១០គីឡូក្រាមក្នុង១០០ម៉ែត្រការ៉េ
- ប៉េហាស (pH) ពី ៦,៦-៧,០ ប្រើកំបោរ ៥០០ គីឡូក្រាមក្នុង១ហិចតា ឬ ៥គីឡូក្រាម/ក្នុង១០០ ម៉ែត្រការ៉េ
- កំបោរមិនត្រូវបានគេប្រើចំពោះ ប៉េហាសលើសពី ៧ នោះទេ។

## សីតុណ្ហភាពនិងកម្រិតរលាយអុកស៊ីសែនក្នុងទឹក (DO)

សីតុណ្ហភាពទឹកស្រះអាស្រ័យលើសីតុណ្ហភាពខ្យល់ និងធាតុអាកាសខាងក្រៅ ហើយពិបាកត្រួតពិនិត្យណាស់ ព្រោះថាស្រះវាចំហរ។ ទឹកក្នុងស្រះអាចផ្តុំជាស្រទាប់ៗដែលស្រទាប់លើក្តៅជាងស្រទាប់បាតដែលមានសីតុណ្ហភាពត្រជាក់ជាង។ នេះជារឿងពិតប្រាកដ ចំពោះស្រះដែលមានជម្រៅជ្រៅ ស្រទាប់លើមានប្លង់តុងរុក្ខជាតិ ហើយមានកម្រិតអុកស៊ីសែនខ្ពស់ជាងបាតស្រះមានទឹកត្រជាក់ ដែលអាចមានកម្រិតអុកស៊ីសែនទាប ឬគ្មានតែម្តង។ កម្រិតអុកស៊ីសែននៅបាតស្រះធ្វើឱ្យត្រីស្រទាប់បាតស្រេ្តស តែបើមានខ្យល់ខ្លាំងនិងមានសីតុណ្ហភាពត្រជាក់អាចឱ្យទឹកស្រះធ្វើចលនាពីស្រទាប់លើទៅបាតក្រោមបានយ៉ាងស្រួល។ ជួនកាល ការធ្វើចលនាពីស្រទាប់លើទៅបាតក្រោម បណ្តាលឱ្យកម្រិតអុកស៊ីសែនធ្លាក់ចុះខ្លាំង និងត្រីស្រេ្តស ឬងាប់បាន។

កម្រិតរលាយអុកស៊ីសែនក្នុងទឹក (DO) ជាចំនុចសំខាន់បំផុតសម្រាប់ការលូតលាស់បានល្អ និងអត្រាត្រីរស់ច្រើន។ តម្រូវការអុកស៊ីសែនអាស្រ័យតាមទំហំ និងប្រភេទត្រី សម្រាប់ត្រីមានទំហំតូចត្រូវការអុកស៊ីសែនច្រើនជាងត្រីធំក្នុងត្រីបរិមាណ ១គីឡូក្រាមដូចគ្នា។ តែរឿងដែលសំខាន់អ្នកត្រូវតែដឹងថាតើត្រីរបស់អ្នកត្រូវការអ្វីដើម្បីលូតលាស់បានល្អ។ កាលណាអុកស៊ីសែនទាបពេក បើទោះជាប្រភេទត្រីអាចដកដង្ហើមពីក្នុងបរិយាកាស (ត្រីប្រា ត្រីរ៉ស់ ឆ្តោរ ជាដើម) ក៏ដោយក៏ត្រីទាំងនោះស្ថិតក្នុង ស្ថានភាពស្រេ្តសដែរ ហើយជាលទ្ធផលគឺ មេគុណចំណី (FCR) អន់បំផុត (មេគុណចំណីខ្ពស់) ហើយវានឹងឈានទៅរកការផ្ទុះជំងឺ។ បើសង្កេតឃើញត្រីហែលមកលើផ្ទៃទឹកជាប្រចាំដើម្បីដកដង្ហើម វាត្រូវចំណាយថាមពលជាច្រើន ដែលថាមពលនោះត្រូវចំណាយសម្រាប់ការលូតលាស់របស់វា។ មានន័យថា អ្នកត្រូវចំណាយលុយជាច្រើនលើចំណីសម្រាប់ការផលិតបរិមាណត្រីដូចគ្នា ។



រូបភាព៖ ឧបករណ៍វាស់អុកស៊ីសែនអេឡិចត្រូនិច

គេអាចវាស់អុកស៊ីសែនដោយប្រើឧបករណ៍វាស់អុកស៊ីសែនទាំងអេឡិចត្រូនិចនិងសារធាតុគីមី។ វិធីទាំងពីរមានភាពប្រាកដប្រជាណាស់ តែចំពោះឧបករណ៍វាស់អុកស៊ីសែនអេឡិចត្រូនិច អាចវាស់បានលឿន និងច្រើនស្រះទៀតផង ។ ថ្វីបើឧបករណ៍វាស់អុកស៊ីសែនអេឡិចត្រូនិច (DO) មានតម្លៃថ្លៃ តែគួរតែវិនិយោគលើឧបករណ៍ដ៏ល្អនេះ ដើម្បីជៀសវាងការបាត់បង់ត្រីដោយសារតែមានបរិមាណអុកស៊ីសែនទាប(តិច)។ ឧបករណ៍នេះត្រូវតែថែរក្សាឱ្យបានល្អ និងផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវមុនប្រើប្រាស់។ បរិមាណអុកស៊ីសែនក្នុងស្រះទឹកសាបអាស្រ័យលើកត្តាជាច្រើនរួមមានដូចជា សីតុណ្ហភាព និងសម្ពាធប៉ារ៉ូម៉ែត្រ តែកត្តាសំខាន់និងពិសេសនោះគឺការគ្រប់គ្រងកសិដ្ឋាន ដូចជាការផ្តល់ចំណី និងដង់ស៊ីតេកូនត្រីចិញ្ចឹមក្នុងស្រះ។

ដៃគូអនុវត្តគម្រោង៖

នៅកម្ពុជា សីតុណ្ហភាពមិនប្រែប្រួលច្រើនទេព្រោះវាក្តៅល្មម តែយ៉ាងណាការគ្រប់គ្រងកសិដ្ឋានមានភាពខុសគ្នាខ្លាំង។ ចំពោះទឹកស្រះដែលមានពណ៌បៃតង កម្រិតអុកស៊ីសែនកើនឡើងកំឡុងពេលថ្ងៃ ព្រោះប្លង់តុងរុក្ខជាតិបង្កើតអុកស៊ីសែនតាមរយៈការធ្វើរស្មីសំយោគ ប៉ុន្តែវានឹងធ្លាក់ចុះវិញពេលយប់ ព្រោះពេលល្ងាចប្លង់តុងរុក្ខជាតិប្រើអុកស៊ីសែនសម្រាប់ដកដង្ហើម។ ចំពោះទឹកស្រះថ្លា ឬល្អក់ខ្លាំងកម្រិតអុកស៊ីសែនមិនសូវមានការប្រែប្រួល ព្រោះមានប្លង់តុងរុក្ខជាតិតិចតួច។ តែបើទឹកស្រះមានពណ៌បៃតងចាស់នោះ កម្រិតអុកស៊ីសែនមានការប្រែប្រួលខ្លាំងរហូតដល់ទាបបំផុតពេលយប់ បណ្តាលឱ្យត្រីស្ត្រេស ឬអាចធ្វើឱ្យត្រីងាប់បានយ៉ាងងាយ។ ការគ្រប់គ្រងប្លង់តុងរុក្ខជាតិក្នុងទឹកស្រះបានល្អជាវិធីសាស្ត្រមួយដ៏ល្អបំផុតដើម្បីផ្តល់អុកស៊ីសែនគ្រប់គ្រាន់សម្រាប់ត្រីក្នុងស្រះ ។

កម្រិតរលាយអុកស៊ីសែនក្នុងស្រះអាចប្រែប្រួលរៀងរាល់ថ្ងៃ អាស្រ័យលើចំនួនប្លង់តុងក្នុងស្រះ និងដំណើររស្មីសំយោគរួមជាមួយនឹងបរិមាណចំណីប្រចាំថ្ងៃដែលផ្តល់ឱ្យត្រី។ ដ្យាក្រាមខាងស្តាំបង្ហាញពីកំណើននិងការធ្លាក់ចុះនៃកម្រិតអុកស៊ីសែនរលាយក្នុងស្រះរយៈពេល ៦ ថ្ងៃនៅក្នុងស្រះដែលមានទឹកពណ៌បៃតង។ តាមការអង្កេតលើគំនូសតាងគ្រប់យ៉ាងដំណើរការជាប្រក្រតីរហូតដល់ថ្ងៃទី៥ ជាពេលដែលមានភ្លៀងធ្លាក់យ៉ាងខ្លាំងនៅពេលរសៀលដែល ទាញទម្លាក់កម្រិតអុកស៊ីសែនក្នុងស្រះដល់កម្រិតគ្រោះថ្នាក់ហើយបណ្តាលឱ្យត្រីងាប់នាពេលយប់នោះ។




ស្រះទឹកប្រៀបបាននឹងធនាគារ។ នៅពេលថ្ងៃស្រះទឹកផលិត(ផ្ទុក)អុកស៊ីសែន(ប្រមូលលុយចូល)។ ចំណែកពេលយប់ទាំងរុក្ខជាតិ និងសត្វក្នុងស្រះប្រើប្រាស់អុកស៊ីសែន។ ប្រសិនបើពេល ថ្ងៃស្រះមិនអាចផលិត(ផ្ទុក) អុកស៊ីសែនគ្រប់គ្រាន់ ពេលយប់មកដល់ស្រះទឹកនឹងមានអុកស៊ីសែនគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។ នៅពេលមានភ្លៀងមកប្លន់ធនាគារ នោះនឹងខ្វះអុកស៊ីសែនហើយត្រីនឹងងាប់។

នៅពេលដែលកម្រិតអុកស៊ីសែនក្នុងស្រះចុះទាបខ្លាំង ការបញ្ចូលខ្យល់ក្នុងទឹកដោយប្រើស្លាបចក្រ បូមទឹកបាញ់សាចក្នុងខ្យល់អាចជួយបង្កើនកម្រិតអុកស៊ីសែនបានមួយចំណែក។ ប្រសិនបើមានទឹកដែលមានគុណភាពល្អ វារីវប្បករអាចប្តូរទឹកកខ្វក់ចេញ ជំនួសមកវិញដោយទឹកល្អ។ បើគ្មានជម្រើសទាំងពីរនេះទេ ការការពារទុកជាមុនគឺជាប្រការចាំបាច់។ វិធានការការពារមានដូចជា ការដាក់កូនត្រីចិញ្ចឹមក្នុងកម្រិតមួយដែលមិនលើសពីសមត្ថភាពផ្ទុករបស់ស្រះ កំណត់កម្រិតអតិបរិប្បមានៃបរិមាណចំណីប្រចាំថ្ងៃ (គីឡូក្រាមក្នុង១ថ្ងៃ) ដើម្បីការពារកុំឱ្យមានការធ្លាក់ចុះកម្រិតអុកស៊ីសែនក្នុងស្រះ។



រូបភាព៖ ការបញ្ចូលខ្យល់ក្នុងទឹកដោយប្រើស្លាបចក្រ

## អាម៉ូញាក់ និងនីទ្រីត

អាម៉ូញាក់ គឺជាសំណល់របស់ត្រីដែលបញ្ចេញចោលតាមរយៈស្រកីរបស់វា។ ជាមួយគ្នានេះដែរ ត្រីបញ្ចេញទឹកនោម និង លាមក។ អាម៉ូញាក់ក៏កើតឡើងដោយការបំបែកប្រូតេអ៊ីនក្នុងចំណីត្រីផងដែរ។

បរិមាណចំណីប្រហែល ៦០ ទៅ ៧០ភាគរយបានបាត់បង់ ហើយក្លាយជាកាកសំណល់។ ពេលដែលដាក់ចំណីត្រីកាន់តែច្រើន ហើយមានកម្រិតប្រូតេអ៊ីនកាន់តែខ្ពស់អាម៉ូញាក់ ក្នុងស្រះកាន់តែកើនឡើង។ អាម៉ូញាក់សរុបត្រូវបានគេរកឃើញជាទម្រង់គីមីពីរយ៉ាងគឺ ទម្រង់មិនមានអ៊ីយ៉ុង $NH_3$ និងទម្រង់ដែលមានអ៊ីយ៉ុង $NH_4^+$ នៅក្នុងទឹក។ ភាគរយនៃទម្រង់អាម៉ូញាក់ទាំងពីរអាស្រ័យលើសីតុណ្ហភាព និងប៉េហាស (pH) ហើយជាពិសេស គឺប៉េហាស (pH) តែម្តងដែលមានទំនាក់ទំនងខ្លាំង។ ពេលសីតុណ្ហភាព និងប៉េហាស់ (pH) កើន (ប៉េហាស់ pH លើស៧) ភាគរយរបស់ $NH_3$ កើន។ $NH_3$ គឺជាអាម៉ូញាក់ដែលមានជាតិពុល។ ប្រសិនបើប៉េហាសនៅកម្រិតក្រោម៧ អាម៉ូញាក់ពុលក្នុងទម្រង់គីមី$NH_3$ មិនកើតមាននោះឡើយ។ ប៉េហាស(pH)គឺជាតួអង្គដែលបង្កឱ្យអាម៉ូញាក់មានទម្រង់គីមី$NH_3$ដែលពុលដល់ត្រី។ ដោយសារតែប៉េហាស់ (pH) កើនឡើងនៅពេលថ្ងៃ ដូចនេះស្រះមានទឹកពណ៌បៃតងដែលមានអាម៉ូញាក់ពុលក៏កើនឡើងដែរ។ ប្លង់តុងរុក្ខជាតិក្នុងស្រះប្រើប្រាស់អាម៉ូញាក់ជាចំណី ដែលជួយកំចាត់អាម៉ូញាក់ពីក្នុងស្រះ ដូច្នេះមានន័យថាអាម៉ូញាក់ត្រូវបានកំចាត់ចេញពីក្នុងទឹកស្រះពណ៌បៃតងបានច្រើនជាងទឹកស្រះដែលថ្លាឬល្អក់។ មានបាក់តេរីមួយចំនួនក៏អាចបំលែង អាម៉ូញាក់ទៅជាទម្រង់គីមីមួយថ្មីដែរគឺនីទ្រីត ($NO_2$)។ ប៉ុន្តែនីទ្រីត ($NO_2$) បំពុលត្រីខ្លាំងជាអាម៉ូញ៉ាក់ទៅទៀត។ ជាធម្មតានីទ្រីត ($NO_2$) បំលែងទៅជានីត្រាត ($NO_3$) ហើយពពួកនីត្រាត ($NO_3$) ត្រូវពពួកប្លង់តុងរុក្ខជាតិស្រូបយក ដែលធ្វើឱ្យកម្រិតនីត្រាត($NO_3$) មិនសូវមានវត្តមានច្រើនក្នុងទឹកច្រើនទេ។

ទម្រង់អាសូតដែលរលាយក្នុងទឹកទាំងបី (អាម៉ូញាក់ពុល $NH_3$ នីទ្រីត $NO_2$ និងនីត្រាត $NO_3$) អាចរកឃើញដោយប្រើឧបករណ៍វាស់សាមញ្ញ ឬក្រដាសចង្អុលពណ៌ ប៉ុន្តែវាមិនសុក្រឹតដូចការវិភាគនៅក្នុងមន្ទីរពិសោធន៍។ យ៉ាងណាក៏ដោយ ទាំងឧបករណ៍ធម្មតាឬក្រដាសចង្អុលពណ៌វាគ្រប់គ្រាន់ឱ្យយើងដឹងថាសារធាតុពុលកំពុងបង្កបញ្ហា ហើយត្រូវចាត់វិធានការដើម្បីដោះស្រាយ។ ការវាស់វែងលើទម្រង់អាសូត ដែលរលាយក្នុងទឹកទាំងបី (អាម៉ូញាក់ពុល $NH_3$ នីទ្រីត $NO_2$ និង នីត្រាត $NO_3$) ត្រូវគិតជា មីលីក្រាមក្នុង១លីត្រទឹក ដែលមានន័យថាគេធៀបសារធាតុទាំងនេះជាមួយនឹងមាឌទឹក។ នៅពេលដែលអាម៉ូញាក់មិនអាចកំចាត់តាមការរៀបរាប់ខាងលើ វិធានការសាមញ្ញមួយដែលអាចកំចាត់បានគឺ ការប្តូរទឹកដោយបញ្ចេញចោលនៅទឹកកខ្វក់ និងបញ្ចូលទឹកថ្មីល្អ។ នៅពេលនីទ្រីតកើនខ្ពស់ វារីវប្បករអាចប្រើអំបិលក្នុងបរិមាណស្មើនឹង ១០ ទៅ២០ដងនៃកម្រិតនីត្រាតក្នុងទឹក។

**ឧទាហរណ៍ថា** កម្រិតនីត្រាតដែលវាស់ឃើញមាន ០,៥មីលីក្រាមក្នុងទឹក ១លីត្រ ដូច្នេះត្រូវដាក់អំបិល ៥ ទៅ ១០ មីលីក្រាមក្នុងទឹក ១លីត្រ។ ប្រសិនបើតំបន់របស់អ្នកមិនមានទឹកគ្រប់គ្រាន់សម្រាប់ផ្លាស់ប្តូរទេ អ្នកត្រូវមានវិធានការការពារ។ វិធានការការពារនោះ គឺការកំណត់កម្រិតអតិបរមានៃការផ្តល់ចំណីប្រចាំថ្ងៃដោយយកបទពិសោធន៍របស់ខ្លួនកន្លងមកជាគោល។

នៅពេលអាម៉ូញាក់មានកម្រិតខ្ពស់ ត្រីសំកាំងខ្លួន ហើយមិនស៊ីចំណី។ ចំណែកត្រីដែលពុលដោយនីត្រាតវិញ វាធ្វើសកម្មភាពដូចពេលខ្វះអុកស៊ីសែនដែរ។ ត្រីហែលនៅផ្ទៃទឹកខាងលើដើម្បីដកខ្យល់ ហើយឆាប់ផ្អើល។ ការបំពុលដោយនីទ្រីតត្រូវគេឱ្យឈ្មោះថា ជំងឺឈាមពណ៌ត្នោត ព្រោះវាធ្វើឱ្យឈាមត្រីប្រែក្លាយពីពណ៌ក្រហមធម្មតាទៅពណ៌ត្នោត។ នីទ្រីតបំផ្លាញអុកស៊ីសែនក្នុងឈាម ដូច្នេះវាធ្វើឱ្យឈាមត្រីស្វះ។ ចំពោះករណីទាំងពីរខាងលើនេះ វារីវប្បករគួរផ្អាកការផ្តល់ចំណីរហូតដល់ស្ថានភាពប្រែមកប្រក្រតីវិញ។

## កម្រិតថ្លានៃទឹក

ការវាស់វែងកម្រិតថ្លានៃទឹកអាចប្រើឧបករណ៍មួយឈ្មោះថា សេជីឌីស។ កម្រិតថ្លានៃទឹកស្រះអាចកើតមានដោយសារលក្ខខណ្ឌសរីរាង្គបង្កដោយពួកប្លង់តុង និងលក្ខខណ្ឌអសរីរាង្គបង្កដោយដីឥដ្ឋជាដើម។ នៅប្រទេសកម្ពុជា ទឹកភាគច្រើនល្អក់ដោយសារតែម៉ូលេគុលដីឥដ្ឋដែលអណ្តែតតាមប្រភពទឹកនានា ឬក៏ដោយសារការរៀបចំជើងទេររបស់ស្រះមិនបានល្អនាំឱ្យមានការហូរច្រោះពេលភ្លៀងធ្លាក់។

ភាពល្អក់ដែលបង្កដោយម៉ូលេគុលដីឥដ្ឋ បានរារាំងការចាំងចូលក្នុងស្រះរបស់ពន្លឺព្រះអាទិត្យ កាត់បន្ថយដំណើររស្មីសំយោគរបស់ប្លង់តុងរុក្ខជាតិ ដែលនាំដល់ការលំបាកក្នុងការផលិតចំណីធម្មជាតិក្នុងស្រះ និងបង្កឱ្យមានការស្ទះស្រកីត្រី។



រូបភាព សេជីឌីស

នៅក្នុងកសិដ្ឋានផលិតកូនត្រី ឬកសិដ្ឋានផ្សាំកូនត្រី គេប្រើប្រាស់ចំណីរស់ (ជាលក្ខណៈ ធម្មជាតិ) ដូចជាពពួកប្លង់តុងរុក្ខជាតិ ប្លង់តុងសត្វ ដូច្នេះកម្រិតល្អក់ត្រូវតែកាត់បន្ថយដើម្បីធានាថាការផលិតចំណីធម្មជាតិក្នុងស្រះអាចដំណើរការបានជាប្រក្រតី។ វារីវប្បករគួរបង្វែរទឹកចូលក្នុងស្រះបម្រុង ឬប្រឡាយ ជាមុនសិន ដើម្បីឱ្យកករមួយចំនួនរង ឬម្យ៉ាងទៀតវារីវប្បករអាចប្រើសារធាតុគីមីមួយចំនួនដូចជា ទង់ដែងស៊ុលផាតក្នុងកម្រិត ១០ ទៅ ១៥មីលីក្រាមក្នុងទឹក១លីត្រ កំបោរកសិកម្មក្នុងកម្រិត ២ ០០០ ទៅ ៣ ០០០គីឡូក្រាមក្នុង១ហិកតា កាល់ស្យូមស៊ុលផាតក្នុងកម្រិត ១៥០ ទៅ ៣០ មីលីក្រាមក្នុងទឹក១លីត្រ អំបិលក្នុងកម្រិត ១ ០០០ ទៅ ២ ០០០មីលីក្រាមក្នុងទឹក១លីត្រ ឬលាមកសត្វក្នុងកម្រិត ១ ០០០គីឡូក្រាមក្នុង១ហិចតា។ សូមចងចាំថាការប្រើលាមសត្វអាចបណ្តាល ឱ្យកម្រិតអុកស៊ីសែនក្នុងទឹកចុះទាប។



រូបភាព ស្រះដែលមានទឹកល្អក់

ភាពល្អក់បង្ករដោយលក្ខខណ្ឌសរីរាង្គអាចបណ្តាលមកពីបរិមាណប្លង់តុង(ទឹកពណ៌បៃតង) ច្រើនលើសលប់ ដោយសារតែសារធាតុចិញ្ចឹមមានច្រើនក្នុងស្រះ។ ភាពល្អក់បែបសរីរាង្គនេះ អាចបង្កឱ្យកម្រិតអុកស៊ីសែន និងប៉េហាស (pH) ក្នុងស្រះឡើងចុះខ្លាំង ចំពោះស្រះដែលមានអាល់កាឡាំងទាប។ នៅពេលដែលសេជីឌីស មើលឃើញក្នុងជម្រៅទាបជាង ៣០ សង់ទីម៉ែត្រ (៣តឹត) វារីវប្បករអាចប្រើទង់ដែងស៊ុលផាតដើម្បីបន្ថយបរិមាណ ប្លង់តុងក្នុងស្រះ។

បរិមាណទង់ដែងស៊ុលផាតដែលត្រូវប្រើអាចគណនាដោយយកកម្រិតអាល់កាឡាំងចែកនឹង១០០ រួចគុណនឹងមាឌទឹកក្នុងស្រះ។ ខាងក្រោមនេះជាឧទាហរណ៍ចំពោះស្រះទំហំ ០,៥ហិកតា មានជម្រៅ២ម៉ែត្រ ហើយមានកម្រិតអាល់កាឡាំង ៨០មីលីក្រាមក្នុងទឹក១លីត្រ។

៨០មីលីក្រាម ÷ ១០០ = ០,៨មីលីក្រាមក្នុងទឹក១លីត្រ ឬ ០,៨ក្រាមក្នុងទឹក១ម៉ែត្រគូប
០,៥ហិកតា x ១០ ០០០ម៉ែត្រការ៉េ = ៥,០០០ម៉ែត្រការ៉េ x ២ម៉ែត្រ = ១០ ០០០ម៉ែត្រគូប
០,៨ក្រាមក្នុង១ម៉ែត្រគូប x ១០ ០០០ ម៉ែត្រគូប= ៨ ០០០ក្រាម = ៨ គីឡូក្រាម
ប្រើក្នុងកម្រិត៣០ភាគរយនៃ៨ គីឡូក្រាម (៨គីឡូក្រាម x ៣០ភាគរយ) = ២,៤គីឡូក្រាម

## អ៊ីដ្រូសែនស៊ុលផួរ

ឧស្ម័នអ៊ីដ្រូសែនស៊ុលផួរ បង្កឡើងដោយសារជាតុសរីរាង្គមានប្រតិកម្មជាមួយសារធាតុអាស៊ីតបាតស្រះ ពេលដែលអុកស៊ីសែនក្នុងស្រះចុះទាប។ វាចាប់ផ្តើមភាយចេញពេលដែលសារធាតុស៊ុលផួរត្រូវបានមីក្រូសារពាង្គកាយប្រើប្រាស់ ហើយបំលែងដីបាតស្រះទៅជាពណ៌ខ្មៅព្រមទាំងមានក្លិនដូចពងមាន់ស្អុយ។ អ៊ីដ្រូសែនស៊ុលផួរបំពុលត្រីយ៉ាងមានប្រសិទ្ធភាព។ វារីវប្បករអាចគេចចេញពីបញ្ហាទាំងនេះដោយការបាចកំបោរទៅលើដីបាតស្រះដែលមានជាតិអាស៊ីត មិនផ្តល់ចំណីច្រើនហួស និងធ្វើយ៉ាងណាឱ្យ ស្រទាប់បាតនៃស្រះមានអុកស៊ីសែនគ្រប់គ្រាន់។ មុននឹងចាប់ផ្តើមចិញ្ចឹមត្រីវគ្គថ្មី ដីបាតស្រះដែលមានពណ៌ខ្មៅត្រូវតែយកចេញ ហើយហាលបាតស្រះឱ្យស្ងួត បាចកំបោរនិងធ្វើឱ្យមានខ្យល់ចូលក្នុងស្រទាប់ដី (ជីកឱ្យមានអាចម៍បំណះ)។

## កត្តាព្រួយបារម្ភផ្សេងទៀត

នៅប្រទេសកម្ពុជា ទឹកប្រែប្រួលទៅជាបៃតងជ្រុល ឬបៃតងតិចពេកក្នុងអំឡុងពេលទឹកជន់ និងប្រែជាពណ៌ត្នោតនារដូវប្រាំង។ ដោយសារតែប្រទេសកម្ពុជាស្ថិតក្នុងតំបន់ត្រូពិចរដូវកាលចិញ្ចឹមត្រីពឹងផ្អែកលើប្រភពទឹក ប៉ុន្តែមិនមែនសីតុណ្ហភាព ដែលជាមូលហេតុមិនអាចធ្វើការចិញ្ចឹមបានជាប់ជាប្រចាំនោះឡើយ។ ក្រៅពីបញ្ហាប្រភពទឹក ប្រទេសកម្ពុជានៅមានបញ្ហាទាក់ទងនឹងសារធាតុលោហៈធ្ងន់ដូចជាអាសេនិកក្នុងទឹកផងដែរ។ ក្នុងកម្រិតមួយ សារធាតុអាសេនិកបង្កជាជាតិពុល ប៉ុន្តែនៅក្នុងកម្រិតទាប វាធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់និងសុខភាពត្រី។ មុនពេលជ្រើសយកប្រភពទឹកមកចិញ្ចឹមត្រី វារីវប្បករគួរពិនិត្យរកសារធាតុលោហៈធ្ងន់ ឬសារធាតុពុលផ្សេងទៀតដូចជាសារធាតុគីមី ឬទឹកស្អុយ។



រូបភាព៖ ស្រះស្តុកទឹក

# មេរៀន ៖

# កូនត្រីមានគុណភាពខ្ពស់
# សម្រាប់ទីផ្សារ

# កូនត្រីមានគុណភាពខ្ពស់សម្រាប់ទីផ្សារ

## លក្ខណៈវិនិច្ឆ័យលើគុណភាពកូនត្រី

| គុណភាពមិនល្អ | គុណភាពល្អ |
|---|---|
| ទំហំតូច (តូចជាង ៥ក្រាម) | ទំហំធំ (ចាប់ពី ៥ក្រាមឡើង) |
| កូនត្រីមានទំហំមិនស្មើគ្នា | កូនត្រីមានទំហំប៉ុនៗគ្នា |
| កូនត្រីស្គម វែង | មានសាច់ មានរូបរាង និងសម្បុរស្អាត |
| មិនដឹងអាយុរបស់កូនត្រី (ត្រីតូចតែអាយុច្រើនខែ) | ដឹងពីអាយុកូនត្រី ព្រោះផលិតដោយស្ថានីយ៍ដែលមានការកត់ត្រាច្បាស់លាស់ |
| **<u>សុខភាពខ្សោយ</u>**<br>• ស្បែកមានសម្បុរមិនល្អ មានស្នាមជាំ ឬអុចក្រហម<br>• មានភ្នែកលៀន ពោះប៉ោងធំអន្ទិល<br>• រូបរាងមិនប្រក្រតី (ខ្នងកោង)<br>• មិនសូវមានកំលាំង (បណ្តែតខ្លួន)<br>• ផលិតនៅក្នុងស្ថានីយ៍ដែលកខ្វក់ គ្មានរបៀប ហើយប្រើប្រាស់សារធាតុគីមីច្រើនប្រភេទ | **<u>សុខភាពល្អ</u>**<br>• មានសម្បុរស្បែកស្រស់ស្អាត មិនដាច់ រលាត់ ឬរបក ស្រកា(ចំពោះត្រីមានស្រកា)<br>• គ្មានសរីរៈណាមួយខុសប្រក្រតី<br>• រូបរាងល្អស្អាត ជាពិសេសមិនមានដុំពកឬប៉ោង<br>• មានកំលាំង រហ័សរហួន<br>• ផលិតនៅក្នុងស្ថានីយ៍ដែលមានការកត់ត្រាច្បាស់លាស់ មានកេរ្តិ៍ឈ្មោះល្អ និងរៀបចំបានស្អាត |



រូបភាព៖ កូនត្រីមានគុណភាពល្អ




រូបភាព៖ កូនត្រីមិនមានគុណភាព

ដៃគូអនុវត្តគម្រោង៖

- កូនត្រីតូចៗបើទោះជាពូជត្រីមួយចំនួនដែលអាចដកដង្ហើមក្នុងបរិយាកាសបានក៏ដោយ ក៏កូនត្រីតូចៗទាំងនោះមិនអាចស្រូបយកអុកស៊ីសែនពីក្នុងបរិយាកាសបានទេ ហើយពួកវាងាយរងគ្រោះដោយគុណភាពទឹកកខ្វក់។
- ត្រីដែលមានអាយុច្រើនខែតែតូចៗ (ឧទាហរណ៍ កូនត្រីទម្ងន់២ក្រាម អាយុ៣ខែ) មិនអាចមានកម្រិតលូតលាស់លឿនបើប្រៀបធៀបកូនត្រីទំហំប៉ុនគ្នាតែអាយុតិចជាង។
- បើប្រៀបធៀបជាមួយការដាក់ចិញ្ចឹមកូនត្រីធំ កូនត្រីតូចត្រូវការរយៈពេលចិញ្ចឹមយូរជាង (១ខែ) ដើម្បីដល់ទំហំដែលអាចលក់បាន ហើយអ្នកចិញ្ចឹមត្រីតូចត្រូវចំណាយពេល និងចំណី(មានតម្លៃថ្លៃ)។
- ត្រីតូចមានអត្រារស់ត្រឹម៥0 ភាគរយ ឬអាចតិចជាងនេះ ប៉ុន្តែកូនត្រីទំហំធំមានអត្រារស់រហូតដល់ ៩0ភាគរយ
- យើងពិបាកមើលឃើញត្រីតូចងាប់ ដូច្នេះហើយវារីវប្បករមួយចំនួនចេះតែគិតថាត្រីក្នុងស្រះមានចំនួនច្រើន ហើយដាក់ចំណីច្រើន ប៉ុន្តែវារីវប្បករនឹងខកចិត្តនៅពេលប្រមូលផល ហើយហួសពេលតវ៉ាជាមួយអ្នកផលិត(លក់)កូនត្រីពូជទៅហើយ។
- កូនត្រីនៅតូចៗងាយងាប់បំផុត ហេតុអ្វីអ្នកមិនទុកឱ្យអ្នកផលិតកូនត្រីជាអ្នកដោះស្រាយ ហើយអ្នកចាំយកកូនត្រីធំដែលមានហានិភ័យទាបជាងត្រីតូច?



ឧទាហរណ៍៖

កសិករចង់បានត្រី ១០ ០០០ក្បាលនៅពេលប្រមូលផល។ កសិករសុខសម្រេចចិត្តទិញកូនត្រី ២០ ០០០ ក្បាល (គុណភាពមិនល្អហើយតូចៗ) ក្នុងតម្លៃ៨០រៀលក្នុងមួយក្បាលដោយរំពឹងថាចុងក្រោយគាត់នឹងសល់ត្រី ១០ ០០០ ក្បាល។ គាត់ចំណាយលុយ ១ ៦០០ ០០០ លានរៀល។

កសិករសៅសម្រេចចិត្តទិញកូនត្រីធំមានគុណភាពល្អក្នុងតម្លៃ១៥០រៀលក្នុងមួយក្បាល ហើយគាត់ត្រូវការទិញ ១១ ០០០ក្បាល ដើម្បីសល់ត្រី ១០ ០០០ក្បាល នៅពេលប្រមូលផល។ គាត់ចំណាយ ១១ ០០០ គុណនឹង ១៥០រៀល = ១ ៦៥០ ០០០ លានរៀល។

កសិករសៅចំណាយ ៥០ ០០០រៀលច្រើនជាងកសិករសុខ ប៉ុន្តែគាត់ចំណេញពេលវេលាចិញ្ចឹម ការចំណាយចំណីដែលបានប្រើ និងពលកម្ម។

## ស្ថានីយ៍ផលិតកូនត្រីពូជដែលផ្គត់ផ្គង់កូនត្រីមានគុណភាពខ្ពស់គួរតែ៖

- បង្ហាញអ្នកទិញថាស្ថានីយ៍របស់ខ្លួនមានការរៀបចំបានល្អ និងដឹងពីលក្ខខណ្ឌបច្ចេកទេសត្រឹមត្រូវ។ ស្ថានីយ៍មានស្តង់ដាផលិតច្បាស់លាស់ ហើយមិនមានកូនត្រីងាប់ច្រើននោះទេ។
- ព្យាយាមបញ្ចុះបញ្ចូលអ្នកទិញថាស្ថានីយ៍មានការយកចិត្តទុកដាក់ចំពោះអតិថិជនរបស់ខ្លួនដើម្បីឱ្យការចិញ្ចឹមរបស់អតិថិជនទាំងអស់របស់ខ្លួនបានផលចំណេញ។
- ទាក់ទងទៅកាន់អ្នកទិញក្នុងរវាងមួយសប្តាហ៍ក្រោយពេលលក់កូនត្រី ដើម្បីដឹងថាតើកូនត្រីទាំងនោះមានស្ថានភាពបែបណា។
- ពេលខ្លះម្ចាស់ស្ថានីយ៍ត្រូវសុំយោបល់ពីអតិថិជន ដើម្បីកែលំអសេវាកម្មរបស់ខ្លួនបន្ថែម។
- ប្រសិនបើអតិថិជនផ្តល់ព័ត៌មានពីការខូចខាតណាមួយ ម្ចាស់ស្ថានីយ៍ត្រូវស្តាប់គាត់សិន ហើយព្យាយាមសម្របតាមនោះ បើទោះបីជាពេលខ្លះការខូចខាតនោះជាកំហុសរបស់អតិថិជនក៏ដោយ។ ការសម្របសម្រួលអាចជាការសងកូនត្រីពាក់កណ្តាល ឬលក់បញ្ចុះតម្លៃពាក់កណ្តាល។
- ប្រសិនបើមានអ្នកទិញរំអុក ឬទទូចទិញកូនត្រីដែលមានទំហំតូច ឬក៏កូនត្រីដែលមិនទាន់បានបង្វឹកសម្រាប់ដឹកជញ្ជូន ម្ចាស់ស្ថានីយ៍ត្រូវព្យាយាមពន្យល់ថាកូនត្រីទាំងនោះមិនល្អទេ។
- ផ្ទៀងផ្ទាត់មើលថាតើចំនួនកូនត្រីដែលអតិថិជនបានបញ្ជាទិញ ត្រូវនឹងទំហំស្រះ បៃ ឬអាងដែលត្រូវដាក់ចិញ្ចឹមឬទេ។ ការលក់កូនត្រីបានច្រើនអាចធ្វើឱ្យម្ចាស់ស្ថានីយ៍ចំណេញរយៈពេលខ្លី ព្រោះនៅពេលចិញ្ចឹមត្រីមិនបានផលល្អ អ្នកចិញ្ចឹមត្រីទម្លាក់កំហុសលើស្ថានីយ៍ផលិតពូជ ឬចំណី។

**ចំណុចគន្លឹះក្នុងការរក្សាទីផ្សារ៖**

១. កេរ្តិ៍ឈ្មោះល្អត្រូវកសាងរាប់ឆ្នាំ តែវាត្រូវបំផ្លាញអស់តែក្នុងរយៈពេលមួយប៉ប្រិចភ្នែក
២. រឿងអាក្រក់ផ្សាយលឿន ជាងរឿងល្អ (រឿងល្អមានអ្នកចែកចាយតែ៥នាក់ តែរឿងអាក្រក់មានអ្នកចែកចាយ៨នាក់)
៣. រកស៊ីកុំលក់ផ្លូវ ចង់ទុកកេរ្តិ៍ដល់កូនចៅកុំរកស៊ីលក់មុខ
៤. ចង់ចំណេញ ប្រយ័ត្នដាច់ចំណង។





រូបភាព៖ ពិធីចុះកិច្ចសន្យាផ្គត់ផ្គង់កូនត្រីពូជរវាងស្ថានីយ៍បង្កាត់ភ្ញាស់ត្រីពូជ និងអ្នកចិញ្ចឹមត្រី

ដៃគូអនុវត្តគម្រោង៖

# មេរៀន ៖

# ការរៀបចំដឹកជញ្ជូនក្លូនត្រី

# ការរៀបចំដឹកជញ្ជូនកូនត្រី

ជាញឹកញាប់វារីវប្បករត្រូវធ្វើការគ្រប់គ្រង និងដឹកជញ្ជូនត្រីគ្រប់ប្រភេទទាំងអស់ ជាពិសេសកូនត្រីតូចៗត្រូវស្ត្រេសក្នុងអំឡុងពេលដឹកជញ្ជូន។ ប្រសិនបើស្ត្រេសខ្លាំងអាចនាំឱ្យមានជាជំងឺ ឬរហូតដល់ងាប់។ ត្រីដែលស្ត្រេសខ្លាំងពេកអាចមើលទៅដូចជាធម្មតានៅពេលដាក់ចិញ្ចឹមក្នុងស្រះឬបែ ប៉ុន្តែក្រោយមកវាអាចងាប់ក្នុងរយៈពេល២ទៅ៣ថ្ងៃបន្ទាប់។ វារីវប្បករប្រហែលជាមិនជឿថាមានត្រីងាប់ទេដោយសារតែវាមានទំហំតូចពេក ហើយលិចទៅដល់បាតស្រះ ឬត្រូវបានសត្វបក្សីចាប់ស៊ីជាអាហារ នៅពេលដែលវាអណ្តែតទៅផ្ទៃទឹកខាងលើ។

ការអនុវត្តការដឹកជញ្ជូនល្អ គឺជាគន្លឹះក្នុងការផលិតត្រីឱ្យមានសុខភាពរឹងមាំ និងមានអត្រាងាប់ទាប។ បើមិនមានការគ្រប់គ្រង និងដឹកជញ្ជូនឱ្យបានត្រឹមត្រូវទេ នោះទោះបីចាប់ផ្តើមដឹកជញ្ជូនកូនត្រីពូជដែលមានគុណភាពល្អនៅកន្លែងបង្កាត់ភ្ញាស់យ៉ាងណាក៏ដោយ នៅពេលដឹកមកដល់ស្រះចិញ្ចឹម វារីវប្បករនឹងទទួលបាននូវកូនត្រីដែលមានគុណភាពមិនល្អ ឈឺ ហើយនិងងាប់។

## ការគ្រប់គ្រងមុនពេលដឹកជញ្ជូន

ត្រីត្រូវការការថែទាំឱ្យបានត្រឹមត្រូវមុនពេលដឹកជញ្ជូន។ ត្រីមានសុខភាពល្អ រួមផ្សំជាមួយទឹកដែលមានគុណភាពល្អ ធ្វើឱ្យត្រីមានកម្លាំងខ្លាំងអាចទប់ទល់ជាមួយនឹងភាពស្ត្រេសនៅអំឡុងពេលដឹកជញ្ជូនបានប្រសើរជាងដឹកជញ្ជូនត្រីជាមួយទឹកដែលមានគុណភាពមិនល្អ។ ធ្វើការកាត់បន្ថយស្ត្រេសដោយរក្សាគុណភាពទឹកឱ្យបានល្អបំផុតអំឡុងពេលដែលរៀបចំដឹកជញ្ជូន។ នៅពេលដែលត្រីមានចំនួនច្រើនក្នុងធុង អុកស៊ីសែនរលាយក្នុងទឹក (DO) អាចធ្លាក់ចុះយ៉ាងឆាប់រហ័ស ហើយអាម៉ូញាក់ចាប់ ផ្តើមកើនឡើងដែលអាចធ្វើឱ្យត្រីស្ត្រេស និងចុះខ្សោយ។ ធុងដាក់ត្រីគួររៀបចំឱ្យបានល្អ ហើយត្រូវផ្លាស់ប្តូរទឹកដែលមានគុណភាពល្អ ដោយរក្សាបរិមាណអុកស៊ីសែនរលាយក្នុងទឹកឱ្យមានលើសពី៦មីលីក្រាម/លីត្រ និងអាម៉ូញាក់ក្បែរសូន្យ។

ទោះបីជា ត្រីដែលមានប្រព័ន្ធដង្ហើមរង (អាចដកដង្ហើមពីបរិយាកាសបាន) ដូចជាពពួកត្រីប្រា និងត្រីរ៉ស់ ក៏ត្រូវការកម្រិតអុកស៊ីសែនល្អនៅក្នុងទឹក ជាពិសេសនៅពេលដែលពួកវានៅតូច។ នៅពេលដែលត្រីត្រូវការស្រូបយកអុកស៊ីសែនពីបរិយាកាស ពួកវានឹងចុះខ្សោយបន្ទាប់ពីហែលដល់ផ្ទៃទឹកខាងលើ។ វារីវប្បករគួរតែដឹកជញ្ជូនត្រីក្នុងរយៈពេលខ្លី (ពេលរសៀលឬមេឃត្រជាក់) ព្រោះបរិមាណកូនត្រីច្រើន វាអាចនឹងបង្កឱ្យមានជាជំងឺ។

មុនពេលដឹកជញ្ជូន មិនត្រូវឱ្យត្រីស៊ីចំណីយ៉ាងហោចណាស់ ២៤-៤៨ម៉ោង និង២៤ម៉ោងសម្រាប់កូនត្រីម្សៅ ។ វាអាចជួយកាត់បន្ថយបរិមាណអាម៉ូញាក់ និងលាមកត្រីក្នុងអំឡុងពេលដឹកជញ្ជូន។ អនុញ្ញាតអោយត្រីសម្អាតក្រពះ មុនពេលដឹកជញ្ជូននិងជួយកាត់បន្ថយកាកសំណល់ក្នុងទឹកអំឡុងពេលដឹកជញ្ជូន និងកាត់បន្ថយស្ត្រេសដល់ត្រី។

សម្រាប់ត្រីទឹកសាប ត្រូវបន្ថែមអំបិល (NaCL) ក្នុងបរិមាណច្រើនជាង ឬស្មើ ០,១ភាគរយ (១គីឡូក្រាម ក្នុងទឹក ១ ០០០លីត្រ) ដើម្បីការពារ ផ្សិតផ្ទុះស្រកា និងបង្កើនរំអិល (រំអិលជួយការពារត្រី)។ រក្សាភាពរឹងរបស់កាល់ស្យូមក្នុងទឹកក្នុងបរិមាណច្រើនជាងឬស្មើ ៥០ មីលីក្រាមក្នុង១លីត្រ។



*រូបភាពៈ នៅក្នុងអាងអាចបង្កើនអុកស៊ីសែន ហើយកាត់បន្ថយឧស្ម័នកាបូនិច និងកាកសំណល់ដែលមាននៅក្នុងទឹក*





## ជម្រើសដឹកជញ្ជូន

ត្រីតូចៗអាចដឹកជញ្ជូនដោយដាក់នៅក្នុងធុង ដែលមានឧបករណ៍ធ្វើឱ្យទឹកមានចរន្ត ឬអុកស៊ីសែន ឬដាក់នៅក្នុងថង់ប្លាស្ទិចដែលមានអុកស៊ីសែន។ ថង់ប្លាស្ទិចល្អបំផុតសម្រាប់ត្រីដែលមានទំហំតូចបំផុត (តូចជាង៥ក្រាម)។ ចំណែកត្រីដែលមានទំហំធំៗ ត្រូវប្រើប្រាស់ធុង ដែលអាចផ្ទុកបានក្នុងអត្រា ៥០គីឡូក្រាមក្នុង១ម៉ែត្រគូប តែត្រូវកាត់បន្ថយបរិមាណផ្ទុកនៅពេលត្រីមានទំហំកាន់តែធំ ឬរយៈពេលដឹកជញ្ជូនកាន់តែយូរ និងសីតុណ្ហភាពកាន់តែក្តៅ។ វាក៏អាស្រ័យលើតម្រូវការគុណភាពទឹកសម្រាប់ប្រភេទត្រីនីមួយៗ និងភាពធន់របស់វាជាមួយនឹងទឹកដែលមានគុណភាពមិនល្អ។ កត្តាសំខាន់គឺកាត់បន្ថយស្រ្តេស និងផ្តល់ត្រីដែលមានសុខភាពល្អរឹងមាំ។

ចំពោះការគ្រប់គ្រងត្រី អាចប្រើប្រាស់អំបិលក្នុងអំឡុងពេលដឹកជញ្ជូន។ ការធ្វើឱ្យទឹកត្រជាក់ដោយដាក់ទឹកកក (មិនមានសារធាតុក្លរីន) អាចជួយឱ្យត្រីស្ងប់បាន។ កុំបន្ថយសីតុណ្ហភាពទឹកលើសពី ៥អង្សាសេពីសីតុណ្ហភាពដើមភ្លាមៗ តែត្រូវបន្ថយ សីតុណ្ហភាពយឺតៗ រហូតដល់សីតុណ្ហភាពដែលយើងចង់បាន។ ចំពោះត្រីនៅតំបន់ត្រូពិច ត្រូវរក្សាសីតុណ្ហភាពដឹកជញ្ជូនលើសពី ២០អង្សាសេ ។ ជាទូទៅ ទឹកកក ១គីឡូក្រាមក្នុងទឹកចំណុះក្រោម ១០០លីត្រ (ទឹកកក ១០គីឡូក្រាមក្នុង១ម៉ែត្រគូប) អាចបញ្ចុះសីតុណ្ហភាពបាន ១អង្សាសេ។ កុំដឹកត្រីនៅខណៈពេលដែលទឹកកកក្នុងទឹកមិនទាន់រលាយអស់ ព្រោះវាអាចធ្វើឱ្យត្រីមានបញ្ហា ត្រូវរង់ចាំឱ្យទឹកកករលាយសិន។ ចំពោះការដឹកជញ្ជូនដោយប្រើប្រាស់ថង់ប្លាស្ទិច ទឹកកកអាចដាក់នៅខាងក្រៅថង់ជាមួយក្រដាសកាសែត ហើយដាក់នៅចន្លោះថង់ និងកញ្ចប់ទឹកកកដើម្បីការពារកុំឱ្យសីតុណ្ហភាពប្រែប្រួលលឿនពេក។






ដៃគូអនុវត្តគម្រោង៖

## ការប្រើប្រាស់ថង់ដោយមានដាក់អុកស៊ីសែន

វិធីសាស្រ្តសម្រាប់ការវេចខ្ចប់ថង់មានសារសំខាន់ណាស់។ ថង់នីមួយៗ ត្រូវដាក់ទឹក ត្រី និងអុកស៊ីសែនរួចចងមាត់ឱ្យជិត មុននឹងច្រកត្រីទៅក្នុងថង់បន្ទាប់។ ប្រសិនបើថង់បានដាក់ទឹក និងត្រី តែអុកស៊ីសែនបាត់ពីទឹកលឿន ត្រីអាចនឹងស្រេ្តស។ ថង់មួយអាចប្រើបានតែម្តងប៉ុណ្ណោះ។

វាជាការល្អបំផុតក្នុងការប្រើថង់ប្លាស្ទិចដែលចងបាត និងមាត់ជិតល្អ និងដាក់ថង់ប្លាស្ទិកពីរជាន់ដាក់ក្នុងប្រអប់មួយដើម្បីការពារថង់នោះ។ ប្រសិនបើប្រើប្រាស់តែថង់មួយជាន់នោះ ក្នុងករណីធ្លាយថង់យើងត្រូវប្រើប្រាស់ថង់ទ្វេរដង។ ការវេចខ្ចប់គួរតែធ្វើឡើងនៅទីតាំងដែលមានម្លប់ដើម្បីការពារការប៉ះនឹងកម្តៅថ្ងៃ ព្រោះវាអាចធ្វើឱ្យទឹកក្នុងថង់ក្តៅ។

ត្រីជាច្រើនងាយនឹងរងគ្រោះនៅពេលប៉ះពាល់ជាមួយពន្លឺថ្ងៃដោយផ្ទាល់។ ដាក់ថង់កុំឱ្យត្រូវនឹងពន្លឺថ្ងៃក្នុងអំឡុងពេលដឹកជញ្ជូន និងបន្សុំទៅទីតាំង ឬ មជ្ឈដ្ឋានថ្មី ដើម្បីការពារពីកម្តៅថ្ងៃ។

គួរដាក់ទឹកក្នុងថង់ប្រហែល ៣០-៣៥ភាគរយ និងអុកស៊ីសែន ៦៥-៧០ភាគរយ ។ ដាក់ត្រីចូលទៅក្នុងទឹកហើយបិទមាត់ថង់ តែត្រូវទុកចន្លោះសម្រាប់បញ្ចូលអុកស៊ីសែន ចូលទៅក្នុងថង់រួចចងមាត់ថង់។ ក្នុងអំឡុងពេលដឹកជញ្ជូនអុកស៊ីសែនដែលបានបញ្ចូលទៅក្នុងទឹក បានដើរតួនាទីជំនួសអុកស៊ីសែនដែលត្រីបានប្រើប្រាស់។ ដោយសារតែថង់ត្រូវបានចងមាត់ជិត ទើបអុកស៊ីសែនអាចនឹងថយចុះ នៅពេលដែលឧស្ម័នកាបូនិច អាម៉ូញាក់ និងកាកសំណល់រឹងផ្សេងៗកើនឡើង។ ការកើនឡើងនៃឧស្ម័នកាបូនិចក៏ជាកត្តាធ្វើធ្វើឱ្យ ប៉េហាស (pH) ថយចុះដែរ។ ដើម្បីការពារកុំឲ្យប៉េហាស (pH) ធ្លាក់ចុះ ត្រូវប្រើប្រាស់សូដ្យូមប៊ីកាបូណាត (baking soda) បន្ថែមទៅក្នុងទឹកនៅក្នុងថង់ក្នុងបរិមាណ៥០មីលីក្រាមសម្រាប់ទឹក១លីត្រ។






ដៃគូអនុវត្តគម្រោង៖

## ការប្រើប្រាស់ធុងដែលមានដាក់ខ្យល់អុកស៊ីសែន ឬធ្វើឱ្យទឹកមានចរន្ត

ធុងជាច្រើនប្រភេទអាចប្រើសម្រាប់ការដឹកជញ្ជូនត្រី ប្រសិនបើវាមានសភាពស្អាត។ មិនគួរប្រើប្រាស់ធុងដែលវែង និងតូចចង្អៀតនោះទេ ព្រោះកាលណាធុងកាន់តែខ្លី វានឹងបង្កភាពងាយស្រួលសម្រាប់ត្រីដែលត្រូវការឡើងទៅដកដង្ហើមនៅផ្ទៃទឹកខាងលើបាន ប្រសិនអុកស៊ីសែនដែលមាននៅក្នុងធុងមានកម្រិត។ ធុងដែលមានគម្របអាចជួយកាត់បន្ថយការបាត់បង់ទឹក និងកាត់បន្ថយការប៉ះពាល់ពន្លឺថ្ងៃដោយផ្ទាល់ ប៉ុន្តែចាំបាច់ត្រូវបើកគម្របខ្លះដើម្បីឱ្យឧស្ម័នកាបូនិចភាយចេញពីទឹក។ ប្រសិនបើប្រើអុកស៊ីសែនសុទ្ធ ត្រូវមានបំពង់អុកស៊ីសែនគ្រប់គ្រាន់នៅលើយានយន្ត ឬទូកសម្រាប់ធ្វើការផ្លាស់ប្តូរឱ្យបានឆាប់រហ័ស ដើម្បីបង្ការកុំឱ្យអស់អុកស៊ីសែន។ ប្រសិនបើ វ៉ាល់បិទបើកអុកស៊ីសែនធ្លាយ វានឹងបង្កឱ្យមានគ្រោះថ្នាក់ខ្លាំង ហើយអាចផ្ទុះឡើង។ បំពង់អុកស៊ីសែនចាំបាច់ត្រូវមានក្បាលវ៉ាល់បិទបើក និងនាឡិកាថ្លឹងអុកស៊ីសែនទៅធុងត្រីនីមួយៗ។ នៅប្រទេសកម្ពុជា កសិករភាគច្រើនបានប្រើប្រាស់បំពង់អុកស៊ីសែន។ បំពង់អុកស៊ីសែនទម្ងន់ ៦៨ គីឡូក្រាមផ្ទុកអុកស៊ីសែនប្រមាណ ៧ ៩០០ លីត្រ។ បំពង់ខ្យល់ភ្ជាប់ក្បាលបង្ហូរទៅនឹងក្បាលខ្យល់នៅបាតធុង។ គួរត្រួតពិនិត្យអុកស៊ីសែន ក្នុងអំឡុងពេលដឹកជញ្ជូនដើម្បីប្រាកដថារក្សាទុកឱ្យបានប្រហែល ៦-៧ មីលីក្រាមក្នុងទឹក១លីត្រ ឬមានគ្រប់គ្រាន់។ កម្រិតអុកស៊ីសែនខ្ពស់ (ធំជាង ២០ មីលីក្រាមក្នុងទឹក១លីត្រ) អាចបង្កគ្រោះថ្នាក់ដល់ត្រីហើយវាខ្ជះខ្ជាយអុកស៊ីសែន (លុយ)។ អត្រាផ្ទុកនៅក្នុងធុងត្រូវកាត់បន្ថយចំពោះការធ្វើដំណើររយៈពេលវែង ហើយទឹកក៏អាចនឹងត្រូវផ្លាស់ប្តូរដើម្បីកាត់បន្ថយអាម៉ូញាក់។ មិនដូចទឹកក្នុងថង់បិទជិតទេ ឧស្ម័នកាបូនិចអាចភាយចេញពីធុងហើយ ប៉េហាស (pH) មិនមានការផ្លាស់ប្តូរច្រើនទេ។ អាចបន្ថែមអំបិលទៅក្នុងទឹកដូចដែលបានបញ្ជាក់ខាងលើដើម្បីការពារត្រី។




រូបភាព៖ ការដឹកជញ្ជូនកូនត្រីក្នុងធុងបិទជិត

## លក្ខខណ្ឌសម្រាប់លែងត្រីទៅក្នុងមជ្ឈដ្ឋានទឹកថ្មី

ជាញឹយៗ ទឹកដែលប្រើសម្រាប់ដឹកជញ្ជូន ខុសគ្នាពីទឹកនៅទីតាំងថ្មីដែលត្រូវយកត្រីទៅដាក់ចិញ្ចឹម។ ចំពោះទឹកសាប វាមានសារសំខាន់ណាស់ក្នុងការទុកពេលវេលាឱ្យត្រីសម្របខ្លួនទៅនឹងការប្រែប្រួលសីតុណ្ហភាព និង ប៉េហាស់ (pH) រួមទាំងភាពរឹង និងអាល់កាឡាំង។ នៅពេលដែលត្រីត្រូវបានផ្លាស់ប្តូរពីទឹកដែលមានភាពរឹង និងអាល់កាឡាំងខ្ពស់ទៅទាប ត្រីត្រូវសម្របខ្លួន (សារធាតុគីមីនៅក្នុងឈាម) ទៅជាមានសារធាតុរ៉ែតិច ដូចជាកាល់ស្យូម និងម៉ាញ៉េស្យូម។ ត្រីតូចៗឆាប់

មានប្រតិកម្មខ្លាំងណាស់សូម្បីតែការផ្លាស់ប្តូរកម្រិត ប៉េហាស់ (pH) បន្តិចបន្តួច (ឧទាហរណ៍ពី ប៉េហាស់ ៧ ទៅ ៨)។ ការសម្របខ្លួនរបស់ត្រីទៅនឹងការប្រែប្រួលសីតុណ្ហភាពខ្លាំង ត្រូវការពេលវេលាបន្ថែមមុននឹងលែងត្រីចូលក្នុងទឹក។

វិធីងាយស្រួលបំផុតដើម្បីកែសីតុណ្ហភាពដល់ត្រីនៅក្នុងថង់ ត្រូវដាក់ថង់ត្រីចូលក្នុងទឹកថ្មីហើយទុកឱ្យទឹកនៅខាងក្នុងថង់មានសីតុណ្ហភាពដូចទឹកថ្មី។ ត្រូវគ្របថង់ឱ្យជិតដើម្បីជៀសវាងការប៉ះពាល់ពន្លឺព្រះអាទិត្យ និងកំដៅដោយផ្ទាល់។ កុំបើកថង់រហូតដល់ពេលត្រូវលែងត្រីចូលក្នុងទឹក ឬបន្តកែសម្រួល ប៉េហាស់ (pH) ភាពរឹង និងអាល់កាឡាំងនៅក្នុងទឹក។ នៅពេលដែលបើកមាត់ថងអុកស៊ីសែននឹងត្រូវបាត់បង់ ហើយអុកស៊ីសែននៅក្នុងទឹកនឹងថយចុះយ៉ាងឆាប់រហ័ស។ ធ្វើឱ្យទឹកនៅក្នុងថង់មានចរន្ត នៅអំឡុងពេលដែលកែសម្រួលទឹក។ ការបន្ថែមទឹកថ្មីទៅក្នុងថង់យឺតៗ ត្រីនឹងអាចសម្របខ្លួនបាន។ ប្រសិនបើអ្នកដឹងពី សីតុណ្ហភាព ប៉េហាស់ (pH) ភាពរឹងនៃទឹក និងអាល់កាឡាំងរបស់ទឹកនៅពេលដឹកជញ្ជូនត្រី និងទឹកថ្មីដែលត្រូវលែងត្រី នោះអ្នកនឹងដឹងពីរយៈពេលដែលត្រូវឱ្យត្រីអាចសម្របខ្លួនទៅនឹងទឹកថ្មីបានយឺតៗ។ ត្រូវទុកយ៉ាងហោចណាស់ ១៥-៣០នាទី បើសីតុណ្ហភាពទឹកខុសគ្នា ៥អង្សាសេ ឬតិចជាងនេះ ហើយទុកមួយរយៈពេល ១ម៉ោង ប្រសិនបើតុណ្ហភាពខុសគ្នា ១០អង្សាសេ។ នៅពេលលែងត្រីក្នុងបែ ឬស្រះ វាអាចជាការប្រសើរណាស់ប្រសិនបើដាក់ត្រីក្នុងហាប៉ា ឬស្បៃដែលមានក្រឡាតូចដែលមានជម្រៅតិចជាង១ម៉ែត្រ រយៈពេលមួយយប់ ឬពីរទៅបីថ្ងៃ ដើម្បីឱ្យវាអាចសម្របខ្លួនបានទៅនឹងមជ្ឈដ្ឋានទឹកថ្មី។ វាអាចការពារពេលដែលត្រីឈឺហើយត្រូវលិចទៅបាតស្រះឬបែ ដែលមានអុកស៊ីសែនទាបបំផុត។ វាក៏ងាយស្រួល ឱ្យវារីវប្បករ រាប់ត្រី ដែលងាប់ក្រោយពេលដឹកជញ្ជូន និងដឹងចំនួនត្រីដែលនៅសល់ក្រោយពេលដាក់ចិញ្ចឹម។ គួរពិនិត្យត្រីជារៀងរាល់ថ្ងៃយ៉ាងហោចណាស់ឱ្យបានបីថ្ងៃ ដោយសារត្រីអាចស្រ្តេសហើយអាចងាប់ក្នុងរយៈពេលពីរទៅបីថ្ងៃក្រោយពេលដឹកជញ្ជូន។ ត្រួតពិនិត្យគុណភាពទឹកឱ្យបានទៀងទាត់ និងកត់ត្រាទុកឱ្យបានល្អប្រសិនបើមានត្រីងាប់ (គោលការណ៍ណែនាំស្តីពីការអនុវត្តវារីវប្បកម្មល្អ អាស៊ាន សម្រាប់ត្រីបរិភោគ ។ ក្រុងចាកាតា៖ លេខាធិការដ្ឋានអាស៊ាន ខែវិច្ឆិកា ឆ្នាំ២០១៥ ASEAN GAqP for Food Fish, Environmental Integrity #2) ។



រូបភាព៖ ការដាក់កូនត្រីក្នុងហាប៉ាឲ្យសម្របខ្លួននឹងមជ្ឈដ្ឋានថ្មី

# មេរៀន ៖

# ការគ្រប់គ្រងសុខភាពត្រី និងជីវសុវត្ថិភាព

# ការគ្រប់គ្រងសុខភាពត្រី និងជីវសុវត្ថិភាព

ការគ្រប់គ្រងសុខភាពត្រីរាប់ចាប់តាំងពីការទិញកូនត្រីដែលមានសុខភាពល្អ ការអនុវត្តវារីវប្បកម្មល្អ និងជីវសុវត្ថិភាពល្អ។ ជីវសុវត្ថិភាពគឺជាខ្សែសង្វាក់នៃការអនុវត្តដែលកាត់បន្ថយហានិភ័យក្នុងការនាំយកជំងឺ និងការធ្វើឱ្យរីករាលដាលជំងឺពីកសិដ្ឋានមួយទៅកសិដ្ឋានមួយ។ គ្មានកសិដ្ឋានណាមួយដែលមានភាពស៊ាំជាមួយជំងឺនោះទេ។ ចំណុចគន្លឹះ គឺការកាត់បន្ថយហានិភ័យ និងត្រៀមលក្ខណៈក្នុងការឆ្លើយតបយ៉ាងឆាប់រហ័សចំពោះការផ្ទុះឡើងនៃជំងឺណាមួយ ព្រមទាំងកាត់បន្ថយលទ្ធភាពរីករាលដាល។

## ប្រភពនៃជំងឺ

### ត្រីដែលយកមកចិញ្ចឹម

កូនត្រី ឬត្រីពូជគួរតែទិញពីស្ថានីយផលិតកូនត្រីពូជ ឬកសិដ្ឋានផ្សាំដែលអាចទុកចិត្តបាន និងមិនធ្លាប់មានផ្ទុះជំងឺ។ ត្រូវមានការត្រួតពិនិត្យត្រីដែលយកចូលក្នុងកសិដ្ឋានដើម្បីដឹងពីជំងឺ ឬប៉ារាសិតមុនពេលមកដល់ យកល្អគួរតែពិនិត្យដោយអ្នកជំនាញខាងសុខភាពត្រី។ ប្រសិនបើមិនអាចធ្វើបានទេ ក៏គួរតែមើលរោគសញ្ញាមួយចំនួនថាតើត្រីមានដំបៅ ស្រកីប្រែពណ៌ ឬស្ថានភាពត្រីមិនល្អជាដើម។ គួរដាក់ត្រីឱ្យនៅដាច់ដោយឡែក ពីស្រះផលិតកម្ម ហើយតាមអង្កេតមើលពីស្ថានភាពប្រែប្រួលលើរូបរាង និងចរិកលក្ខណៈ (ដូចជាការថយចុះនៃការស៊ីចំណី)។ ក្នុងអំឡុងពេលនេះគឺទុកពេលឱ្យត្រីបានស្រួលខ្លួនឡើងវិញបន្ទាប់ពីការដឹកជញ្ជូន ហើយត្រីអាចសម្របខ្លួនជាមួយទឹកថ្មី ចំណីថ្មី ព្រមជាមួយគ្នានេះ វារីវប្បករអាចត្រួតពិនិត្យពីជំងឺត្រីផងដែរ។



រូបភាព៖ ការពិនិត្យមើលស្លាកស្នាម និងស្ថានភាពត្រីពេលយកមកដល់

ដៃគូអនុវត្តគម្រោង៖

## ទឹកដែលយកមកប្រើប្រាស់ក្នុងកសិដ្ឋាន

ទឹកគឺជាប្រភពនៃពពួកប៉ារាសិត និងជំងឺនានា។ មានតែទឹកអណ្តូងដែលបូមដាក់ក្នុងអាងឬស្រះត្រឹមត្រូវប៉ុណ្ណោះដែលគ្មានភ្នាក់ងារបង្កជំងឺ។ ទឹកទន្លេ បឹង ស្ទឹង ព្រែក ឬប្រឡាយសុទ្ធតែអាចមានភ្នាក់ងារបង្កជំងឺ។ ប្រសិនបើ ប្រភពទឹកទាំងនេះត្រូវបានច្រោះដោយតម្រង ហើយស្តុកទុកក្នុងស្រះដែលគ្មានត្រីរយៈពេល២១ថ្ងៃដើម្បីបំផ្លាញវដ្តជីវិតប៉ារាសិត និងទុកពេលឱ្យពពួកបាក់តេរី និងវីរុសវិវត្តដោយគ្មានត្រីដែលជាម្ចាស់បញ្ញើ។ ទឹកអាចសម្អាតដោយប្រើសារធាតុរ៉ូទែនុន (Rotenone) សម្លាប់ត្រីទាំងអស់ ឬដោយប្រើកំបោររស់ ថ្នាំជក់ជាដើម ដែលអាចសម្លាប់អ្វីៗគ្រប់យ៉ាងក្នុងទឹក។ ការស្តុកទឹកមួយរយៈនេះក៏មានប្រយោជន៍ដល់ការរងកករដែលបង្កដោយសារធាតុអសរីរាង្គពីក្នុងទឹកដែលបញ្ចូលមកប្រើក្នុងកសិដ្ឋាន។

## សត្វផ្សេងៗ

សត្វជាច្រើនដែលផ្លាស់ទីនៅជុំវិញស្រះសុទ្ធតែអាចមានផ្ទុកជំងឺឬអាចជាភ្នាក់ងារនាំជំងឺមកតែម្តង។ សត្វស្លាបមួយចំនួនជាអ្នកចម្លងពពួកបាក់តេរី ឬវីរុស។ ពពួកសត្វស្លាបស៊ីត្រីមួយចំនួនមានផ្ទុកប៉ារាសិត (ដង្កូវខ្លួនសំប៉ែត-ត្រេម៉ាតូ...) ដែលទៅតោងលើពពួកខ្យងក្នុងស្រះ ហើយវិវត្តទៅជាប៉ារាសិតក្នុងខ្លួនត្រី។ នៅកម្ពុជា កង្កែប ក្តាមស្រែ និងសត្វមួយចំនួនទៀតផ្លាស់ទីពីស្រះមួយទៅស្រះមួយហើយអាចនាំទាំងជំងឺទៅជាមួយផង។ វារីវប្បករខ្លះព័ទ្ធស្បៃជុំវិញស្រះដើម្បីកុំឱ្យមានសត្វចេញចូល ដែលអាចការពារទាំងត្រីអណ្តែង ឬត្រីរស់ចេញពីក្នុងស្រះរបស់ខ្លួនផងដែរ។ សារធាតុរ៉ូទែនុន (Rotenone) និងកំបោររស់គួរប្រើនៅក្រោយពេលប្រមូលផល និងមុនពេលដាក់ចិញ្ចឹមដើម្បីសម្លាប់ត្រីដទៃ និងសត្វចង្រៃផ្សេងទៀតនៅក្នុងស្រះ។



រូបភាព៖ ប៉ារាសិតតោងជាប់ស្រកីត្រី

## សម្ភារៈប្រើប្រាស់

វារីវប្បករមិនសូវយកចិត្តទុកដាក់លើការចម្លងជំងឺតាមរយៈឧបករណ៍ប្រើប្រាស់ក្នុងកសិដ្ឋាន ដូចជាមង អួន ធុងដាក់និងដឹកជញ្ជូនត្រី កន្ត្រក កញ្ច្រែង ស្បែកជើងកវែង និងសម្ភារៈប្រើប្រាស់ក្នុងកសិដ្ឋានមួយចំនួនទៀត។ សម្ភារៈទាំងនេះ

កាន់តែគ្រោះថ្នាក់ថែមទៀតពេលយកវាទៅដួស កៀរត្រីឈឺឬត្រីងាប់។ ជំងឺត្រីងាយនឹងរាលដាលតាមរយៈសម្ភារៈដែលសើម ឬប្រឡាក់ភក់ដូចជាអួនជាដើម។ ហាលសម្ងួតសម្ភារៈទាំងនោះមុនប្រើប្រាស់ ដើម្បីសម្លាប់ពពួកភ្នាក់ងារចម្លងជំងឺ ប៉ុន្តែយកល្អគួរលាងដោយទឹកក្តៅអ៊ុនៗនិងដុសសាប៊ូមុននឹងហាល។ គួរលាងដោយបាញ់ទឹកដែលមានសម្ពាធខ្លាំង ជាពិសេសលើអួននិងយានយន្តដើម្បីកំចាត់ភ្នាក់ងារបង្កជំងឺ។ អួនឆាប់ខូច នៅពេលដែលមិនមានពន្លឺថ្ងៃសម្រាប់ហាលគ្រប់គ្រាន់។ អួនអាចលើកពាក់ហាលផុតពីដី។ នៅក្នុងប្រព័ន្ធបង្កាត់ភ្ញាស់ មានឧបករណ៍ជាច្រើន ប្រើប្រាស់តាមដំណាក់កាលផ្សេងៗ ដូច្នេះការលាងសម្អាតជារឿងដែលប្រសើរបំផុត។

## មនុស្ស

បុគ្គលិកឬអ្នកខាងក្រៅមកទស្សនាត្រូវតែមានការណែនាំពីវិធានជីវសុវត្ថិភាព ដែលការពារការនាំជំងឺពីកសិដ្ឋានមួយទៅកាន់កសិដ្ឋានមួយទៀត។ អ្នកខាងក្រៅមកទស្សនាគួរត្រូវបានកំណត់ទីតាំងឱ្យចូលមើល ដើម្បីការពារការចម្លងជំងឺដែលនាំមកពីខាងក្រៅ។ អ្នកមកពីខាងក្រៅត្រូវលាងស្បែកជើងជាមួយទឹកសម្លាប់មេរោគ លាងដៃនិងសាប៊ូ ព្រមទាំងបាញ់អាល់កុលផងដែរ ហើយក្នុងករណីខ្លះគួរពាក់អាវការពារផង។ ការកត់ត្រាព័ត៌មានពីអ្នកចូលទស្សនា ថាតើកសិដ្ឋានណាខ្លះដែលអ្នកទាំងនោះបានទៅដល់ មុនពេលមកចូលមកកសិដ្ឋានរបស់យើង ពិតជាមានសារសំខាន់សម្រាប់ការតាមដានរកប្រភពដើម។ វិធានជីវសុវត្ថិភាពគួរត្រូវធ្វើដូចគ្នា មុនពេលដែលអ្នកទស្សនាចេញទៅវិញ។ បុគ្គលិកត្រូវអនុវត្តវិធានជីវសុវត្ថិភាពជាប្រចាំ ព្រមទាំងធ្វើកំណត់ត្រាផងដែរ។

## ការគ្រប់គ្រងសុខភាពត្រី

គោលដៅនៃការគ្រប់គ្រងសុខភាពត្រីគឺ៖

- ការពារការផ្ទុះជំងឺ
- កាត់បន្ថយលទ្ធភាពកើតជំងឺ
- កាត់បន្ថយកម្រិតធ្ងន់ធ្ងរពេលមានកើតជំងឺ។

លទ្ធភាពដែលភ្នាក់ងារចម្លងជំងឺអាចជ្រៀតចូលក្នុងកសិដ្ឋាន ហើយឆ្លងពីស្រះមួយទៅស្រះមួយ បង្កជាការផ្ទុះជំងឺអាស្រ័យដោយ៖

- **ប្រភេទត្រី៖** ភាពស៊ាំរបស់ត្រី ស្ថានភាពឬសុខភាពត្រី អាយុកាល (ឧ. កូនញាស់ កូនម្រៀ កូនពូជ ត្រីជំទង់) និងកត្តាតំណពូជ
- **បរិស្ថាន៖** គុណភាពទឹក និងការគ្រប់គ្រងទឹក
- **ភ្នាក់ងារចម្លង៖** ជីវសាស្ត្រ វដ្តជីវិត ស៊ាំទៅនឹងការព្យាបាល
- **បុគ្គលិក/កម្មករ៖** ការយល់ដឹងពីវិធានជីវសុវត្ថិភាព និងការប្រតិបត្តិតាមវិធានជីវសុវត្ថិភាព។

គន្លឹះក្នុងការការពារការផ្ទុះជំងឺ គឺទិញត្រីដែលមានសុខភាពល្អពីអ្នកផលិតដែលទុកចិត្តបាន។ មានករណីខ្លះអ្នកផលិតត្រីអាចផ្តល់លិខិតបញ្ជាក់អំពីសុខភាពត្រីថាជាពូជមិនមានជំងឺ ( SPF) ប៉ុន្តែប្រហែលជាមិនធ្លាប់មាននៅប្រទេសកម្ពុជាទេ។ ត្រីអាចត្រូវបានពិនិត្យដោយអ្នកឯកទេសខាងសុខភាពត្រី ដើម្បីដឹងពីជំងឺ។ ការដាក់ត្រីឱ្យនៅដាច់ដោយឡែកមុននិងដាក់ចិញ្ចឹម គឺទុកពេលឱ្យត្រីបន្សាំខ្លួនទៅនឹងបរិស្ថានថ្មី និងចំណីថ្មី បន្ទាប់ពីស្ត្រេសក្នុងអំឡុងពេលដឹកជញ្ជូន

ព្រមទាំងអាចឱ្យវារីវប្បករស្រង់ចេញត្រីដែលងាប់ ឬមើលទៅមានជំងឺ។ ការបង្ហូរទឹកចេញ ឬកប់ចោលត្រីងាប់ត្រូវមានវិធានការត្រឹមត្រូវ។

លក្ខខណ្ឌបង្កឱ្យត្រីស្ត្រេសក្នុងអំឡុងពេលដឹកជញ្ជូន ឬពេលដាក់ចិញ្ចឹម ជាកត្តានាំឱ្យភាពស៊ាំរបស់ត្រីប្រឆាំងជំងឺចុះខ្សោយ។ ជាងនេះទៅទៀត វារីវប្បករត្រូវដឹងពីត្រីរបស់ខ្លួន តម្រូវការរបស់ត្រី (សារធាតុចិញ្ចឹម និងគុណភាពទឹក) ព្រមទាំងអនុវត្តតាមគោលការណ៍គ្រប់គ្រងល្អ។ ភ្នាក់ងារបង្កជំងឺរង់ចាំតែឱកាសសមស្រប នៅពេលដែលសុខភាពត្រីចុះខ្សោយដោយសារស្ត្រេសដើម្បីបង្កជាជំងឺ។ ភ្នាក់ងារបង្កជំងឺមួយចំនួនមានវត្តមានក្នុងស្រះ ឬកសិដ្ឋាន ប៉ុន្តែវាបង្កបញ្ហាតែនៅពេលដែលត្រីស្ត្រេស ជាពិសេសបង្កឡើងនៅពេល**គុណភាពទឹក មិនល្អ** មានជាអាទិ៍ **កម្រិតអុកស៊ីសែនចុះទាប ឬអាម៉ូញាក់ឡើងខ្ពស់**។ វារីវប្បករត្រូវដឹងពីត្រីរបស់ខ្លួន និងតម្រូវការរបស់វា។ ហើយត្រូវដឹងនិងយល់ពីគុណភាពទឹកស្រះរបស់ខ្លួនដែលមានការប្រែប្រួលក្នុងមួយថ្ងៃ។

បើទោះជាអនុវត្តតាមវិធានជីវសុវត្ថិភាពក្តី ភ្នាក់ងារបង្កជំងឺ និងប៉ារាសិតមួយចំនួននៅតែអាចបង្កឱ្យមានជំងឺ។ សូមកុំបារម្ភហួសហេតុពេក ប៉ុន្តែត្រូវត្រៀមជាមុន ដោយដឹងថាតើភ្នាក់ងារបង្កជំងឺ ឬប៉ារាសិតណាដែលកំពុងប៉ះពាល់ត្រី និងត្រូវមានផែនការច្បាស់លាស់សម្រាប់ឆ្លើយតបនឹងស្ថានភាព។

ផែនការរួមមានសកម្មភាពដូចខាងក្រោម៖

- ត្រួតពិនិត្យត្រីរាល់ថ្ងៃ និងកត់សម្គាល់ឥរិយាបទ ឬលក្ខខណ្ឌមិនប្រក្រតី រួចកត់ត្រាជាប្រចាំ
- កត់ត្រាពេលត្រីស៊ីចំណីល្អ និងមិនល្អ
- តាមដាននិងកត់ត្រាគុណភាពទឹកជាប្រចាំ (អុកស៊ីសែនប្រចាំថ្ងៃ អាម៉ូញាក់ និងប៉េហាស ប្រចាំសប្តាហ៍)
- ត្រៀមបញ្ចូលខ្យល់ក្នុងទឹកស្រះពេលដែលកម្រិតអុកស៊ីសែនចុះទាប
- ប្រសិនជាអាច ត្រូវដាក់នៅដាច់ដោយឡែកមួយរយៈ ចំពោះត្រីដែលទើបទិញចូល ឬស្រះដែលមានផ្ទុះជំងឺ និងមិនត្រូវប្រើប្រាស់សម្ភារៈដោយមិនបានលាងសម្អាត ឬធ្វើអនាម័យ។



រូបភាព៖ ការដាក់ត្រីដែលទើបទិញចូលកសិដ្ឋានឲ្យនៅដាច់ដោយឡែក

- ទាក់ទងអ្នកឯកទេសខាងសុខភាពត្រីដើម្បីជួយប្រមូលសំណាកសម្រាប់ធ្វើរោគវិនិច្ឆ័យ។
- ត្រូវមានអ្នកជំនាញជំងឺវារីសត្វដែលធ្លាប់ពិនិត្យ និងមានជំនាញលើការចិញ្ចឹមត្រីពូជដូចគ្នា និងអាចចេញវេជ្ជបញ្ជារពេលដែលចាំបាច់ត្រូវព្យាបាល។ មិនត្រូវធ្វើរោគវិនិច្ឆ័យខ្លួនឯង និងមិនត្រូវព្យាបាលដោយខ្លួនឯងនោះឡើយ ។
- ដឹងថាតើត្រូវទៅកន្លែងណាពេលដែលត្រូវព្យាបាលត្រី និងដឹងពីវិធីប្រើប្រាស់ថ្នាំឬសារធាតុផ្សេងឱ្យបានត្រឹមត្រូវ
- គួរតែមានសារធាតុសាមញ្ញមួយចំនួនជាប្រចាំដូចជាអំបិល ប៉ូតាស្យូមពែម៉ង់កាណាត ហ្វ័រម៉ុល(ហ្វ័រម៉ាលីន) ឬអ៊ីដ្រូសែនពែរអុកស៊ីត (ទឹកអុកស៊ីសែនណេ) តាមលទ្ធភាពដែលអាចរកបាន និងមានសារធាតុសម្លាប់មេរោគសម្រាប់សម្អាតអាង និងសម្ភារៈផ្សេងៗ។

## បញ្ជូនសំណាកត្រីដើម្បីធ្វើរោគវិនិច្ឆ័យ

វាមានសារសំខាន់ណាស់ក្នុងការប្រមូលត្រីឈឺ(នៅរស់) និងសំណាកទឹកដើម្បីធានាឱ្យបាននូវការវិភាគលើជំងឺ ឬប៉ារាសិតច្បាស់លាស់។ ត្រីតែងតែបង្ហាញសញ្ញាជំងឺឬប៉ារាសិត។ សំណាកដែលល្អ គួរមានដាក់ត្រីមួយចំនួនដែលបង្ហាញសញ្ញាមិនប្រក្រតី។ ត្រីដែលមានឥរិយាបទមិនប្រក្រតីមានដូចជាសំកាំងលើផ្ទៃទឹក ឬសសៀរនៅកន្លែងរាក់ៗ មិនមានចលនាផ្លាពោះ ហែលមិនមានទិសដៅច្បាស់លាស់ ត្រដុសខ្លួនជាមួយវត្ថុផ្សេងៗ ឬមកផ្តុំគ្នាកន្លែងទឹកហូរចូល។ ដើម្បីប្រមូលត្រីឈឺ វារីវប្បករត្រូវដើរជុំវិញស្រះ ឬអាងដោយមានកន្ត្រងដួស ឬសំណាញ់ រួចដួស ឬបង់យកត្រីដែលមើលទៅឈឺ ឬមានលក្ខណៈមិនប្រក្រតី។ ប្រសិនបើបង់យកត្រីឈឺមិនបានទេ ត្រីដែលងាប់ភ្លាម មានស្រកីពណ៌ក្រហម (មិនស្លេក) និងភ្នែកមើលទៅដូចត្រីនៅរស់ អាចប្រើជាសំណាកបានដែរ។ ដាក់សំណាកត្រីឬត្រីដែលងាប់ភ្លាមៗ លើទឹកកកត្រៀមសម្រាប់ដឹកជញ្ជូន។ មិនត្រូវបង្កកសំណាកត្រីនោះទេ។ អនុវត្តតាមការណែនាំរបស់អ្នកឯកទេសសុខភាពត្រីឬមន្ទីរពិសោធន៍។ ត្រីឈឺ(ដែលនៅរស់) ដឹកទៅធ្វើវិភាគនៅមន្ទីរពិសោធន៍ ត្រូវដាក់ក្នុងធុងមានទឹកបិទគម្រប (សម្រាប់ការដឹកជញ្ជូនក្រោមមួយម៉ោង) ឬដាក់ក្នុងថង់ប្លាស្ទិចមានទឹក និងបញ្ចូលអុកស៊ីសែន (មិនមែនបញ្ចូលខ្យល់) សម្រាប់ការដឹកជញ្ជូនរយៈពេលវែង។ គួរភ្ជាប់សំណាកទឹកប្រហែល៥០០មីលីលីត្រជាមួយ។ ភ្ជាប់ជូននូវកំណត់ត្រាគុណភាពទឹក និងកំណត់ត្រានានាអំពីស្រះ ឬអាងដែលត្រីមានបញ្ហា។

## ការព្យាបាលត្រី

ត្រូវអនុវត្តតាមការណែនាំរបស់អ្នកឯកទេសសុខភាពត្រី ដោយប្រើប្រាស់ឱ្យត្រឹមត្រូវទាំងបរិមាណ និងកម្រិតប្រើប្រាស់ (doses) និងពេលវេលាកំណត់ បើទោះជាឃើញថាត្រីវិលមករកភាពប្រក្រតីហើយក៏ដោយ។ ការខកខានមិនបានធ្វើឱ្យចប់ចុងចប់ដើមនៃការព្យាបាលដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិក ឬប្រើខុសប្រភេទអង់ទីប៊ីយ៉ូទិក និងធ្វើឱ្យមានភាពស៊ាំលើថ្នាំអង់ទីប៊ីយ៉ូទិក ដែលពិបាកព្យាបាលនៅពេលក្រោយ។

ASEAN GAqP. Guidelines on ASEAN Good Aquaculture Practices (ASEAN GAqP) for Food Fish. Jakarta: ASEAN Secretariat, November 2015.

# មេរៀន ៖

# របៀបរក្សាទុកចំណីត្រី និងចំណីសត្វផ្សេងៗឱ្យបានត្រឹមត្រូវ

# របៀបរក្សាទុកចំណីត្រី និងចំណីសត្វផ្សេងៗឱ្យបានត្រឹមត្រូវ

ក្រុមហ៊ុនផលិតចំណីត្រីនានាតែងតែទាមទារអាយុកាលរក្សាទុកឱ្យបានយូរពី៣ទៅ៦ខែ។ រយៈពេលរក្សាទុកគឺគិតចាប់ពីកាលបរិច្ឆេទផលិត។ ការរក្សាទុកក្នុងពេលដ៏យូរមួយ អាចធ្វើទៅបាន បើសិនចំណីត្រូវបានរក្សាទុកក្នុងទីត្រជាក់ខ្លាំង ហើយស្ងួត ដូចជាការរក្សាទុកក្នុងទូក្លាស់សេ។ ចំពោះផលិតផលខ្លះ មានដាក់លាយផ្សំសារធាតុទប់អុកស៊ីតកម្មនៅក្នុងចំណីដើម្បីជួយអូសបន្លាយការរក្សាទុកឱ្យបានយូរ។ ជួនកាលប្រភេទវីតាមីនមួយចំនួនត្រូវបានដាក់លើសកម្រិតតិចតួចដើម្បីការពារការខូចខាតក្នុងរយៈពេលណាមួយផងដែរ។ ដើម្បីរក្សាសុវត្ថិភាព ចំណីគួរតែប្រើប្រាស់ក្នុងកំឡុងពេល ១ខែ ឬ ២ខែ នៃការផលិត។

ទោះជាយ៉ាងណាក៏ដោយ ចំណីអាចខូចគុណភាពយ៉ាងឆាប់រហ័ស ដូច្នេះបច្ចេកទេសរក្សាចំណីទុកបានត្រឹមត្រូវជាការចាំបាច់ណាស់។

ជាដំបូង គឺត្រូវរៀបចំជាប្រព័ន្ធទុកដាក់មួយ ដើម្បីចាត់ចែងរៀបចំទុកដាក់ចំណី នៅក្នុងបន្ទប់ ឬក្នុងអគារ គឺថាចំណីចាស់ ត្រូវទាញយកមកប្រើប្រាស់មុន។ យើងហៅថា "**ចូលមុនចេញមុន**"។ ឃ្លាំងស្តុកចំណីត្រូវតែរៀបចំឱ្យមានរបៀប ដូច្នេះអ្នកលក់អាចយកចំណីចាស់ចេញក្រៅ ដែលជាចំណីស្តុកពីមុន ហើយមិនត្រូវដាក់ចំណីដែលទើបដឹកមកដល់ឃ្លាំងថ្មីៗឱ្យរាំងស្ទះនោះទេ។ កម្មករឃ្លាំងគួរទទួលបានការណែនាំនានាឱ្យបានច្បាស់លាស់ ថាតើចំណីមួយណាដែលត្រូវយកចេញមកប្រើមុន។ អ្នកលក់ខ្លះចងខ្សែពណ៌សំគាល់ចំណាំលើបាវចំណីចាស់ មុនការដាក់ចំណីថ្មីចូលស្តុក។ ដូចនេះកម្មករឃ្លាំងដឹងថាត្រូវយកចំណីដែលមានគូសចំណាំយកមកប្រើមុនគេ។

គ្រប់ចំណីទាំងអស់ ត្រូវតែដាក់ឱ្យផុតពីផ្ទៃកម្រាលបាតក្រោម និងគម្លាត ១តឹកកន្លះ (១៥សង់ទីម៉ែត្រ) ពីជញ្ជាំងនៃអគារឃ្លាំងស្តុកចំណី។ បាឡែត ឬជើងទម្រត្រូវធ្វើពីឈើស្ងួតឬជ័រដែលប្រើជាទម្រដាក់ស្តុកចំណីឱ្យផុតពីផ្ទៃកម្រាលបាតក្រោម។ បាវចំណីគួរតែត្រូវដាក់តម្រៀបតាមលំដាប់លំដោយ តាមលំនាំគំរូណាមួយ ហើយធ្វើដូច្នេះ ការដាក់តម្រៀបបាវចំណីគឺអាចមានលំនឹងដោយខ្លួនឯងបាន គឺថាដោយមិនចាំបាច់ពឹងជញ្ជាំងឡើយ។ បាវចំណីត្រូវដាក់ឃ្លាតពីជញ្ជាំង ១តឹកកន្លះ (១៥ សង់ទីម៉ែត្រ) ឬឆ្ងាយជាងនេះ។ នៅពេលបាវចំណីប៉ះជញ្ជាំង ដោយសារសីតុណ្ហភាពខុសគ្នា វាបង្កឱ្យមានជាសំណើមរាលដាលជ្រាបចូលបាវចំណី ជាហេតុធ្វើឱ្យមានដុះពពួកផ្សិត។ ដូច្នេះហើយ ទោះបីចំណីស្ងួតក៏ដោយ ក៏អាចដុះផ្សិតបានដែរ បើសិនជាដាក់បាវចំណីប៉ះជាប់នឹងជញ្ជាំង ឬដាក់ផ្ទាល់នឹងផ្ទៃកម្រាលបាតក្រោម។





ឃ្លាំងចំណីគួរតែមានវិធីការពារមិនឱ្យពពួកសត្វល្អិតចង្រៃផ្សេងៗចូលក្នុងឃ្លាំងបាន។ មានន័យថាចាំបាច់ត្រូវមានរន្ធខ្យល់ ដើម្បីឱ្យមានខ្យល់ចេញចូល ហើយក៏អាចដាក់សំណាញ់ដែកក្រាស់ៗ ពិដានក៏ដាក់សំណាញ់ដែកក្រាស់ការពារមិនឱ្យសត្វល្អិតចង្រៃចូលបានដែរ។ ជាជម្រើស បើសិនជាឃ្លាំងមិនត្រូវតាមស្តង់ដា បាវចំណីគួរតែរក្សាស្តុកទុកក្នុងបន្ទប់សំណាញ់ ឬទូដែលតម្លើងក្នុងឃ្លាំងដូចរូបភាពខាងក្រោម៖



ក. បាវចំណីក្នុងឃ្លាំងស្តុកនៅលើជើងទម្រ និងឆ្ងាយពីជញ្ជាំងនៃអគារឃ្លាំងដើម្បីការពារសំណើមចូលទៅប៉ះបាវចំណី។នេះជាការការពារពពួកសត្វកកេរមិនឱ្យចូលបាន។



ខ.បាវចំណីស្តុកក្នុងទ្រុង ឬទូឈើ ឬទូសាមញ្ញ និងសំណាញ់ដែកពណ៌កាហ្វេព័ទ្ធជុំវិញមិនឱ្យសត្វល្អិតចូលបាន។

**ការណែនាំផ្សេងៗ៖**

- ជាការល្អគួរមានតារាងកត់ត្រាមួយសម្រាប់កត់ត្រាចំណីដែលត្រូវថ្លឹងចេញពីឃ្លាំង ឬទូស្តុកចំណី។ ម្យ៉ាងទៀតគួរមានឧបករណ៍ចូក ឬដួសចំណី អំបោស និងធុងសម្រាមនៅក្នុងឃ្លាំងចំណី។
- វាមិនមែនជាគំនិតល្អនោះទេដែលស្តុកចំណី និងមងសំណាញ់ក្នុងឃ្លាំងតែមួយ។ សត្វល្អិតចង្រៃនានានឹងរកចំណីស៊ី ហើយធ្វើសំបុកនៅលើមងសំណាញ់ និងបង្កើតរន្ធសត្វល្អិតជាច្រើននៅជាប់នឹងសំណាញ់ដែក។
- អ្វីក៏ដោយដែលអាចធ្វើឲ្យកខ្វក់ ខូច ឬលួយចំណី ដូចជា ប្រេង សារធាតុពុល សម្រាប់បំពុល សត្វល្អិតចង្រៃ មិនគួររក្សាទុកក្នុងឃ្លាំងចំណីនោះទេ។ អន្ទាក់ ឬឧបករណ៍ចាប់ ឬបំពុលសត្វល្អិតចង្រៃនានា គួរដាក់វានៅខាងក្រៅឃ្លាំងចំណី។
- សំបកបាវចំណី (បាវទទេ) មិនគួរដាក់គរគ្នានៅក្នុងឃ្លាំងចំណីឡើយ ពីព្រោះបាវទាំងនោះ ជាជម្រក ឬសំបុកដល់ពពួកសត្វកកេរនានា។

ដៃគូអនុវត្តគម្រោង៖

**សេចក្តីសង្ខេប**

នៅកសិដ្ឋាន ចំណីគួររក្សាទុកក្នុងទីស្ងួតមានខ្យល់ចេញចូលបានល្អ ហើយនៅក្នុងបន្ទប់ដោយដាក់ចំណីផុតពីផ្ទៃកម្រាលបាតក្រោម និងឃ្លាតពីជញ្ជាំង។ មិនត្រូវស្តុកចំណីដូចខាងក្រោមនេះឡើយ ៖

១. មិនត្រូវទុកដាក់ចំណីប៉ះផ្ទាល់នឹងពន្លឺថ្ងៃ និងផ្ទាល់ដីនោះទេ ។

២. មិនត្រូវទុកដាក់ចំណីនៅទីសើម ឬបរិវេណមានសំណើម ។

៣. មិនត្រូវទុកដាក់ចំណីនៅទីដែលមានសត្វកណ្តុរ ឬសត្វកកេរ និងសត្វចិញ្ចឹមចូលទៅដល់កន្លែងដាក់ចំណីទេ។

៤. មិនត្រូវទុកដាក់ចំណីក្នុងបន្ទប់ដែលមានដាក់សារជាតិគីមីពុលដូចជា ថ្នាំសម្លាប់សត្វល្អិតជាដើម។

៥. មិនត្រូវទុកដាក់ចំណីជាមួយរបស់ប្រើប្រាស់ផ្សេងៗទៀតក្នុងកសិដ្ឋាននោះឡើយ។

៦. មិនត្រូវដាក់ចំណីនៅក្នុងបន្ទប់បិទជិត ដោយមិនមានខ្យល់ចេញចូលនោះទេ។

# មេរៀន ៖

# ការត្រួតពិនិត្យលក្ខណៈរូប
# នៃចំណីត្រី

# ការត្រួតពិនិត្យលក្ខណៈរូបនៃចំណីត្រី

ចំណីដែលផលិតដោយម៉ាស៊ីនផលិតចំណីណាមួយក៏ដោយ គួរតែមានស្លាកបញ្ជាក់ពីកាលបរិច្ឆេទផលិតនិងលេខសម្គាល់ជាច្រើនទៀត និងគួរតែចុះបញ្ជីពីសមាសភាពប្រហាក់ប្រហែលនៃសារធាតុផ្សំ។ ជារឿយៗសមាសភាពប្រហាក់ប្រហែលនៃធាតុផ្សំនឹងចុះបញ្ជីពីកម្រិតសំណើមអតិបរមា កម្រិតប្រូតេអ៊ីនអប្បបរមា ការរៀបចំកម្រិតសារធាតុខ្លាញ់ (ទាំងកម្រិតអតិបរមានិងអប្បបរមា) កម្រិតអតិបរមានៃសារធាតុសសៃនិងផេះជាដើម ។







ចំណីមួយដែលមានកម្រិតប្រូតេអ៊ីនតិចជាងចំណីមួយប្រភេទផ្សេងទៀត វានៅតែអាចប្រើប្រាស់បានល្អ បើសិនប្រូតេអ៊ីននោះត្រូវបានផ្សំឡើងពីប្រភពដែលងាយរំលាយអាហារកម្រិតខ្ពស់ និងបើសិនសារធាតុអាមីណូអាស៊ីតត្រូវបានរក្សាលំនឹងគុណភាពសម្រាប់តម្រូវការនៃប្រភេទត្រីនីមួយៗ។ ដូច្នេះ ទោះបីជាភាគរយនៃប្រូតេអ៊ីនសំខាន់យ៉ាងណាក៏ដោយ ក៏មិនមែនជាកត្តាតែមួយគត់ដើម្បីពិចារណាបានឡើយ។

ក្រៅពីនេះ នៅលើសំបកបាវចំណីក៏មានបង្ហាញពី "**សមាសធាតុផ្សំ**"។ ដោយយោងតាមនិយតកម្ម សមាសធាតុផ្សំទាំងឡាយ អាចត្រូវបានគេសរសេរលើសំបកបាវតាមលំដាប់លំដោយ ឬអាចជាការសរសេរទម្រង់ទូទៅ ដូចជាពាក្យថា "**មានសមាសភាពផ្សំដូចខាងក្រោម**"។

**ការវេចខ្ចប់៖** ការវេចខ្ចប់ជួយទប់ស្កាត់សំណើមចូលទៅក្នុងចំណី។ បើសិនប្រើបាវក្រដាស គឺត្រូវស្រោបដោយថង់ប្លាស្ទិចនៅផ្នែកខាងក្នុង។

**នៅពេលពិនិត្យមើលចំណីផ្ទាល់ ត្រូវយកសំណាកចេញ និងធ្វើការកត់សម្គាល់ដូចតទៅ៖**

**ភាពស៊ីគ្នានៃពណ៌៖** បើសិនយើងពិនិត្យមើលពណ៌ ចំណីមានពណ៌ខុសៗគ្នា នោះវាប្រហែលមកពីសារធាតុផ្សំកិនមិនម៉ត់ល្អ។ ការកិនសារធាតុផ្សំមិនបានម៉ត់ល្អនិងគ្រប់គ្រាន់ បណ្តាលមកពីការចម្អិនមិនបានល្អ ដូច្នេះហើយធ្វើឱ្យមានកម្រិតរំលាយអាហារមិនបានល្អផងដែរ។ វារីវប្បករខ្លះចូលចិត្តទិញចំណីដែលមានពណ៌ក្រម៉ៅ ពីព្រោះពួកគាត់គិតថាចំណីនោះមានផ្ទុកម្សៅត្រីច្រើន។ ក៏ប៉ុន្តែក្រុមហ៊ុនខ្លះ បានបន្ថែមស្ករអង្គ ឬកាកស្ករដើម្បីធ្វើឱ្យចំណីមានពណ៌ក្រម៉ៅ ដូចនេះការកំណត់ពណ៌ចំណី មិនប្រាកដថាជាការសម្គាល់ចំណីមានគុណភាពល្អឡើយ។

ចំណីគ្រាប់ ត្រូវមានរាងសណ្ឋាននិងទំហំដូចៗគ្នា និងមើលទៅរាងស្មើរតែមានរាងមូល។ នៅពេលចំណីគ្រាប់មានប្រវែងបណ្តោយនិងទទឹងដូចគ្នា វាងាយឱ្យត្រីស្រួលលេប។ បើសិនចំណីគ្រាប់មានទំហំខុសៗគ្នា នោះចំណីគ្រាប់ខ្លះ ធំៗពេកសម្រាប់ត្រីស៊ី។

បន្ទាប់ពីធ្វើការត្រួតពិនិត្យចំណីគ្រាប់រួចហើយ ត្រូវធ្វើតេស្តសាកល្បងសំណាកនៅក្នុងកែវឬក្នុងកែវថ្លា លាយជាមួយទឹកដើម្បីវាយតម្លៃ ការជ្រាបទឹកក្នុងចំណី ភាពអណ្តែតលើទឹក និងធាតុបន្សំចម្រុះផ្សេងៗដែលគេហៅថា "**ភាពមានលំនឹង**" ។

**ការជ្រាបទឹក៖** បើសិនចំណីទំនងជាបាត់បង់ពណ៌នៅក្នុងទឹក នេះមានន័យថា វាកំពុងជ្រាបសារជាតិចិញ្ចឹមពីក្នុងចំណីចូលក្នុងទឹក។ នេះមានន័យថា ពេលយើងឱ្យចំណីត្រីស៊ី យើងមិនចាំបាច់ចាក់ចំណីភ្លាមៗទេ ធ្វើឱ្យសារជាតិចិញ្ចឹមមួយចំនួននឹងបាត់បង់ដោយសារការជ្រាបចូលក្នុងទឹក។

**ការអណ្តែតលើទឹក៖** ភាគរយអណ្តែតលើទឹកអាចត្រូវបានវាយតម្លៃដោយការរាប់ចំណីចំនួន១០០គ្រាប់ នៅក្នុងធុងទឹក ថាតើមានចំនួនប៉ុន្មានគ្រាប់នៅអណ្តែតលើទឹក នៅក្នុងរយៈពេលណាមួយនោះ (ជាធម្មតាប្រើពេល១ម៉ោងឬយូរជាងនេះ)។ វាជាការលំបាក(និងមានតម្លៃថ្លៃ) ក្នុងការផលិតចំណីគ្រាប់តូចៗ(ទំហំតូចជាង២មីលីម៉ែត្រ) ដែលអណ្តែតលើទឹក។ ចំណីគ្រាប់អណ្តែតលើទឹកនៅពេលណាម្សៅនៅក្នុងចំណីត្រូវបានចម្អិនល្អ និងចំនួនម្សៅក្នុងចំណីក៏គ្រប់គ្រាន់ដែរ។ ត្រីមិនត្រូវការម្សៅទេ ក៏ប៉ុន្តែម្សៅធ្វើឱ្យចំណីអណ្តែតលើទឹក ដូច្នេះម្សៅត្រូវការចាំបាច់ ហើយម្យ៉ាងទៀតម្សៅមានតម្លៃថោក។ បើសិនចំណីលិចគឺត្រូវបានប្រើក្នុងគោលបំណងផ្សេង យើងគួរតែឱ្យចំណីយឺតៗជាងចំណីអណ្តែត សម្រាប់ប្រភេទត្រីមួយចំនួនដែលមិនចាប់ចំណីនៅបាតស្រះ។

**សារធាតុផ្សំចម្រុះ៖** ពាក្យនេះមានន័យថា រយៈពេលយូរប៉ុណ្ណាដែលចំណីគ្រាប់នេះរក្សាទម្រង់របស់វាបាន។ វាប្រហែលអូសបន្លាយពេលបានយូរបន្តិចនៅពេលវាស្រូបទឹក ក៏ប៉ុន្តែចំណីគ្រាប់ដែលមានសារធាតុផ្សំចម្រុះល្អ គឺនៅរក្សាទម្រង់ដើមដដែលនៅពេលដាក់ក្នុងទឹក។ ចំណីគ្រាប់ដែលចម្អិនមិនបានល្អ ឬដោយមានម្សៅផ្សំកម្រិតទាបនឹងធ្លាក់បំណែកចំណីយ៉ាងលឿនចូលក្នុងទឹក ហើយត្រីមិនអាចចាប់បានគ្រប់សារធាតុចិញ្ចឹមក្នុងចំណីគ្រាប់នោះបានទេ។

ចំណីគ្រាប់ដែលមានសារធាតុផ្សំចម្រុះមិនល្អនឹងធ្លាក់ទៅបាតស្រះហើយចុងក្រោយក្លាយជាសារធាតុបំពុលទឹកច្រើនជាងចំណីអណ្តែតដែលមានសារធាតុផ្សំចម្រុះល្អ។ បើសិនឃើញផ្នែកខ្លះនៃចំណីអណ្តែតលើទឹក ហើយវារីវប្បករមិនបានយល់ដឹង គាត់ប្រហែលជាបានផ្តល់ចំណីត្រីឱ្យត្រីស៊ីលើសលប់ផងដែរ ដូច្នេះវាជាការខ្ជះខ្ជាយលុយកាក់ពីចំណីដែលត្រីមិនស៊ីលិចទៅបាតស្រះនិងបំពុលទឹកស្រះទៀតផង។

## លក្ខណៈខាងក្រៅរបស់ចំណី៖

តើចំណីគ្រាប់**ផ្តុំជាប់គ្នាជាដុំៗឬទេ**? នេះអាចសម្គាល់ដឹងថាចំណីត្រូវទឹកសើមនិងមានផ្សិតដុះ។ តើចំណីនេះបាត់ពណ៌មែនទេ (ផ្ទៃចំណីគ្រាប់ឡើងពណ៌ប្រផេះស្រាលៗឬប្រផេះបៃតង)? នេះក៏មានន័យថាចំណីគឺមានដុះផ្សិតដែរ។ ពពួកផ្សិតនៅលើចំណីអាចបង្កើតជាតិពុលដែលធ្វើឱ្យអន្តរាយដល់ការលូតលាស់និងសុខភាពរបស់ត្រី។

វារីវប្បករចិញ្ចឹមត្រីតែងតែ**ហិតក្លិន**ចំណីស្ទើរគ្រប់ចំណី។ វារីវប្បករគិតថា បើសិនចំណីមានធំក្លិនឆ្អាបគឺជាការល្អ។ នេះមិនជាករណីចាំបាច់ទេ។ ក៏ប៉ុន្តែបើសិនចំណីធំក្លិនខា ឬធំក្លិនដូចត្រីស្អុយ នោះអាចជាបញ្ហា។

តើចំណីគួរតែមានសភាព**ភ្លឺរលោងឬ**? វារីវប្បករទំនងលំអៀងចូលចិត្តចំណីដែលមើលឃើញសភាពភ្លឺរលោង។ ក្រុមហ៊ុនផលិតចំណីជាច្រើន ប្រើប្រេង ឬជាតិខ្លាញ់ស្រោបលើចំណី ដូច្នេះមើលទៅភ្លឺរលោង។ ជាតិប្រេងនេះ អាចជួយកាត់បន្ថយកំទេចធូលីក្នុងចំណី។ ការស្រោបប្រេង ឬខ្លាញ់ជាទ្រនាប់លើចំណីគ្រាប់ ជួយធ្វើឱ្យចំណីមានជាតិប្រេង ឬខ្លាញ់ខ្ពស់ ពីព្រោះដោយសារជាតិប្រេងឬខ្លាញ់ ច្រើនតែមួយមុខគត់អាចត្រូវបានបន្ថែមទៅលើចំណីគ្រាប់។ វាមិនតម្រូវឲ្យប្រើជាទ្រនាប់លើចំណីទេ ដោយសារវាងាយបាត់បង់គុណភាពដោយសារកម្ដៅ តែគេអាចប្រើបានសម្រាប់ទាក់ទាញការចាប់ស៊ីចំណីរបស់ត្រី។

ជាចុងបញ្ចប់ ចំនួនបរិមាណ**សារធាតុល្អិតម៉ត់**នៅក្នុងចំណី មានសារៈសំខាន់ណាស់។ សារធាតុល្អិតម៉ត់ គឺជា លទ្ធផលមួយនៃចំណីគ្រាប់ដែលមានផ្ទៃគគ្រើមខ្លាំងដែលត្រដុសកកិតនៅពេលយកចំណីមកប្រើ។ សារធាតុល្អិតម៉ត់ជាច្រើននៅក្នុងចំណីធ្វើឱ្យបំពុលទឹក ពីព្រោះសារធាតុល្អិតម៉ត់នេះ ជាធម្មតាគឺត្រីមិនស៊ីទេ។ ភាគរយសារធាតុល្អិតម៉ត់ អាចត្រូវវាស់កម្រិតវាបាន ដោយប្រើកន្ត្រងសម្រាប់មើលសំណាកចំណី។ ត្រូវតែមានការប្រុងប្រយ័ត្នក្នុងការប្រើកន្ត្រងសម្រាប់ធ្វើជាសំណាកតំណាង។ បើសិនជាបាវចំណីបញ្ឈរ នៅពេលខ្លះសារធាតុល្អិតម៉ត់នេះ ធ្លាក់ចុះក្រោមទៅបាតបាវ ។ សារធាតុល្អិតម៉ត់នេះ គួរតែតិចជាង២ភាគរយនៃចំណីក្នុងបាវ។

## សេចក្តីសង្ខេប

- ការប៉ាន់ប្រមាណអំពីសមាសសភាពផ្សំនៃចំណីមានសារៈសំខាន់ណាស់ ដើម្បីយល់ដឹងពីចំណីនោះ ក៏ប៉ុន្តែមានកត្តាដទៃជាច្រើនទៀត ដើម្បីកំណត់ពីគុណភាពចំណីឱ្យបានល្អ។
- យកល្អត្រូវសាកល្បងប្រើចំណីមួយប្រភេទឱ្យបានច្បាស់លាស់ និងកត់ត្រាឱ្យបានល្អត្រឹមត្រូវ អំពីមេគុណចំណី និងការលូតលាស់របស់ត្រីក្នុងរយៈពេលចិញ្ចឹម។
- លក្ខណៈរូបនៃចំណីសម្រាប់វារីវប្បករ មិនប្រាកដដូចគ្នាទៅនឹងលក្ខណៈរូប និងសារៈសំខាន់ចំពោះត្រីនោះទេ។
- ចំណីគ្រាប់មានគុណភាពអន់នឹងបណ្តាលឱ្យខូចនិងមានការបំពុលទឹកដ៏ធំសម្បើម ដែលនឹងកាត់បន្ថយសមត្ថភាពផ្ទុករបស់ស្រះ។

ចំណីគ្រាប់ដែលល្អគឺរក្សាបាននូវរូបរាងនិងសារធាតុផ្សំចម្រុះរបស់វានៅក្នុងទឹកបានច្រើនម៉ោង។ នេះគឺអ្វីដែលហៅថាជាចំណីដែលមាន "លំនឹងក្នុងទឹក"។ ចំពោះចំណីគ្រាប់មានគុណភាពអន់ វានឹងបែកខ្ទេចភ្លាមៗពេលចូលទៅក្នុងទឹក។



បើសិនជាអ្នកឱ្យចំណីកូនត្រីអណ្តែង អ្នកចង់ឱ្យគ្រប់បំណែកនៃចំណីទៅជាបំណែកតូចៗ ដូច្នេះត្រីមិនរង់ចាំចំណីដើម្បីបំបែកជាបំណែកតូចៗមុនពេលវាស៊ីនោះទេ។ក្រុមហ៊ុនផលិតចំណីជាច្រើនមានការលំបាកក្នុងការកែតម្រូវម៉ាស៊ីនកាត់នៃម៉ាស៊ីនផលិតចំណីគ្រាប់ ហើយមិនផលិតជាចំណីគ្រាប់ដែលមានទំហំសណ្ឋានតូចៗបានដែរ។ នេះនឹងបណ្តាលឱ្យមានការខ្ជះខ្ជាយចំណី។



**ក. ចំណីគ្រាប់ដែលល្អ**

សម្គាល់ពណ៌សណ្ឋាននៃគ្រាប់ចំណីនិងមិនមានសារធាតុម្សៅ។



**ខ. ចំណីគ្រាប់ដែលដុះផ្សិត**

សម្គាល់៖

១. ពណ៌នៃគ្រាប់ចំណីមិនមានសណ្ឋានដូចគ្នា

២.  សារធាតុម្សៅនៅសេសសល់នៅលើដៃ និង

៣. ប្រហោងតូចៗក្នុងគ្រាប់ចំណី។ ពណ៌សព្រឿងៗ និងសារធាតុម្សៅដែលនៅសេសសល់លើដៃគឺដោយសារផ្សិតដុះ។ ប្រហោងនានាគឺដោយសារសត្វល្អិត។

# មេរៀន ៖

# មេគុណចំណី

# មេគុណចំណី

**តើអ្វីជា "មេគុណចំណី" និង ត្រូវប្រើប្រាស់វាយ៉ាងណា?**




**មេគុណចំណី**គឺជាបរិមាណចំណីដែលបានប្រើប្រាស់ក្នុងផលិតកម្មមួយ ចែកជាមួយនឹងកំណើនទម្ងន់របស់ត្រី។ ចំណីគឺជាការ ចំណាយខ្ពស់បំផុតក្នុងចំណោមការចំណាយក្នុងផលិតកម្ម។ ការយល់ដឹងច្បាស់អំពីមេគុណចំណី (FCR) គឺជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅរកការគ្រប់គ្រងដែលល្អ និងការសម្រេចចិត្តដែលត្រឹមត្រូវ ។

**រូបមន្តៈ** មេគុណចំណី $= \dfrac{\text{ទម្ងន់ចំណីសរុបដែលបានប្រើ}}{\text{កំណើនទម្ងន់សរុបរបស់ត្រី**}}$

**កំណើនទម្ងន់សរុបរបស់ត្រី = (ទម្ងន់ត្រីសរុបនៅពេលប្រមូលផល) – (ទម្ងន់ត្រីសរុបពេលដាក់ចិញ្ចឹម)

**ឧទាហរណ៍ ការគណនាមេគុណចំណីៈ**

- ចំនួនកូនត្រី ៥ ០០០ ក្បាល
- ទម្ងន់កូនត្រីជាមធ្យម ៥ ក្រាម
- ទម្ងន់សរុបនៅពេលស្តុកកូនត្រី ២ ៥០០០ ក្រាម ឬ ២៥ គីឡូក្រាម (៥ ០០០ ក្បាល x ៥ ក្រាម)
- ទម្ងន់សរុបពេលប្រមូលផល ២ ១២៥ គីឡូក្រាម
- កំណើនទម្ងន់សរុបរបស់ត្រី ២ ១០០ គីឡូក្រាម (២ ១២៥ គីឡូក្រាម - ២៥ គីឡូក្រាម)
- ទម្ងន់ចំណីសរុបដែលបានប្រើប្រាស់ក្នុងផលិតកម្ម (ចំណីគ្រាប់) ៣ ៥០០គីឡូក្រាម
- មេគុណចំណី (FCR) ៣ ៥០០ ÷ ២ ១០០ = ១,៦៧ (១,៧)

មេគុណចំណីគឺពិតជាសំខាន់ខ្លាំងណាស់ ព្រោះវាអាចឱ្យវារីវប្បករដឹងពីការប្រើប្រាស់លុយទៅលើផលិតកម្មរបស់ពួកគាត់។ ទោះបីជាចំណីខ្លះត្រីមិនស៊ី ឬត្រីខ្លះត្រូវបានបាត់បង់ក្នុងកំឡុងពេលចិញ្ចឹមក៏ដោយ ចំណីទាំងអស់នេះនៅតែជាការចំណាយនៅក្នុងផលិតកម្មនោះ ហើយក៏ត្រូវបូកសរុបចូលនៅពេលគណនាមេគុណចំណីដែរ។

ដៃគូអនុវត្តគម្រោងៈ

## ការវាយតម្លៃទៅលើ មេគុណចំណី

នៅពេលយើងគិតទៅលើ**មេគុណចំណី** យើងក៏ត្រូវមើលទៅលើតម្លៃចំណីដែលវាបានជះឥទ្ធិពលមួយផ្នែកធំទៅលើការចំណាយក្នុងផលិតកម្មទាំងមូល។ ជាទូទៅ វារីវប្បករមានជម្រើសជាច្រើនទាក់ទងទៅនឹងចំណី និងការឱ្យចំណី។ មធ្យោបាយមួយសម្រាប់ប្រើប្រាស់មេគុណចំណីដើម្បីវាយតម្លៃទៅលើចំណី គឺត្រូវយកតម្លៃចំណី គុណនឹង មេគុណចំណី។

**ចំពោះចំណីដែលមានតម្លៃទាប ជាទូទៅមិនបានកាត់បន្ថយថ្លៃដើមនៃផលិតកម្មនោះទេ។**

មេគុណចំណីអាស្រ័យលើកត្តាសំខាន់ៗដូចខាងក្រោម៖

- ពូជ ប្រភេទត្រីដែលចិញ្ចឹម
- ប្រភេទចំណីដែលប្រើប្រាស់
- របៀបផ្តល់ចំណី (ការគ្រប់គ្រង)។

## តើមេគុណចំណី ១,៧ ល្អដែរឬទេ?

គឺវាពឹងផ្អែកទៅលើតម្លៃចំណី។ បើសិនជាប្រើប្រាស់ចំណីប្រភេទតែមួយ ហើយមេគុណចំណី ២,៨ ថាតើ មេគុណចំណីមួយណាដែលមានឥទ្ធិពលលើថ្លៃដើមផលិតកម្មខ្ពស់ជាង? ជាទូទៅ ក្នុងករណីចំណីប្រភេទតែមួយ និងមានមេគុណចំណីទាបជាង គឺបានន័យថាការប្រើប្រាស់ចំណីតិចជាង ដែលស្មើនឹងការចំណាយលើផលិតកម្ម (ចំណី) កាន់តែទាប។ នៅពេលដែលមេគុណចំណីខ្ពស់មានន័យថាវារីវប្បករបានផ្តល់ចំណីទៅឱ្យត្រី តែត្រីមិនសូវមានការលូតលាស់ ។

## គន្លឹះសំខាន់ៗនៃមេគុណចំណី៖ ការគ្រប់គ្រងចំណី និងគុណភាពចំណី

ហេតុផលមួយចំនួនដែលធ្វើឱ្យមេគុណចំណីខ្ពស់ រួមមានដូចជា គុណភាពចំណី និងរបៀប ឬវិធីសាស្ត្រនៃការប្រើប្រាស់ចំណី។ វារីវប្បករគួរតែយល់ដឹងអំពីអ្វីជាចំណីដែលមានគុណភាព និងគួរប្រើប្រាស់ចំណីដោយមានរបៀបបំផុត។



មូលហេតុដែលអាចបណ្តាលឱ្យមេគុណចំណីខ្ពស់៖

១. ត្រីមិនអាចរំលាយ និងសំយោគសារធាតុចិញ្ចឹមពីចំណីបានល្អ
២. ចំណីខ្វះសារធាតុចិញ្ចឹមដែលត្រីត្រូវការដើម្បីលូតលាស់
៣. ចំណីដែលបានផ្តល់ឱ្យត្រីមិនគ្រប់គ្រាន់សម្រាប់ការលូតលាស់ គឺត្រឹមតែអាចរក្សាទម្ងន់ឱ្យនៅដដែលតែប៉ុណ្ណោះ
៤. អ្នកដែលផ្តល់ចំណីឱ្យត្រី មិនបានដាក់ចំណីក្នុងស្រះ ឬ ក្នុងបែ ឱ្យបានត្រឹមត្រូវ
៥. អ្នកដែលផ្តល់ចំណីឱ្យត្រី គឺចេះតែចាក់ចំណីចូលដោយខ្វះការអង្កេតថាត្រី ស៊ីឬមិនស៊ី
៦. ទំហំត្រីនៅក្នុងស្រះខុសគ្នាខ្លាំងដែលធ្វើឱ្យត្រីតូចស៊ីមិនឈ្នះត្រីធំ
៧. មានការបាត់បង់ត្រីច្រើនកំឡុងពេលចិញ្ចឹម។

**ឧទាហរណ៍ ផែនការផលិតកម្ម**

វារីវប្បករម្នាក់មានស្រះមួយទំហំ ២០០ម៉ែត្រការ៉េ កំពុងចិញ្ចឹមត្រីប្រាហើយប្រើប្រាស់ចំណីកែច្នៃដោយខ្លួនឯង (ចំណីផ្សំ) ទទួលបានទិន្នផលសរុប ៨០០គីឡូក្រាម។ គាត់បានប្រើប្រាស់ចំណីកូរ អស់ ៤ ០០០គីឡូក្រាម ក្នុងផលិតកម្មនោះ និងមានមេគុណចំណី ៥,០។ បើសិនជាតម្លៃចំណីក្នុងមួយគីឡូក្រាម ស្មើនឹង ១ ១០០រៀល ដូចនេះការចំណាយទៅលើចំណីគឺ ៤ ៤០០ ០០០ រៀល។

នៅក្នុងឧទាហរណ៍នេះ ការចំណាយទៅលើចំណីគឺស្មើនឹង៨០ភាគរយនៃការចំណាយសរុបក្នុងផលិតកម្ម។ ដូចនេះការចំណាយសរុបក្នុងផលិតកម្មនេះ គឺ ៥ ៥០០ ០០០រៀល ហើយវារីវប្បករនោះលក់ត្រីនៅកសិដ្ឋានរបស់គាត់ក្នុងតម្លៃ ៧ ០០០រៀលក្នុង១គីឡូក្រាម។ ដូចនេះចំណូលសរុបស្មើនឹង ៥ ៦០០ ០០០រៀល។ សរុបមកការចំណេញគឺ ១០០ ០០០ រៀល (៥ ៦០០ ០០០រៀល ទៅ ៥ ៥០០ ០០០រៀល)។

**តើវារីវប្បករអាចបង្កើនប្រាក់ចំណេញដោយប្រើប្រាស់ចំណីដែលមានគុណភាពល្អដែរឬទេ?**

តារាងខាងក្រោមជាឧទាហរណ៍ អំពីជម្រើសផ្សេងៗនៃការប្រើប្រាស់ចំណី។ ជម្រើសទី១ ចំណីគ្រាប់មានប្រូតេអ៊ីន ២៤ ភាគរយ មានតម្លៃ ២ ២០០រៀលក្នុង១គីឡូក្រាម។ ជម្រើសទី២ ចំណីគ្រាប់មានគុណភាពកាន់តែល្អ និងមានប្រូតេអ៊ីនដល់ទៅ ៣០ភាគរយ ហើយមានតម្លៃ ៣ ០០០រៀលក្នុង១គីឡូក្រាម។ តើជម្រើសមួយណាដែលវារីវប្បករគួរជ្រើសរើស?

| ប្រភេទចំណី | ចំណីកូរ | ប្រូតេអ៊ីន ២៤ ភាគរយ | ប្រូតេអ៊ីន ៣០ ភាគរយ |
|---|---|---|---|
| ១. មេគុណចំណី | ៥,០ | ២,២ | ១,៥ |
| ២. តម្រូវការចំណី (គីឡូក្រាម) = (១) x (៦) | ៤ ០០០ | ២ ២០០ | ១ ៥០០ |
| ៣. តម្លៃចំណី (រៀលក្នុង១គីឡូក្រាម) | ១ ១០០ | ២ ៣០០ | ៣ ០០០ |
| ៤. តម្លៃចំណីសរុប (រៀល) = (២) x (៣) | ៤ ៤០០ ០០០ | ៥ ០៦០ ០០០ | ៤ ៥០០ ០០០ |
| ៥. ការចំណាយសរុប (រៀល) | ៥ ៥០០ ០០០ | ៦ ៣២៥ ០០០ | ៥ ៦២៥ ០០០ |
| ៦. ទិន្នផលសរុប (គីឡូក្រាម) | ៨០០ | ១ ០០០ | ១ ០០០ |
| ៧. ចំណូលសរុប (រៀល) | ៥ ៦០០ ០០០ | ៧ ០០០ ០០០ | ៧ ០០០ ០០០ |
| ៨. ចំណេញ (រៀល) = (៧) – (៥) | ១០០ ០០០ | ៦៧៥ ០០០ | ១ ៣៧៥ ០០០ |
| ៩. ចំណេញ (ភាគរយ) | ២ | ១១ | ២៤,៥ |

សង្ខេបៈ ដើម្បីគណនាមេគុណចំណី យើងត្រូវដឹងអំពីទម្ងន់ត្រីសរុបនៅពេលដាក់ចិញ្ចឹម ទម្ងន់ត្រីសរុបនៅពេលលក់ និងបរិមាណចំណីដែលបានប្រើប្រាស់សរុប។ មេគុណចំណី(FCR)ខ្ពស់ ជាទូទៅបានឆ្លុះបញ្ចាំងទៅដល់គុណភាពចំណីមិនល្អ ឬការគ្រប់គ្រងចំណីមិនបានល្អ។ ដើម្បីទទួលបានមេគុណចំណីល្អ (ទាប) វារីវប្បករគួរតែជា **អ្នកផ្តល់ចំណីឱ្យត្រី**

ម្នាក់ដ៏ល្អ **មិនមែនជាអ្នកចាក់ចំណីនោះទេ។** ការយល់ដឹងអំពីមេគុណចំណីជួយវារីវប្បករអាចព្យាករណ៍អំពីតម្រូវការចំណី និងការចំណាយរបស់ផលិតកម្មនោះបាន។

## អនុសាសន៍សម្រាប់ការផ្តល់ចំណីត្រី

### សម្រាប់ការងារប្រចាំថ្ងៃ៖

ថ្លឹងចំណីពេលឱ្យត្រីស៊ីប្រចាំថ្ងៃ បន្ទាប់មកថ្លឹងចំណីដែលនៅសល់ចុងបញ្ចប់នៃថ្ងៃនីមួយៗ។ មិនចាំបាច់បែងចែកចំណីឱ្យស្មើៗគ្នាក្នុងពេលផ្តល់ចំណីម្តងៗនោះទេ ព្រោះថាក្នុងមួយថ្ងៃត្រីវាស៊ីចំណីច្រើនក្នុងពេលមួយជាក់លាក់។ ប្រសិនបើមិនមានជញ្ជីងទេ អ្នកអាចប្រើរង្វាស់ឬខ្ទាតជាធុងក៏បានដែលអាចកំណត់ទម្ងន់ចំណីក្នុងមួយដងបាន ហើយពេលថ្លឹងលើកក្រោយត្រូវប្រើឧបករណ៍ដូចគ្នា ។ ប្រសិនបើផ្លាស់ប្តូររង្វាស់នោះទម្ងន់ចំណីវានឹងប្តូរ ។

មុនពេលផ្តល់ចំណីម្តងៗ ត្រូវសម្គាល់ថាតើមានចំណីសេសសល់នៅកន្លែងណានៃស្រះដែរឬអត់ (កណ្តាលស្រះ ជ្រុងស្រះ ឬក្បែរហាប៉ា ជាដើម)។ ប្រសិនបើមានចំណីសល់ត្រីមិនស៊ី ត្រូវប្រមូលចូលក្នុងហាប៉ា ឬកន្លែងណាដែលត្រីអាចស៊ីបាន។ ធ្វើដូចនេះការខ្ជីខ្ជាចំណីត្រូវបានដោះស្រាយ មិនមានចំណីសល់ក្នុងស្រះទៀតឡើយ។

កំឡុងពេលផ្តល់ចំណី ត្រូវអង្កេតដោយប្រុងប្រយ័ត្នបំផុត៖

- អង្កេតមើលសកម្មភាពរបស់ត្រីថាតើឃើញត្រីមកស៊ីចំណីមុនពេលផ្តល់ ឬមួយមិនមានសកម្មភាពអ្វីនោះទេ ។
- ពេលកំពុងផ្តល់ចំណី ថាតើត្រីមានសកម្មភាពក្លៀវក្លា/ខ្លាំង បែកទឹកខ្ទាយឬទេ ឬក៏មានសកម្មភាពតិចតួចនិងស្ងាត់ស្ងៀម ។
- ថាតើមានត្រីមករកស៊ីចំណីតែបែរជាមិនស៊ីទៅវិញ?
- តើការស៊ីចំណីតាំងពីដើមដល់ចប់មានសកម្មភាពដូចគ្នាពីដំបូង ឬមានលក្ខណៈខុសគ្នា? ហើយខុសគ្នាយ៉ាងដូចម្តេច?
- តើមានត្រីមួយចំនួនស្ថិតនៅម្ខាងនៃហ្វូងត្រី ហើយមិនមកស៊ីចំណីដែរឬទេ?

### ការងារប្រចាំសប្តាហ៍៖

ពិនិត្យការកត់ត្រាអំពីសកម្មភាពស៊ីចំណីរបស់ត្រីក្នុងស្រះ ហើយធ្វើការសម្រេចចិត្តថាតើបរិមាណចំណីត្រូវកែប្រែ ឬយ៉ាងណា? ត្រូវប្រើតារាងចំណីជាមូលដ្ឋានតែក៏ត្រូវអង្កេតសកម្មភាពស៊ីចំណីផងដែរ។ តារាងចំណីវាគឺជាអនុសាសន៍នៃការផ្តល់ចំណីដល់ចំណុចខ្ពស់បំផុត។ យ៉ាងណាក៏ដោយ ប្រសិនបើអ្នកមិនបានផ្តល់ចំណី ដោយសារអាកាសធាតុមិនល្អ ហេតុនេះ ថ្ងៃបន្ទាប់បរិមាណចំណីត្រូវឱ្យត្រីស៊ីអាចនឹងច្រើនជាងក្នុងតារាង ប្រសិនបើត្រីនៅស៊ីចំណី។

ការអង្កេតទាំងនេះនឹងជួយកែលម្អដល់បច្ចេកទេសផ្តល់ចំណីរបស់អ្នកបានយ៉ាងប្រសើរ ។

**ចំណុចគួរចងចាំ:**

អ្នកចិញ្ចឹមត្រី ឬអាជីវករប្រកបរបរចិញ្ចឹមត្រីត្រូវចងចាំថា អ្នកផ្តល់ចំណីជាបុគ្គលដ៏សំខាន់ក្នុងកសិដ្ឋាន។ ពួកគេគឺជាអ្នកធ្វើឱ្យមេគុណចំណី (FCR) ប្រែប្រួល និងមានឥទ្ធិពលលើផលចំណេញរបស់អ្នក ។ តើអ្នកមានបុគ្គលធ្វេសប្រហែសជាអ្នកផ្តល់ចំណីក្នុងកសិដ្ឋានរបស់អ្នកឬទេ?

# មេរៀន ៖

# ការប្រើប្រាស់តារាងចំណី៖

# តើខ្ញុំគួរឱ្យចំណីត្រីប៉ុន្មាន?

# ការប្រើប្រាស់តារាងចំណី៖ តើខ្ញុំគួរឱ្យចំណីត្រីប៉ុន្មាន?

នៅពេលយើងនិយាយអំពីការគ្រប់គ្រងចំណី យើងនឹងបង្ហាញវិធីសំខាន់ៗ គឺត្រូវឱ្យចំណីត្រីតាមបរិមាណមួយដ៏ត្រឹមត្រូវ ធ្វើដូច្នេះគឺយើងមិនខ្ជះខ្ជាយលុយកាក់ និងបំពុលទឹកផងដែរ។ យ៉ាងណាក៏នៅមានជម្រើសមួយចំនួនសម្រាប់កសិករត្រូវយល់ដឹងផងដែរ។





រូបភាព៖ ការអោយចំណីត្រី

## ១. កែតម្រូវការដាក់ចំណីមួយចម្អែត

ជាធម្មតា ត្រូវមានតារាងចំណីមួយ។ ទោះជាយ៉ាងណាក៏ដោយ វារីវប្បករខ្លះមិនយល់ពីរបៀបប្រើប្រាស់តារាងចំណីឡើយ ហេតុនេះពួកគេមិនជឿពីតារាងផ្តល់ចំណីនោះទេ។ ដូច្នេះពួកគេឱ្យចំណីដោយពឹងលើបរិមាណចំណីដែលត្រីអាចស៊ីបាន។ ខាងក្រោមនេះជាវិធីសាស្រ្តល្អៗក្នុងការដាក់ចំណី៖

- ត្រូវប្រាកដថាមិនមានចំណីនៅសេសសល់ក្នុងស្រះ ឬបែត្រីឡើយ។ នេះមានន័យថា អ្នកផ្តល់ចំណីត្រីត្រូវស្ថិតនៅស្រះចិញ្ចឹមត្រី រហូតទាល់តែត្រីស៊ីចំណីអស់។ ដូច្នេះបើសិនជា ″**ចាក់ចំណី**″ តារាងផ្តល់ចំណីនេះនឹងមិនមានប្រសិទ្ធភាពនោះទេ។
- ថ្ងៃមួយនៃសប្តាហ៍ ធ្វើការផ្តល់ចំណីឱ្យច្រើនតាមតែត្រីអាចស៊ីបាននៅក្នុងថ្ងៃនោះ ហើយត្រូវធ្វើការកត់ត្រាបរិមាណចំណីដែលឱ្យត្រីស៊ីឱ្យបានច្បាស់លាស់។ ការផ្តល់ចំណីបែបនេះគេហៅថា **ការផ្តល់ចំណីមួយចម្អែត**។
- សម្រាប់ថ្ងៃផ្សេងៗក្នុងសប្តាហ៍នោះ អាចផ្តល់ចំណីតិចតួចជាងបរិមាណចំណីដែលត្រូវផ្តល់ឱ្យ។ នៅរៀងរាល់ថ្ងៃទីមួយនៃសប្តាហ៍គេអាចផ្តល់ចំណី ១០០គីឡូក្រាម ចំណែក ៦ថ្ងៃទៀតអាចផ្តល់ត្រឹមតែ៩០គីឡូក្រាមប៉ុណ្ណោះ។ បើសិនជាមានហេតុផលណាមួយ ត្រីស៊ីមិនអស់ចំណី៩០គីឡូក្រាម ដូច្នេះកុំផ្តល់ចំណីឱ្យច្រើនពេកក្នុងថ្ងៃនោះ។
- បន្ទាប់មកអនុវត្តវិធីដដែលម្តងទៀតនូវការផ្តល់ចំណីមួយចម្អែតនៅសប្តាហ៍ក្រោយ ហើយធ្វើការកែតម្រូវតាមវិធីដដែលទៀត។

## ២. ការប្រើប្រាស់តារាងផ្តល់ចំណី

តារាងនេះតម្រូវឱ្យយើងដឹងថាតើក្នុងស្រះចិញ្ចឹមត្រីមានត្រីចំនួនប៉ុន្មានក្បាល ហើយមានទំហំប៉ុន្មានក្នុង១ក្បាលៗ ។ វារីវប្បករភាគច្រើនធ្វើការប៉ាន់ស្មានលើសពីចំនួនត្រី និងទំហំត្រីក្នុងស្រះរបស់ពួកគាត់។ ខាងក្រោមជាតារាងផ្តល់ចំណីគួរយកមកប្រើក្នុងការផ្តល់ចំណី ។

| ទំហំត្រីគិតជាក្រាម | ទម្ងន់ត្រីធៀបនឹងចំណី (ភាគរយ) |
|---|---|
| ១០ ទៅ ៤៩ ក្រាម | ៤,៣ |
| ៥០ ទៅ ៩៩ ក្រាម | ២,៧ |
| ១០០ ទៅ ១៤៩ ក្រាម | ២,៥ |
| ១៥០ ទៅ ២០០ ក្រាម | ២,១ |
| លើសពី ២០០ ក្រាម | ១,៧ |

សាកល្បងគណនាថាតើចំណីចំនួនប៉ុន្មានគីឡូក្រាម ត្រូវផ្តល់ឱ្យត្រីចំនួន ១ ០០០ក្បាល ដោយត្រី១ក្បាលៗមានទម្ងន់ ៧៥ក្រាម។ យោងទៅតាមតារាងផ្តល់ចំណី យើងអាចគណនាដូចតទៅ៖ (១ ០០០ក្បាល x ៧៥ក្រាម x ២,៧ភាគរយ) = ២ ២០៥ក្រាម ឬជាង២គីឡូក្រាម។

ដូចគ្នាដែរ ក្នុងការគណនាចំណីសម្រាប់ត្រី ១ ០០០ក្បាល ដែលត្រីមួយក្បាលៗមានទម្ងន់ ១៤៥ក្រាម និង១៥៥ក្រាម ត្រូវផ្តល់ចំណីចំនួន ៣ ៦២៥ក្រាម ឬប្រហែល ៣,៦គីឡូក្រាម និង ៣ ២៥៥ក្រាម ឬប្រហែល ៣,៣គីឡូក្រាម ។

យើងឃើញថា តារាងនេះមានបញ្ហាមួយ ព្រោះថាជួនកាលវារីវប្បករឱ្យចំណីលើស និងពេលខ្លះទៀតវារីវប្បករឱ្យចំណីមិនគ្រប់គ្រាន់ តែទោះជាយ៉ាងណាវាអាចប្រើប្រាស់ជាការណែនាំ ជាប្រយោជន៍សម្រាប់វារីវប្បករបាន។

តារាងចំណីមួយប្រភេទទៀត ជាតារាងចំណីដែលរួមបញ្ចូលទាំងការព្យាករណ៍ទុកជាមុននៃការលូតលាស់របស់ត្រី តារាងនេះមានប្រយោជន៍យ៉ាងច្រើន ដល់វារីវប្បករណាដែលមិនអាចធ្វើសំណាកបានល្អ។ បើសិនវារីវប្បករធ្វើសំណាកគំរូនៃតារាងចំណីត្រី ដូចបានណែនាំ គឺពួកគេអាចយោងត្រឡប់ទៅគណនាទម្ងន់ត្រីគិតជាមធ្យម និងធ្វើការកែតម្រូវផ្សេងៗ។ សូមមើលតារាងពីការផ្តល់ចំណីក្នុងមួយសប្តាហ៍ជាមូលដ្ឋាន។

តារាងខាងលើនឹងព្យាករណ៍ទុកជាមុនពីទម្ងន់ត្រីគិតជាមធ្យម ក៏ប៉ុន្តែធ្វើការប៉ាន់ស្មានដោយផ្អែកលើ ចំណីដែលត្រីស៊ី ហើយវាក៏ផ្អែកទៅលើប្រភេទចំណីដែរ។ ជាឧទាហរណ៍ បើសិនជាយើងស្តុកកូនត្រីទីឡាព្យាធំៗមានទម្ងន់ ១៧ក្រាម បន្ទាប់ពី១០អាទិត្យ ត្រីទីឡាព្យាអាចកើនទម្ងន់ ១៧០ក្រាម។ ក៏ប៉ុន្តែត្រីទាំងនោះមិនអាចឈានដល់ទំហំហ្នឹងបានទេ បើសិនជាប្រើចំណីក្លូ (ចំណីដែលកសិករធ្វើពីកន្ទក់ និងត្រីដី)។

តារាងខាងក្រោមត្រូវបានចងក្រងដោយផ្អែកលើព័ត៌មានពីការធ្វើតេស្តសាកល្បងនៅកម្ពុជា ដោយការប្រើចំណីផលិតដោយក្រុមហ៊ុនអាហ្គ្រីម៉ាស្ទ័រហ្វីតដែលមានប្រូតេអ៊ីន ៣៥ភាគរយ។ ចំពោះគុណភាពទឹកដែលចិញ្ចឹមត្រី គឺទឹកល្អ ដូច្នេះការលូតលាស់លឿនជាងធម្មតា ។

បើសិនជាយើងធ្វើសំណាកនៅអាទិត្យទី១២ ហើយទម្ងន់ត្រីមធ្យមត្រឹមតែ ១៥០ក្រាមនោះ គួរផ្តល់ចំណីត្រឹមតែ ៤,៨៨ក្រាមប៉ុណ្ណោះសម្រាប់ត្រី១ក្បាល។

## គន្លឹះខ្លះៗត្រូវចងចាំពីតារាងផ្តល់ចំណី៖

ត្រីមិនអាចពិនិត្យមើលតារាងផ្តល់ចំណី និងការលូតលាស់នោះទេ ដូច្នេះហើយពួកវានឹងស៊ីចំណីទៅតាមប្រភេទ ឬបរិមាណដែលវាចង់ស៊ី (ត្រូវចាំថា នេះជាហេតុផលដែលត្រីមិនស៊ីទៅតាមបរិមាណដែលយើងគិតថាវាគួរស៊ីនោះទេ)។

- តារាងផ្តល់ចំណីនេះវាជាការណែនាំមួយប៉ុណ្ណោះ។ លេខក្នុងតារាងនេះជាកម្រិតអតិបរមានៃចំណីដែលត្រូវផ្តល់ឱ្យត្រីស៊ី។ ប៉ុន្តែបើត្រីមិនស៊ីចំណីដែលផ្តល់ឱ្យទេ សូមកុំផ្តល់ចំណីក្នុងបរិមាណដែលបានកំណត់តាមការគណនា។
- អ្នកផ្តល់ចំណីដ៏ល្អម្នាក់ មានសារៈសំខាន់ជាងតារាងផ្តល់ចំណីទៅទៀត។
- តារាងផ្តល់ចំណីដែលល្អ គួបផ្សំនឹងអ្នកផ្តល់ចំណីដ៏ល្អ នឹងជួយកសិករក្នុងការរកប្រាក់ចំណេញបានយ៉ាងច្រើន។
- តារាងផ្តល់ចំណី និងការលូតលាស់នឹងប្រែប្រួលអាស្រ័យតាមប្រភេទចំណី និងប្រភេទត្រី។ ចំណីដែលមានប្រូតេអ៊ីនទាប ជាធម្មតាធ្វើឱ្យត្រីមានការលូតលាស់យឺត ឬក៏តម្រូវការចំណីបន្ថែមដើម្បីទទួលបានការលូតលាស់ដូចគ្នា មានន័យថាពួកត្រីទាំងនោះនឹងត្រូវការចំណីច្រើន និងមានមេគុណចំណីខ្ពស់ជាង (ឬកម្រិតផ្តល់ចំណីខ្ពស់)។

សីតុណ្ហភាពទឹក មិនបានគិតបញ្ចូលក្នុងតារាងផ្តល់ចំណីនោះទេ ហេតុនេះបរិមាណចំណីគួរកាត់បន្ថយ នៅពេលដែលសីតុណ្ហភាពទឹកធ្លាក់ចុះទាប ឬឡើងខ្ពស់ជាងកម្រិតប្រក្រតី។ ឧទាហរណ៍ បរិមាណចំណីគួរតែកាត់បន្ថយ២៥ភាគរយ នៅពេលដែលសីតុណ្ហភាពទឹកថយចុះមកត្រឹម២៦អង្សាសេ ឬក៏នៅពេលវាឡើងលើស៣៤អង្សាសេ សម្រាប់ការចិញ្ចឹមត្រីក្នុងប្រទេសកម្ពុជា។ យើងអាចដាក់ឈ្មោះប្រភេទត្រីផ្សេងៗ និងវិធីមួយចំនួន ដើម្បីពិពណ៌នាពីប្រភេទត្រីទាំងនោះ។ យើងនឹងពិនិត្យម្តងហើយម្តងទៀតពីស្ថានភាពសីតុណ្ហភាពទាំងនោះ ប្រហែលនៅចន្លោះរវាងពី ២៧ ទៅ ៣៣ អង្សាសេ។

តារាងនេះអាចប្រើសម្រាប់ត្រីទីឡាព្យាផងដែរ។ ទោះជាយ៉ាងណាក៏ដោយ យើងគួរប្រើតារាងដោយផ្អែកលើទិន្នន័យនៅកម្ពុជា។ តារាងនេះនឹងត្រូវបានផ្ទៀងផ្ទាត់ ហើយនឹងត្រូវប្រើប្រាស់នាពេលឆាប់ៗ។

# មេរៀន ៖

# ប្រព័ន្ធបញ្ចូលខ្យល់

# ប្រព័ន្ធបញ្ចូលខ្យល់

យើងអាចបែងចែកការពិភាក្សាស្តីពី ប្រព័ន្ធបញ្ចូលខ្យល់ ទៅជា២ផ្នែកធំៗ។ ទី១៖ ប្រព័ន្ធបញ្ចូលខ្យល់នៅក្នុងអាង ដូចជា ប្រពន្ធ័ចិញ្ចឹមតាមបែក្នុងស្រះ ធុងដឹកជញ្ជូនត្រី និងប្រព័ន្ធទឹកវិល និងទី ២៖ ប្រព័ន្ធបញ្ចូលខ្យល់នៅក្នុងស្រះ។

## ផ្នែកទីមួយ៖ ម៉ាស៊ីនផ្លុំខ្យល់ ម៉ាស៊ីនសម្ពាធខ្យល់ និងម៉ាស៊ីនបូមខ្យល់

ប្រព័ន្ធបញ្ចូលខ្យល់នៅក្នុងអាងភ្ញាស់ត្រូវបានដំឡើង ដើម្បីផ្តល់អុកស៊ីសែន និងរក្សាកម្រិតអុកស៊ីសែនឱ្យបានគ្រប់គ្រាន់ សម្រាប់ត្រីដែលស្ថិតក្នុងស្ថានភាពចង្អៀត។ វិធីសាស្ត្រដែលគេនិយមប្រើមានដូចជា ម៉ាស៊ីនផ្លុំខ្យល់ ឬម៉ាស៊ីនសម្ពាធខ្យល់ដើម្បីជំរុញឱ្យមានចលនាខ្យល់ក្នុងទឹក និងធ្វើឱ្យទឹកមានចលនាផងដែរ។

## ម៉ាស៊ីនផ្លុំខ្យល់

ម៉ាស៊ីនផ្លុំខ្យល់ផ្តល់បរិមាណខ្យល់យ៉ាងច្រើននៅក្នុងជម្រៅទឹកមានសម្ពាធទាប។ ម៉ាស៊ីនផ្លុំខ្យល់ភាគច្រើនរុញខ្យល់បានល្អបំផុតនៅជម្រៅទឹក១ម៉ែត្រ ឬតិចជាងនេះ។ ខ្យល់ត្រូវបានឆ្លងកាត់ឧបករណ៍បំបែកចរន្តខ្យល់ឱ្យទៅជាពពុះតូចៗនៅក្នុងទឹក យើងហៅថា **ឧបករណ៍បញ្ចូលខ្យល់ ឬដុំខ្យល់** ។ ពពុះខ្យល់តូចៗកាន់តែច្រើន វាអាចនៅក្នុងទឹកបានកាន់តែយូរ ហើយវានឹងបង្កើនអុកស៊ីសែនបានកាន់តែច្រើននៅក្នុងទឹក។






រូបភាព៖ ឧបករណ៍បញ្ចូលខ្យល់ និងដុំខ្យល់

## ឧទាហរណ៍ខ្លះៗនៃឧបករណ៍បញ្ចូលខ្យល់

ម៉ាស៊ីនផ្លុំខ្យល់មានប្រយោជន៍ណាស់ពីព្រោះ ម៉ាស៊ីនផ្លុំខ្យល់មួយអាចផ្គត់ផ្គង់ខ្យល់ដល់អាងជាច្រើន។ ពេលខ្លះគេប្រើវាសម្រាប់បញ្ចូលខ្យល់ទៅក្នុងស្រះផងដែរ។ ម៉ាស៊ីនផ្លុំខ្យល់តូចបំផុត (ប្រហែល ០,៥សេះ) បញ្ចូលខ្យល់បានប្រហែល ៧០០លីត្រក្នុងមួយនាទី។ ម៉ាស៊ីនផ្លុំខ្យល់ធំៗ ឧទាហរណ៍កម្លាំង២សេះ នឹងអាចបញ្ចូលខ្យល់បាន ៣ ៥០០លីត្រក្នុងមួយនាទី។



រូបភាព៖ ម៉ាស៊ីនផ្លុំខ្យល់

**ផ្នែកស្រូបខ្យល់ចូល៖** ខ្យល់ចូលតាមបំពង់ស្រូបខ្យល់ចូល។ ម៉ាស៊ីនផ្លុំខ្យល់ដែលល្អនឹងមានតម្រងមួយ ដើម្បីការពារ កំទេចកំទីភាគល្អិតតូចៗមិនឱ្យឆ្លងកាត់ ដែលធ្វើឱ្យស្ទះដល់ផ្នែកខាងក្នុងនៃឧបករណ៍បញ្ចូលខ្យល់។ ប្រសិនបើគ្មានតម្រងទេ វារីវប្បករអាចប្រើតម្រងខ្យល់ឡានជំនួសបាន។ គួរតែសម្អាតតម្រងឱ្យបានទៀងទាត់ ប្រសិនបើតម្រងមានភាពកខ្វក់នោះធ្វើឱ្យលំហូរខ្យល់ចូលក្នុងទឹកនឹងត្រូវកាត់បន្ថយ។

**ម៉ូទ័រ៖** ម៉ូទ័រមានកម្លាំងរ៉ុល ចំនួនជុំ និងមានគុណភាពខុសៗគ្នា ទៅតាមប្រព័ន្ធការពារកម្តៅទឹក (ដែលអាចបិទម៉ូទ័របានប្រសិនបើវាឡើងកម្តៅខ្លាំងពេក) ឬ ល្បឿនម៉ូទ័រជាដើម ។

**កង្ហារ៖** កង្ហារមានរាងមូលដែលមានបន្ទះស្លាប ឬផ្លិតតូចៗជាច្រើន ហើយរុញខ្យល់ឆ្លងកាត់ម៉ាស៊ីនបញ្ចូលខ្យល់។ ប្រសិនបើកង្ហារខូច ឬសឹក មានការលំបាកក្នុងការប្តូរដុំប៉ាដាងរបស់វា ដែលភាគច្រើនគេប្តូរម៉ាស៊ីនផ្លុំខ្យល់តែម្តង។

**ទុយោបញ្ចេញខ្យល់៖** កត្តាសំខាន់របស់បំពង់នេះគឺជាប្រភេទបំពង់ដែលអាចបត់បែនបាននិងធន់នឹងកំដៅ។ ម៉ាស៊ីនផ្លុំខ្យល់ធ្វើឱ្យមានរំញ័រខ្លះៗ ហើយបំពង់ដែលអាចបត់បែនបាន អាចធន់នឹងកម្លាំងរំញ័រដោយមិនធ្វើឱ្យរហែក ឬបែកទុយោប្លាស្ទិច។ នៅពេលមានខ្យល់ចេញក្នុងបំពង់ ម៉ាស៊ីនផ្លុំខ្យល់អាចនឹងឡើងកម្តៅខ្លាំង ដូចនេះបំពង់ដំបូងដែលដាក់ឱ្យត្រូវនឹងម៉ាស៊ីនគួរតែជាបំពង់ស្រោបដែក ឬមានគុណភាពខ្ពស់សំបកទុយោក្រាស់(កម្រាស់សំបកទុយោលេខ ៨០) ជាប្រភេទទុយោជ័រក្រាស់ និងមាំ (PVC) ។

**វ៉ាល់មួលបិទបើកតែមួយទិស ឬវ៉ាល់មួលបិទបើកមួយជុំ ឬ វ៉ាល់សម្រាប់ឆែក៖** វ៉ាល់ទាំងនេះជារឿយៗត្រូវបានបំពាក់ដើម្បីការពារលំហូរខ្យល់ត្រឡប់ក្រោយ ក្នុងករណីដែលមានម៉ាស៊ីនផ្លុំខ្យល់ច្រើន ត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធតែមួយ។ វារីវប្បករត្រូវពិនិត្យឱ្យម៉ត់ចត់ និងប្រាកដថា វ៉ាល់ត្រូវបានដំឡើងយ៉ាងត្រឹមត្រូវ ហើយត្រូវបានសាកល្បងបិទបើកឱ្យដឹងពីដំណើរការល្អមុនពេលបំពាក់បំពង់ខ្យល់ដទៃទៀត។ ជារឿយៗ តំណត្រង់ (សុង) ត្រូវបានប្រើមុន ឬពីក្រោយវ៉ាល់ ដូច្នេះឧបករណ៍ផ្លុំខ្យល់អាចដកយកចេញបានដោយមិនចាំបាច់កាត់បំពង់ណាមួយឡើយ។

បន្ទាប់ពីត្រួតពិនិត្យវ៉ាល់រួចហើយ ខ្យល់អាចត្រូវបានបញ្ចេញតាមបំពង់ទីបដែកមួយ ដើម្បីសាយភាយកំដៅបន្ថែម ឬចូលទៅក្នុងបំពង់ទីបជ័រធំមួយ ដែលអាចបំបែកខ្នែងតភ្ជាប់ជាមួយទុយោផ្សេងៗទៀត។ បំពង់ទីបជ័រធំនេះ មានមុខងារដើម្បីកាត់បន្ថយការកកិត ហើយវាអាចស្រូបខ្យល់បានច្រើនលើសពីម៉ាស៊ីនផ្លុំខ្យល់មួយ ។

**វ៉ាល់បន្ធូរសម្ពាធ៖** មានវិធីមួយចំនួនដើម្បីការពារម៉ូទ័រ និងម៉ាស៊ីនផ្លុំខ្យល់ពីការឡើងកម្ដៅ ក្នុងករណីកើតមានបញ្ហាដែលធ្វើឱ្យទុយោបញ្ចេញខ្យល់រួមតូច។ វ៉ាល់បន្ធូរសម្ពាធ នឹងបិទខ្យល់លើសមិនឱ្យចូល ប្រសិនបើទុយោបញ្ចេញខ្យល់ត្រូវបានបិទ។ វារក្សាម៉ាស៊ីនផ្លុំខ្យល់ឱ្យនៅដំណើរការដដែល ។

**វ៉ាល់បន្ធូរខ្យល់ចេញ៖** អនុញ្ញាតឱ្យអ្នកប្រើ អាចបន្ធូរខ្យល់លើសចេញ ប្រសិនបើមិនត្រូវការខ្យល់ទាំងអស់នោះ។ វ៉ាល់នេះវាមាន តម្លៃថោកជាង វ៉ាល់បន្ធូរសម្ពាធ ព្រោះវាអាចបើកបិទដោយដៃបាន។ វិធីមួយផ្សេងទៀតដែលអ្នកប្រើបើកបន្ធូរខ្យល់លើសចេញ គឺត្រូវបើកវ៉ាល់ពីរ ឬបើកន្លែងដែលគ្មានឧបករណ៍តភ្ជាប់ទុយោខ្យល់ជាមួយគ្នា ដោយហេតុថាវាអាចដើរតួនាទីជំនួសជាវ៉ាល់បន្ធូរខ្យល់។ ដោយសារតែមានអាងជាច្រើនមានទឹកពេញ ហើយត្រូវការខ្យល់បន្ថែម ដូចនេះត្រូវបិទវ៉ាល់ដែលបានបើកចំហរចោល។

**ការប្រុងប្រយ័ត្ន៖** កុំបើក ឬដំណើរការម៉ាស៊ីនផ្លុំខ្យល់ក្នុងរយៈពេលយូរពេកប្រសិនបើត្រូវការប្រើខ្យល់តិចតួច ព្រោះវានឹងបង្កើតជាសម្ពាធខ្យល់ ហើយធ្វើឱ្យម៉ាស៊ីនផ្លុំខ្យល់នោះបូមខ្យល់ត្រលប់ក្រោយវិញ។ ហើយវាក៏ស៊ីភ្លើង និងប្រេងអូសផងដែរ។ ទំហំម៉ាស៊ីនផ្លុំខ្យល់ គួរតែត្រូវបានជ្រើសរើសផ្អែកលើបរិមាណ និងសម្ពាធខ្យល់ដែលត្រូវការ។ ម៉ាស៊ីនផ្លុំខ្យល់ គួរតែដំណើរការឱ្យពេញសមត្ថភាព និងប្រកបដោយប្រសិទ្ធភាព មិនគួរប្រើសម្រាប់សាយភាយខ្យល់ចូលទៅក្នុងបរិយាកាសទេ។

## ម៉ាស៊ីនសម្ពាធខ្យល់

ម៉ាស៊ីនសម្ពាធខ្យល់ ប្រៀបដូចជាម៉ាស៊ីនសប់កង់ឡាន។ វាបង្កើតជាសម្ពាធខ្យល់ខ្លាំងហើយផ្លុំខ្យល់ចេញវិញ។ ម៉ាស៊ីនសម្ពាធខ្យល់ ជាធម្មតាដំណើរការបានក្នុងរយៈពេលខ្លីប៉ុណ្ណោះ ដូច្នេះភាគច្រើនវាមានធុងផ្ទុកខ្យល់ដែលត្រូវបានបំពេញខ្យល់ឡើងវិញនៅពេលគេចាប់ផ្ដើមប្រើខ្យល់ពីធុងនោះ ។ បញ្ហាធំមួយសម្រាប់ម៉ាស៊ីនប្រភេទនេះ គឺធុងខ្យល់អាចបង្កជាទឹកដែលបានមកពីចំហាយទឹកនៅក្នុងធុងខ្យល់ហើយបង្កជាច្រែះ ក្នុងពេលណាមួយ។ ម៉ាស៊ីនសម្ពាធខ្យល់ ដែលគ្មានធុងខ្យល់ (រូបភាពខាងក្រោម) ត្រូវបានប្រើជាញឹកញាប់ដើម្បីបញ្ចូលខ្យល់នៅតាមបឹងជ្រៅៗ ។






រូបភាព៖ ម៉ាស៊ីនសម្ពាធខ្យល់

## ម៉ាស៊ីនបូមខ្យល់

ម៉ាស៊ីនបូមខ្យល់ មានរូបរាងច្រើនបែប ហើយត្រូវបានប្រើជាញឹកញាប់សម្រាប់ការអនុវត្តវារីវប្បកម្មខ្នាតតូច ដូចជា វារីវប្បករ មានអាងពីរ ឬបីជាដើម។ មានម៉ាស៊ីនប្រភេទខ្លះអាចផលិតខ្យល់ពី ២០ ទៅ ២០០ លីត្រក្នុងមួយនាទី។ ម៉ូដែល ម៉ាស៊ីនខ្លះអាចដំណើរការ ២ ទៅ ៣ ដងនៃសម្ពាធម៉ាស៊ីនផ្លុំខ្យល់ ។

- ម៉ាស៊ីនបូមខ្យល់ប្រភេទឌីយ៉ាហ្វ្រាមអាចបឺតរុញខ្យល់ចេញដោយភ្នាសកៅស៊ូក្រាស់ៗបានយ៉ាងងាយស្រួល។ ភ្នាសទាំងនេះដាច់ដោច ឬប្រេះ ហើយចាំបាច់ត្រូវដូរថ្មីបន្ទាប់ពីប្រតិបត្តិការជាបន្តបន្ទាប់ប្រហែលមួយឆ្នាំ ។ ប្រភេទម៉ាស៊ីនបូមខ្យល់ប្រើប្រាស់នៅកន្លែងចិញ្ចឹមត្រីលម្អតាមផ្ទះ ភាគច្រើនប្រើប្រភេទម៉ាស៊ីនបូមខ្យល់ឌីយ៉ាហ្វ្រាម ។
- មានប្រភេទម៉ាស៊ីនបូមខ្យល់ជាច្រើនទៀតអាចប្រើពីស្តុងបាន។ វាមានពីស្តុងតូចមួយរុញខ្យល់ ហើយពីស្តុងនេះមានអាយុកាល និងប្រើបានយូរជាងម៉ាស៊ីនបូមខ្យល់ឌីយ៉ាហ្វ្រាម។






រូបភាព៖ ម៉ាស៊ីនបូមខ្យល់

## ប្រព័ន្ធដើរដោយថាមពលពន្លឺព្រះអាទិត្យ

បញ្ហាមួយក្នុងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ គឺត្រូវការថាមពលច្រើនជាងពីរដងអំឡុងពេលថ្ងៃដើម្បីឱ្យថាមពលនោះអាចរក្សាទុកក្នុងអាគុយ ហើយអាចប្រើ ឬដំណើរការម៉ាស៊ីននៅពេលយប់បាន។ ប្រសិនបើថាមពលត្រូវបានកាត់ផ្តាច់ក្នុង រយៈពេលពីរ ឬបីនាទី បន្ទាប់មកប្រព័ន្ធបញ្ចូលខ្យល់ត្រូវតែចាប់ផ្តើមដំណើរការឡើងវិញដែលត្រូវប្រើថាមពលច្រើនជាងមុនដើម្បីរុញទឹកចេញ មុនពេលវាអាចឆ្លងកាត់ឧបករណ៍បញ្ចេញខ្យល់។ ប្រព័ន្ធបញ្ចូលខ្យល់ដើរដោយថាមពលពន្លឺព្រះអាទិត្យត្រូវបានគេប្រើលក្ខណៈតូចតាចមានកម្លាំង ១២ វ៉ុលចរន្តភ្លើងផ្ទាល់នៅស្ថានីយ៍ផលិតកូនត្រីពូជ។ ម៉ាស៊ីនផ្លុំខ្យល់ក៏អាចមានកម្លាំង ១២វ៉ុលផងដែរ។ ម៉ាស៊ីនបូមខ្យល់ដែលមានកម្លាំង ១២ វ៉ុលភាគច្រើនប្រើដុំភ្លើងដែលគេហៅថា ធ្យូងដេម៉ារ៉ី ដែលអាចសឹករេចរឹលក្នុងពេលមួយកំណត់នឹងត្រូវជួសជុលឬប្តូរថ្មី។ ទោះជាយ៉ាងណាក៏ដោយ ក៏មានម៉ាស៊ីនផ្លុំខ្យល់ប្រើធ្យូងដេម៉ារ៉ីនេះ មានកម្លាំងពី១២ ដល់ ២៤ និង ៤៨ វ៉ុលដែរ។ គួរសម្គាល់ ឬចំណាំថា ចរន្តបង្កើតដោយថាមពលពន្លឺ



រូបភាព៖ ប្រព័ន្ធបញ្ចូលខ្យល់ដើរដោយថាមពលព្រះអាទិត្យ

ព្រះអាទិត្យ ត្រូវបានថយចុះយ៉ាងខ្លាំងនៅពេលប្រើក្នុងចម្ងាយកាន់តែឆ្ងាយទៅៗ។ ដូច្នេះជាការល្អបំផុត ត្រូវមានបន្ទះសូឡា និងម៉ាស៊ីនបូមខ្យល់នៅជិតគ្នា។

វារីវប្បករជាច្រើនតែងគិតថាពួកគាត់ចាំបាច់ត្រូវមើលឃើញពពុះខ្យល់ជាច្រើនលេចចេញមកផ្ទៃទឹកខាងលើ។ ពួកគាត់គួរតែដឹងនិងយល់ថា ពពុះខ្យល់ដែលពួកគាត់បានឃើញនៅផ្ទៃខាងលើមិនត្រូវបានរលាយក្នុងទឹកនោះទេ វាគឺជាពពុះខ្យល់រសាត់ទៅបាត់អស់ទៅហើយ។ ជាការពិត វាមើលទៅគួរឱ្យចាប់អារម្មណ៍ណាស់ ប៉ុន្តែគេមិនប្រើវានោះទេ។

វារីវប្បករគួរតែស្វែងរកពពុះខ្យល់តូចៗ និងផុសចេញមកផ្ទៃខាងលើយឺតៗ ឬអាចនៅក្នុងទឹករយៈពេលយូរ។ ម្យ៉ាងទៀតថ្មខ្យល់ដែលដាក់នៅទាបក្រោមផ្ទៃទឹករាក់ពេក មិនសូវដំណើរការល្អទេ ។ ថ្មខ្យល់គួរតែដាក់នៅនឹងបាត ឬនៅជិតបាតអាង។



រូបភាព៖ ប្រព័ន្ធបញ្ចូលខ្យល់ដើរដោយថាមពលព្រះអាទិត្យ

**គោលការណ៍មួយចំនួន៖**

- ខ្យល់នឹងផ្លាស់ទីទៅកន្លែងណាដែលមានសម្ពាធទឹកតិចបំផុត ដូច្នេះអាងដែលមានជម្រៅទឹករាក់ នឹងទទួលបានខ្យល់ច្រើនជាងអាងដែលមានជម្រៅទឹកជ្រៅ។ ដូចនេះដើម្បីបានលំហូរខ្យល់ចូលក្នុងអាងនីមួយៗស្មើគ្នា ត្រូវដាក់វ៉ាល់សម្រាប់មួលបិទ បើកឱ្យបានត្រឹមត្រូវ។ បំពង់ដែលមានអង្កត់ផ្ចិតតូចផ្តល់នូវការកកិតច្រើន ដូចនេះនឹងមានលំហូរខ្យល់តិច បើប្រៀបធៀបទៅនឹងបំពង់ដែលមានអង្កត់ផ្ចិតធំ។ វាមានសារសំខាន់ណាស់ ជាពិសេសសម្រាប់ម៉ាស៊ីនបូមខ្យល់តូច និងមានសម្ពាធទាបដូចជា ម៉ាស៊ីនផ្លុំខ្យល់ ហើយម៉ាស៊ីនទាំងនោះមិនត្រូវដាក់ផ្ទាល់ដីនោះទេ ព្រោះវានឹងធ្វើឱ្យកខ្វក់នៅក្បែរច្រកស្រូបខ្យល់ចូល ហើយអាចនឹងមានគ្រោះថ្នាក់ ប្រសិនបើមានទឹកលេច។ យកល្អគួរដាក់ផុតពីទឹក និងនៅកន្លែងដែលងាយស្រួលទៅថែរក្សា និងត្រួតពិនិត្យ ។
- ត្រូវប្រើតម្រងខ្យល់សម្រាប់ការស្រូបខ្យល់ចូល និងសម្អាតជាប្រចាំ។
- ឧបករណ៍ផ្លុំខ្យល់ខ្លះងាយបែកបាក់ ហើយនឹងមានធ្លាយខ្យល់ចេញជាពពុះធំៗ ដែលអាចទាញយកខ្យល់ពីម៉ាស៊ីនដទៃផ្សេងទៀត។
- ត្រូវប្រុងប្រយ័ត្នខ្ពស់ ចំពោះឧបករណ៍អគ្គិសនីដែលនៅក្បែរទឹក។ វាមានគ្រោះថ្នាក់ខ្ពស់ដោយសារការឆក់ដោយចរន្តអគ្គិសនី។

## តើត្រូវជ្រើសយកម៉ាស៊ីនផ្លុំខ្យល់ ឬម៉ាស៊ីនបូមខ្យល់ទំហំប៉ុនណា?

អ្នកផ្គត់ផ្គង់ភាគច្រើននឹងផ្តល់ក្រាហ្វិក ឬតារាងបង្ហាញសមត្ថភាពបញ្ចេញខ្យល់នូវកម្រិតសម្ពាធផ្សេងៗគ្នា។ ដូច្នេះវារីវប្បករត្រូវដឹងថាតើទឹកជម្រៅណាដែលនឹងមាននៅក្នុងអាង និងគួរតែគិតអំពីអង្កត់ផ្ចិតនិងប្រវែងទុយោខ្យល់ដែលត្រូវប្រើ។ ពួកគាត់គួរតែដឹងថា តើចង់ប្រើថ្មខ្យល់ចំនួនប៉ុន្មានជាមួយម៉ាស៊ីនផ្លុំខ្យល់នោះ? ហើយថ្មខ្យល់ទាំងនោះត្រូវការកម្លាំងផ្លុំដូចម្តេច?

**ឧទាហរណ៍:** ឧបមាថា យើងមានអាងចំនួន១០ អាងនីមួយៗត្រូវការប្រដាប់ផ្លុំខ្យល់ចំនួន៥។ ទឹកនៅក្នុងអាងនោះមានជម្រៅ ៥០ សង់ទីម៉ែត្រ។ អ្នកផលិតថ្មខ្យល់និយាយថា ថ្មខ្យល់នីមួយៗ អាចដំណើរការបានល្អបញ្ចេញខ្យល់៥លីត្រ/នាទី។

ក្រាហ្វិកខាងក្រោមបង្ហាញពីដំណើរការរបស់ម៉ាស៊ីនផ្លុំខ្យល់ដែលមានទំហំខុសៗគ្នា។ តើថ្មខ្យល់មួយណាដែលតូចជាងគេបំផុត នឹងយកមកដំណើរការក្នុងស្ថានភាពនេះ?

- ថ្មខ្យល់សរុប= ១០ x ៥ = ៥០ គ្រាប់
- តម្រូវការខ្យល់សរុប = ថ្មខ្យល់ចំនួន ៥០ គ្រាប់ x ៥ លីត្រ/នាទី/គ្រាប់ = ២៥០ លីត្រក្នុង១នាទី

សម្ពាធសរុបក្នុងទឹកជម្រៅ ៥០សង់ទីម៉ែត្រ = ០,០៥ បារ ឬ ៥០មីលីបារ ឬ ០,៧ PSI (តិចជាងនេះចំពោះទឹកក្តៅឧណ្ណៗ)។ ទុយោខ្យល់របស់អ្នកនឹងប្រើសម្ពាធមួយចំនួនដើម្បីរ៉ាប់រងការកកិតដូច្នេះអាចនិយាយបានថាយើងចង់បញ្ជូនខ្យល់ ២៥០ លីត្រក្នុងមួយនាទីនូវសម្ពាធ ១០០ មីលីបារ (ឬ ១ បារ ឬ ១,៤ PSI) ។

ក្រាហ្វិកខាងក្រោមត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនផលិតម៉ាស៊ីនបូមខ្យល់៖
តាមក្រាហ្វិកខាងស្តាំ អ្នកអាចមើលឃើញថាម៉ូដែលម៉ាស៊ីនបូមខ្យល់ SL១៩០ អាចបញ្ជូនខ្យល់ដែលយើងត្រូវការ បានតិចតួចណាស់។ តាមពិតថ្មខ្យល់ដែលមានទុយោខ្យល់វែងមិនអាចទទួលខ្យល់បានគ្រប់គ្រាន់ទេពីព្រោះខ្យល់ ២៥០ លីត្រក្នុង១នាទី ហើយសម្ពាធនឹងតិចជាង ១ PSI ពីអ្វីដែលយើងអាចប៉ាន់ស្មានបានមកពីក្រាហ្វិក។




| MAX DEPTH (IN) | WATTS | OUTLET (IN) | 60HZ* CFM@1 PSI | CFM@2 PSI |
|---|---|---|---|---|
| AIR PUMPS FOR INDOOR USE | | | | |
| 85 | 9 | 1/4 | 0.5 | 0.2 |
| 120 | 15 | 1/4 | 0.85 | 0.56 |
| AIR PUMPS FOR OUTDOOR USE | | | | |
| 150 | 50 | 3/4 | 2 | 1.5 |
| 180 | 90 | 3/4 | 3.7 | 3 |
| 190 | 190 | 3/4 | 8.8 | 8.1 |

*For 50 HZ performance, deduct 17% from CFM ratings.

REPAIR KITS
Includes diaphragms, heads and valves.

| MODEL | FOR AIR PUMP MODELS | EACH |
|---|---|---|
| SL1424RK | SL14, SL24 | $49.19 |

## ផ្នែកទីពីរ៖ ការរៀបចំប្រព័ន្ធបញ្ចូលខ្យល់ក្នុងស្រះ

### ប្រភេទនៃប្រព័ន្ធបញ្ចូលខ្យល់

#### ១. ប្រព័ន្ធបាចទឹកទៅក្នុងខ្យល់

- កង្ហាទឹក
- ម៉ូទ័រសាចទឹក

#### ២. ប្រព័ន្ធរុញខ្យល់ចូលក្នុងទឹក

- ម៉ូទ័ររុញខ្យល់

- ម៉ូទ័របញ្ចូលខ្យល់
- ម៉ូទ័រសម្ពាធខ្យល់
- ម៉ូទ័របញ្ចូលខ្យល់តូចៗដូចជា ម៉ូទ័រខ្យល់ឌីយ៉ាហ្វ្រាម និងម៉ូទ័រខ្យល់ប្រើពីស្តុង

**របៀបវាយតម្លៃប្រព័ន្ធបញ្ចូលខ្យល់**

- តើបរិមាណអុកស៊ីសែនប៉ុន្មានត្រូវបញ្ចូលក្នុងទឹកនៅក្នុងមួយពេល?
- តើការប្រើប្រាស់ថាមពល១ គីឡូវ៉ាត់ វាអាចរុញបរិមាណអុកស៊ីសែនចូលក្នុងទឹកបានប៉ុន្មានលីត្រ?
- គួរគិតផងដែរពីតម្លៃរបស់ប្រព័ន្ធបញ្ចូលខ្យល់ តំរូវការថែរក្សា និងអាយុកាល

**របៀបនៃការគណនា (នេះគឺជាការបកស្រាយសាមញ្ញ - សមីការជាច្រើននឹងត្រូវប្រើ)**

១. ត្រូវដឹងចំណុះអាងឱ្យច្បាស់លាស់

២. ដកយកបរិមាណអុកស៊ីសែនចេញ

៣. បើកប្រព័ន្ធបញ្ចូលខ្យល់ និងវាស់បរិមាណអុកស៊ីសែនរៀងរាល់ពីរទៅបីនាទីម្តង។ កត់ត្រាពេលវេលា សីតុណ្ហភាព និងកម្រិតអុកស៊ីសែនរលាយក្នុងទឹក។

៤. បញ្ឈប់នៅពេលបរិមាណអុកស៊ីសែនដល់កម្រិតឆ្អែតប្រហែលជា៨០៥ នៅសីតុណ្ហភាពណាមួយ តេស្តនេះអាចធ្វើម្តងទៀតនៅពេលទឹកមានកំហាប់អំបិលខុសៗគ្នាប្រសិនបើត្រូវការព័ត៌មាន។

សង្ខេបតម្លៃនៃកម្រិតផ្ទេរអុកស៊ីសែនស្តង់ដា (SOTR) ដោយគិតជា (គីឡូអុកស៊ីសែន/ម៉ោង) និងតម្លៃមេគុណប្រសិទ្ធភាពការបូមខ្យល់ស្តង់ដា (SAE) ដោយគិតជា (គីឡូអុកស៊ីសែន/គីឡូវ៉ាត់ម៉ោង) សម្រាប់ប្រព័ន្ធខ្យល់ ប្រើអគ្គិសនីក្នុងវារីវប្បកម្ម។ តម្លៃSAE គឺទាក់ទងទៅនឹងថាមពលដែលត្រូវបានអនុវត្តចំពោះឧបករណ៍បង្កំនៃប្រព័ន្ធបូមខ្យល់ (ហ្វ្រាំងទប់អគ្គិសនី)(Boyd 1998) ។

| ប្រភេទប្រព័ន្ធបញ្ចូលខ្យល់ | ចំនួនម៉ូទ័រខ្យល់សាកល្បង | លំដាប់របស់ SOTR | SAE ជាមធ្យម | លំដាប់ |
|---|---|---|---|---|
| | | គីឡូអុកស៊ីសែន ក្នុង ១ម៉ោង | គីឡូអុកស៊ីសែន ក្នុង ១គីឡូវ៉ាត់ម៉ោង | គីឡូអុកស៊ីសែន ក្នុង ១គីឡូវ៉ាត់ម៉ោង |
| កង្ហារទឹក | ២៤ | ២,៥ - ២៣,២ | ២,២ | ១,១ - ៣,០ |
| ម៉ូទ័ររុញខ្យល់ | ១១ | ០,១ - ២៤,៤ | ១,៦ | ១,៦ - ១,៨ |
| ម៉ូទ័របញ្ចូលខ្យល់ | ១៥ | ០,៣ - ១០,៩ | ១,៤ | ០,៧ - ១,៨ |
| ម៉ូទ័រសាចខ្យល់ | ៣ | ១១,៩ - ១៤,៥ | ១,៣ | ០,៩ - ១,៩ |
| ថ្មខ្យល់ | ៥ | ០,៦ - ៣,៩ | ០,៩ | ០,៧ - ១,២ |

**គួរចំណាំថា៖** កង្ហារវាយទឹកមានទំហំខុសៗគ្នាជាច្រើន ហើយអាចមានទំហំធំទៀតផង ដូច្នេះកម្រិតស្តង់ដាផ្ទេរអុកស៊ីសែន (SOTR) អាចល្អបំផុត។ សូមកត់សំគាល់ផងដែរថា ប្រព័ន្ធផ្លុំខ្យល់ល្អ អាចមានសមត្ថភាពដូចកង្ហារវាយទឹកដែលរៀបចំមិន

បានល្អ។ រហាត់ទឹកដែលប្រើថាមពលពីត្រាក់ទ័រ វាអាចបញ្ជារហាត់វាយទឹកបានយ៉ាងល្អ ហើយអាចផ្តល់បរិមាណអុកស៊ីសែនយ៉ាងច្រើនដោយធ្វើឱ្យទឹកមានចលនាក្នុងស្រះ។ ក្នុងករណីមានគ្រាអាសន្ន វាជួយបានល្អ និងមានប្រសិទ្ធភាព ប៉ុន្តែវាមានតម្លៃថ្លៃចំពោះប្រតិបត្តិការរយៈពេលយូរ ។ ដោយសារវាធ្វើចលនាទឹកបានយ៉ាងល្អ ដូច្នេះវាក៏អាចច្រោះដីតាមគែមស្រះបានផងដែរ។





រូបភាព៖ រហាត់ទឹកដែលប្រើថាមពលពីត្រាក់ទ័រ

នៅពេលដែលវារីវប្បករ ពឹងផ្អែកខ្លាំងលើប្រព័ន្ធបញ្ចូលខ្យល់ ពួកគេក៏ចាប់ផ្តើមដំឡើងប្រព័ន្ធបញ្ចូលខ្យល់ដើរដោយថាមពលអគ្គិសនីនៅលើស្រះរបស់ពួកគេ ។

ខាងក្រោម៖ កង្ហារវាយទឹកដើរដោយថាមពលអគ្គិសនីផលិតនៅអាមេរិកនៅក្នុងអាងសាកល្បង







កង្ហារវាយទឹកផលិតនៅតៃវ៉ាន់ មានប្រសិទ្ធភាពតិចជាង ពាក់កណ្តាល បើធៀបទៅនឹងកង្ហារវាយទឹកដើរដោយថាមពលអគ្គិសនីផលិតនៅអាមេរិក ប៉ុន្តែវាមិនសូវថ្លៃនោះទេ និងមានលក់នៅក្នុងប្រទេសជាច្រើន។ វាក៏អាចរុញទឹកដែលមានអុស៊ីសែនឆ្លងកាត់ស្រះផងដែរ។

ប្រព័ន្ធបញ្ចូលខ្យល់ប្រភេទបាញ់ទឹក មើលទៅគួរឱ្យចាប់អារម្មណ៍ណាស់ ប៉ុន្តែវាមិនមានប្រសិទ្ធភាពច្រើនទេ។ នៅពេលដែលបាញ់ទឹកឡើងដល់កម្ពស់ ៣០សង់ទីម៉ែត្រឡើងទៅគឺមិនមានអុកស៊ីសែនរលាយក្នុងទឹកនោះទេ ប៉ុន្តែត្រូវចំណាយថាមពលជាច្រើនដើម្បីជំរុញទឹកឱ្យខ្ពស់។ ចំពោះប្រព័ន្ធបញ្ចូលខ្យល់ដោយបូមទឹក ត្រូវបូមទឹកឱ្យបានច្រើន ហើយបំបែកទឹក



រូបភាព ប្រព័ន្ធបញ្ចូលខ្យល់ប្រភេទបាញ់ទឹក

ជាដំណក់ទឹកតូចៗតាមដែលអាចធ្វើទៅបាន និងរក្សាកម្ពស់ទឹកមិនអោយខ្ពស់ជាង៣០សង់ទីម៉ែត្រ។ ប្រភេទម៉ាស៊ីនខ្យល់ល្អខ្លះ រុញចលនាទឹកបានច្រើន ហើយបំបែកទឹកវាជាដំណក់តូចៗ។ ទោះជាយ៉ាងណា ពួកវានៅតែមានគុណវិបត្តិនៃការបឺតរុញទឹកដែលនៅជិតម៉ាស៊ីននោះដដែលៗដូច្នេះវាសមបំផុតចំពោះស្រះដែលមានទំហំតូចៗ។

ម៉ាស៊ីនខ្យល់ប្រើស្លាបចក្រ ទាញខ្យល់ចូលតាមរយៈរន្ធតូចៗ ហើយរុញខ្យល់តាមស្លាបកង្ហារ ចូលទៅក្នុងទឹក ហើយនៅឃ្លាតឆ្ងាយពីតួម៉ាស៊ីនបូម។ វារីវប្បករចិញ្ចឹមបង្គានិយមប្រើម៉ាស៊ីនបែបនេះ ពីព្រោះវាអាចរុញទឹកដែលមានខ្យល់ ឬអុកស៊ីសែន ឆ្ពោះទៅបាតស្រះដែលជាកន្លែងបង្គារស់នៅ។ ស្លាបកង្ហារអាចផ្លាស់ប្តូរទិសមុំបាន។



រូបភាព៖ ម៉ាស៊ីនខ្យល់ប្រើស្លាបចក្រ

ម៉ូទ័ររុញខ្យល់ (ជាទូទៅដំណើរការដោយ ម៉ូទ័រផ្លុំខ្យល់ ឬម៉ូទ័របញ្ចេញខ្យល់ដោយប្រើប្រាស់សម្ពាធ) បញ្ជាជាមួយនឹងប្រព័ន្ធបូមខ្យល់ គឺពុំមានពពុះទឹកតូចៗលាយឡំជាមួយខ្យល់ស្ថិតនៅក្នុងទឹកបានយូរទេ ហើយប្រសិនបើពពុះទឹកកាន់តែមានទំហំធំនោះនឹងពុំមានអុកស៊ីសែនច្រើនរលាយក្នុងទឹកនោះទេ។ ទោះយ៉ាងណាក៏ដោយ ម៉ូទ័របែបនេះពួកវាដំណើរការបានល្អ ក្នុងការធ្វើចលនាទឹកពីបាតស្រះឆ្ពោះទៅលើបានល្អ និងធ្វើឱ្យទឹកស្រះច្របល់លាយគ្នាបានយ៉ាងល្អ ។ មានម៉ូដែលថ្មីៗខ្លះធ្វើឱ្យពពុះឡើងទៅលើប៉ះនឹងគម្រប រុញបន្ត ហើយរុញទឹកដែលមានខ្យល់ទៅជាមួយ ហើយរុញទឹកទៅឆ្ងាយដូចកង្ហារវាយទឹកដែរ ។



រូបភាព៖ ម៉ូទ័ររុញខ្យល់

# មេរៀន ៖

# ការចិញ្ចឹមត្រីក្នុងបៃ

# ការចិញ្ចឹមត្រីក្នុងបែ

ការចិញ្ចឹមត្រីក្នុងបែបានក្លាយជាវិស័យវារីវប្បកម្មដែលកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័សបំផុត នៅក្នុងប្រទេសដែលធ្វើវារីវប្បកម្មធំជាងគេបំផុតនៅលើពិភពលោក (ប្រទេសចិន)។ ការចិញ្ចឹមត្រីក្នុងបែកំពុងតែបានអនុវត្តនៅគ្រប់ទីកន្លែងជុំវិញពិភពលោក ក្នុងស្រះទឹកសាប បឹង អាងស្តុកទឹក ទឹកភ្លាវ និងទឹកសមុទ្រ។

ការចិញ្ចឹមត្រីក្នុងបែគឺជាការចិញ្ចឹមត្រីដាក់នៅក្នុងកន្លែងហ៊ុមជិតដែលមានសំណាញ់ព័ទ្ធជុំវិញ និងផ្នែកខាងក្រោមដែលអាចរក្សាត្រីបានឱ្យនៅខាងក្នុងហើយអាចឱ្យទឹកហូរចេញចូលដោយសេរី ផ្លាស់ប្តូរជាមួយនឹងបរិស្ថាន។

- បែដំបូងដែលបានប្រើប្រាស់ជាបែឈើ និងឫស្សី ជាមួយនឹងការផ្លាស់ប្តូរទឹកមិនល្អ។
- ចំណីជាប្រភេទកាកសំណល់ផ្ទះបាយ(ត្រីធម្មជាតិ)។ល។
- ការចិញ្ចឹមត្រីក្នុងបែតាមបែបប្រពៃណីបានអនុវត្តដោយប្រើប្រាស់ចំណីដែលមានគុណភាពមិនល្អ និងបែមានការផ្លាស់ប្តូរទឹកមានគុណភាពមិនល្អ។ ទីតាំងដែលស្ថិតនៅកន្លែងដែលសកម្មភាពមនុស្សជាច្រើន អាចបង្កអន្តរាយដល់បរិស្ថាន និងមានហានិភ័យច្រើន និងអាចសម្លាប់ត្រីទាំងអស់បានភ្លាមៗ។
- ការអនុវត្តន៍គោលការណ៍អេកូឡូស៊ីជាមូលដ្ឋាននៃវារីវប្បកម្ម ចំពោះការចិញ្ចឹមក្នុងបែ បានធ្វើឱ្យមានការកើនឡើងនូវចំនួនផលិតកម្មវារីវប្បកម្មដែលបានកើតមកពីចិញ្ចឹមក្នុងបែ។

ការរីកចម្រើនថ្មីៗនៅក្នុងការចិញ្ចឹមក្នុងបែគឺដោយសារតែ៖

- បង្កើនគុណភាពចំណីត្រី (ចំណីអណ្តែត៖ ល្អក្នុងការរំលាយ និងមេគុណចំណីទាប ការបំពុលទឹកតិច)
- ការយល់ដឹងកាន់តែច្បាស់អំពីចំនួនដងនៃការឱ្យចំណី និងបច្ចេកទេសកាត់បន្ថយការបាត់បង់ចំណីទៅក្នុងទឹក
- ដឹងពីកត្តាដែលធ្វើឱ្យត្រីក្នុងបែស្ត្រេស៖
    - គុណភាពទឹកមិនល្អ
    - លក្ខណៈនៃការគ្រប់គ្រង
    - ការរំខានដោយពួកមំសាសី(ត្រី ឬសត្វកាចសាហាវ)
- បែត្រូវបានរៀបចំឱ្យបានត្រឹមត្រូវនឹងលក្ខខណ្ឌបរិស្ថាន និងសេដ្ឋកិច្ច (បែតូច និងបែធំ)

## គោលការណ៍ណែនាំមួយចំនួនទាក់ទងទៅនឹងការចិញ្ចឹមក្នុងបែ

**ចំណុចសំខាន់បំផុតដែលត្រូវយល់ដឹង៖**

"គុណភាពទឹកក្នុងបែមិនអាចល្អជាងគុណភាពទឹកខាងក្រៅ វាអាចដូច ឬអន់ជាងអាស្រ័យទៅលើការផ្លាស់ប្តូរទឹក"

**គុណភាពទឹកនៅក្នុងបែអាស្រ័យលើ៖**

១. គុណភាពនៃផ្ទៃទឹកខាងក្រៅបែ

២. អត្រានៃការផ្លាស់ប្តូរទឹក រងឥទ្ធិពលដោយសារ៖

**២.១ ការសាងសង់បែ**

- ទំហំក្រឡាសំណាញ់ និងសម្ភារៈសាងសង់

- រូបរាង ទ្រង់ទ្រាយបៃ និងទីតាំងទិសនៃបៃ
- ទំហំបៃ

### ២.២ លំហូរទឹកឆ្លងកាត់បៃ

- ចរន្តទឹក
- ការដាក់ទីតាំងបៃស្របតាមលក្ខខណ្ឌបរិស្ថាន
- ការដាក់បៃឱ្យស្របទៅនឹងទីតាំងបៃផ្សេងទៀត
- ការដាក់បៃនៅក្បែរគ្នាធ្វើឱ្យងាយស្រួលសម្រាប់អ្នកចិញ្ចឹមប្រើផ្លូវដើរកាត់បៃនីមួយៗ ប៉ុន្តែវាធ្វើឱ្យប៉ះពាល់ដល់លំហូរទឹក ហើយគួរតែជៀសវាង។
- កសិដ្ឋានធំៗមួយចំនួនដាក់បៃរាប់រយនៅក្បែរគ្នាហើយពួកគេត្រូវរើសត្រីដែលងាប់ជាច្រើនគីឡូរៀងរាល់ថ្ងៃ។



រូបភាព៖ បៃចិញ្ចឹមត្រី

| | | |
|---|---|---|
| ១ | ២ | ៣ |
| ៤ | ៥ | ៦ |
| ៧ | ៨ | ៩ |

- តើបៃណាដែលអាចនឹងមានគុណភាពទឹកមិនល្អបំផុត?
- តើបៃណាខ្លះដែលអាចនឹងមានគុណភាពទឹកល្អបំផុត?

**ដង់ស៊ីតេ** គឺជាចំនួនត្រី ឬទំងន់ត្រីក្នុងចំណុះ១ម៉ែត្រគូប នៃបៃ។

ឧទាហរណ៍៖ ប្រសិនបើបៃមានទំហំ ៥ម x ៥ម x ៣ម ជម្រៅទឹក ដូច្នេះបរិមាណទឹកគឺ ៥ x ៥ x ៣ = ៧៥ ម៉ែត្រគូប (ម³)

- មិនត្រូវបញ្ចូលផ្នែកខាងក្រៅទឹកនៃបៃនោះទេ
- ប្រសិនបើបៃមានត្រីចំនួន ៥ ២៥០ក្បាលនោះ ៥ ២៥០ ចែកនឹង ៧៥ = ៧០ក្បាល/ម³

បៃតូចៗអាចផ្ទុកត្រីក្នុងដង់ស៊ីតេខ្ពស់ជាងបៃធំៗ។ ហេតុអ្វីក៏បែបនេះ?

និយាយឱ្យខ្លីទៅ មកពីបៃតូចៗវាមានភាពទូលាយរវាងបៃមួយ ទៅបៃមួយទៀត ដែលវាអាចអោយទឹកហូរចេញចូលបានល្អ។ បៃមានគ្រប់ទំហំនិងទម្រង់រាង។ តារាងខាងក្រោមបានបង្ហាញលំដាប់ខ្នាតមួយចំនួន។ ដោយបានសំគាល់ឃើញថា បៃកាន់តែធំ ដង់ស៊ីតេកាន់តែទាប។

| បរិយាយ | បែធំ | បែតូចតែដង់ស៊ីតេខ្ពស់ LVHD cage |
|---|---|---|
| ចំណុះ (ម៉ែត្រគូប) | ១០០ - ១ ០០០ + | ១ ទៅ ៥ |
| ដង់ស៊ីតេ (ចំនួនក្នុង១ម៉ែត្រគូប) | ៥ - ៥០ | ៣០០ - ៥០០ |
| ទិន្នផល (គីឡូក្រាមក្នុង១ម៉ែត្រគូប) | ២-២៨ | ១៥០-៥០០ ខ្ពស់បំផុត២០០ |

ការប្រៀបធៀបសមាមាត្រនៃកម្រិតផ្លាស់ប្តូរទឹក ខុសៗគ្នាតាមផ្ទៃខាងរបស់បែ (LSA)៖ ការប្រៀបធៀបការផ្លាស់ប្តូរទឹកត្រូវគណនាយកបែ ១ម៉ែត្រគូប ជាមូលដ្ឋាន។ ផ្ទៃខាងទាំងបួនរបស់បែដែលបានបូកសរុបហើយធ្វើការប្រៀបធៀប។ មិនមែនបាតទេ។

| វិមាត្រ (បxទxជ)ម៉ែត្រ | មាឌ (ម៉ែត្រគូប) | ផ្ទៃខាងបែ LSA: មាឌ ម៉ែត្រការ៉េ : ម៉ែត្រគូប | កម្រិតនៃការផ្លាស់ប្តូរទឹក (ភាគរយ) |
|---|---|---|---|
| ១ x ១ x ១ | ១ | ៤:១ | ១០០ ភាគរយ |
| ២ x ២ x ១ | ៤ | ២:១ | ៥០ ភាគរយ |
| ៤ x ៤ x ៤ | ៣២ | ១:១ | ២៥ ភាគរយ |
| ៧ x ៧ x ២ | ៩៨ | ០,៥៧:១ | ១៤ ភាគរយ |
| ៦ x ៦ x ៦ | ២១៦ | ០,៦៦:១ | ១៦,៦ ភាគរយ |
| ១១ x ១១ x ៣ | ៣៦៣ | ០,៣៦:១ | ៩ ភាគរយ |

ហេតុអ្វីបានជា ការចិញ្ចឹមត្រីក្នុងបែ **"ទំហំតូចដង់ស៊ីតេខ្ពស់"** ហើយវាមិនមែនជាបែធំលើសពី ១ ០០០ម៉ែត្រគូប

- ល្អបំផុតនៅពេលសំបូរទឹក ឬចរន្តទឹកហូរយឺត។
- មានហានិភ័យទាប លើការខាតបង់ខ្ពស់ ប្រសិនបើបែរហែក ឬធ្លាយ។
- តម្រូវការក្នុងការចំណាយទុនតិច ដូច្នេះងាយស្រួលសម្រាប់ "អ្នកចិញ្ចឹមត្រីខ្នាតតូច" ដើម្បីចាប់ផ្តើម។
- សម្ភារៈក្នុងការតម្លើងបែមានស្រាប់នៅក្នុងតំបន់។
- អាចឱ្យវារីវប្បករមានបែ បី-បួន ដូច្នេះអាចចិញ្ចឹមប្រភេទត្រីខុសគ្នា ឬក៏ធ្វើផែនការប្រមូលផលពេញមួយរដូវកាល។

## ការឱ្យចំណីត្រីក្នុងបែ

ត្រីដែលចិញ្ចឹមក្នុងបែមានដង់ស៊ីតេខ្ពស់ជាងត្រីដែលចិញ្ចឹមក្នុងស្រះ ហើយពួកវាក៏មិនមានឱកាសក្នុងការស្វែងរកចំណីធម្មជាតិនោះដែរ ដូច្នេះរបបអាហាររបស់ពួកវាត្រូវមានវីតាមីន និងជាតិរ៉ែហើយអាចមានតុល្យភាពជាមួយនឹងសារធាតុចិញ្ចឹម។ ប្រសិនបើមិនដូច្នេះទេ ពួកវានឹងមានសុខភាពខ្សោយ ឆាប់ឈឺ និងធំយឺត។ ប្រហែលត្រីដែលលូតលាស់ល្អបណ្តាលមកពីវាស៊ីគ្នាឯង។ ដូច្នេះចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ជាចំណីត្រូវការចាំបាច់ ហើយវាជាប្រភេទចំណី

អណ្តែត។ ចំណីទាំងអស់នោះអាចនឹងថ្លៃ តែប្រសិនបើប្រើប្រាស់ត្រឹមត្រូវ វាអាចជួយសន្សំសំចៃថវិកាជាងឱ្យស៊ីត្រីស្រស់។ ប្រសិនបើមានចំណីសល់ក្នុងបែនោះនឹងខាតលុយ។ ដូច្នេះពួកគេត្រូវតែធ្វើយ៉ាណាឱ្យចំណីទាំងអស់ស្ថិតនៅក្នុងបែ។ ពួកគេតែងតែការពារចំណីចេញដោយរៀបសំណាញ់ក្រឡាញឹកព័ទ្ធជុំវិញបែពីផ្ទៃខាងលើចុះទៅក្រោមប្រហែល ៤០សង់ទីម៉ែត្រ។

ទោះបីជាយ៉ាងណាក៏ដោយ សំណាញ់ដែលមានក្រឡាញឹកអាចរារាំងទឹកស្រទាប់លើមិនឱ្យហូរចូលក្នុងបែ ដែលស្រទាប់ទឹកខាងលើមានគុណភាពល្អបំផុត។ ទឹកដែលល្អបំផុតគឺនៅខាងលើ ដូច្នេះកុំបាំងទឹកហូរចូលបែ។

- វារីវប្បករមួយចំនួនប្រើប្រាស់បាវចំណីចាស់ៗជារនាំង ហើយទម្លាក់របាំងឱ្យទាបនៅពេលឱ្យចំណី។ ក្រោយពេលឱ្យចំណីរួចពួកគាត់ក៏លើករបាំងឡើងវិញ។
- អ្នកខ្លះធ្វើរបាំងចំណីនៅក្នុងបែ។ តំបន់ដែលឱ្យចំណីគួរតែ ១/៥ នៃទំហំបែ។
- ចំពោះបែធំ ឱ្យចំណីនៅកណ្តាលបែជាជម្រើសល្អបំផុត។


រូបភាព៖ បែដែលមានរបាំងចំណីក្នុងបែ

## គម្របបែ

មានភស្តុតាងមួយចំនួន ដែលបង្ហាញថាគម្របបម្លប់ធ្វើការបានល្អក្នុងការបង្ការត្រីខ្លាចក្នុងការបង្ហាញខ្លួននៅលើផ្ទៃទឹក ពិសេសសក្នុងស្ថានភាពទឹកថ្លា។ គម្របអាចជួយកាត់បន្ថយការបាត់បង់ត្រីពីការរំខានរបស់មំសាសីដែលជាពពួកត្រីស៊ីសាច់ជាអាហារ។ គុណវិបត្តិ គឺវាពិបាកសម្រាប់កសិករក្នុងការមើលថា តើត្រីកំពុងស៊ីចំណី និងដកត្រីដែលងាប់ចេញយ៉ាងដូចម្តេច។ ដូច្នេះ កសិករជាច្រើនបានចាប់ផ្តើមប្រើគម្របសំណាញ់មួយដែលត្រូវបានចងភ្ជាប់ ប៉ុន្តែងាយស្រួលសម្រាប់កសិករក្នុងការមើលឃើញត្រី និងបើកក្នុងករណីដែលពួកគេចង់យកសំណាក ប្រមូលផល ឬយកត្រីដែលងាប់ចេញ។

## ចំណុចដែលមានបញ្ហា

- ប្រភេទសំណាញ់ និងទំហំ៖ ប្រសិនបើវាតូចពេក វានឹងងាយប្រមូលផ្តុំពពួកកាកសំណល់ ឬគីង។ បើទំហំសំណាញ់ធំពេកត្រីងាយនឹងរួចបាត់អស់។ សូមចាំថា ទម្ងន់មធ្យមគឺគ្រាន់តែជាកម្រិតមធ្យម។ វាមិនប្រាប់អ្នកថាមានត្រីតូចៗប៉ុន្មាន ហើយមានទំហំប៉ុនណានោះទេ។
- អត្រាស្លាប់ខ្ពស់បន្ទាប់ពីស្តុក៖ កូនត្រីដែលមានគុណភាពមិនល្អមធ្យោបាយដឹកជញ្ជូន ឬការគ្រប់គ្រងមិនបានល្អ។
- ការផ្តល់ចំណីដែលសម្របនឹងត្រី៖ ត្រូវការយន្តការត្រួតពិនិត្យសារពើភ័ណ្ឌរួមមាន៖ មើលសកម្មភាពចាប់ចំណី ការយកសំណាកដើម្បីកំណត់ទម្ងន់ជាមធ្យម និងអាចជាការបូកសរុបទិន្នន័យសារពើភ័ណ្ឌពេញលេញមួយ បន្ទាប់ពីដំណាក់កាលបំប៉នកូន។
- ចំណីមានតម្លៃថ្លៃ៖ ត្រួតពិនិត្យដោយគណនា ដោយវិភាគមេគុណចំណីហើយធៀបនឹងតម្លៃចំណី។ ចំណីថោកអាចឱ្យវារីវប្បករចំណាយច្រើននៅពេលបូកសរុបនៅគ្រាចុងបញ្ចប់។
- អស់ថវិការសម្រាប់ផ្គត់ផ្គង់មុនពេលប្រមូលផលត្រី៖ រៀបចំផែនការចំណាយឱ្យបានល្អ ត្រូវយល់ដឹងពីតម្លៃចំណី

ដៃគូអនុវត្តគម្រោង៖ World Vision, Kansas State University, Auburn University

• ការលួចត្រីពីបែះ ដំបូងត្រូវប្រាកដថាអ្នកនឹងមិនបានធ្វើឱ្យត្រីងាប់នោះទេ។ បន្ទាប់មកពិនិត្យមើលនៅជុំវិញ ហើយស្ទើរតែគ្រប់គ្នាអាចស្គាល់ត្រីដែលចិញ្ចឹមក្នុងបែ។

## ការអនុវត្តការគ្រប់គ្រងវារីវប្បកម្មល្អសម្រាប់ការចិញ្ចឹមក្នុងបែ

- ប្រើប្រាស់តែចំណីអណ្តែតដែលមានគុណភាពខ្ពស់ (លើកលែងប្រភេទត្រីមួយចំនួន)។
- ការឱ្យចំណីមិនខ្ជះខ្ជាយ៖ ធានាថាត្រីស៊ីចំណីក្នុងរយៈពេល៥នាទី ឬតិចជាងនេះ មុនពេលដាក់ចំណីបន្ថែម។
- ផ្លាស់ទីបែ ១០ម៉ែត្រ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំដើម្បីឱ្យបាតបែទទេរស្អាត។ (ធ្វើឱ្យរូបធាតុសរីរាង្គនៅផ្នែកខាងក្រោមបំលែង)
- ប្រើគម្របបែ និងចាក់សោរ (បើចាំបាច់) ដើម្បីចៀសវាងការបំផ្លិចបំផ្លាញពីសត្រូវរបស់ត្រី។ សូមកុំប្រើការកំចាត់ត្រីកាច ដោយប្រើវិធីដែលគ្រោះថ្នាក់ ។
- ប្រមូលត្រីងាប់ពីបែរាល់ថ្ងៃ និងបោះចោលគ្រោងឆ្អឹងដែលនៅសល់លើដីឱ្យបានត្រឹមត្រូវ។
- កុំបោះចោលត្រីងាប់ចូលទៅក្នុងបឹង។
- ប្រមូលសំរាម និងកាកសំណល់វារផ្សេងទៀតចេញពីបែ ហើយបោះចោលឱ្យបានត្រឹមត្រូវ។
- សម្អាតសំណាញ់បែនៅលើគោក បន្ទាប់ពីប្រមូលផលត្រីក្នុងបែរួច។
- ពិនិត្យមើលកម្រិតថ្លានៃទឹក និងកម្រិតអុកស៊ីសែនរលាយក្នុងទឹកជារៀងរាល់សប្តាហ៍ក្នុងតំបន់ជុំវិញបែ និងនៅឆ្ងាយពីទីតាំងបែ ៥០ម៉ែត្រ។
- រក្សាកំណត់ត្រាការផ្តល់ចំណីប្រចាំថ្ងៃ និងទំងន់នៅពេលប្រមូលផល ដូច្នេះយើងអាចគណនាមេគុណចំណីបាន។
- ការប្រើប្រាស់ចំណីមានលាយថ្នាំ គួរតែត្រូវបានកំណត់ជំងឺ និងសមាសធាតុដែលត្រូវបានបញ្ជាក់ពីរដ្ឋាភិបាល។



រូបភាព៖ បែបណ្តែតក្នុងស្រះ

# មេរៀន ៖

# ប្រព័ន្ធវារីវប្បកម្មទឹកថ្លៃ ជាប្លុកក្នុងស្រះ

## ប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ (IPRS)

### វារីវប្បកម្មក្នុងបៃ/ប្រព័ន្ធបៃក្នុងស្រះ

យើងអាចធ្វើការប្រៀបធៀបរវាងការធ្វើវារីវប្បកម្មនៅក្នុងស្រះ ការចិញ្ចឹមក្នុងបៃ និងប្រព័ន្ធបៃក្នុងស្រះ។

### និយមន័យដំបូងមួយចំនួន៖

ការធ្វើវារីវប្បកម្មនៅក្នុងស្រះ គឺជាការចិញ្ចឹមត្រីក្នុងស្រះចំហរ។ មិនមែនជាទម្រង់ហាប៉ាក្នុងស្រះ ហើយក៏មិនមែនជាបៃក្នុងស្រះដែរ។ ទោះជាយ៉ាងណាក៏ដោយពេលខ្លះហាប៉ាក៏ត្រូវបានប្រើប្រាស់សម្រាប់ដាក់ត្រីបណ្តោះអាសន្នក្នុងស្រះដែរ។

ការធ្វើវារីវប្បកម្មនៅក្នុងបៃ គឺជាការដាក់ចិញ្ចឹមត្រីនៅក្នុងសំណាញ់ នៅក្នុងស្រះឬបឹង ឬនៅក្នុងប្រភពទឹកផ្សេងទៀតដូចជាប្រឡាយឬទន្លេ។

ចំពោះប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ វាប្រៀបដូចជាការចិញ្ចឹមត្រីក្នុងទម្រង់ជាអាង ឬប្រអប់ ជាធម្មតាមានរាង ចតុកោណកែងទ្រវែង ដែលជញ្ជាំង និងបាតមានលក្ខណៈបិទជិត ហើយជ្រុង២ទៀត ព័ទ្ធដោយសំណាញ់។ ការចិញ្ចឹមត្រីប្រព័ន្ធបែបនេះ អាចសាងសង់នៅក្នុងស្រះ ដែលជាធម្មតាគេសាងសង់ជាបេតុង (ជញ្ជាំង និងបាត) ឬជាជញ្ជាំងបិទជិត ដែលអាចធ្វើពីសំភារះដែលអាចអណ្តែតបាន។








ក្បាលផុងដែលបង្កើតលំហូរទឹក



ពពោះខ្យល់នាំទឹកឡើងលើអោយមានលំហូរ

ត្រូវបន្ថែមសន្ទះទៅក្នុងស្រះដើម្បីនាំទឹកជាចលនាលំហូរទឹកជុំវិញស្រះមុនពេលនាំទឹកត្រលប់ចូលប្រព័ន្ធបៃវិញ។







ទាំងនេះជាអាងប្រអប់ក្នុងស្រះ មួយចំនួន៖



ប្រអប់ចិញ្ចឹមត្រី (អាងបេតុង)៖ ប្រព័ន្ធចិញ្ចឹមតាមបៃ ក្នុងស្រះ ដោយប្រើ**កង្ហារ**រុញចលនាទឹកយឺតៗចូលទៅក្នុងប្រព័ន្ធបៃនីមួយៗ



ប្រអប់ចិញ្ចឹមត្រី (អាងអណ្តែត)៖ ប្រព័ន្ធចិញ្ចឹមតាមបៃ ក្នុងស្រះ ដោយប្រើ**ម៉ាស៊ីនខ្យល់**រុញចលនាទឹកយឺតៗចូលទៅក្នុងប្រព័ន្ធបៃ



ប្រព័ន្ធនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិ ដែលវារីវប្បករគួរតែគិតពិចារណា៖

| | ស្រះ | បែ | ទឹកវិលជាប្លុកក្នុងស្រះ |
|---|---|---|---|
| តម្លៃសាងសង់ | • តំលៃថោក<br>• តម្លៃផលិតក្នុង១គីឡូក្រាម អាចកើនខ្ពស់<br>• អាចកាត់បន្ថយថ្លៃដើមផលិតនៃស្រះក្នុងមួយគីឡូក្រាមហើយបន្ថែមឧបករណ៍ រហាត់ទឹក និងការផ្លាស់ប្តូរទឹក | • បែមានតំលៃថ្លៃ<br>• ថ្លៃក្នុងមួយគីឡូមានតម្លៃទាប<br>• ទាំង ស្ពានដើរ និងទូកមានតម្លៃថ្លៃជាងស្រះ | • មានតម្លៃថ្លៃ<br>• ថ្លៃក្នុងមួយគីឡូមានតម្លៃទាប<br>• ទទួលបានទិន្នផលខ្ពស់។ដោយសារមានឧបករណ៍ធ្វើឱ្យទឹកមានចលនា |
| អាយុកាល | • អាចប្រើពី ៥-៥០ ឆ្នាំ អាស្រ័យលើបច្ចេកទេសសាងសង់ | • ត្រូវជួសជុលសំណាញ់បែ ក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំ អាស្រ័យលើគុណភាពសំណាញ់ដែលប្រើប្រាស់ | • រៀបចំប្រព័ន្ធអាងធ្វើពីបេតុងអាចប្រើប្រាស់ក្នុង រយៈពេលយូរ៖ អាង សាងសង់កាលពី២០ឆ្នាំមុន ក៏នៅប្រើប្រាស់បានធម្មតា |
| កែសម្រួលគុណភាពទឹកដោយប្រើប្រាស់សារធាតុគីមី ឬឧបករណ៍រហាត់ទឹក | • គួរតែពិនិត្យគុណភាពទឹកដែលចូលទៅក្នុងស្រះ | • ត្រូវគ្របបែដោយប្រើតង់ បន្ទាប់មកកែសម្រួល ឬពិនិត្យបែ | • ត្រូវការបិទផ្នែកខាងមុខ និងខាងក្រោយនៃចរន្តទឹកដើម្បីកែប្រែគុណភាពទឹក។<br>• នៅពេលដែលមិនត្រូវការកែលំអគុណភាពទឹក ត្រូវបន្តប្រើឧបករណ៍បញ្ចូលខ្យល់ក្នុងទឹកដោយរុញចរន្តទឹកបាចឡើងទៅលើ។ |
| ប្រភេទត្រី ដែលគួរចិញ្ចឹម | • គ្រប់ប្រភេទ ប៉ុន្តែអាចនឹងពិបាកប្រើអួនក្នុងការប្រមូលផល អាចនឹងប្រសើរជាងបើអាចដាក់ប្រព័ន្ធបែក្នុងស្រះ | • ត្រីចាំបាច់ត្រូវមានលក្ខខណ្ឌដង់ស៊ីតេខ្ពស់<br>• ងាយស្រួលចំពោះត្រីដែលពិបាកប្រើអួនអូស | • ប្រមូលផលត្រីអោយបានល្អ ចំពោះត្រីដែលពិបាកប្រើអួនអូស<br>• ត្រីមានតម្លៃ ដោយសារត្រូវចិញ្ចឹមក្នុងប្រព័ន្ធ ដែលមានឧបករណ៍រហាត់ទឹក<br>• ចិញ្ចឹមត្រីទីឡាព្យ៉ាបានល្អ ដូចគ្នានឹងត្រីកាបស៊ីស្មៅផងដែរ<br>• ប្រភេទត្រីដែលស៊ីចំណីតាមរយៈការច្រោះអាចត្រូវបន្ថែមក្នុងស្រះបាន |
| ដង់ស៊ីតេត្រី | • 0.៥ ទៅ ២ គ.ក / ម៣ ក្នុងទឹកនឹង (អាចចិញ្ចឹមក្នុង<br>• ដង់ស៊ីតេខ្ពស់ ប្រសិនមានរហាត់ទឹកផ្តល់អុកស៊ីសែន និងផ្លាស់ប្តូរទឹក) | • ដាក់ពី ២០ ទៅ ២០០ គ.ក / ម៣ ក្នុងបែ<br>• តែបែក្នុងស្រះអាចដាក់<br>• 0.៥ ទៅ ១ គ.ក / ម៣ | • ១០០-២០០ គ.ក / ម៣ ចំពោះប្រព័ន្ធបែក្នុងស្រះ<br>• សម្រាប់ស្រះ ដែលមានប្រព័ន្ធបែអាច<br>• ផលិតបាន ពី ២ ទៅ ៤ គ.ក / ម៣ ឬច្រើនជាងនេះប្រសិនបើប្រមូលកាកសំណល់បានល្អ |

| | | | |
|---|---|---|---|
| វិធីសាស្ត្រឱ្យចំណី | • អាស្រ័យទៅលើប្រភេទត្រី អាចប្រើចំណីធម្មតា និងជី ឬចំណីរោងចក្រ | • ដាក់ចំណីនៅកណ្តាលបែឬប្រើកន្ត្រងដាក់ចំណី<br>• ត្រូវប្រើចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ | • ឱ្យស៊ីឃើតៗ នៅពីមុខបែ មិនត្រូវឱ្យចំណីប៉ះនឹងជញ្ជាំងបែខាងក្រោយឡើយ<br>• ត្រូវប្រើចំណីគ្រាប់ |
| វិធីសាស្ត្រប្រមូលផល | • ប្រើអួន តែវាមិនអាចប្រមូលត្រីបានអស់នោះទេ ត្រូវការបូមបន្ថែម | • លើកបែឡើងយកត្រីចេញ ហើយជញ្ជូនត្រីទៅកាន់ច្រាំង។ ជាធម្មតាត្រូវយកបែចេញ និងសម្អាត | • ត្រីច្រើននៅក្នុងបែ ប្រមូលត្រីចេញបន្ទាប់មកអាចលើកបែឡើងប្រសិនជាអាចធ្វើបាន ឬបើកផ្នែកខាងក្រោយនៃបែអោយត្រីចូលក្នុងអួន ឬសំណាញ់ដែលបានរៀបចំជាស្រេច បន្ទាប់មកយកត្រីក្នុងអួនដាក់ស្រះ |
| ហានិយភ័យ | • ស្រះនឹងរីងស្ងួតនៅរដូវប្រាំង<br>• ទឹកជន់ទៅក្នុងស្រះ<br>• ប្រឈមពពួកសត្វចង្រៃ/ត្រីកាច<br>• គុណភាពទឹកមិនល្អធ្វើឱ្យត្រីងាប់ឆាប់រហ័ស | • គុណភាពទឹកក្នុងបែ មិនដែលល្អជាងគុណភាពទឹកក្រៅបែនោះទេ<br>• បែហែកបណ្តាលឱ្យបាត់បង់ត្រី<br>• បើគុណភាពទឹកនៅបឹងឬស្រះមិនល្អ ត្រីក្នុងបែនឹងងាប់មុនត្រីនៅក្នុងស្រះ<br>• ជារឿយៗម្ចាស់បែ មានការគ្រប់គ្រងតិចតួចឬគ្មានការគ្រប់គ្រងទឹក | • សម្រាប់ប្រពន្ធ័បែចាស់ៗដែលបានជួសជុលរអាចប្រឈមនឹងទឹកជំនន់ជាកត្តាដែលធ្វើឱ្យបាត់បង់ត្រី<br>ជ្រើសរើសប្រពន្ធ័បែដែលមានគុណភាពអន់អាចធ្វើឱ្យត្រីរួចចេញយ៉ាងងាយ<br>• ការដាច់ចរន្តអគ្គិសនីអាចនាំឱ្យត្រីងាប់យ៉ាងច្រើន។ ត្រូវតែមានថាមពលបម្រុងទុកដែលអាចទុកចិត្តបាន |
| លក្ខខ័ណ្ឌ<br>បរិស្ថាន | • ស្រះដើរតួជាតម្រងជីវសាស្ត្រ ហើយសំណល់ត្រីនឹងវិលចុះឡើងក្នុងស្រះ។<br>• នេះជាមូលហេតុដែលអត្រាឱ្យចំណីជាមធ្យមពី ៥០ ទៅ ១០០ គ.ក / ហិកតា / ថ្ងៃ | • បែអនុញ្ញាតឱ្យកាកសំណល់ត្រីចូលផ្លូវទឹកដែលជាកន្លែងដាក់សាងសង់បែ។<br>• មានចំណីអតិប្បរិមាក្នុងមួយហិកតាក្នុងមួយថ្ងៃមានបរិមាណទាបជាងស្រះ (២ ទៅ ៨ គីឡូក្រាម / ហិកតា / ថ្ងៃ)។ | • ប្រព័ន្ធបែអាចរុញកាកសំណល់ចូលក្នុងប្រព័ន្ធស្រះ។ ទោះបីជាយ៉ាងណាក៏ដោយ ជាធម្មតាស្រះនិងប្រព័ន្ធបែ ត្រូវគ្រប់គ្រងដោយម្ចាស់ តែមួយ។<br>• អាចកំចាត់កាកសំណល់ពីត្រី ដូច្នេះធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពផ្ទុករបស់ស្រះ។ |

តើអ្វីទៅជាចំណុចខុសគ្នារវាងការចិញ្ចឹមក្នុងបែ និងការចិញ្ចឹមប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ?

- គុណភាពទឹកក្នុងបែគឺដូចគ្នា ហើយមានគុណភាពអន់ល្អជាង គុណភាពទឹកក្នុងប្រព័ន្ធស្រះ
- ប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ គុណភាពទឹកនៅក្នុង ប្រព័ន្ធបែប្រសើរជាងក្នុង ប្រព័ន្ធស្រះ ពីព្រោះវាផ្លាស់ប្តូរដោយសាររហាត់ទឹក។ ដូច្នេះកម្រិតអុកស៊ីសែនក្នុងស្រះអាចទាប តែកើនឡើងតិចតួចនៅក្នុងប្រព័ន្ធបែ។
- សម្រាប់បែ ប្រសិនបើដាក់បែច្រើនពេកទៅក្នុងស្រះ ឬបឹង គុណភាពទឹកនឹងឆាប់ប្រែទៅជាមិនល្អ។ ប្រសិនបើវាជាបឹងសាធារណៈ នៅពេលអ្នកចិញ្ចឹមត្រីចាប់ផ្តើមរកលុយបានពីការចិញ្ចឹមតាមបែជាលើកដំបូង ពេលនោះនឹងមានអ្នកផ្សេងចូលក្នុងបឹងនោះ ហើយដែលអាចបំពុលត្រីដោយសារតែកាកសំណល់របស់ត្រី ទាំងនោះជាបញ្ហាដែលកើតឡើងសម្រាប់អ្នកចិញ្ចឹមគ្រប់គ្នាៗ។
- ចំពោះការចិញ្ចឹមប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះគ្រប់ពេលដាក់បែបន្ថែម នោះឧបករណ៍បញ្ចូលខ្យល់ក្នុងទឹកក៏ត្រូវបានបន្ថែមដែរ។ ផ្ទៃទឹកអាចផ្ទុកលើសចំណុះ ប៉ុន្តែដោយសារតែមានការបញ្ចូលខ្យល់ក្នុងប្រព័ន្ធ ដូចនេះវាអាចនឹងកើតឡើងយឺតៗ ។
- ដូចគ្នានេះដែរ ប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ បានធ្វើការកំចាត់កាកសំណល់រឹងនៅផ្នែកខាងក្រោយនៃបែដោយសារតែទឹកកខ្វក់ត្រូវបានបញ្ជូនចេញដោយផ្ទាល់ទៅកាន់ផ្នែកម្ខាងទៀតនៃបែតាមលំហូទឹក
- គេសន្និដ្ឋានថា សាច់ត្រីដែលបានមកពីការចិញ្ចឹមប្រព័ន្ធបែក្នុងស្រះ មានគុណភាពល្អជាង ពីព្រោះត្រីរស់នៅក្នុងទឹកដែលមានចលនា។









# សន្ទានុក្រម និងបច្ចេកសព្ទ
# ធារីវប្បកម្ម

# សន្ទានុក្រម និងបច្ចេកសព្ទវារីវប្បកម្ម

| ល.រ | English | ពាក្យខ្មែរ |
|---|---|---|
| 1 | Abnormal | មិនប្រក្រតី |
| 2 | Absorb | ស្រូបទឹក |
| 3 | Accumulated | ដែលលាយឡំជាមួយ ឬដែលប្រមូល ផ្តុំបាន |
| 4 | Acclimate | បន្សាំទៅនឹងមជ្ឈដ្ឋានថ្មី |
| 5 | Adrenaline | អ័រម៉ូនអាត្រេណាលីន |
| 6 | Advantage | អត្ថប្រយោជន៍ |
| 7 | Advisable | ជាការណែនាំ |
| 8 | Aeration | ការបញ្ចូលខ្យល់ក្នុងទឹក |
| 9 | Agriculture lime | កំបោរកសិកម្ម |
| 10 | Aggressive | គឃ្លើន កាច |
| 11 | Air bubble | ពពុះខ្យល់ |
| 12 | Air breathing fish | ត្រីដែលអាចដកដង្ហើមក្នុងខ្យល់ ឬត្រីដែលមានប្រព័ន្ធដកដង្ហើមរង |
| 13 | Air pump | ម៉ាស៊ីនខ្យល់ ឬ ម៉ូទ័រខ្យល់ |
| 14 | Air stone | ដុំខ្យល់ ឬ ក្បាលខ្យល់ |
| 15 | Air tubing | ប្រព័ន្ធទុយោខ្យល់ |
| 16 | Alkalinity | អាល់កាឡាំង |
| 17 | Aluminum Sulfate (Alum) | សាច់ជូរ ស |
| 18 | Amino Acid | អាមីណូអាស៊ីត ឬ អាស៊ីតអាមីនេ |
| 19 | Ammonia | អាម៉ូញាក់ |

| | | |
|---|---|---|
| 20 | Anesthetic | ថ្នាំសណ្ដំ |
| 21 | Antibiotic | អង់ទីប៊ីយ៉ូទិច |
| 22 | Antibiotic resistance | ភាពស៊ាំនៃឱសថអង់ទីប៊ីយ៉ូទិច |
| 23 | Antibody | អង្គបដិបក្ខ |
| 24 | Anti-oxidant | ភ្នាក់ងារប្រឆាំងអុកស៊ីតកម្ម ឬ អង់ទីអុកស៊ីដង់ |
| 25 | Appearance | រូបរាងខាងក្រៅ អាការៈក្រៅ |
| 26 | Apply | ប្រើប្រាស់ ឬស្នើសុំ |
| 27 | Appropriate | សមស្រប ឬ ត្រឹមត្រូវ |
| 28 | Aquaculture | វារីវប្បកម្ម |
| 29 | Aquaria | ជលវប្បដ្ឋាន |
| 30 | Aquifer | ដង្ហើមទឹក |
| 31 | Arsenic | សារធាតុអាសេនិច |
| 32 | Artemia | អាតេមៀ |
| 33 | Artesian Well | អណ្ដូងដែលចេញទឹកផុតពីផ្ទៃដី |
| 34 | Ash | ផេះ |
| 35 | Assumption | ការសន្មត |
| 36 | Backflow | លំហូត្រឡប់ក្រោយ |
| 37 | Bacteria | បាក់តេរី |
| 38 | Bank | ច្រាំងស្រះ |
| 39 | Barbed | ដែលមានងាង |
| 40 | Batch | វគ្គ ក្រុម |
| 41 | Belt-driven equipment | ឧបករណ៍អូសដោយខ្សែពាន |

| | | |
|---|---|---|
| 42 | Best management practice | ការអនុវត្តការគ្រប់គ្រងល្អបំផុត |
| 43 | Biofilter | ចម្រោះជីវសាស្ត្រ |
| 44 | Biological Oxygen Demand (BOD) | កំរិតអុកស៊ីសែនសមស្របសម្រាប់រក្សាជីវិតបាក់តេរីដែលត្រូវការអុកស៊ីសែន |
| 45 | Biological process | ដំណើរការផ្នែកជីវសាស្ត្រ |
| 46 | Biology | លក្ខណជីវសាស្ត្រ |
| 47 | Biosecurity | ជីវសុវត្ថិភាព |
| 48 | Biosecurity protocol | វិធានជីវសុវត្ថិភាព |
| 49 | Black water | ទឹកកខ្វក់ |
| 50 | Blast | ផ្ទុះ ផ្ទុះចេញ |
| 51 | Bleed Off | បន្ទូរខ្យល់ ឬឧស្ម័ន ឬហូរចេញ |
| 52 | Blood chemistry | សារធាតុគីមីក្នុងឈាម |
| 53 | Blower | ម៉ាស៊ីនផ្លុំខ្យល់ |
| 54 | Borehole | អណ្តូងខួង |
| 55 | Brand | យីហោ |
| 56 | Break down (Nutrients) | បំបែក បំលែង |
| 57 | Broad-spectrum disinfectant | សារធាតុគីមីសម្លាប់មេរោគដែលមានវិសាលភាពធំទូលាយ |
| 58 | Bubble | ពពុះ |
| 59 | Buried | ដែលកប់ក្នុងដី |
| 60 | Burnt Lime | កំបោររស់ |
| 61 | Cage Culture | វារីវប្បកម្មក្នុងបែ |
| 62 | Calcium | កាល់ស្យូម |

| | | |
|---|---|---|
| 63 | Calcium Carbonate | កាល់ស្យូមកាបូណាត ឬកំបោរកសិកម្ម |
| 64 | Calibrated cup | កែវក្រិត (ខ្នាច់) |
| 65 | Canal | ប្រឡាយទឹក |
| 66 | Carbone brush | ធ្យូងដេម៉ារ័ |
| 67 | Carbone dioxide | ឧស្ម័នកាបូនិច |
| 68 | Carrier | ភ្នាក់ងារចម្លង |
| 69 | Carrying Capacity | សមត្ថភាពផ្ទុក |
| 70 | Catch basin | អាងប្រមូលផ្ដុំត្រីក្នុងស្រះ |
| 71 | Central nervous system | ប្រព័ន្ធសសៃប្រសាទកណ្ដាល |
| 72 | Chemical | សារធាតុគីមី |
| 73 | Chemical Oxygen Demand (COD) | បរិមាណអុកស៊ីសែនដែលប្រើប្រាស់ក្នុងប្រតិកម្មអុកស៊ីតកម្មដើម្បីបំបែកសារធាតុសរីរាង្គក្នុងទឹក |
| 74 | Chemistry | លក្ខណៈគីមី |
| 75 | Chlorine | ក្លរ |
| 76 | Clay content | សមាសធាតុដីឥដ្ឋ |
| 77 | Climbing perch | ត្រីក្រាញ់ |
| 78 | Clogged | ស្ទះ |
| 79 | Clump | ផ្ដុំជាប់គ្នា ឬកកជាដុំ |
| 80 | Colloid | ភាគល្អិតតូចៗដែលរសាត់ក្នុងផ្ទៃទឹក |
| 81 | Coloration | ការធ្វើឱ្យមានព័ណ៌ |
| 82 | Combustion | ការឆាបឆេះ |
| 83 | Compaction | ការបង្ហាប់ |

| | | |
|---|---|---|
| 84 | Composition | សារធាតុផ្សំ |
| 85 | Compressor | ម៉ាស៊ីនសម្ពាធខ្យល់ |
| 86 | Compromised | ខូចសមត្ថភាព ខ្សោយសមត្ថភាព |
| 87 | Concentration | កំហាប់ |
| 88 | Condensation | ការកជាដំណក់ទឹក |
| 89 | fish Conditioning | ការដាក់ត្រីក្នុងស្ថានភាពឬកន្លែងណាមួយក្នុងរយៈពេលកំណត់ណាមួយ មុននឹងយកត្រីទាំងនោះទៅកន្លែងណាមួយ ដើម្បីបន្ថយនូវភាពស្ត្រេស |
| 90 | Consistency | ដែលដូចគ្នា ដែលប្រដំប្រសងនឹងគ្នា |
| 91 | Constructed Wetland | បរិវេណកែគុណភាពទឹក |
| 92 | Contaminate | ធ្វើឱ្យកខ្វក់ ធ្វើឱ្យប្រឡាក់ ធ្វើឱ្យឆ្លងរោគ |
| 93 | Container | ធុង |
| 94 | Copper Sulfate | សាច់ជូរខៀវ ឬទង់ដែងស៊ុលផាត |
| 95 | Corrosive | កាត់ ដែលកាត់ ដែលស៊ី ដែលច្រេះចាប់ |
| 96 | Cortisol | អ័រម៉ូនគ័រទីសូល (អ័រម៉ូនស្ត្រេស) |
| 97 | Crack | ប្រេះបែកក្រហែង |
| 98 | Crooked | កោង |
| 99 | Crop | វគ្គ ឬលើកនៃការចិញ្ចឹម |
| 100 | Culturist | វារីវប្បករ |
| 101 | Cycle | វគ្គ ឬ វដ្តនៃការចិញ្ចឹម វដ្តជីវិត |
| 102 | Dam | ទំនប់ |
| 103 | Decimate | បំផ្លាញ |

| | | |
|---|---|---|
| 104 | Decomposition | ការបំបែកសារធាតុសរីរាង្គដោយសកម្មភាពមីក្រុប |
| 105 | Decontaminate | សម្លាប់មេរោគ |
| 106 | Deformity | ការខូចទ្រង់ទ្រាយដើម |
| 107 | Dehydration | ការបាត់បង់ជាតិទឹក |
| 108 | Density | ដង់ស៊ីតេ |
| 109 | Deplete | ប្រើអស់ |
| 110 | Descending | តាមលំដាប់លំដោយពីធំមកតូច |
| 111 | Detergent | សាប៊ូ |
| 112 | Deteriorate | ធ្វើឱ្យខូច ធ្វើឱ្យបាត់បង់សមត្ថភាព បំផ្លាញ |
| 113 | Detrimental | បង្កអន្តរាយ |
| 114 | Diaphragm pump | ម៉ូទ័រខ្យល់(ឌីយ៉ាហ្វ្រាម) |
| 115 | Diffuser | ឧបករណ៍បញ្ចូលខ្យល់ ឧបករណ៍បំបែកខ្យល់ |
| 116 | Digest | រំលាយ |
| 117 | Digestible | ដែលអាចរំលាយបាន |
| 118 | Dike | ទំនប់ ឬភ្លឺស្រែ |
| 119 | Dilution | ការធ្វើឱ្យរាវ ការបន្ថយកំហាប់ |
| 120 | Dimension | វិមាត្រ |
| 121 | Dip | ជ្រលក់ |
| 122 | Dip net | កន្ត្រងដួស |
| 123 | Disable (Disease) | អសមត្ថភាព ពិការ |
| 124 | Discolor | បាត់ព័ណ៌ ស្លកព័ណ៌ |
| 125 | Disease | ជំងឺ |

| | | |
|---|---|---|
| 126 | Disease-causing organism | ភ្នាក់ងារបង្កជំងឺ |
| 127 | Disinfect | សម្លាប់មេរោគ |
| 128 | Disintegrate | បំបែក |
| 129 | Dissipate | បន្ថយ រសាយ |
| 130 | Dissolved Oxygen (DO) | អុកស៊ីសែនរលាយក្នុងទឹក |
| 131 | Distended | ដែលប៉ោងធំ |
| 132 | Drain | បូមទឹកចេញ បង្ហូរទឹកចេញ ពង្រីង បូម |
| 133 | Drop | ដំណក់ ស្រក់ បន្តក់ |
| 134 | Drug | ថ្នាំ |
| 135 | Dry | ហាល ឬស្ងួត |
| 136 | Duckweed | ចកបាយទា |
| 137 | Dumper | អ្នកចាក់ចំណី ឬអ្នកផ្តល់ចំណីមិនអនុវត្តតាមបច្ចេកទេស |
| 138 | Dyke | ទំនប់ ឬភ្លឺស្រែ |
| 139 | Ecological principle | គោលការណ៍អេកូឡូស៊ី |
| 140 | Elevation | ការវាស់កំពស់ទីតាំង ឬនីវ៉ូ |
| 141 | Encystment | រស់នៅក្នុងថង់ភ្នាស |
| 142 | Enzyme | អង់ស៊ីម |
| 143 | Eradicate | បំផ្លាញឱ្យផុតពូជ លុបបំបាត់ឱ្យផុតពូជ |
| 144 | Erode | ច្រោះដី |
| 145 | Evaporation | រំហួត |
| 146 | Evapo-transpiration | ការស្រូបបំភាយ រំហួត បំភាយទឹកពីស្លឹករុក្ខជាតិទៅក្នុងបរិយាកាស |

| | | |
|---|---|---|
| 147 | Exotic | កម្រ ក្រៅស្រុក |
| 148 | Facility | កន្លែង |
| 149 | Farm Enterprise Plan | ផែនការអាជីវកម្មកសិដ្ឋាន |
| 150 | Feces | លាមក |
| 151 | Feed Conversion Ratio (FCR) | មេគុណចំណី |
| 152 | Feed barrier | របាំងការពារចំណី |
| 153 | Feeder | អ្នកឱ្យចំណី ឬឧបករណ៍ផ្តល់ចំណី |
| 154 | Feeding response | សភាពស៊ីចំណី |
| 155 | Feeding table | តារាងផ្តល់ចំណី |
| 156 | Fencing | ការព័ទ្ធរបង |
| 157 | Fertilizer | ជី |
| 158 | Fiber | ជាតិសរសៃ |
| 159 | Fine mesh | សំណាញ់ក្រឡាញឹក |
| 160 | Fingerling | កូនត្រីពូជ |
| 161 | First in-first out | ចូលមុនចេញមុន(សម្រាប់ឃ្លាំង) |
| 162 | Fish-eating bird | បក្សីស៊ីត្រីជាអាហារ |
| 163 | Fish-free pond | ស្រះដែលគ្មានត្រី ឬស្រះទំនេរ |
| 164 | Fish-free water | ទឹកដែលគ្មានត្រី ឬទឹកដែលបានច្រោះរួច ដោយស្បៃ ឬសំណាញ់ |
| 165 | Fish movement | ការបម្លាស់ទីត្រី |
| 166 | Float | អណ្តែតលើទឹក |
| 167 | Floating feed | ចំណីអណ្តែត |
| 168 | Fluid | សារធាតុរាវ |

| | | |
|---|---|---|
| 169 | Flushing out | បង្ហូរទឹកចេញ |
| 170 | Formalin | ហ្វ័រម៉ុល |
| 171 | Foul | ធ្វើឱ្យកខ្វក់ |
| 172 | Fountain | ឧបករណ៍បាញ់ទឹកផុសឡើង |
| 173 | Fragile | ដែលងាយបាក់បែក |
| 174 | Freeboard | កម្ពស់នៃមាត់អាង ស្រះ ឬបែ ធៀបទៅនឹងកម្ពស់នៃទឹកក្នុងប្រព័ន្ធនោះ |
| 175 | Friction | សំណឹកនៃលំហូរសារធាតុរាវក្នុងបំពង់ ឬទុយោ |
| 176 | Frog | កង្កែប |
| 177 | Fry | កូនត្រីម្សៅ |
| 178 | Fungus | ពពួកផ្សិត |
| 179 | GI pipe | បំពង់ទីប |
| 180 | Galvanize | ស្រោបពីក្រៅការពារច្រែះ |
| 181 | Genetic Marker | ព័ត៌មានសេនេទិច |
| 182 | Gill | ស្រកី |
| 183 | Glove | ស្រោមដៃ |
| 184 | Goggle | វ៉ែនតាការពារភ្នែក |
| 185 | Good Aquaculture Practices | ការអនុវត្តវារីវប្បកម្មល្អ |
| 186 | Gravity flow | ហូរពីខ្ពស់មកទាប |
| 187 | Grind | កិន |
| 188 | Groundwater | ទឹកក្រោមដី |
| 189 | Growth | ការលូតលាស់ |

| | | |
|---|---|---|
| 190 | Growth out | ការចិញ្ចឹមយកសាច់ ឬផលិតកម្មត្រីសាច់ |
| 191 | Grub | ដង្កូវបរាសិត |
| 192 | Gut | ក្រពះ |
| 193 | Gypsum | ជីកាល់ស្យូមស៊ុលផាត |
| 194 | HACCP | គោលការណ៍ហាសិប |
| 195 | Habitat | ជម្រក |
| 196 | Handle | គ្រប់គ្រង កាន់ ចាប់ សម្រួល |
| 197 | Hapa | ហាប៉ា |
| 198 | Harvest | ប្រមូលផល |
| 199 | Harvest basin | អាងប្រមូលផល |
| 200 | Harvest record | កំណត់ត្រាប្រមូលផល |
| 201 | Hatch | ញាស់ ឬភ្ញាស់ |
| 202 | Hatchery | ស្ថានីយ៍ ឬកន្លែងបង្កាត់ភ្ញាស់ត្រីពូជ |
| 203 | Heavy metal | លោហៈធ្ងន់ |
| 204 | High-fat diet | ចំណីមានជាតិខ្លាញ់ខ្ពស់ |
| 205 | High-value | ដែលមានតម្លៃសេដ្ឋកិច្ច |
| 206 | High pressure hose | ទុយោដែលធន់នឹងសម្ពាធខ្ពស់ |
| 207 | Home-made feed | ចំណីផ្សំ ឬចំណីដែលផលិតនៅកសិដ្ឋានផ្ទាល់ |
| 208 | Host | ម្ចាស់បញ្ញើ |
| 209 | Humid | ដែលមានសំណើម |
| 210 | Humidity | សំណើម |
| 211 | Hydraulic | នៃសំពាធទឹក |

| | | |
|---|---|---|
| 212 | Hydrated lime | កំបោរងាប់ |
| 213 | Hydrogen peroxide | អ៊ីដ្រូសែនពែអុកស៊ីត ឬទឹកអុកស៊ីសែនណេ |
| 214 | Hydrogen sulfide | អ៊ីដ្រូសែនស៊ុលភីត |
| 215 | Hypochlorite (HTH) | អ៊ីប៉ូក្លរីត |
| 216 | Illustration | ការពន្យល់ ឬបង្ហាញដោយរូបភាព |
| 217 | Immerse | ជ្រលក់ ឬពន្លិច |
| 218 | Immune | ស៊ាំ |
| 219 | Impede | រារាំង បង្អាក់ |
| 220 | In-pond-raceway system (IPRS) | ប្រព័ន្ធវារីវប្បកម្មទឹកវិលជាប្លុកក្នុងស្រះ |
| 221 | Inactive | បញ្ឈប់សកម្មភាព ឬអសកម្ម |
| 222 | Incoming Fish | ត្រីដែលយកចូលក្នុងកសិដ្ឋាន |
| 223 | Incoming Water | ទឹកដែលយកមកប្រើក្នុងកសិដ្ឋាន |
| 224 | Incorporate | រួមបញ្ចូល |
| 225 | Indicator | សូចនាករ |
| 226 | Infected fish | ត្រីដែលឆ្លងជំងឺ |
| 227 | Infested snail | ខ្យងដែលមានមេរោគ (ខ្យងដែលផ្ទុកនូវបរាសិត) |
| 228 | Infested water | ទឹកដែលមានមេរោគ |
| 229 | Inflammation | ការរលាក |
| 230 | Ingredient | គ្រឿងផ្សំ |
| 231 | Inject | ចាក់ដោយម្ជុល |
| 232 | Inhibit | រារាំងស្កាត់ ឬ ពន្យឺត |
| 233 | Inorganic turbidity | ភាពល្អក់បង្កដោយសារធាតុអសរីរាង្គ |

| | | |
|---|---|---|
| 234 | Insect | សត្វល្អិត |
| 235 | Inspection | ការត្រួតពិនិត្យ |
| 236 | Insufficient | ដែលមិនបានល្អ ដែលមិនគ្រប់គ្រាន់ |
| 237 | Insurance | ធានារ៉ាប់រង |
| 238 | Intake | ស្រូបចូល ស្រូបយក |
| 239 | Integrity | ភាពនៅជាទម្រង់ដើម ការរក្សានូវទម្រង់ដើម |
| 240 | Intensify | ពង្រីកឱ្យកាន់តែធំ ឬធ្វើឱ្យកាន់តែធ្ងន់ធ្ងរ |
| 241 | Intensity | អាំងតង់ស៊ីតេ |
| 242 | Interest | ការប្រាក់ |
| 243 | Introduce | នាំចូល (ការនាំចូលត្រីទៅក្នុងកសិដ្ឋាន) |
| 244 | Inventory | សារពើភ័ណ្ឌ (រាប់ចំនួន) |
| 245 | Iodine | អ៊ីយ៉ូត |
| 246 | Ion balance | តុល្យភាពអ៊ីយ៉ុង |
| 247 | Juvenile | វារីសត្វជំទង់ |
| 248 | Label | បិទ ឬដាក់ស្លាក |
| 249 | Laboratory | មន្ទីរពិសោធន៍ |
| 250 | Lake-based aquaculture | វារីវប្បកម្មក្នុងផ្ទៃបឹង |
| 251 | Land-based aquaculture | វារីវប្បកម្មលើផ្ទៃគោក |
| 252 | Larvae | កូនញាស់ |
| 253 | Leaching | ការលេចចេញ ឬបាត់បង់សារធាតុអ្វីមួយ |
| 254 | Leafy | ដែលមានស្លឹក |
| 255 | Leftover | នៅសល់ ឬទុកចោល |

| | | |
|---|---|---|
| 256 | Length | បណ្ដោយ ប្រវែង |
| 257 | Lethal | ដែលបណ្ដាលឱ្យស្លាប់ |
| 258 | Levee | ទំនប់ |
| 259 | Lily pad | ស្លឹកព្រលិត |
| 260 | Limitation | ដែនកំណត់ |
| 261 | Liner | កៅស៊ូក្រាលសម្រាប់ចិញ្ចឹមវារីសត្វ |
| 262 | Lipid | លីពីត (ខ្លាញ់) |
| 263 | Live vests (lifejacket) | អាវពោង |
| 264 | Low volume-high density | មានមាឌតូច តែផ្ទុកដង់ស៊ីតេខ្ពស់ |
| 265 | Magnesium | ម៉ាញេស្យូម |
| 266 | Manifold | បំបែកខ្នែង ឬក្បាលបំបែកទុយោ |
| 267 | Manufacturer | រោងចក្រផលិត |
| 268 | Manure | ជីលាមកសត្វ |
| 269 | Market size | ទំហំតាមតម្រូវការទីផ្សារ |
| 270 | Mesh | ក្រឡាសំណាញ់ |
| 271 | Mask | ម៉ាស់ការពារ |
| 272 | Metabolism | មេតាប៉ូលីសកម្ម ឬការកិនក្នុងប្រព័ន្ធរំលាយអាហារ |
| 273 | Metal | គ្រឿងលោហៈ ដែលធ្វើពីលោហធាតុ |
| 274 | Method | វិធីសាស្ត្រ |
| 275 | Migrate | ផ្លាស់ទី |
| 276 | Mill | រោងចក្រ |
| 277 | Moisture | សំណើម |

| | | |
|---|---|---|
| 278 | Molasses | ស្កររង្វ |
| 279 | Mold | ផ្សិត (ដែលដុះលើចំណី) |
| 280 | Moldy pellets | ចំណីគ្រាប់ដែលដុះផ្សិត |
| 281 | Mortality | ការបាត់បង់ ការស្លាប់ |
| 282 | Moving water | ទឹកមានចលនា |
| 283 | Mucus | រំអិល |
| 284 | Mucus layer | ស្រទាប់ទឹករំអិលរបស់ត្រី ឬសារធាតុខាប់អន្ទិលរបស់ត្រី |
| 285 | Muddy | ដែលមានភក់ |
| 286 | Net cages | បែរសំណាញ់ |
| 287 | Neutralize | បន្សាប |
| 288 | Nitrogen | អាសូត |
| 289 | Nitrite | នីទ្រីត |
| 290 | Nursery | ការផ្សាំ ការបំប៉ន |
| 291 | Nutrient | សារធាតុចិញ្ចឹម |
| 292 | Off-site | ក្រៅកសិដ្ឋាន |
| 293 | One-way-valve | វ៉ាល់មួលបិទបើកតែមួយទិស |
| 294 | One bag at a time | ដាក់ម្តងមួយបាវ |
| 295 | Optimum | កម្រិតប្រសើរ ឬសមរម្យ |
| 296 | Opportunistic | ឱកាសនិយម |
| 297 | Organic | សរីរាង្គ |
| 298 | Organic matter | សារធាតុសរីរាង្គ |
| 299 | Organic turbidity | ភាពល្អក់ដែលបង្កដោយសារធាតុសរីរាង្គ |

| | | |
|---|---|---|
| 300 | Organic waste | សំណល់សរីរាង្គ |
| 301 | Organism | សារពាង្គកាយ |
| 302 | Ornamental pond | ស្រះចិញ្ចឹមត្រីលម្អ |
| 303 | Osmoregulation | ការសម្របសម្រួលសំពាធអូស្មូស(ការរក្សាលំនឹងអំបិល និងទឹកនៅក្រៅនិងក្នុងខ្លួនត្រី) |
| 304 | Outbreak | ការផ្ទុះឡើងនៃជំងឺ |
| 305 | Outbreeding Depression | ផលប៉ះពាល់ដែលបណ្ដាលមកពីការបង្កាត់ពូជថ្មីដែលមានសេនេទិច ប្រភពមិនច្បាស់លាស់ ឬមិនសមស្របតាមតម្រូវការ |
| 306 | Outlet | បំពង់បង្ហូរចេញ |
| 307 | Over-feeding | ការផ្ដល់ចំណីលើស |
| 308 | Overflow | ហៀរចេញ |
| 309 | Overheat | ឡើងកម្ដៅខ្ពស់ |
| 310 | Overestimate | ប៉ាន់ប្រមាណលើសពីភាពជាក់ស្ដែង |
| 311 | Oxygenation | ការបង្កើតឱ្យមានអុកស៊ីសែន |
| 312 | Oxygen cylinder | បំពង់អុកស៊ីសែន |
| 313 | Ozone | ឧស្ម័នអូសូន |
| 314 | Packaging | ការវិចខ្ចប់ |
| 315 | Paddlewheel | របហាត់វាយទឹក |
| 316 | Pallet | កំណល់ |
| 317 | Parameter | ប៉ារ៉ាម៉ែត្រ |
| 318 | Parasites | ប៉ារ៉ាសិត |
| 319 | Particle | គ្រាប់ ឬភាគល្អិត |

| | | |
|---|---|---|
| 320 | Pathogen | ភ្នាក់ងារចម្លង |
| 321 | Pelleted feed | ចំណីគ្រាប់ |
| 322 | Peroxide | ពែរអុកស៊ីត |
| 323 | Pesticide | ថ្នាំពុលកសិកម្ម |
| 324 | pH | ប៉ូតង់សែលអ៊ីដ្រូសែន (ប៉េហាស) |
| 325 | Phosphorus | ផូស្វ័រ |
| 326 | Photosynthesis | រស្មីសំយោគ |
| 327 | Physical | ដែលអាចមើលឃើញ ឬជារូបវន្ត |
| 328 | Physical barrier | របងការពាររូបសាស្ត្រ |
| 329 | Physiological response | ការឆ្លើយតបផ្នែកសរីរៈ |
| 330 | Phytoplankton | ប្លង់តុងរុក្ខជាតិ |
| 331 | Plant | រុក្ខជាតិ |
| 332 | Poikilotherm | សត្វឈាមត្រជាក់ (សីតុណ្ហភាពខ្លួនប្រែប្រួលតាមបរិស្ថានដែលសត្វរស់នៅ) |
| 333 | Poison | ថ្នាំពុល |
| 334 | Pollution | ការបំពុល |
| 335 | Pond Culture | ការចិញ្ចឹមក្នុងស្រះ |
| 336 | Popping | លៀនចេញ |
| 337 | Porous | ដែលជ្រាប ដែលហូរច្រោះ |
| 338 | Post-filling | ក្រោយពេលបញ្ចូលទឹក |
| 339 | Potassium permanganate | ប៉ូតាស្យូមពែរម៉ង់កាណាត |
| 340 | Power-take-off | គ្រឿងបង្កំកំលាំងរុញរិល (កាឡេ) |

| | | |
|---|---|---|
| 341 | Pre-filling | មុនពេលបញ្ចូលទឹក |
| 342 | Predator | ពពួកសត្វបំផ្លាញត្រីក្នុងកសិដ្ឋាន |
| 343 | Predictor | អ្នកព្យាករណ៍ |
| 344 | Pressure relief valve | វ៉ាល់បន្ធូរសម្ពាធឧស្ម័ន |
| 345 | Production goal | គោលដៅផលិតកម្ម |
| 346 | Profit | ប្រាក់ចំណេញ |
| 347 | Proliferation | ការលូតលាស់ រាលដាលពាសពេញ |
| 348 | Proportion | សមាមាត្រ |
| 349 | Protein | ប្រូតេអ៊ីន |
| 350 | Protocol | ពិធីសារ |
| 351 | Pump | ម៉ាស៊ីន ម៉ូទ័របូមខ្យល់ ឬទឹក |
| 352 | Quarantine | ចត្តាឡីស័ក |
| 353 | Quick lime | កំបោររស់ |
| 354 | Raceway | ប្រព័ន្ធចិញ្ចឹមត្រីទឹកហូរ (ដែលមានចរន្តទឹកហូរឆ្លងកាត់ពីខ្ពស់មកទាប) |
| 355 | Recharge rate | កម្រិតទឹកចេញ(របស់អណ្តូង) |
| 356 | Recirculate | ហូរវិលឆ្លងកាត់ប្រព័ន្ធច្រោះ |
| 357 | Recirculating Aquaculture System (RAS) | ប្រព័ន្ធចិញ្ចឹមត្រីទឹកវិល |
| 358 | Record Keeping | កំណត់ត្រា |
| 359 | Regulation | បទបញ្ញត្តិ |
| 360 | Regulator | និយ័តករ |
| 361 | Remedy | ដំណោះស្រាយ ឬវិធីសាស្ត្រកែលម្អឱ្យប្រសើរឡើង |

| | | |
|---|---|---|
| 362 | Reproduction | ការបន្តពូជ |
| 363 | Reservoir | អាងស្តុកទឹក |
| 364 | Residue | កាកសំណល់ |
| 365 | Respiration | ដំណកដង្ហើម |
| 366 | Rhythm | ការកើនឡើង ឬធ្លាក់ចុះនៃអ្វីមួយ |
| 367 | Robust | រឹងមាំ មិនប្រែប្រួល |
| 368 | Rodent | ពពួកសត្វកកេរ |
| 369 | Rooted | ដែលមានឫស |
| 370 | Rout | បញ្ចេញខ្យល់ ឬបញ្ជូនខ្យល់ |
| 371 | Rotenone | រ៉ូទីណូន(ឫសរុក្ខជាតិម្យ៉ាងដែលមានជាតិពុល) |
| 372 | Runoff | ការហូរច្រោះ |
| 373 | Safety | សុវត្ថិភាព |
| 374 | Sample | សំណាក |
| 375 | Sampling | ការធ្វើសំណាក |
| 376 | Sanitation | អនាម័យ |
| 377 | Satiation | ឆ្អែត ស្កប់ស្កល់ |
| 378 | Saturation | ពេញ ជោគជាំ |
| 379 | Scale | ជញ្ជីង កម្រិត ឬ ស្រកាត្រី |
| 380 | Scoop | ស្នូកដួស |
| 381 | Screen | ចម្រាញ់ រែង រនាំងបាំង |
| 382 | Scrub | ដុសសំអាត |
| 383 | Secchi disk | សាជីឌីស (ឧបករណ៍វាស់កម្រិតថ្លានៃទឹក) |

| | | |
|---|---|---|
| 384 | Seep | ជ្រាប |
| 385 | Seine net | អួនអូស(នាម)<br>អូសអួន (កិ) |
| 386 | Sensitive | ដែលងាយនឹងរងផលប៉ះពាល់ |
| 387 | Settle out | ដោះស្រាយ |
| 388 | Settling Pond | ស្រះចម្រោះ ស្រះរងកករ |
| 389 | Shade | ម្លប់ ផ្តល់ម្លប់ |
| 390 | Shallow | រាក់ |
| 391 | Shelf life | រយៈពេលរក្សាទុក ឬអាយុកាលនៃផលិតផល |
| 392 | Shiny | ដែលស្រស់ថ្លា ដែលភ្លឺរលោង ឬដែលចែងចាំង |
| 393 | Silver Barb | ត្រីឆ្ពិន |
| 394 | Single stage pressure regulator | នាឡិកាវាស់សំពាធឧស្ម័នក្បាលមួយ |
| 395 | Sinking feed | ចំណីលិច |
| 396 | Slope | ជើងទេ រាងទេរ ឬជម្រាល |
| 397 | Sluice gates | សន្ទះទប់ទឹក ទ្វារទឹក |
| 398 | Sock | ស្បៃច្រោះ |
| 399 | Sodium hydroxide | សូដ្យូមអ៊ីដ្រុកស៊ីត |
| 400 | Sodium thiosulfate | សូដ្យូមត្រូស៊ុលផាត(ថ្នាំបន្សាបជាតិក្លរ) |
| 401 | Solid | រឹង វត្ថុរឹង |
| 402 | Soluble | ដែលអាចរលាយ |
| 403 | Solar-power system | ប្រព័ន្ធថាមពលផ្តល់ដោយពន្លឺព្រះអាទិត្យ |
| 404 | Specific pathogen free (SPF) | ដែលមិនមានផ្ទុកនូវប្រភេទភ្នាក់ងារបង្កជំងឺជាក់លាក់ណាមួយ |

| | | |
|---|---|---|
| 405 | Spherical | រាងមូល |
| 406 | Spine | ឆ្អឹងខ្នង |
| 407 | Splashing | ដែលជះបាចសាច |
| 408 | Spoiled | ដែលខូចគុណភាព ស្អុយ |
| 409 | Spontaneous | ដំណាលគ្នា |
| 410 | Spore | ស្ប៉័រ |
| 411 | Spread | រីករាលដាល |
| 412 | Stack | គរតម្រៀប |
| 413 | Standard Operating Protocol | ពិធីសារអនុវត្តតាមស្តង់ដា |
| 414 | Standpipe | បំពង់បង្ហៀរ (កំណត់កម្ពស់ទឹក) |
| 415 | Starch | ម្សៅ |
| 416 | Sterilize | សម្លាប់មេរោគ |
| 417 | Stock | សន្និធិ ដាក់ចិញ្ចឹម |
| 418 | Stocking density | ដង់ស៊ីតេដាក់ចិញ្ចឹម |
| 419 | Strain susceptibility (genetics) | សែនដែលស៊ាំ ឬមិនស៊ាំទៅនឹងជំងឺណាមួយ |
| 420 | Stress | ស្ត្រេស |
| 421 | Stressor | កត្តាធ្វើឱ្យស្ត្រេស |
| 422 | Strip spawning | ការច្បូតពងត្រី |
| 423 | Sub-optimum concentration | ក្រោមកម្រិតដែលសមស្រប |
| 424 | Submersible pump | ម៉ាស៊ីនបូមទឹក (ប្រភេទត្រាំក្នុងទឹក) |
| 425 | Suppress | ដែលធ្វើឱ្យខ្សោយ |
| 426 | Surface | ផ្ទៃទឹក |

| | | |
|---|---|---|
| 427 | Surface mucus | រំអិលលើខ្លួនត្រី |
| 428 | Survival | ដែលនៅរស់ |
| 429 | Susceptible | ដែលងាយឆ្លង ដែលងាយរងឥទ្ធិពល |
| 430 | Suspend | អណ្តែតពាសពេញ |
| 431 | Swallow | លេប |
| 432 | Swollen | ហើម |
| 433 | Tadpole | កូនក្អុក |
| 434 | Tagging | ដាក់ស្លាកសម្គាល់ត្រី |
| 435 | Thermal protection | ការការពារការឡើងកម្តៅ |
| 436 | Tilapia | ត្រីទីឡាព្យា |
| 437 | Tissue | ជាលិកា |
| 438 | Top-coat | ស្រោបពីលើ |
| 439 | Toxin | ជាតិពុល |
| 440 | Traceability | ប្រព័ន្ធអង្កេតដាន |
| 441 | Transfer | ផ្ទេរ |
| 442 | Transmit | បំលែង |
| 443 | Transportation tank | ធុងដឹកត្រី |
| 444 | Trematode | ដង្កូវខ្លួនសំប៉ែត |
| 445 | Trench | ស្នាមភ្លោះ កូនប្រឡាយ ឬរណ្តៅ |
| 446 | Turbidity | ភាពល្អក់ |
| 447 | Ultraviolet | កាំរស្មីពណ៌ស្វាយ |
| 448 | Underfeeding | ការផ្តល់ចំណីមិនគ្រប់ |

| | | |
|---|---|---|
| 449 | Uneven | មិនស្មើ |
| 450 | Unit price | តម្លៃឯកតា |
| 451 | Unmarketable | ដែលមិនអាចលក់បាន |
| 452 | Unwanted fish | ត្រីដែលយើងមិនត្រូវការ |
| 453 | Uptake | ស្រូបយក |
| 454 | Vegetation | ពពួករុក្ខជាតិដែលដុះក្នុងប្រព័ន្ធវារីវប្បកម្ម |
| 455 | Vermin-proof | ការពារសត្វចង្រៃ |
| 456 | Veterinarian | ពេទ្យសត្វ |
| 457 | Viral | ដែលបង្កដោយពួកវីរុស |
| 458 | Viscosity | ភាពខាប់ ឬអន្ទិល នៃសារធាតុរាវ |
| 459 | Volume | មាឌ ឬចំណុះ |
| 460 | Walking catfish | ត្រីអណ្ដែង |
| 461 | Walkway | ផ្លូវដើរ |
| 462 | Waders | អាវពាក់ចុះទឹក |
| 463 | Wasted feed | សំណល់ចំណី |
| 464 | Water column | ផ្ទៃទឹក |
| 465 | Water hyacinth | កំប្លោក |
| 466 | Water Quality | គុណភាពទឹក |
| 467 | Water table | នីវ៉ូទឹក ធារទឹក |
| 468 | Watershed | ជម្រាលទឹកហូរ |
| 469 | Weaken | ធ្វើឱ្យចុះខ្សោយ |
| 470 | Weight | ទម្ងន់ |

| | | |
|---|---|---|
| 471 | Well-trained feeder | អ្នកបច្ចេកទេសផ្តល់ចំណី |
| 472 | Withdrawal period | រយៈពេលសាបរលាបនៃថ្នាំ និងសារធាតុគីមីដែលប្រើសម្រាប់ព្យាបាល |
| 473 | Yield | ទិន្នផល |

ឧបសម្ព័ន្ធទី១

| **កំណត់ត្រាសកម្មភាពការរៀបចំ និងការគ្រប់គ្រងស្រះ** | | | | | | |
|---|---|---|---|---|---|---|
| ថ្ងៃខែឆ្នាំ | បរិយាយ | ឯកតា | ចំនួនឯកតា | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) | សំគាល់ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ឧបសម្ព័ន្ធទី២

**កំណត់ត្រាការលែងកូនត្រីក្នុងស្រះ**

| ថ្ងៃខែឆ្នាំ | បរិយាយ (ប្រភេទ និងទំហំត្រី) | ឯកតា | ចំនួនឯកតា | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) | សំគាល់/ប្រភពកូនត្រី |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ឧបសម្ព័ន្ធទី៣

**កំណត់ត្រាការធ្វើសំណាក**

| ថ្ងៃខែឆ្នាំ | ចំនួនត្រីធ្វើសំណាក | ទម្ងន់ត្រីធ្វើសំណាក | ទម្ងន់ត្រីជាមធ្យមក្នុង១ក្បាល | យោបល់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

ឧបសម្ព័ន្ធទី៤

## កំណត់ត្រាការប្រើប្រាស់ចំណី

| ថ្ងៃខែឆ្នាំ | ប្រភេទ/ ទំហំចំណី | ភាគរយ ប្រូតេអ៊ីន | បរិមាណចំណីដែល ប្រើ (គីឡូក្រាម) | តម្លៃ/គ.ក្រ (រៀល) | ទំហំត្រី (ក្រាម/ក្បាល) | អង្កេតសកម្មភាពត្រី |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**ឧបសម្ព័ន្ធទី៥**

**កំណត់ត្រាការប្រមូលផល**

| ថ្ងៃខែឆ្នាំ | ប្រភេទត្រី | ចំនួនក្បាលត្រី | ទំងន់ត្រីសរុប | តម្លៃត្រីក្នុង១គីឡូ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## តារាងកត់ត្រាសំណាកក្នុងពេលប្រមូលផល

ចំនួនត្រីសរុប៖...................ក្បាល　　ទម្ងន់ត្រីជាមធ្យម៖..........គីឡូក្រាម

**ចាប់លើកទី ១**

| ថ្ងៃ........ខែ......ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទម្ងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ២**

| ថ្ងៃ.........ខែ.........ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទម្ងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៣**

| ថ្ងៃ........ខែ.......ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទម្ងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៤**

| ថ្ងៃ........ខែ...........ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៥**

| ថ្ងៃ..........ខែ........ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៦**

| ថ្ងៃ.......ខែ......ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៧**

| ថ្ងៃ......ខែ......ឆ្នាំ២០២២ | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៨**

| ថ្ងៃ........ខែ.......ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ៩**

| ថ្ងៃ.......ខែ........ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ១០**

| ថ្ងៃ......ខែ......ឆ្នាំ២០២.. | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ១១**

| ថ្ងៃ........ខែ.......ឆ្នាំ២០២២ | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |

**ចាប់លើកទី ១២**

| ថ្ងៃ........ខែ........ឆ្នាំ២០២២ | | |
|---|---|---|
| ប្រភេទត្រី | ទំងន់ត្រី (គ.ក្រ) | ចំនួនក្បាលត្រី |
| | | |
| | | |
| | | |
| សរុប | | |